# កម្ពុជវេយ្យាករណ៍

ដោយ

ភិក្ខុ ធម្មបាលោ ខៀវ-ជុំ

វត្តលង្កា ក្រុងភ្នំពេញ

បណ្ណាគារក្រួរតន៍

ផ្ទះលេខ១៣៦អឺ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស ២៥០៤ គ.ស ១៩៦២

www.elibraryofcambodia.org

# កម្ពុជវេយ្យាករណ៍

ដោយ

ភិក្ខុ ធម្មបាលោ ទៀវ-ង៉ី

វត្តលង្កា ក្រុងភ្នំពេញ

បោះពុម្ពលើកទី ១ ចំនួន ១.០០០ ក្បាល

ដោយ សៅ-ភ័ នៅរោងពុម្ពតារា

ព.ស. ២៥០៤

គ.ស. ១៩៦២

Ecole Française d'Extrême-Orient
Fonds Michael Vickery

www.elibraryofcambodia.org

www.elibraryofcambodia.org

# ពាក្យឧទ្ទិស

សូមលើកកុសលដ៏ខ្ពង់ខ្ពស់ ដែលកើតឡើងអំពីការរៀបចំសៀវភៅនេះ ថ្វាយចំពោះសម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះបិតាឯករាជ្យជាតិ ប្រធានសង្គមរាស្ត្រនិយម ព្រះមុខរដ្ឋខ្មែរ ក្នុងសម័យបច្ចុប្បន្ន ព្រះអង្គជាព្រះអគ្គុបត្ថម្ភកៈនៃភាសាជាតិ ។

សូមកុសលដែលកើតឡើងដោយចិត្តបរិសុទ្ធរបស់ខ្ញុំ ជួយទ្រទ្រង់នូវព្រះវិរិយកម្មបច្ចុប្បន្នរបស់ព្រះអង្គ ឲ្យចំរើនរុងរឿងអស់កាលជានិរន្តរ៍ កុំបីឃ្លាតឃ្លាយទៅជាប្រការដទៃឡើយ ។

ប្រគេនសម្តេចព្រះមហាសុមេធាធិបតី (ជ.ណ.) សង្ឃនាយកគណៈមហានិកាយ ព្រះបិតានៃអក្សរសាស្ត្រខ្មែរ សូមកុសលនេះជួយទ្រទ្រង់នូវសុខភាពរបស់សម្តេច ឲ្យបានស្ថិតស្ថេរអស់កាលជានិរន្តរ៍ កុំបីឃ្លាតឃ្លាយទៅជាប្រការដទៃឡើយ ។

ប្រគេនព្រះសពសម្តេចព្រះធម្មលិខិត ល្វី-ឯម អតីតៈចៅអធិការវត្តលង្កា ដែលបានឲ្យខ្ញុំ ខ្ចីគម្ពីរអក្សរសាស្ត្រ និងសាសន-

www.elibraryofcambodia.org

សាស្ត្រ សូមកុសលនេះ ជួយទ្រទ្រង់កតថ្វីរបស់សម្ដេច ឲ្យបានប្រកបដោយសេចក្ដីសុខគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

ប្រគេន និងជូនសម្លាញ់ស្នេហាអក្សរសាស្ត្រ ទាំងបព្វជិត ទាំងគ្រហស្ថ ទាំងមានជីវិតនៅ ទាំងបាត់បង់ជីវិតទៅ សូមសម្លាញ់ទាំងឡាយ បានប្រកបដោយសេចក្ដី សុខចំរើនគ្រប់ទិវារាត្រីកាល ដោយការគាំទ្រនៃកុសលនេះ ។

---

## សេចក្ដីរំលឹក

ខ្ញុំមានសេចក្ដីស្ដាយជាទីបំផុត ដោយកាលដែលរៀបចំសៀវភៅនេះហើយ កុំបានប្រគេនសម្ដេច ព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ( ជ.ណ. ) សង្ឃនាយកគណមហានិកាយ នូវការពិនិត្យផ្ទៀងផ្ទាត់ ដែលសម្ដេចធ្លាប់អនុគ្រោះ ដល់អ្នកនិពន្ធទាំងឡាយ ព្រោះក្នុងបច្ចុប្បន្នកាលនេះ សម្ដេចមានព្រះអង្គកាន់តែទន់ខ្សោយដោយអំណាចជរាព្រឹទ្ធសង្កត់ តែខ្ញុំមានសេចក្ដីពេញចិត្តច្រើន

www.elibraryofcambodia.org

ដោយបានរៀបចំសៀវភៅនេះ តាមផ្លូវដែលសម្ដេចបានត្រាយ និងតាមទស្សនគតិរបស់សម្ដេចគ្រប់អន្លើទាំងអស់ ។

ក្នុងឱកាសនេះ, ខ្ញុំសូមថ្លែងនូវអំណរគុណចំពោះលោក ជួប-សុខន (ហៅសាត) មហាមធ្យមវិជ្ជា ដែលបានជួយសរសេរ-ចម្លងច្បាប់បោះពុម្ព ដោយសេចក្ដីរីករាយ និងដោយការយកចិត្តទុកដាក់ជាពិសេស ។

ភ្នំពេញ, នៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៦០

ភិក្ខុ ធម្មបាលោ ទៀវ-ជុំ

www.elibraryofcambodia.org

www.elibraryofcambodia.org

# ពាក្យប្រារព្ធ

ដោយប្រជាជាតិយើង មានការចាំបាច់ប្រើអក្សរសាស្ត្រជាតិជាបន្ទាន់ ក្នុងសម័យបានឥស្សរភាពបរិបូណ៌ មានសិទ្ធិរៀបចំវប្បធម៌របស់ជាតិ ដោយផ្ទាល់ខ្លួន នៅក្រោមការដឹកនាំដ៏ក្លៀវក្លានៃអគ្គសម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ;

ដោយជាតិមានបំណងសិក្សាភាសាជាតិ ឲ្យបានច្បាស់លាស់ ដើម្បីបង្កើនតម្លៃប្រទេសរបស់ខ្លួន និងដើម្បីលើកដម្កើងវប្បធម៌ជាតិឲ្យមានគុណភាពស្មើនឹងប្រទេសនានា;

ដោយអក្សរសាស្ត្រជាតិបានទទួលសេចក្តីឧបត្ថម្ភពីអគ្គសម្តេចព្រះអគ្គមគ្គុទ្ទេសក៍ និងប្រជាជនគ្រប់ជាន់ថ្នាក់ តែអ្នកវេយ្យាករណ៍ពុំទាន់បានជួបនឹងការដោះស្រាយដោយជ្រៅជ្រះ នូវវប្បធម៌របស់ជាតិ ឲ្យសមតាមបំណងរបស់ប្រជាជន;

ដោយជាតិកំពុងស្រេកឃ្លានរសជាតិភាសារបស់ខ្លួន គ្រប់ៗគ្នា ព្រោះតែស្រេកហៅរកក្បួនខ្នាតសម្រាប់តម្រាមកទៀត ដើម្បីពង្រីកភាសាជាតិឲ្យបានដល់ទីបំផុត;

ខ្លួនខ្ញុំជាកូនខ្មែរម្នាក់ ធ្លាប់បានគិតគូរពីអក្សរសាស្ត្រ ជាមួយ

www.elibraryofcambodia.org

មិត្តទាំងឡាយជាយូរណាស់មកហើយដែរ ប៉ុន្តែព្រឹត្តិការណ៍របស់ជីវិត ហេតុការណ៍របស់ប្រទេស និងកាលទេសៈ ពេះតែគំនិតមិនអនុញ្ញាតឲ្យគំនិតនេះស្តែងចេញទៅសកម្មភាពណាមួយបានឡើយ ។ លុះចូលមកក្នុងសករាជ២៥០២ ហេតុការណ៍ទាំងអស់ដែលតែងតែជំទាស់សកម្មភាពរបស់ខ្ញុំ ក៏ប្រែក្លាយជាសភាពប្រក្រតីឡើងវិញ ខ្ញុំក៏ចាប់សរសេរសៀវភៅនេះភ្លាម ៗ សៀវភៅនេះ ខ្ញុំសរសេរឡើងដោយផ្អែកគំនិតទៅលើក្បួនតម្រាសាស្ត្របុរាណខ្លះ លើសៀវភៅទាំងឡាយក្នុងបច្ចុប្បន្ននេះខ្លះ មានសៀវភៅវចនានុក្រម[illegible]ជាពិសេស ខ្ញុំបានទទួលឯកសារអក្សរសាស្ត្រខាង[illegible] នៃវេយ្យាករណ៍ ដោយលាយលក្ខណ៍អក្សរខ្លះ និង[illegible] ផ្ទាល់មាត់ខ្លះ ។ ខ្ញុំសូមគោរពចំពោះគ្រូសៃនវេយ្យ[illegible] ដោយស្មោះអស់ពីដួងចិត្ត សូមព្រះគុណទទួលអំពីខ្ញុំ [illegible] សេធម៌និងកតញ្ញូធម៌ដ៏ខ្ពង់ខ្ពស់ដោយសេចក្តីអនុគ្រោះ ។ ការសរ-សេរសៀវភៅវេយ្យាករណ៍ មិនមែនជាការងាយ, មិនមែនចេះតែសរសេរទៅតាមអារម្មណ៍ ឬតាមតែគំនិតរបស់ខ្លួន ដូចសៀវភៅឯទៀត ៗ បានទេ ។ មុននឹងខ្ញុំទាក់ពាក្យមួយម៉ាត់ ៗ ទៅលើក្រដាស

www.elibraryofcambodia.org

អ្នកនិពន្ធបានប្រើគំនិតបកស្រាយគ្រប់ពាក្យទាំងអស់ ។ឧទាហរណ៍ ដូចពាក្យថា "ជម្ងឺ" ពាក្យនេះ ជាពាក្យនាម កំណើតរបស់ពាក្យនេះ មកពីពាក្យកិរិយាថា "ឈឺ" ។ អ្នកវេយ្យាករណ៍ត្រូវពិចារណាឲ្យដឹងថាពាក្យ "ជម្ងឺ" មួយម៉ាត់នេះ ស៊ីគ្នានឹងកិរិយាឬទេ រកឃើញថា មិនស៊ីគ្នានឹងកិរិយាទេ ព្រោះកិរិយាថា "ឈឺ" គួរចេញទៅជា "ជម្ហឺ" ដែលចេញទៅជា "ជម្ងឺ" ឃើញខុសនឹងកន្លែងដទៃ ដែលជាកិរិយាសព្ទប្រកបដោយតួអក្សរដូចគ្នា ដូចជា: រឹង> របឹង, រឹប>របឹប, រៀន>របៀន, រាំ> របាំ, ឈប់> ជំហប់, ឈាន> ជំហាន ។ល។ ហេតុនេះ បានជាខ្ញុំហ៊ាននិយាយថា ការសរសេរសៀវភៅវេយ្យាករណ៍ ជាការលំបាកខ្លាំងណាស់ អ្នកនិពន្ធត្រូវតែរកសេចក្ដីខុសត្រូវគ្រប់ពាក្យទាំងអស់ ដើម្បីឲ្យអក្សរសាស្រ្តរបស់ខ្លួន មានគោលការត្រឹមត្រូវ មានបែបផែនហ្មត់ចត់ល្អ ដូចអក្សរសាស្រ្តភាសាជាតិនានាក្នុងពិភពលោក ។

អក្សរសាស្រ្តជាតិដែលប្រាសចាកសេចក្ដីវិបត្តិ នឹងប្រកបដោយគុណសម្បត្តិនានា ត្រូវតែពឹងផ្អែកទៅលើអ្វីខ្លះ? មិនមែនទៅលើវេយ្យាករណ៍ទេឬ ?

École Française d'Extrême-Orient
Fonds Michael Vickery

www.elibraryofcambodia.org

ជាការពិតណាស់, គ្រប់សាសន៍ជាតិទាំងអស់ក្នុងសាកលចក្រវាឡ មិនចំពោះជាតិណាមួយ ៗ ទេ គម្រោងវេយ្យាករណ៍ជាគ្រឿងដឹកនាំគំនិត បំភ្លឺន័យ បង្ហាញផ្លូវរបស់អក្សរសាស្ត្រ មិនឲ្យកាន់ច្រឡំខុសចាកសេចក្ដីពិត និងមិនឲ្យវៀងឃ្លាតចេញក្រៅគោលគំនិតរបស់ប្រជាជាតិ ។

ដូច្នេះហើយ, បានជាខ្ញុំខំប្រឹងផ្គូរផ្គាប់ប្រយុទ្ធនឹងសេចក្ដីលំបាកដែលខ្ញុំបានជួបប្រទះក្នុងពេលកំពុងសរសេរ លុះត្រាតែបានសម្រេចជាគម្រោងមួយឡើង មាននាមថា "កម្ពុជវេយ្យាករណ៍" ។

"កម្ពុជវេយ្យាករណ៍" នេះជាវេយ្យាករណ៍ខ្មែរ ដែលមិនថ្មីពេក មិនចាស់ពេក គឺខ្ញុំរៀបចំឲ្យសមគួរល្មមនឹងអធ្យាស្រ័យនៃជនជាតិយើងគ្រប់ឋានៈ មានសេចក្ដីពន្យល់ជ្រៅជ្រះ វែកញែកពាក្យមួយ ៗ ល្អិតល្អន់ មើលងាយយល់ មានអត្ថពាក្យគ្រប់ទាំងអស់ ៗ ភិក្ខុ, សាមណេរ, និស្សិត, កូនសិស្ស, គ្រូ, សាស្ត្រាចារ្យ អាចអានមើល និងរៀនសូត្របានដោយស្រួល ។

ខ្ញុំសូមរំលឹកថា កាលណាអស់លោក-អ្នកអាន បានប្រទះឃើញពាក្យថ្មី ៗ ដែលពុំធ្លាប់បានឃើញពីមុនមក, សូមកុំអាល

www.elibraryofcambodia.org

ធុញទ្រាន់នឹងពាក្យអស់ទាំងនោះ ។ សូមបេះតែអានមើលតទៅទៀត កុំលះបង់ចោលឲ្យសោះ ព្រោះពាក្យខ្លះៗនោះ មិនមែនអ្នកនិពន្ធបង្កើតថ្មីទេ គឺជាពាក្យមានស្រាប់ក្នុងវេយ្យាករណ៍សម័យបូរាណ ។ តែពាក្យខ្លះក៏បាត់បង់ទៅ ពាក្យខ្លះនៅមានជាប់រហូតមក ដូចពាក្យថា "ថ្មើរ" នឹងពាក្យថា "ឆ្មាំ" ពាក្យនេះចេញមកពីកិរិយាសព្ទថា "ដើរ" ថា "ចាំ" កើតបានជាពាក្យនាមថា "សេចក្តីដើរ, ការដើរ, ដំណើរ, អ្នកដើរ, ថ្មើរ; សេចក្តីចាំ, ការចាំ, ចំណាំ, អ្នកចាំ, ឆ្មាំ" ។ ពាក្យពីរម៉ាត់នេះ, យើងនៅមានប្រើសព្វថ្ងៃនេះ ពាក្យនេះហើយ ដែលជាគ្រូសម្រាប់ឲ្យយើងស្រាវជ្រាវរកពាក្យដែលបាត់បង់ទៅ ឲ្យបានគ្រប់គ្រាន់មកវិញ ដើម្បីឲ្យភាសាយើងមានពាក្យប្រើច្រើនដូចក្នុងបុរាណសម័យ ។

ខ្ញុំមានសេចក្តីសង្ឃឹមថា កម្ពុជវេយ្យាករណ៍ នេះ, គង់បានជាតម្រាមួយជួយបន្ថែមសេចក្តីតាមគន្លងខាងផ្លូវគំនិត, ជួយបំពេញឧត្តមប្រយោជន៍របស់ជាតិខាងផ្នែកអក្សរសាស្ត្រ នឹងជួយបន្ថែមសេចក្តីចេះដឹងមួយថ្មីទៀត ទៅលើសេចក្តីចេះដឹងដែលអស់លោកធ្លាប់មានមកហើយ ។

www.elibraryofcambodia.org

ម្យ៉ាងទៀត ខ្ញុំមានសេចក្ដីព្រួយបារម្ភជាខ្លាំង ដោយសៀវភៅនេះ ជាសិល្បៈនៃការសរសេរជាដំបូងនៃរបស់ខ្ញុំ ខាងផ្នែកល័ខវិជ្ជា, ខ្ញុំនឹកថា ទោះណាជាខ្ញុំខំប្រឹងប្រែងប្រៀបយ៉ាងណាក៏ដោយ សេចក្ដីភ្លាំងភ្លាត់ គង់តែចូលមកជ្រៀតជ្រែកក្នុងការដែលខ្ញុំប្រុងប្រយ័ត្ននេះ ជាមិនខាន ៗ តែខ្ញុំមានសេចក្ដីសប្បាយចិត្ត ដោយនឹកថា មិត្តរួមជាតិ គង់អត់ទោសឲ្យខ្ញុំ ចំពោះសេចក្ដីភ្លាំងភ្លាត់ ដែលខ្ញុំបានធ្វើដោយអចេតនា ៗ អ្នកប្រាជ្ញវេយ្យាករណ៍ទាំងឡាយ គង់ជួយកែតម្រូវ ជួយឲ្យយោបល់ខ្ញុំក្នុងអនាគតកាល ដោយសុទ្ធចិត្តជាពុំខានឡើយ ៗ

សូមឲ្យអក្សរសាស្ត្រជាតិរបស់ខ្ញុំ ក្នុងសម័យដឹកនាំ ដោយសម្ដេចព្រះឧបយុវរាជ នរោត្ដម សីហនុ ព្រះបិតាឯករាជ្យជាតិ បាន[illegible]ដាលទៅលើប្រជាជាតិ! ទៅលើអន្តរជាតិ! ទៅលើសាកលចក្រវាឡ ! ៗ

ភ្នំពេញ, ថ្ងៃ[illegible] ខែធ្នូ ឆ្នាំ១៩៦០

ភិក្ខុ ធម្មបាលោ ទៀវ-ជុំ

# ប្រវត្តិអក្សរសាស្ត្រ

## អំពីតួអក្សរ

ប្រមាណប្រាំពីរពាន់ឆ្នាំកន្លងមកហើយ មនុស្សគ្រប់ជាតិគ្រប់សាសន៍មិនមានអក្សរប្រើទេ លុះចំណេរកាលមកប្រហែលជាប្រាំមួយពាន់ឆ្នាំកន្លងមកហើយនេះ ទើបមានជនជាតិអេហ្ស៊ីប(Egypte) ជាជាតិនាំបង្កើតអក្សរនេះមុនគេបង្អស់ តែអក្សរដែលអេហ្ស៊ីបបង្កើតឡើងនោះ មិនមែនជាតួអក្សរទេ គឺជារូបភាពផ្សេងៗ ជាគ្រឿងសំគាល់ ដូចយ៉ាងគូររូបមនុស្សឈរយកដៃស្ដាំបិទមាត់ដៃឆ្វេងចង្អុលទៅរកផ្ទះ ជាសេចក្ដីថា នៅឯផ្ទះមិនមានអាហារបរិភោគជាដើមៗ

ព្រោះហេតុនោះ, រូបភាពទើបអាចស្ដែងសេចក្ដីប៉ុនប៉ងបានដោយមិនបាច់សរសេរតួអក្សរ តែការគូរជារូបភាពនេះ ក៏ស្រេចនៅលើសេចក្ដីចូលចិត្ត ឬគ្រឿងសំគាល់ក្នុងសង្គមមួយ ៗ លុះដល់សម័យខាងក្រោយមក ទើបមានព្រះមហាក្សត្រអេហ្ស៊ីបដែលនោះ ព្រះអង្គទ្រង់រើសរូបភាពទាំងនោះ ឲ្យចូលគ្នាជាពួកជាក្រុមឡើង ដើម្បីធ្វើឲ្យគ្រឿងសំគាល់នោះមានន័យងាយយល់បន្តិចឡើងៗ

www.elibraryofcambodia.org

តែរូបភាពទាំងអស់នោះ ក៏មិនមែនចាត់ឈ្មោះថាជាតួអក្សរទេ ។ លុះកន្លងពេលយូរមកទៀត ទើបគេអាចធ្វើជាតួអក្សរឲ្យមានសម្លេងផ្សេង ៗ គ្នាបាន ជាដំបូងរូបភាពដែលគូរឡើង មានសេចក្តីសំគាល់ចំពោះរបស់មួយ ៗ ឬក៏រូបភាពជាអ្វី ក៏នៅជារបស់នោះដដែលទៅ មិនអាចនឹងផ្លាស់ប្តូរទៅជារបស់ផ្សេងបានឡើយ សន្មតថាគូររូបគោ ក៏ជាទំនៀមត្រូវឲ្យអានថា គោ នឹងអានទៅជាអ្វីផ្សេងក្រៅពីគោពុំបានឡើយ ។

ជាន់ទីពីររូបភាពទាំងនោះ រូបមួយ ៗ ក្លាយទៅជាគ្រឿងសំគាល់សម្រាប់តួអក្សរមួយព្យាង្គ ១ ដូចរូបភាពស្លឹកឈើ ក៏បញ្ចេញសម្លេងថាលីហ្វ (Leaf ស្លឹកឈើ) ជាអក្សរមួយព្យាង្គ ក្នុងទំនងដូចគ្នានេះ រូបភាពសត្វឃ្មុំ ក៏បញ្ចេញសម្លេងថាប៊ី (Bee សត្វឃ្មុំ) មួយព្យាង្គដែរ ។ លុះជាន់ក្រោយគេមកក៏យកព្យាង្គនេះផ្សំចូលជាមួយគ្នា ដូចយករូបសត្វឃ្មុំ (ប៊ី) នឹងរូបស្លឹកឈើ (លីហ្វ) រៀងគ្នារួមជាពាក្យមួយ ព្យាង្គពីរ ហើយអានថា ប៊ីលីហ្វ (Be lief ជំនឿ )

កាលបើរូបគំនូរក្លាយជាតួអក្សរមានព្យាង្គ, ហើយមានមាត្រា

www.elibraryofcambodia.org

បញ្ចេញសម្លេងបានដូចនេះ, ពេលនោះហើយ ដែលកំណត់បានថា ពិភពលោកមានអក្សរប្រើ មានការប្រាស្រ័យទាក់ទងគ្នាដោយអក្សរ, ព្រោះថា បើចង់សរសេរពាក្យឲ្យចេញសម្លេងយ៉ាងណា ក៏អាចនឹងប្រើគ្រឿងសំគាល់ឲ្យចេញសម្លេងយ៉ាងនោះបាន ដូចគូរជារូបក្អែកឲ្យបញ្ចេញសម្លេងថា ក្អែក បើត្រូវការប្រើទៅជាពាក្យដទៃ មានសម្លេងថា "ក្អែក" ដូចគ្នា តែមិនដៅសេចក្ដីថា សត្វក្អែក, ក៏ត្រូវយករូបក្អែកមកប្រើជំនួសបាន អ្នកអានឃើញរូបក្អែក ក៏អានថា ក្អែកបានក្លាម, ដោយមិនដៅសេចក្ដីថា ជាសត្វក្អែកក៏បានដែរ ។

តួអក្សររបស់ជាតិ អេហ្ស៊ីប, មានគ្រឿងសំគាល់ជារូបភាពទាំងអស់ ជាងប្រាំមួយរយរូប តួខ្លះប្រើជាប់តែឯង តួខ្លះជារូបផ្សំគ្នា ហេតុនោះ ការសរសេរអក្សររបស់ជនជាតិ អេហ្ស៊ីប ទើបជាវិធីគូររូបជាពួក ៗ ពួកមួយៗ ជាពាក្យមួយ, យកពាក្យមករៀងគ្នាជាភ្នាក់ ជាក្រុម ក៏ទៅជាប្រយោគមួយ ឯរូបភាពនោះ គេគូរនៅលើផែនដីស្អិត លុះប្រទេសបានទទួលសេចក្ដីចំរើនបន្តិចឡើង, គេគូរលើផែនសិលា ជាលំដាប់មក ។

www.elibraryofcambodia.org

តមកខាងក្រោយទៀត, ជនជាតិ អេហ្ស៊ីប ក៏គិតរកឧបាយធ្វើជារូបមួយ ៗ ប្រើជំនួសពាក្យមួយ ៗ ទៀងទៀត ហើយក្នុងរូបមួយៗប្រើជំនួសពាក្យមួយៗ គឺតួអក្សរហ្នឹងឯង ។ ឯតួអក្សររបស់គេមាន ២៤ តួ ។ អេហ្ស៊ីបជាជាតិបានប្រើតួអក្សរមកក្នុងលោក មុនពុទ្ធសករាជប្រហែលជាងពីរពាន់ឆ្នាំ ។ អេហ្ស៊ីបអាចប្រើអក្សរ ២៤ តួនេះ សម្រាប់សរសេរក្នុងការងាររបស់ខ្លួនបានដោយគ្រប់គ្រាន់ ។

តែដោយអាស្រ័យជនជាតិនេះ ធ្លាប់តួរូបភាពប្រើជំនួសតួអក្សរមកច្ចកទិស្សយណាស់ទៅហើយ ទើបមិនអាចប្រើអក្សរបែបថ្មីនេះឲ្យលឿនរហ័សទៅបាន ។

លុះចំណេរកាលមក, ជនជាតិនេះ បានរកមធ្យោបាយ ធ្វើទឹកខ្មៅសម្រាប់សរសេរ ដោយយកជ័រឈើមកលាយជាមួយទឹក និងធ្វើក្រដាសអំពីសំបកឈើម្យ៉ាង ហៅថា ប៉េប៉ាយរ៉ុស (Papyrus)។

តមកខាងក្រោយជនជាតិបាប៊ីឡូន (Babilonien) ក៏បានយកអក្សរបែបនោះមកប្រើ ហើយផ្សាយចេញទៅឲ្យពួកភេនីសៀន (Phenishian) ទៀត តែជនជាតិទាំងពីរនៅសរសេរអក្សរលើផែនដីស្អិតនៅឡើយ ។

---

www.elibraryofcambodia.org

# ការផ្សាយតួអក្សរចូលទៅក្នុងទ្វីបអឺរ៉ុប

សម័យតមក ជាតិហ្វេនី បានបោះបង់ឈប់ប្រើតួអក្សររបស់បាប៊ីឡូន ដែលចម្លងមកពីអេហ្ស៊ីប ហើយដែលសរសេរនៅលើផែនដីស្អិតនោះ, ព្រោះយល់ឃើញថា អក្សរបែបនេះ ប្រើមិនស្រួល ហើយក៏បានទៅយកក្រដាសដែលធ្វើអំពីដើមប៉ាព្យរុស ពីប្រទេសអេហ្ស៊ីប មកប្រើជំនួសផែនដីស្អិត រួចហើយក៏គិតគូរធ្វើតួអក្សរជាគ្រឿងសំគាល់របស់ខ្លួនឡើងថ្មីមួយបែបទៀត តួអក្សរនេះមានត្រឹមតែម្ភៃពីរតួ គ្រឿងសំគាល់ទាំងនោះមិនប្រាកដជា ប្រើជំនួសពាក្យមួយព្យាង្គដូចអក្សររបស់អេហ្ស៊ីបទេ ៗ គ្រឿងសំគាល់មួយតួ ក៏នៅជាមួយតួដដែល ហើយមិនទាន់ជាមានតួស្រះទេ ដោយហេតុនេះ ទើបគប្បីថាជនជាតិហ្វេនី ជាជាតិដែលគិតរកតួអក្សរជាដំបូង ពោលគឺតួអក្សរស្ទួនៗនេះហើយ ៗ សេចក្ដីអង់អាចរបស់ជនជាតិហ្វេនីក្នុងរឿងនេះ មតិសាកលលោកភាគច្រើនឃើញថា យកអេហ្ស៊ីបជាគ្រូ ៗ

ជាតិហ្វេនី បានរៀបរៀងតួអក្សរបែបថ្មីនេះ ឲ្យមានលំដាប់លំដោយល្អ ដើម្បីឲ្យអក្សរម្ភៃពីរតួនេះ មានរបៀបទីងមានលំនាំ

www.elibraryofcambodia.org

ត្រឹមត្រូវស្រួលរៀន ស្រួលទន្ទេញ ដូចយ៉ាង ក, ខ, គ, ឃ, ង,... របស់យើងក្នុងបច្ចុប្បន្នដែរ លុះរៀបរៀងជាលំដាប់គ្នាដូច្នោះហើយ, ក៏ឲ្យឈ្មោះតួអក្សរទាំងនោះដោយយក "គោ" មកឲ្យឈ្មោះ តួអក្សរដើម ដោយពាក្យថា "គោ" ភាសាហេព្រឺសៀងថា អេឡេហ្វ (A leph) ដែលគេកប់ A ជាដំបូងបង្អស់ អក្សរទីពីរឲ្យឈ្មោះថា "ផ្ទះ" ដែលហេព្រឺសៀង ហៅថាបេថ (Beth)ដែលមានដើមជាតួ B ហើយឲ្យឈ្មោះរៀងតាមលំដាប់ទៅ, ដូច្នេះបើកូនក្មេងហេព្រឺសៀង រៀនតាមអក្សរ វាក៏តាមថា អេឡេហ្វបេថ ។ល។

អក្សរ ២២ តួរបស់ជនជាតិ ហេព្រឺ ជាអក្សរមានតួតិច ប្រើការមិនគ្រប់គ្រាន់, ប្រើបានតែពួកឈ្មួញកត់ត្រាបញ្ជីបន្តិចបន្តួចប៉ុណ្ណោះ ។ តែជនជាតិនេះ បានផ្សាយចេញទៅក្នុងដែនដែលនៅក្បែរសមុទ្រមេឌីទែរ៉ាណេ រៀងទៅភាគខាងលិច រហូតដល់ទៅអឺរ៉ុប ។ ឯជាតិអឺរ៉ុប ដែលទទួលយកអក្សរហេព្រឺសៀងមកប្រើមុនគេនោះ គឺជាតិក្រិក, តែសម័យតមក ជាតិក្រិកនេះ មានគំនិតប្រាជ្ញាច្រើន, គេពិចារណាឃើញថា អក្សរហេព្រឺសៀង មានតួចំនួនតិចពេក ហើយថែមទាំងមិនមានស្រៈផង, ប្រើការមិនបានគ្រប់

គ្រាន់ ហើយតួអក្សរខ្វះ មិនមានសំនៀងក្នុងភាសាក្រេកផង ទើបគេកែប្រែរៀបរៀងតួអក្សរជាថ្មីឡើងទៀត ហើយក៏ផ្សាយទៅពេញទាំងប្រទេសក្រេក សម្រាប់ប្រើក្នុងកិច្ចការជំនួញនិងការគ្រប់គ្រង ។ លុះដល់សម័យពុទ្ធសករាជ ១៥០ ឆ្នាំ វិជ្ជាអក្សរសាស្ត្រនេះ ក៏ផ្សាយចូលទៅទាំងទ្វីបអឺរ៉ុប គឺផ្សាយទៅដល់ អ៊ីតាលី អេស្ប៉ាញ បារាំង និងអង់គ្លេសជាដើម ។

ឯវិធីដែលកូនក្មេងជាតិក្រេករៀនអាន ក៏ហៅឈ្មោះតួអក្សរតាមភាសាភេនីស្យេន, អានតួអក្សរបាន តែស្ដាប់សេចក្ដីមិនបាន ច្បាស់ ហើយភាសាមួយៗក៏ប្ដូរពាក្យសម្លេងដើមអស់ទៅ ដូចពាក្យដែលអានថា អាឡេហ្វ បេថ ។ល។ ក៏ក្លាយទៅជា អាល់ហ្វា បេតា (A lpha, beta) ទៅ ។ ឯពាក្យបារាំងថា (Alphabet) ក៏ក្លាយមកពីពាក្យនេះដែរ មិនតែប៉ុណ្ណោះសោត គ្រឿងសម្រាប់សរសេរ ដូចក្រដាសជាដើម ក៏ផ្សាយចូលទៅអឺរ៉ុបដែរ បានជាពួកអឺរ៉ុបមានបារាំងនិងអង់គ្លេសជាដើម ហៅឈ្មោះក្រដាសនេះតាមភាសាអេហ្ស៊ីប ដែលហៅថា ប៉ាពីរុស គ្រាន់តែប្ដូរសម្លេងប៉ុណ្ណោះ ដូចបារាំង ហៅថា ប៉ាព្យេ (papier) អង់គ្លេស ហៅថា

www.elibraryofcambodia.org

ប៉េប៉ឺរ៍ រហូតមកដល់សព្វថ្ងៃនេះ ។ ក្រដាស ប៉េពាយរ៉ុស ដែលក្រិកនាំយកមកប្រើ ពួកហ្វេនីស្សៀនបាននាំយកមកពីស្រុក បៃប្លូស៍ (Byblos) ដែលជាស្រុករបស់ហ្វេនីស្សៀន ហេតុនោះ កាលបើក្រិកទទួលយកក្រដាសនោះទៅប្រើប្រាស់សម្រាប់សរសេរ អក្សរ ក៏ឲ្យឈ្មោះថា បៃប្លៀ (Biblia) លុះចំណេរកាល មក ក៏យារក្លាយទៅជាពាក្យអង់គ្លេសថាបៃប៊្លឺ បារាំងថា ប៊ិប្ល៍ (Bible) ដែលជាពាក្យសម្រាប់ហៅឈ្មោះគម្ពីរព្រះត្រៃបិដករបស់ គ្រិស្តសាសនាក្នុងសម័យបច្ចុប្បន្ន ។ តាមការពិត ពាក្យថា (Bible) មានន័យថា សៀវភៅ ។

---

## ការផ្សាយតួអក្សរចូលមកក្នុងទ្វីបអាស៊ី

សម័យមុនព្រះគ្រិស្តសករាជ ៤៥០ ឆ្នាំ ជនជាតិ អាមែន (Armian) ជាជាតិមានការរីកចម្រើនខ្ពស់ ដោយបានទទួលអក្សរមកពីជនជាតិ ហ្វេនីស ដែលជាជាតិប្រើតួអក្សរមុនគេបង្អស់ ហើយបានផ្សាយតៗ មកដល់ដែនដីក្បែរទន្លេយូហ្វ្រាតេស ចូលរហូតទៅដល់ប្រទេស-ប៉ែរ្ស ទីទ្វីបអាស៊ីភាគកណ្ដាល រហូតដល់ព្រំដែនប្រទេស ឥណ្ឌៀ ។

www.elibraryofcambodia.org

តែមុនដែលអក្សរជនជាតិនេះផ្សាយចូលមកទូទៅក្នុងទ្វីបអាស៊ី ក្នុងសម័យនោះ មានអក្សររូបសត្វរបស់ជនជាតិបាប៊ីឡូន ផ្សាយចូលមកមួយលើកហើយ ហេតុនោះ ជនជាតិទ្វីបអាស៊ី ទោះណាជាបានទទួលអក្សរមានតួស្រះរបស់ជនជាតិអារមែន មកប្រើហើយក៏ដោយ តែដោយខ្លួនមាននិស្ស័យពេញចិត្តនឹងអក្សររូបសត្វខ្លះ ក៏នៅតែកែសម្រួលឲ្យទៅជាអក្សរមានតួស្រះសាធមិនកើត គឺនាំគ្នាកែសម្រួលខ្លះដែរតែមិនអស់ ដូចចិនបានកែសម្រួលតួអក្សររូបសត្វខ្លះ ឲ្យជាអក្សរមានតួស្រះ តែក៏នៅញើមញ៉ាំ មានសណ្ឋានដូចជារូបសត្វដដែល ព្រោះតែនៅជាប់និស្ស័យនឹងអក្សររូបសត្វដែលជាអក្សរផ្សាយចូលមកក្នុងជាន់មុន ។

ហេតុនេះ, អក្សររបស់ជនជាតិក្នុងទ្វីបទាំងពីរគឺ អាស៊ីនឹងអឺរ៉ុបនេះខុសគ្នាគឺ អក្សររបស់ជនជាតិក្នុងទ្វីបអឺរ៉ុប ជាអក្សរមានទ្រង់ទ្រាយលើសស្អាត ដោយគេបានទទួលពីជនជាតិហ្វេនី ហើយក្រែកយកទៅកែឲ្យមានរបៀបមួយលើកទៀត ។ ឯអក្សររបស់ជនជាតិអាស៊ី ជាអក្សរមានទ្រង់ទ្រាយមិនលើសស្អាត ដោយបានទទួលពីជនជាតិបាប៊ីឡូន ដែលបានផ្សាយមកមុនគេ ។

www.elibraryofcambodia.org

ហេតុការណ៍ទាំងនេះ, នាំឲ្យយើងសន្និដ្ឋានបានថា ជនជាតិអឺរ៉ុប ចូលចិត្តខាងការសាងឫទ្ធិអំណាច ហេតុនោះ ទើបគេប្រើអក្សររលីងស្អាតឲ្យសមទៅតាមភាពនៃអ្នកសាងឫទ្ធិអំណាច ព្រោះអក្សរបែបនេះ ប្រើការបានឆាប់រហ័ស ។ ឯជនជាតិភាគអាស៊ី ចូលចិត្តខាងសិល្បវិជ្ជា មានចម្លាក់ក្បាច់ក្បូរជាដើម ហេតុនោះទើបចូលចិត្តប្រើអក្សរបែបនេះ ព្រោះស្រួលក្នុងការរចនាជាក្បាច់ក្បូរផ្សេងៗ ។

---

## ការកែប្រែតួអក្សរ

អក្សរប្រទេសទាំងអស់ក្នុងលោក សុទ្ធតែមានអក្សរប្រចាំជាតិគេរៀងៗជាតិ ហើយអក្សររបស់ជាតិទាំងនោះ សុទ្ធតែមានរបៀបរៀបរយល្អ ទើបនឹងប្រើការខាងសរសេរ ឬខាងវាយពុម្ពផ្ចាត់បានឆាប់រហ័សដោយសារគេនាំគ្នាកែប្រែឲ្យបានស្រួលម្តងបន្តិចៗ ជាលំដាប់នៃសតវត្សរបស់លោករៀងមក ដើម្បីឲ្យប្រើការបានឆាប់រហ័សសមទៅតាមសម័យលោកនិយម ។

ឯអក្សរខ្មែរយើង ក៏មានអ្នកកែប្រែច្រើនជង់ច្រើនគ្រាដែរ ។

www.elibraryofcambodia.org

កាលសម័យដើម ខ្មែរយើងប្រើអក្សរតាមរបៀបអក្សរសំស្រ្កឹត ហើយក៏ចេះតែនាំគ្នាកែប្រែម្តងបន្តិចៗ តាមលំដាប់សតវត្សរៀងមក ការកែអក្សររបស់យើងមិនសូវបានល្អស្អាតទេ, ព្រោះខ្មែរសម័យនោះចូលចិត្តខាងសិល្បវិជ្ជា ចម្លាក់ក្បាច់ក្បូរ មិនសូវចូលចិត្តខាងការពង្រីកវឌ្ឍិពលទេ ម្ល៉ោះហើយ ទើបនាំគ្នាកែប្រែដែរ តែច្រើនតម្រូវទៅតាមនិស្ស័យសន្តានរបស់ខ្លួន ដែលធ្លាប់មានមកពីដើម ។

លុះដល់មករាជ្យ ព្រះបាទជ័យវរ្ម័នទីពីរ ដោយសារព្រះមហាក្សត្រអង្គនេះ ទ្រង់សព្វព្រះរាជហឫទ័យក្នុងការពង្រីកវឌ្ឍិពល ទើបទ្រង់កែប្រែអក្សរខ្មែរឲ្យមានសណ្ឋានល្អកប់ស្មើ, ឲ្យជាការស្រួលសរសេរបានឆាប់រហ័ស សមទៅតាមសម័យដែលទ្រង់ផ្សាយអំណាចនោះ ។ តែសម័យក្រោយមក, ដោយសារខ្មែរមាននិស្ស័យសន្តានធ្លាក់ទៅក្នុងការរចនា មានចម្លាក់ក្បាច់ក្បូរជាដើម ក៏នាំគ្នាកែប្រែអក្សរឲ្យមានសណ្ឋានមិនល្អមិនពេស្មើទៅវិញ ជាប់រហូតមកដល់បច្ចុប្បន្នសម័យនេះ ។

www.elibraryofcambodia.org

# អំពីភាសាជាតិ

គេបានដឹងថា នៅគ្រប់សាសន៍ជាតិក្នុងលោក មានការពាក់ព័ន្ធគ្នាខាងភាសា ពីជាតិមួយទៅជាតិមួយ គឺប្រជាជាតិណាដែលមានសេចក្ដីចំរើនខាងវប្បធម៌ ។ល។ មុនគេ ប្រជាជាតិនោះ ក៏បានជាប្រភពរបស់ជាតិនានា គឺជាជាតិដែលត្រូវបានធ្វើជាអ្នកដឹកនាំគេឲ្យបានទទួលសេចក្ដីចំរើនដូចខ្លួន ។ នៅក្នុងប្រជុំបរសុវណ្ណភូមិ (ឥណ្ឌូចិន) យើងក្នុងអតីតកាល, ក៏មានសាសន៍ជាតិណាមានសេចក្ដីចំរើនដោយវប្បធម៌ខាងភាសាមុនខ្មែរយើងទេ ។ តែភាសាខ្មែរក្នុងសម័យនោះ មានប្រភពមកពីភាសាណាទៀត លំបាកនឹងស្រាវជ្រាវរកឲ្យឃើញពិតប្រាកដណាស់ ។ ខាងអក្សរសាស្ត្រគេរកឃើញ ដោយពិនិត្យលក្ខណៈទ្រង់ទ្រាយ, ហើយគាបសន្និដ្ឋានបានថា មានប្រភពមកពីឥណ្ឌៀ ព្រោះអក្សរយើង ក្នុងសម័យបុរាណមានទំរង់ស្រដៀងនឹងអក្សរជាតិខ្លះក្នុងឥណ្ឌៀ ឬនឹងថាអក្សរយើងមានប្រភពមកពីអក្សរសំស្ក្រឹតក៏មិនខុស ព្រោះទ្រង់ទ្រាយអក្សរដែលមាននៅក្នុងសិលាចារឹកក្នុងសម័យបុរាណ ក៏មិនសូវខុសគ្នានឹងអក្សរថ្នសំស្ក្រឹតប៉ុន្មានដែរ ។ ចំណែកខាងភាសា

www.elibraryofcambodia.org

លំបាកធ្វើសេចក្ដីចូលចិត្តណាស់ បើនឹងពិនិត្យតាមសំនៀង ដូច ពិនិត្យអក្សរតាមទំនង់ ក៏មិនឃើញមានជាតិណាក្នុងជ្រោយសុវណ្ណ-ភូមិផងគ្នាមានសំនៀងដូចយើង ៗ ភាសាខ្មែរយើង, ជាភាសាកប់ ចូលក្នុងពួកភាសារ៉ង, ធុន, យ៉ក ខុសពីភាសាប្រជាជាតិក្នុងជ្រោយ សុវណ្ណភូមិដូចគ្នា គឺភូមា, សៀម, យួន, លាវ ដែលជាភាសា ទន់, ស្រាល, រហ័ស ៗ ក្រៅពីជាតិសាសន៍ ក្នុងជ្រោយសុវណ្ណ-ភូមិដូចគ្នា មានចិនទីងស៊ណៀ ដែលជាជាតិមានវប្បធម៌ចំរើន រុងរឿងមុនយើង, តែភាសាជាតិទាំងពីរនេះ ក៏មិនមែនជាប្រភព របស់ភាសាយើងទេ ព្រោះតាមការសង្កេតឃើញថា ភាសាជាតិ ទាំងពីរនេះ រឹតតែខុសឆ្ងាយពីភាសាយើង ទាំងដំណើរ ទាំងសំនៀង ទាំងពាក្យមិនមានប្រហែលគ្នាសោះ ៗ

តើភាសាខ្មែរយើង មានដើមកំណើតមកពីភាសាណា? មុននឹងតបសំនួរនេះ ខ្ញុំសូមបញ្ជាក់អ្នកអានជាថ្មីទៀតថា គ្រប់ ៗ ភាសាសុទ្ធតែមានកំណើត ឬមានប្រភពទាំងអស់ តែខុសគ្នាត្រង់ ប្រភពនៃភាសាខ្លះ គេឃើញបានដោយងាយ ខ្លះគេឃើញបាន ដោយលំបាក ៗ ប្រភពនៃភាសាខ្លះ គេឃើញច្បាស់ ខ្លះគេមិន

www.elibraryofcambodia.org

ឃើញច្បាស់ទេ មានខ្លះទៀតរកមិនឃើញក៏មានដែរ ។ ចំពោះភាសាខ្មែរយើង បើរកតាមដូចរៀបរាប់មកខាងលើ ក៏មិនអាចសន្និដ្ឋានបានថា ភាសាខ្មែរយើង មានកំណើតមកពីភាសាណាបានទេ ។ តែបើរកតាមផ្លូវវេយ្យាករណ៍ យើងអាចសន្និដ្ឋានបានខ្លះថា ភាសាយើងមានកំណើតទកពីអំបូរភាសាដែលមានរបៀបមានវេយ្យាករណ៍យ៉ាងខ្ពង់ខ្ពស់ ព្រោះភាសាយើង ជាភាសាមានរបៀប មានវេយ្យាករណ៍យ៉ាងទូលំទូលាយ ដូចអារ្យភាសាខាងក្នុងពិភពលោក ។ តែការដោះស្រាយនេះ ក៏មិនបានជាច្បាស់លាស់ប៉ុន្មានទេ ព្រោះអ្នកអាននៅតែចង់ដឹងថា អារ្យភាសានោះគឺភាសាណាមួយ ។ ត្រង់ចំណុចនេះ ខ្ញុំមិនអាចនឹងប្រាប់ឱ្យចំទៅលើភាសាមួយៗ បានទេ តែខ្ញុំក៏មិនអួតអាងថា ភាសាខ្មែរជាភាសាដឹកនាំគេក្នុងពិភពលោកឡើយ ។

តាមសេចក្ដីសង្កេតរបស់ខ្ញុំឃើញថា ភាសាខ្មែរយើង, បានជាភាសាដឹកនាំគេម្ដងក្នុងក្រោយសុវណ្ណភូមិនេះ, ភាសាយើងបានធ្វើឱ្យភាសា សៀម លាវ ទាំងពីរនេះ មានរបៀបរៀបរយ មានសិល្បៈ មានវេយ្យាករណ៍ មានវណ្ណកម្មខាងអក្សរសាស្ត្រយ៉ាង

www.elibraryofcambodia.org

ខ្ពង់ខ្ពស់ ៗ សៀវភៅក្បួនតម្រាខ្លះ ៗ ដែលសរសេរដោយជាតិទាំងពីរនេះ មានលាយចម្រុះដោយពាក្យខ្មែរយើងដោយច្រើន ៗ អ្នកប្រាជ្ញសៀមម្នាក់ឈ្មោះវិចិត្រវាទការ ដែលធ្លាប់តែរិះគន់ខ្មែរ ធ្លាប់តែតតៀងបន្ទាបខ្មែរយ៉ាងឈ្លើយ បាននិយាយក្នុងសៀវភៅឈ្មោះ "ជ្រោយសុវណ្ណភូមិ" របស់ខ្លួនថា វប្បធម៌ខ្មែរជាដើមកំណើតនៃវប្បធម៌សៀម ៗ ពាក្យនេះ គួរឲ្យយើងជឿណាស់ ព្រោះជាពាក្យលេចឮឡើងអំពីបុគ្គល ដែលបានព្យាយាមសរសេរសៀវភៅបន្ទាបខ្មែរ ដែលធ្លាប់តែថា ខ្មែរមិនកើត មិនមានអារ្យធម៌អ្វីនៅក្នុងលោកនេះឡើយ ៗ

ការពិតមែនទែន, ខ្មែរបុរាណ ជាជាតិមួយមានសេចក្តីចំរើនជាងគេក្នុងជ្រោយសុវណ្ណភូមិ បានធ្វើជាមេដឹកនាំជាតិទាំងអស់ក្នុងជ្រោយសុវណ្ណភូមិទាំងខាងសិល្បៈ ទាំងខាងវប្បធម៌ គឺមានតែជាតិខ្មែរយើងទេ ដែលជាម្ចាស់នៃអារ្យធម៌របស់ជាតិនានាក្នុងជ្រោយសុវណ្ណភូមិ ៗ

នៅក្នុងភាសាខ្មែរយើង, មានលាយឡំដោយភាសាបាលីនិងសំស្ក្រឹតដោយច្រើន ដោយភាសាទាំងពីរនេះ បានផ្សាយចូល

www.elibraryofcambodia.org

មកក្នុងប្រទេសខ្មែរយើងតាមផ្លូវទូតរបស់ប្រទេសខ្លះ តាមផ្លូវទូតរបស់សាសនាខ្លះ ។ ខាងផ្លូវទូតរបស់ប្រទេស បានដល់បេសកជនឥណ្ឌៀពួកមួយ ដែលបានចូលមកទាក់ទងជាមួយខ្មែរ ដើម្បីឲ្យប្រទេសយើងបានជាមិត្តនឹងប្រទេសរបស់គេ ។ ខាងផ្លូវទូតរបស់សាសនា បានដល់បេសកសមណៈក្នុងសាសនាព្រាហ្មណ៍ខ្លះ ក្នុងពុទ្ធសាសនាផ្នែកមហាយានខ្លះ ផ្នែកហីនយានខ្លះ ដែលបានចូលមកទាក់ទងជាមួយខ្មែរ ដើម្បីផ្សាយលទ្ធិសាសនារបស់ខ្លួន ក្នុងប្រទេសខ្មែរយើង ។ ការទាក់ទងទាំងពីរផ្លូវនេះហើយ ដែលធ្វើឲ្យប្រទេសខ្មែរយើងបានទទួលវប្បធម៌ឥណ្ឌៀ ដែលនៅក្នុងនោះមានភាសាបាលីនិងសំស្ក្រឹតផង ។

ទោះណាជាភាសាខ្មែរយើង មានភាសាបាលីនិងសំស្ក្រឹតលាយឡំដោយច្រើន តែភាសាទាំងពីរនេះ ក៏មិនមែនជាដើមកំណើតនៃភាសាខ្មែរទាំងមូលទេ ។ ភាសាបាលី. សំស្ក្រឹត មានវេយ្យាករណ៍ទូលំទូលាយដូចភាសាខ្មែរតែសព្ទ ពាក្យមិនត្រូវគ្នាទេ ។ បើតាមសេចក្ដីសន្និដ្ឋានរបស់ខ្ញុំ, ភាសាបាលីនិងសំស្ក្រឹតនេះ គង់បានជាដើមកំណើតនៃភាសាខ្មែរយើងខ្លះ ខាងវេយ្យាករណ៍ ប៉ុន្តែខាងសំនៀង

www.elibraryofcambodia.org

ពាក្យទឹងរប់ថា ជាកំណើតនៃភាសាខ្មែរពុំបានឡើយ ។

កាលសម័យកណ្ដាលនៅអង្គរ ភាសាខ្មែរបានចុះអន់ថយច្រើន ដោយហេតុគ្រប់គ្រង បានលើកយកភាសាបាលីនិងសំស្ក្រឹតជាភាសាផ្លូវការ ជាភាសាដែលគេសំគាល់ថា ពូកែស័ក្ដិសិទ្ធិ ។ ដោយមកអំពីហេតុនេះហើយ បានជាសិលាចារឹកទាំងអស់គេប្រើភាសាទាំងពីរនេះដោយច្រើន ។ តែដោយភាសាសំស្ក្រឹត ជាភាសាមានរបៀបស្រួលប្រើ តែជាភាសាលំបាករៀន មិនយូរប៉ុន្មានគេក៏បានបោះបង់ចោលបន្តិចម្ដងៗ ហើយភាសាខ្មែរយើង ក៏បានចំរើនឡើងវិញ តែក៏មិនយូរប៉ុន្មាន ក៏ត្រូវសាបសូន្យទៅវិញទៀត ដោយមកពីប្រទេសកើតសង្គ្រាមជាញឹកញាយ គឺក្នុងសម័យនោះ ជាតិសៀមចេះតែវាយលុកមកក្នុងប្រទេសខ្មែរយើង ។ ការចាញ់ចម្បាំងនឹងសៀម ក្នុងសម័យកណ្ដាលនៅអង្គរក្ដី នៅបន្ទាយលង្វែកក្ដី ជាគ្រោះថ្នាក់មួយយ៉ាងធំរបស់ជាតិ ដោយប្រជាពលរដ្ឋសាមញ្ញនៅក្នុងតំបន់បរាជ័យសឹក, ត្រូវគេកៀរយកទៅស្រុកកំណើតរបស់គេ អ្នកប្រាជ្ញបណ្ឌិត្យ ត្រូវគេលួចយកទៅប្រើក្នុងប្រទេសគេ, គម្ពីរដីកាក្បួនខ្នាតត្រូវគេយកទៅប្រើជាផ្លូវធម៌របស់គេ, ទ្រព្យ

www.elibraryofcambodia.org

សម្បត្តិក្នុងប្រទេសត្រូវគេដឹកជញ្ជូនយកទៅស្រុកគេអស់ច្រើន ។

គ្រោះថ្នាក់ដ៏ធំសម្បើមនេះ, មិនទាន់បាត់ពីត្រចៀកប្រជាជនផង ក៏ស្រាប់តែមានគ្រោះថ្នាក់មួយយ៉ាងសម្បើមថ្មីទៀត គឺជាតិបារាំងសេសបានចូលមកគ្រប់គ្រងប្រទេសខ្មែរ ដោយសំអាងថាទំនុកបំរុង ។ ការទំនុកបំរុងរបស់បារាំង បានធ្វើឲ្យវប្បធម៌ខ្មែរដែលនៅសេសសល់បន្តិចបន្តួចពីដៃសៀម បានធ្លាក់ចុះយ៉ាងរហ័សដោយបារាំងគេយកវប្បធម៌របស់គេមកសង្កត់វប្បធម៌យើង ។ អក្សរសាស្ត្រខ្មែរបានរត់ទៅជ្រកនៅក្នុងវត្តលោកសង្ឃអស់ពេល ៨០ ឆ្នាំគត់ ។ លុះអស់អំណាចត្រួតត្រារបស់បារាំង ដោយអំណាចព្រះរាជបេសកកម្មនៃព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រខ្មែរ ។ អក្សរសាស្ត្រខ្មែរ ក៏បានវិលចំរើនជាប់រហូតដល់សព្វថ្ងៃនេះ ។

ការកែប្រែកែច្នៃភាសាខ្មែរឲ្យបានច្បាស់លាស់នោះ មិនមែនជាការងាយ ដូចកែប្រែកែច្នៃអក្សរទេ ព្រោះអក្សរមានតែពីរបែប គឺបែបដែលមានតួរលីងស្អាត ១, បែបដែលមានតួប្រកបដោយក្បាច់ក្បូរ ១ ។ អក្សរខ្មែរយើងមានដើមកំណើតមកពីអក្សរមានក្បាច់

www.elibraryofcambodia.org

ក្បូរ ៗ យើងនឹងចង់សម្រេចថា មកពីលង្កា ឥណ្ឌា សំស្រ្កឹត ៗលៗ ណាមួយក៏បាន ឲ្យតែនៅក្នុងជាតិដែលមានអក្សរប្រកប ដោយក្បាច់ក្បូរ ៗ

ក្នុងបច្ចុប្បន្ននេះ, មានប្រជាជាតិប្រហែលជាង ៣ ក្នុងភាគ ៥ ប្រើអក្សរលើងស្អាត ៗ ប្រហែលជិត ២ ក្នុងភាគ ៥ ប្រើអក្សរ ក្បាច់ក្បូរ នៅក្នុងចំនួននោះ មានប្រជាជាតិខ្មែរយើងផង ៗ [illegible] ចំណុចនេះហើយ ដែលនាំឲ្យឆ្ងាយដល់ការស្រាវជ្រាវ ៗ គឺការបើ ណាបើគេចង់ដឹងថា ជាតិណាមានប្រភពនៃអក្សររបស់ខ្លួន មកពី ណា គេក៏អាចនឹងធ្វើសេចក្ដីសន្និដ្ឋាន តាមទំរង់តួអក្សរនិងទឹកតួ អក្សរក្បាច់ក្បូរបានភ្លាមៗ ដោយសំអាងទៅលើប្រវត្តិការណ៍ ដែល នាំឲ្យមានអក្សរក្នុងលោក ដូចបាននិយាយមកហើយ ៗ ចំណែក ខាងការស្រាវជ្រាវរកប្រភពនៃភាសានោះ លំបាកណាស់ ព្រោះ ភាសាមានច្រើនណាស់ ហើយខ្ញុំនៅតែចាំមិនភ្លេចថា ការរកឲ្យ ឃើញនូវប្រភពនៃភាសាខ្មែរ ដោយផ្អែកទៅលើសព្ទ សំនៀង ពាក្យ ៗលៗ មិនងាយនឹងរកឃើញ [illegible] ភាសាយើង មានសព្ទសំនៀង និងពាក្យ ពុំមានប្រហាក់ប្រហែលនឹងភាសាជាតិ

www.elibraryofcambodia.org

ណាមួយ នៅក្នុងប្រជុំសុវណ្ណភូមិនេះ ។ តែបើគេរកដោយផ្អែកទៅលើ របៀប វណ្ណកម្ម និងវេយ្យាករណ៍ ប្រហែលជាមានផ្លូវច្រើនជាងផ្លូវដទៃៗ ហើយអាចនឹងប្រមូលផ្តុំគំនិតរើរកយឲ្យបានជាគំនិតរឹងប៉ឹងមាំមួន, ឲ្យបានជាគំនិតនឹងនួន នៅលើព្រឹត្តិការណ៍ដ៏ប្រកបដោយហេតុផល ហើយការស្រាវជ្រាវតាមក្រសែគំនិតនេះ ។

ការស្រាវជ្រាវ ដោយប្រើគំនិតប្រកបដោយហេតុផលេ បើមិនត្រូវចំ ក៏គង់ត្រូវជិតៗដែរ ប្រសិនបើអ្នកស្រាវជ្រាវនោះ បានកាត់ចោលនូវអគតិធម៌ បានដម្កល់ខ្លួននៅក្នុងសច្ចធម៌ និងឧត្តមគតិដ៏ខ្ពង់ខ្ពស់របស់ខ្លួន ។

មានអ្នកប្រវត្តិសាស្ត្រណាខ្លះ ដែលមិនដឹងថា សុវណ្ណភូមិជារបស់ខ្មែរ ? បើសុវណ្ណភូមិជារបស់ខ្មែរ, តើខ្មែរត្រូវមានសេចក្តីរុងរឿងខាងផ្លូវសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងនយោបាយផងទេ ? ។ ព្រះរាជអាណាចក្រខ្មែរក្នុងសម័យនោះ ខាងលិចមានការប្រាស្រ័យទាក់ទងជាមួយប្រទេសឥណ្ឌា ខាងកើតមានការប្រាស្រ័យទាក់ទងជាមួយប្រទេសចិន តើមានអ្នកណាខ្លះដែលមិនថា ខាងវប្បធម៌ខ្មែរ

www.elibraryofcambodia.org

បានទទួលមកអំពីឥណ្ឌៀ ការសេដ្ឋកិច្ចខ្មែរបានទទួលមកពីចិន ។ ដូច្នេះ, វប្បធម៌ខ្មែរ មិនមែនកើតមានតែក្នុងព្រំដែនសុវណ្ណភូមិទេ គឺមានចូលមកពីខាងក្រៅខ្លះ បើមិនច្រើនក៏តិច តាំងពីកាលខ្មែរយើងមានសំបូរជាខ្មែរមន ខ្មែរកម្ពុជ ខ្មែរដែលសៀមហៅថា "ខម" ។ល។ បើភាសាខ្មែរមានប្រភពមកពីភាសាដទៃ យើងត្រូវដឹងថា ប្រភពនោះមិនមែននៅក្នុងព្រំដែនសុវណ្ណភូមិទាំងអស់ទេ គឺប្រាកដជាមកពីខាងក្រៅខ្លះហើយ តែនឹងចង្អុលឲ្យទៅលើភាសាណាមួយៗ ក៏មិនងាយនឹងត្រូវដែរ ព្រោះភាសារបស់ជាតិមួយ ៗ ក្នុងលោកនេះ មានការវិវត្តន៍គ្រប់សតវត្ស លំនាំនឹងប្រៀបធៀបគ្នាណាស់ ។ ប៉ុន្តែខ្ញុំអាចបញ្ជាក់បានថា ប្រភពដើមកំណើតនៃភាសាខ្មែរយើងនោះ មិនមែនមកពីអនារ្យភាសាទេ គឺប្រាកដជាមកពីអារ្យភាសា ដូចខ្ញុំបាននិយាយមកហើយ ។

ភ្នំពេញ; នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៦១

ភិក្ខុ ធម្មធារោ ទៀវ-ជុំ

www.elibraryofcambodia.org

# កម្ពុជវេយ្យាករណ៍

# (GRAMMAIRE CAMBODGIENNE)

## ភាគទី ១

### អក្ខរវិធី (Orthographe)

កម្ពុជវេយ្យាករណ៍ ជាគម្ពីររៀនភាសាជាតិ ដើម្បីធ្វើភាសានិយាយស្រួលប្រពៃ ជាសុន្ទរកថា ជាទេសនា ។ល។ ឲ្យបានទៀងទាត់ត្រឹមត្រូវ ។ គម្ពីរកម្ពុជវេយ្យាករណ៍ រៀបរៀងតាំងពីអក្ខរវិធី និងរបៀបផ្ដុំព្យាង្គអក្សរជាដើមរៀងទៅ ។

អក្ខរវិធី គឺរបៀបមួយផ្ដុំព្យាង្គអក្សរ ក្រោយពីរបៀបសរសេរនេះឲ្យត្រឹមត្រូវតាមសេចក្ដីនិយម លោកចាត់ទុកជាគម្ពីរផ្នែកមួយឈ្មោះថា “អក្ខរវិធី” សេចក្ដីពិត គម្ពីរអក្ខរវិធីនេះមិនមែនជាគម្ពីរវេយ្យាករណ៍ទេឡើយ ព្រោះគម្ពីរវេយ្យាករណ៍នោះស្ដីដោយរបៀបផែនរបស់ភាសាដែលរៀបចំឡើងសម្រាប់រៀនចំពោះភាសាជាតិមួយៗ តែដោយអក្ខរវិធីនេះ ស្ដីដោយគ្រឿងសំគាល់សម្រាប់ប្រើជំនួសភាសាមួយចំណែកទៀត ដើម្បីសង្គ្រោះ

www.elibraryofcambodia.org

អក្ខរវិធីនេះ ចូលក្នុងពួកវេយ្យាករណ៍ ដាក់ទុកជាខាងដើមបង្អស់ នៃគម្រោងវេយ្យាករណ៍ ។

## ប ឍ ធ័ ១

## លក្ខណៈអក្សរ

១– លក្ខណៈអក្សរ, អក្សរក្នុងកម្ពុជភាសាចែកជា ២ យ៉ាងគឺ ស្រៈ ១. ព្យញ្ជនៈ ១ ។

### ស្រៈ ( Voyelles )

ស្រៈមាន ៣ ពួក ស្រៈពេញតួ ១, ស្រៈនិស្ស័យ ១, ស្រៈផ្សំ ១ ។

ស្រៈពេញតួក្នុងភាសាជាតិមាន ១៤ គឺ

អ អា ឥ ឦ ឧ ឪ ឫ.ឬ ឭ ឮ ឯ ឰ ឱ ឳ អុំ អំ អាំ អះ ។

ស្រៈនិស្ស័យក្នុងភាសាជាតិមាន ២១ តួគឺ

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ

ស្រៈផ្សំក្នុងភាសាជាតិមាន ៦ តួគឺ

ុះ ិះ ុះ េះ ែះ ោះ

www.elibraryofcambodia.org

ស្រៈពេញតួនោះគឺ ស្រៈដែលប្រើជាតួព្យញ្ជនៈ ដូចពាក្យថា: អវគុណ, អាប, ឥឡូវ, ឦសី, ឧត្តម, ឩឡឹក, ឫក្ស, ឬស្សី, ឮលាន់, ឯក, ឰដ៏, ឱ្យ, ឱស្ឋ, ក្រឪ ។ ស្រៈនិស្ស័យនោះជាស្រៈដែលប្រើរួមជាមួយព្យញ្ជនៈ ដូចពាក្យថា: កល, តាម, ពិនិត្យ, កី, ដឹក, តឺ, ចុង, កូរ, យួរ, កើត, ជឿ, កៀន, កេ, ថែ, ដៃ, គោ, ជៅ, កុំ, ខំ, ចាំ, វះ ។ ស្រៈផ្សំប្រើដូចនេះ កិះ, កឹះ, កុះ, កើះ, កេះ, កោះ ។

## ព្យញ្ជនៈ (Consonnes)

ព្យញ្ជនៈក្នុងកម្ពុជភាសាមាន៣៣ តួគឺ

ក្កខ្ខគ្គឃ្ឃង្ង ច្ចឆ្ឆជ្ជឈ្ឈញ្ញ ដ្ដឋ្ឋឌ្ឌឍ្ឍណ្ណ ត្តថ្ថទ្ទធ្ធន្ន ប្បផ្ផព្ពភ្ភម្ម យ្យរ្រល្លវ្វស្សហ្ហឡ អ្អ ។

ព្យញ្ជនៈ ៣៣ ចែកចេញជា ៥ វគ្គគឺ

កខគឃង ហៅថា កវគ្គ ឬវគ្គទី១ ។ ចឆជឈញ ហៅថា ចវគ្គ ឬវគ្គទី២ ។ ដឋឌឍណ ហៅថា ដវគ្គ ឬវគ្គទី៣ ។ តថទធន ហៅថា តវគ្គ ឬវគ្គទី៤ ។ បផពភម ហៅថា បវគ្គ ឬវគ្គទី៥ ។

ព្យញ្ជនៈក្រៅពីនេះ ៨តួគឺ យរលវសហឡអ ហៅថាអវគ្គ

www.elibraryofcambodia.org

ឬព្យញ្ជនៈមិនមានវគ្គ ឬសេសវគ្គ ។

[illegible]ញ្ជនៈទាំងឡាយក្នុងកម្ពុជភាសាមានសម្លេងជា ២ ពួកគឺ ពួកសម្លេងតូច ហៅថា អឃោសៈ, ពួកសម្លេងធំ ហៅថា ឃោសៈ ។

ព្យញ្ជនៈអឃោសៈ គឺ

ក ខ ច ឆ ដ ឋ ត ថ ប ផ ស. ។

ព្យញ្ជនៈឃោសៈ គឺ

គ ឃ ង ជ ឈ ញ ឌ ឍ ណ ទ ធ ន ព ភ ម យ រ ល វ ស ហ ឡ

[illegible] [illegible]ឃោសា ឃោសវិមុត្តិ គឺមិនមែនឃោសៈទាំង [illegible] ព្យញ្ជនៈទាំងឡាយមានសម្លេងផ្សេងៗ គ្នា [illegible] ១, ព្យញ្ជនៈមានសម្លេងផ្សំ ។ ពួកដែលមានសម្លេង [illegible] ២ [illegible] ដែលមានសម្លេងផ្សំ ហៅថា ធនិត ។

ព្យញ្ជនៈសិថិល គឺ

ក គ ច ជ ដ ឌ ត ទ ប ព យ រ ល វ ស ហ និងនិគ្គហិត ង ញ ណ ន ម ំ ។

ព្យញ្ជនៈធនិត គឺ

ខ ឃ ឆ ឈ ឋ ឍ ថ ធ ផ ភ ។

www.elibraryofcambodia.org

ព្យញ្ជនៈសិថិលមានសម្លេងតែ១ សម្លេងតូចស្រាល ដូចពាក្យ
ជាៈ ក, ច, ដ,... ។

ព្យញ្ជនៈធនិតមានសម្លេងធ្ងន់យើក ព្រោះផ្សំមកពីព្យញ្ជនៈ២
តួដូច : ខ, ឃ, ឆ,...

ខ កើតមកពី ក នឹង ហ

ឃ ——— គ —— ហ

ឆ ——— ច —— ហ...

ជាគូៗគឺ កនឹងខ, គនឹងឃ, ចនឹងឆ, ជនឹងឈ, ដនឹងឋ, ឌនឹងឍ, តនឹងថ, ទនឹងធ, បនឹងផ, ពនឹងភ, គឺយកអក្សរសិថិលទៅផ្សំនឹងតួ ហ កើតទៅជាធនិត ដូចតួយ៉ាងខាងក្រោមនេះៈ

ក + ហ = ខ

ច + ហ = ឆ

ដ + ហ = ឋ

ឌ + ហ = ឍ

ត + ហ = ថ

ប + ហ = ផ

www.elibraryofcambodia.org

ក + ហ = ក

ឯព្យញ្ជនៈអវគ្គ និងក្រុមព្យញ្ជនៈខាងចុងវគ្គទាំង ៥ ក៏ជាសិថិល ដែរ តែមិនមានគូផ្សំឡើយ ។

## ព្យញ្ជនៈលំអៀងសម្លេង

ដើម្បីនឹងប្រើការឱ្យបានគ្រប់គ្រាន់ក្នុងភាសាជាតិ លោកយក វណ្ណយុត្តិ មូសិកទន្ត ( ៉ ) និងត្រីស័ព្ទ ( ៊ ) មកដាក់លើព្យញ្ជនៈ ខ្លះ ៗ ព្យញ្ជនៈទាំងនោះគឺ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ ។ តែបើកាលណាមានស្រៈនិស្ស័យ ឬនិគ្គហិត ( ំ ) នេះនៅពីលើ លោកឱ្យផ្លាស់វណ្ណយុត្តិ ( ៉ ៊ ) ជាក្បៀសក្រោម ( ុ ) ដូចពាក្យ ថា ប៊ិន ម៉ឺន ប៉ី រ៉ី ស៊ី ហ៊ី ប៉ឹម ប៉ើង ញ៉ាំង យ៉ាំង... ។

## ឋានករណៈនៃអក្សរក្នុងកម្ពុជភាសា (*)

កន្លែងកើតសម្លេងនៃអក្សរ មាន ៧ យ៉ាងគឺ ក ១, ពិតាន ១, ក្បាល ១, ធ្មេញ ១, បបូរមាត់ ១, ច្រមុះ ១, ទ្រូង ១, ។ អក្សរ

* ពាក្យថា កម្ពុជភាសាសុទ្ធ គឺយកភាសាខ្មែរដែលប្រើជាបុរាណនឹងសំស្ក្រឹត ។ កម្ពុជភាសា គឺយកភាសាខ្មែរសុទ្ធ និងភាសាខ្មែរដែលក្លាយមកពីភាសាបាលី និង សំស្ក្រឹត និងភាសាបរទេស ដែលប្រើជាមួយភាសាខ្មែរ ។

www.elibraryofcambodia.org

ពួកខ្លះកើតក្នុងឋាន ១, ពួកខ្លះកើតក្នុងឋាន ២ ។ អ អា ក ខ គ ឃ ង ហ ៨ តួនេះកើតក្នុង ក ហៅថា កណ្ឋជៈ ។ ឥ ឦ ច ឆ ជ ឈ ញ យ ៨ តួនេះកើតក្នុងពិតាន ហៅថា តាលុជៈ ។ ដ ឋ ឌ ឍ ណ រ ឡ ៧ តួនេះកើតក្នុងក្បាល ហៅថា មុទ្ធជៈ ។ ត ថ ទ ធ ន ល ស ៧ តួនេះកើតត្រង់ប្រទាល់ធ្មេញ ហៅថា ទន្តជៈ ។ ឧ ឩ ប ផ ព ភ ម ៧ តួនេះកើតត្រង់ខែមបបូរមាត់ ហៅថា ឱដ្ឋជៈ ។ និគ្គហិតកើតក្នុងច្រមុះ ហៅថា នាសិកជៈ ។

អក្សរប៉ុណ្ណោះលើកលែងតែវៀរបញ្ចមវគ្គ ៥ តួគឺ ង ញ ណ ន ម នេះចេញ លោកពោលថាកើតក្នុងឋាន ១ ។ ឯ កើតក្នុងឋាន ២ គឺ ក និង ពិតាន ហៅថា កណ្ឋតាលុជៈ ។ ឱ កើតក្នុង ២ ឋានគឺ ក និង បបូរមាត់ ហៅថា កណ្ឋោដ្ឋជៈ ។ ព្យញ្ជនៈវៀរបញ្ចមវគ្គទាំង ៥ គឺ ង ញ ណ ន ម កើតក្នុង ២ ឋាន គឺតាមឋានរៀងខ្លួននិងច្រមុះ ហៅថា សកដ្ឋាននាសិកជៈ ។ វ កើតក្នុង ២ ឋាន គឺធ្មេញនិងខែមបបូរមាត់ ហៅថា ទន្តោដ្ឋជៈ ។ ហ បើប្រកបចូលនឹងព្យញ្ជនៈ ៨ គឺ ញ ណ (ន) ម យ ល វ ឡ ដូចពាក្យថា គញ្ហិ តណ្ហា តម្ហា មយ្ហំ វុល្ហំ ជិវ្ហា រុឡ្ហ ដូច្នេះជាដើម លោកពោលថាកើតក្នុងទ្រូង ហៅថា ឧរជៈ បើ

www.elibraryofcambodia.org

មិនប្រកបចូលក្នុងព្យញ្ជនៈ ទាំង ៨ នេះទេ កើតក្នុងភាសាមហានដើម របស់ខ្លួនដែល ។

អក្សរ ៨ តួ ដែលប្រើក្នុងកម្ពុជភាសាសុទ្ធគឺ អ អា ឥ ឦ ឧ ឩ ឯ ឲ ឈ្មោះថា ស្រះ ព្រោះបញ្ចេញសម្លេងបានតាមរំលើងខ្លួនឯងផង ហើយអាចនឹងញុំាងព្យញ្ជនៈ ឲ្យបញ្ចេញសម្លេងផងបាន ។ ស្រះ ៨ តួនេះចាត់ជាគូបាន ៣ គូ គឺ អ អា ហៅថា អវណ្ណ ជាគូ ១, ឥ ឦ ហៅថា ឥវណ្ណ ជាគូ ១, ឧ ឩ ហៅថា ឧវណ្ណ ជាគូ ១ ។ ស្រះ ឯ នឹង ឲ ទាំង ២ តួនេះ ហៅថា សំយុត្តស្រះ ព្រោះប្រកបសម្លេងស្រះ ២ តួ ផ្សំចូលគ្នាជាសម្លេង ១ គឺ អ នឹង ឥ ផ្សំចូលគ្នាជា ឯ, អ នឹង ឧ ផ្សំចូលគ្នាជា ឲ ព្រោះហេតុនោះ ស្រះទាំងពីរតួនេះ ទើបកើតក្នុង ២ ឋាន តាមន័យដែលបានពោលមកហើយ ។

ករណៈ គឺអវយវៈ ជាទីចេញនូវសម្លេងនៃអក្ខរៈក្នុងកម្ពុជភាសាមាន ៤ យ៉ាងគឺ ជិវ្ហាមជ្ឈ ពាក់កណ្ដាលអណ្ដាត ១, ជិវ្ហោបគ្គំ រលាស់ចុងអណ្ដាតចូលមក១, ជិវ្ហគ្គំ ចុងអណ្ដាត១, សកដ្ឋានំ ឋានរបស់ខ្លួន ១ ។ ពាក់កណ្ដាលអណ្ដាតជាករណៈ របស់អក្ខរៈដែលជាតាលុជៈ, រលាស់ចុងអណ្ដាតចូលមកជាករណៈ

www.elibraryofcambodia.org

របស់អក្ខរៈដែលជាមុខជៈ, ចុងអណ្ដាត ជាករណៈរបស់អក្ខរៈដែលជាទន្តជៈ, ឋានរបស់ខ្លួន ជាករណៈរបស់អក្ខរៈដែលសល់ពាក អក្ខរៈជាតាលុជៈ, មុខជៈ និងទន្តជៈ ។

ស្រៈទាំង ៨ តួ ដែលប្រើក្នុងកម្ពុជភាសាសព្វ ចែកចេញជា ២ពួក គឺជារស្សៈពួក ១, ជាទីឃពួក១; ស្រៈដែលមានមាត្រារហ័ស ៣ តួគឺ អ ឥ ឧ ឈ្មោះថា រស្សៈ ព្រោះជាស្រៈមានសម្លេងខ្លី ដូចពាក្យថា អបិ ទុ ដូច្នេះជាដើម ។

ស្រៈដែលមានសម្លេងវែង ៥ តួគឺ អា ឦ ឩ ឯ ឱ ឈ្មោះថា ទីឃៈ ព្រោះជាស្រៈមានសម្លេងវែង ដូចពាក្យថា ភាគី ជូចោ ដេហេ ដូច្នេះជាដើម ។

ស្រៈទីឃៈ ២ តួគឺ ឯ និង ឱ បើមានព្យញ្ជនៈសំយោគ នៅខាងមុខ [illegible] មានសម្លេងខ្លី ប្រហែលដូចជារស្សៈ ដូចពាក្យថា ឯត្ថ មេត្តា សេយ្យោ សេដ្ឋី ឱដ្ឋោ សោត្ថិ ដូច្នេះជាដើម

អក្ខរៈ ៣៣ តួ មាន ក ជាដើម មាន អ ជាទីបំផុតឈ្មោះថា ព្យញ្ជនៈ ព្រោះជាអក្ខរៈធ្វើឱ្យសេចក្ដីឲ្យច្បាស់ប្រាកដ តែថាលុះតែនៅអាស្រ័យជាមួយនឹងស្រៈផង ទើបអាចនឹងធ្វើឱ្យសេចក្ដីឲ្យច្បាស់

www.elibraryofcambodia.org

ប្រាកដឡើងបាន ដូចពាក្យថា ជ្ញា មិតា គោសា ដូច្នេះ ជាដើម បើព្យញ្ជនៈមិនចូលអាស្រ័យនឹងស្រៈផងទេ ក៏ពុំសូវកែ សម្លេងស្រៈឲ្យប្លែក ក្រឡះទៅជាពួកថា ុ, ា, ៉, ា, េ, ា ។

ព្យញ្ជនៈ ៣៣ តួ ចែកចេញជា ២ ពួក គឺ វគ្គពួក ១, អវគ្គពួក ១, ដូចពោលមកហើយ ; ព្យញ្ជនៈវគ្គ ២៥ តួ កើតក្នុងឋានករណៈ ជាមួយគ្នា ដូចពោលមកហើយ ហេតុនោះ ទើបឈ្មោះថា វគ្គ ។

ព្យញ្ជនៈអវគ្គ កើតក្នុងឋានករណៈផ្សេងគ្នា ដូចពោលមកហើយ ទើបមានឈ្មោះថា អវគ្គ ។ ព្យញ្ជនៈ គឺ ំ ១ តួនេះហៅថា និគ្គហិត, និគ្គហិតនេះ លុះតែមានស្រៈ ៣ តួ អ ឥ ឧ នៅខាងក្រោម ទើបអាស្រ័យនៅបាន ដូចពាក្យថា អហំ សេតុំ អកាសិំ ដូច្នេះជាដើម ។

## អក្សរប្រភេទក្នុងកម្ពុជភាសា

ប្រភេទនៃអក្សរក្នុងកម្ពុជភាសាមាន ១០ យ៉ាងគឺ សិថិល ១, ធនិត ១, ទីឃៈ ១, រស្សៈ ១, គរុ ១, លហុ ១, សម្ពន្ធ ១, វិវដ្ដ ១, និគ្គហិត ១, វិមុត្ត ១ ។

ព្យញ្ជនៈជាបឋម នៃព្យញ្ជនៈជាតំរប់ពួកក្នុងវគ្គទាំង៥ ហៅថា

www.elibraryofcambodia.org

សិថិល មានសម្លេងដូចពោលមកហើយ ។ ព្យញ្ជនៈជាគម្រប់ ២ និងព្យញ្ជនៈជាគម្រប់ ៤ ក្នុងវគ្គទាំង ៥ ហៅថា ធនិត មានសម្លេងដូចពោលមកហើយ ។

ស្រៈទីឃៈ និងរស្សៈទាំង ២ នេះ ក៏មានសម្លេងដូចពោលមកហើយដែរ ។ ស្រៈដែលជាទីឃៈសុទ្ធនិងស្រៈដែលជារស្សៈ ដែលមានព្យញ្ជនៈសំយោគនៅខាងចុង ឬមាននិគ្គហិតនៅខាងលើ ដូចពាក្យថា ពុទ្ធំ ធម្មំ សង្ឃំ សម្មាសម្ពុទ្ធោ ដូច្នេះជាដើម ហៅថា គរុ ត្រូវពោលបន្លឺឲ្យយូរឲ្យធ្ងន់ ។

ស្រៈដែលជារស្សៈសុទ្ធ មិនមានព្យញ្ជនៈសំយោគនៅខាងចុង និងមិនមាននិគ្គហិតនៅខាងលើ ដូចពាក្យថា ឥតិបិ ខមតុ ដូច្នេះជាដើម ហៅថា លហុ ត្រូវការឲ្យមានសម្លេងស្រាលរហ័ស ។

អក្ខរៈដែលលោកតបទសន្ធិទាំងពីរតួ ឬ ២ បទឡើងទៅឲ្យជាប់ចូលគ្នាជាបទ ១ ដូចពាក្យថា សន្និដ្ឋិ, តិដ្ឋុ, វុត្តមិ, ធុរិ-ធោត្តមំ ដូច្នេះជាដើម ហៅថា សម្ពន្ធ ត្រូវការឲ្យជាប់ជាបទ ១ កុំញែកឲ្យដាច់ពីគ្នា ។

អក្សរដែលលោកកាត់បទញែកចេញពីបទសន្ធិឲ្យដាច់ចេញពី

www.elibraryofcambodia.org

ភាគនៃពេលដែលត្រូវប្រែយកសេចក្ដី ដូចពាក្យថា ស្មឹ ង, កឹ ង, វាំ ឧត្ដម, ធុំធំ ឧត្ដម ដូច្នេះជាដើម ហៅថា វិគ្គហ ត្រូវការឲ្យជាប់គ្នា ព្រោះជាអក្ខរៈគាត់ចេញសម្រាប់ប្រែឲ្យដឹងសេចក្ដី ។

អក្ខរៈឯណាក្នុងវេលាដែលនឹងពោលមានសម្លេងដូចគួង ឬគួ ម ប្រកបខាងចុង ដូចពាក្យថា ពុទ្ធំ ធម្មំ សង្ឃំ ពុទ្ធម៍ ធម្មម៍ សង្ឃម៍ ដូច្នេះជាដើម អក្ខរៈនោះឈ្មោះ និគ្គហិត ។

អក្សរឯណាក្នុងវេលាដែលនឹងការបើកមាត់ហាធំលើសប្រក្រតី ដូចពាក្យថា ទក់ទោ, ះះ, ឆាះ, ប៉ាណោ ដូច្នេះជាដើម អក្សរនោះឈ្មោះថា វិមុត្ត ។

ឥក្ខសរាបធធឹក (ចខសម្រាប់ហាត់ដឹកន្សំយើញ)

១- កម្ពុជវេយ្យាករណ៍ បានសេចក្ដីថាម៉េច?

២- អក្ខរវិធី បានសេចក្ដីយ៉ាងណា?

៣- អក្សរចែកចេញជាប៉ុន្មានយ៉ាង?

៤- យ៉ាងម៉េចហៅថា ស្រៈពេញតួ? យ៉ាងម៉េចហៅថា ស្រៈនិស្ស័យ? មានប៉ុន្មានយ៉ាង?

៥- ព្យញ្ជនៈមានប៉ុន្មានតួ? គឺអ្វីៗ? ចូររាប់មកផង!

www.elibraryofcambodia.org

៦- ព្យញ្ជនៈចែកចេញជាវគ្គបានប៉ុន្មានវគ្គ? ក្នុងវគ្គមួយ ៗ មានប៉ុន្មានតួ? ដូចម្ដេចទើបហៅថា ព្យញ្ជនវគ្គ?

៧- ព្យញ្ជនៈដូចម្ដេច ដែលហៅថា ព្យញ្ជនៈមិនមានវគ្គ? មានប៉ុន្មានតួ?

៨. ព្យញ្ជនៈទាំងឡាយមានសម្លេងយ៉ាងណាខ្លះ? សម្លេងនោះៗ ហៅថាអ្វី?

៩-ព្យញ្ជនៈដែលមិនមែនជាឃោសៈនិងអឃោសៈ គឺព្យញ្ជនៈតួណា?

១០- ព្យញ្ជនៈសិថិលមានប៉ុន្មានតួ? ធនិតប៉ុន្មានតួ? មានសម្លេងខុសគ្នាយ៉ាងណា?

១១-ព្យញ្ជនៈដែលជាធនិតៈកើតមកពីតួផ្សំ តើផ្សំមកពីតួណា? ចូរធ្វើធៀបផ្សំមកមើល?

១២- ព្យញ្ជនៈលំអៀងសម្លេងបានឬទេ? មានអ្វីជាគ្រឿងសម្រាប់លំអៀងសម្លេងព្យញ្ជនៈ? មានប៉ុន្មានយ៉ាង?

១៣- កន្លែងកើតសម្លេងនៃអក្ខរៈមានប៉ុន្មានយ៉ាង? អ្វីខ្លះ? ឥ ឦ ច ឆ ជ ឈ ញ យ កើតក្នុងទីណា?

www.elibraryofcambodia.org

១៤- អក្សរណាខ្លះកើតក្នុង ២ ឋាន? ក្ដី ហ បើមិនប្រកបចូល នឹងព្យញ្ជនៈ ៨ តួ គឺ ញ ណ (ន) ម យ ល វ ឡ កើតក្នុងទីណា?

១៥- ស្រៈក្នុងកម្ពុជភាសា មានប៉ុន្មានតួ? អ្វីខ្លះ? តួណាជាស្រៈវែង? តួណាជាស្រៈខ្លី? តួណាជាស្រៈផ្សំ? ចែកចេញជាប៉ុន្មានពួក? ក្ដីដូចម្ដេចដែលស្រៈវែងក្លាយទៅជាស្រៈខ្លី? ចូរឲ្យឧទាហរណ៍មកផង ?

១៦ - ពាក្យថាស្រៈនឹងពាក្យថាព្យញ្ជនៈ បានសេចក្ដីយ៉ាងណា ? អង្គពីរនេះត្រូវអាស្រ័យគ្នាដូចម្ដេច? បើគេប្រើតែមួយៗ មិនផ្សំគ្នាបានដែរឬទេ ? មានឧទាហរណ៍ដូចម្ដេច ?

១៧ - ព្យញ្ជនៈគឺ ំ ហៅថា និគ្គហិត អាស្រ័យបាននឹងស្រៈណាខ្លះ? បើមិនមានស្រៈបានឬទេ ?

១៨ - ករណៈគឺអវយវៈធ្វើសម្លេងមានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់ឈ្មោះឲ្យគ្រប់ផង ?

១៩-ប្រភេទអក្ខរៈមានប៉ុន្មានយ៉ាង? សម្ពន្ធនឹងកើតផ្សេងគ្នាដូចម្ដេច? ចូរឲ្យឧទាហរណ៍មកផង ?

---

www.elibraryofcambodia.org

## បទទី ២

## របៀបផ្សំអក្សរ និង ប្រើអក្សរ

អក្សរក្នុងកម្ពុជភាសា មានរបៀបផ្សំស្រៈនឹងព្យញ្ជនៈចូលគ្នា ឲ្យកើតទៅជាសេចក្តី ទៅតាមរឿង ចែកជា ៣ យ៉ាងគឺ

១- ផ្សំស្រៈនឹងព្យញ្ជនៈចូលគ្នា ហៅថា បំបែក ឬវិធីផ្សំស្រៈនឹងព្យញ្ជនៈ ឬ ក កា;

២- យកព្យញ្ជនៈនឹងព្យញ្ជនៈផ្សំគ្នា ហៅថា តម្រួតឬផ្ទើយជើង;

៣- យកព្យញ្ជនៈដែលបំបែកហើយ នឹងតម្រួតហើយផ្សំចូលគ្នាហៅថា ប្រកប ។

របៀបបំបែកមានដូចតទៅនេះ

ក) ផ្សំស្រៈនឹងព្យញ្ជនៈ ឧទាហរណ៍:

ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ កេ កែ កៃ កោ កៅ កុំ កំ កាំ កះ ។ល។

ខ) ផ្ទើយជើង ឬតម្រួតព្យញ្ជនៈជាមួយគ្នា ឧទាហរណ៍:

ក្រ ក្រា ក្រិ ក្រី ក្រឹ ក្រឺ ក្រុ ក្រូ ក្រួ ក្រើ ក្រឿ ក្រៀ ក្រេ ក្រែ ក្រៃ ក្រោ ក្រៅ ក្រុំ ក្រំ ក្រាំ ក្រះ ។ល។

www.elibraryofcambodia.org

ង) ប្រកបទ្វេកកជាសេចក្ដី ឧទាហរណ៍ :

កក, កាក, កិក, ក័ក, កឹក, កឺក, កុក, , កូក, កួក, កើក, កឿក, កៀក, កេក, កែក, កោក ។ល។

របៀបប្រើអក្សរ, ដើម្បីឱ្យអ្នករៀនបានយល់ច្បាស់ គន្ធការសរសេរនឹងការនិយាយឲ្យបានល្អិតល្អន់ អ្នករៀនគួរកំណត់ជំនូវលក្ខណភាសា ដូចតទៅនេះ ៖

## សម្លេងក្នុងកម្ពុជភាសា

សម្លេងក្នុងកម្ពុជភាសាអាចចែកបានជា ៣ យ៉ាងគឺ

១- សម្លេងសុទ្ធ គឺសម្លេងដែលចេញមកពីបំពង់ករត្រង់ៗ មិនមែនប្រើអណ្ដាត ឬបបូរមាត់បំបែរឱ្យផ្លាស់ប្ដូរ ដូចជាសម្លេងក្មេងតូច ៗ ដែលកាន់និយាយចេះចេញមកដោយមិនទាន់ប្រែកដាក់ជាអ៊ី នៅឡើយ គឺមិនទាន់ច្បាស់ជាសម្លេង អប្ពា, អប្ពអេ ជាដើម;

២- សម្លេងប្រែផ្លាស់ គឺសម្លេងសុទ្ធ ៗ ដែលលាន់ចេញមក ពីអណ្ដាត [illegible] អណ្ដាតនិងបបូរមាត់ សម្រាប់ធ្វើឱ្យសម្លេងខុសគ្នាតាម ក, [illegible] ឬបបូរមាត់ ធ្វើឱ្យសម្លេងប្រែប្រួលទៅជាសម្លេង [illegible] "ក" ឬ "ច" ឬ "ដ" ឬ "ប" ជាដើម;

www.elibraryofcambodia.org

៣- សម្លេងឡើងចុះ គឺសម្លេងសុទ្ធ ឬសម្លេងប្រែប្រួល ដែលអ្នកនិយាយធ្វើឲ្យលាន់ចេញមកខ្ពស់ទាប ៗ ស្រដៀងនឹងសម្លេងតន្ត្រី ដូចជាពាក្យថា: ខានណា៎! ហ្ន៎ះខានណា៎! ខុ៎ះខិ ជាដើម ៗ:

## តួអក្សរកើតឡើងតាមសម្លេង

កាលបើសម្លេងក្នុងកម្ពុជភាសាមាន ៣ យ៉ាងដូចនេះ ទើបលោករៀបចំតួអក្សរឡើងជា ៣ យ៉ាង ដើម្បីជំនួសសម្លេងទាំង៣ នោះគឺ

១– អក្សរសម្រាប់ជំនួសសម្លេងសុទ្ធ ឲ្យឈ្មោះថា "ស្រះ";

២– អក្សរសម្រាប់ជំនួសសម្លេងប្រែប្រួល ឲ្យឈ្មោះថា "ព្យញ្ជនៈ";

៣– អក្សរសម្រាប់ជំនួសសម្លេងឡើងចុះ ឲ្យឈ្មោះថា "វណ្ណយុត្តិ" ៗ

## ឫសគល់នៃតួអក្សរ

តួអក្សរគឺ "ស្រះ" នឹង "ព្យញ្ជនៈ" ក្នុងកម្ពុជភាសានោះមាន

www.elibraryofcambodia.org

ឬសគល់មកពីភាសាបាលីនិងសំស្ក្រឹត មានល័ក្ខ(១)គោលដែលអាចសង្កេតបានគឺ

១– លក្ខណរូបតួអក្សររបស់កម្ពុជៈ ចម្លងបែបមកពីបាលីនិងសំស្ក្រឹត តាមសេចក្ដីសង្កេតរបស់អ្នកប្រាជ្ញវេយ្យាករណ៍ឃើញថា អក្សរខ្មែរយើងមានភាពលំនាំស្រដៀងៗ គ្នានឹងបាលីសំស្ក្រឹត;

២- ការរៀងលំដាប់តួអក្សរក៏ស្រដៀងគ្នា គឺរៀងស្រៈទុកខាងដើម រៀងព្យញ្ជនៈទុកខាងចុង រៀបចំវគ្គរៀងគ្នាតាមលំដាប់ឋាន(ទីកើតអក្សរ)គឺ ក, ពិតាន, ក្បាល, ធ្មេញ និងបបូរមាត់;

៣– វិធីប្រកបផ្សំអក្សររៀងស្រៈទុកមុខខ្លះ ខាងក្រោយខ្លះ ខាងលើខ្លះ ខាងក្រោមខ្លះ របៀបទាំងនេះស្រដៀងៗ គ្នាបាលីនិងសំស្ក្រឹតដែរ ។

ចំណែកខាងវណ្ណយុត្តិនោះ ក្នុងភាសាបាលីនិងសំស្ក្រឹតមិនមានទេ ។ សេចក្ដីពិត នៅគ្រប់ភាសាទាំងអស់ រមែងមានសម្លេងឡើងចុះ ឬសម្លេងតន្ត្រី គឺសម្លេងខ្ពស់ៗ ទាបៗ ដូចគ្នាទាំងអស់ តែ

(១) ពាក្យថា ល័ក្ខ នឹងពាក្យថា ល័ខ ទាំងពីរនេះប្រើបានដូចគ្នា មានន័យថា គោល ឬសសរ ។

www.elibraryofcambodia.org

ភាសាខ្លះ ក៏មិននិយមឲ្យដំណើរសេចក្ដីរបស់ពាក្យដែលមានសម្លេងខ្ពស់ទាបនោះប្រព្រឹត្តទៅញែកៗ ដូច្នោះ ភាសាទាំងនោះ ទើបមិនចាំបាច់ឲ្យមានតួអក្សរផ្ទួនសម្លេងតន្ត្រី ឬឲ្យមានខ្លះយ៉ាងតិចបំផុត ស្ទើរតែមិនមាន ដូចកម្ពុជភាសា បាលីភាសា សំស្ក្រឹតភាសា និងអង់គ្លេសភាសាជាដើម ភាសាអស់នេះរាប់ថា ជាភាសាមិនមានវណ្ណយុត្តិ ឬមានយ៉ាងតិចបំផុត ។

អ្នករៀន, កាលបើបានស្គាល់លក្ខណអក្សរ, របៀបផ្សំអក្សរ និងលក្ខណភាសា ដូចបានពោលមកហើយ, ក៏អាចសរសេរនិងអានពាក្យបាន តែពុំទាន់គ្រប់គ្រាន់ល្មមដល់សេចក្ដីត្រូវការដែលនិយមប្រើក្នុងភាសាជាតិនៅឡើយ ។ ដូច្នេះ នឹងអធិប្បាយពីលក្ខណៈប្រើអក្សរតទៅ ។ ការប្រើតួអក្សរ គឺសរសេរនិងអានឲ្យត្រឹមត្រូវតាមបែបផែនដែលនិយមប្រើក្នុងជាតិមួយៗនោះ ត្រូវអាស្រ័យល័ក្ខគឺ

១- របៀបផ្លាស់អក្សរ;

២- សន្ធិរបៀបភ្ជាប់ពាក្យឲ្យជាប់គ្នា;

៣- របៀបសរសេរ;

៤- របៀបអាន ។

www.elibraryofcambodia.org

## វិធីផ្លាស់អក្សរ

វិធីផ្លាស់អក្សរ គឺផ្លាស់តួអក្សរឲ្យខុសពីទម្រង់ដើម ដើម្បីប្រើក្នុងការតែងសេចក្ដីឬប្រព័ន្ធពាក្យកាព្យ ៗ រៀបរៀងពាក្យនិយាយឲ្យស្អាតល្អ; របៀបផ្លាស់ត្រូវធ្វើដូចនេះ៖

១– ល័ក្ខគោលក្នុងកម្ពុជភាសា មានវិធីផ្លាស់ពាក្យឲ្យមានសេចក្ដីផ្សេងគ្នា ដូចជា "ជិះ" ផ្លាស់ទៅជា "ជំនិះ"; "គូរ" ផ្លាស់ទៅជា "គំនូរ" ។ល។ បន្ថែមព្យាង្គខាងមុខស្រដៀងនឹងឧបសគ្គៈ ដូចជា "ហាក់" បន្ថែម "បំ" ចូលមកជា "បំហាក់" ផ្លាស់និគ្គហិតជា "ង" ផ្សំទៅជា "បង្ហាក់"; "រៀន" បន្ថែម "បំ" ចូលមកជា "បំរៀន" ផ្លាស់និគ្គហិតជា "ង" ទៅជា "បង្រៀន" ។ល។ វិធីនេះក្នុងកម្ពុជភាសាយើងមានប្រើជាច្រើនដូចជា កើត, កំណើត; ចាយ, ចំណាយ; ត្រួត, តម្រួត; កើត, បង្កើត; រាយ, ពង្រាយ ដូច្នេះជាដើម ;

២– អក្ខរវិធីក្នុងភាសាបាលីនិងសំស្ក្រឹត មានរបៀបព្រឹទ្ធិ "ឥ" ទៅជា "ៃអ", "ឧ" ទៅជា "អៅ" ។ល។ គឺផ្លាស់ព្យញ្ជនៈក្ដី បន្ថែមតួព្យញ្ជនៈដែលហៅថាចុះព្យញ្ជនៈអាគមក្ដី របៀបនេះក៏មានប្រើក្នុង

www.elibraryofcambodia.org

កម្ពុជភាសាខ្លះ ឧទាហរណ៍ដូចៈ អេកវ៍ណ ជា អែកវ៍ណ ជាដើម;

៣ – របៀបប្រើភាសា ដែលទាក់ទងមកពីភាសាប្រាក្រឹត ដែលប្រជាជាតិឥណ្ឌាផ្សាយចូលមកក្នុងប្រទេសយើង តាមភាសាសំស្រ្កឹត តែគេតាងក្នុងអក្សរតាមភាសាប្រាក្រឹតរបស់គេ ដូចជាតាងសម្ងន់ "គ" ទៅជាសម្ងន់ "ខ" ជាច្រើន ក្នុងពាក្យដូច មាគា ទៅជា មាខា, គេហ ទៅជា ខេហ ។ល។ ហើយសម្ងន់ "វ" ច្រើនផ្លាស់ទៅជាសម្ងន់ "ព" ក្នុងភាសាបាលីស្ទើរតែទាំងអស់ នេះជាផ្លូវមួយទៀតជាដើម, របៀបដូរក្នុងអក្សរនេះ យើងក៏និយមប្រើតាមគេជាច្រើនដែរ ។

របៀបផ្លាស់ក្នុងអក្សរតាមល័ក្ខដែលបានពោលមកនេះ មាន ២ យ៉ាងគឺ ១- ផ្លាស់ស្រៈ, ២- ផ្លាស់ព្យញ្ជនៈ ។

## វិធីផ្លាស់ស្រៈ

ស្រៈដែលផ្លាស់ក្នុងទៅជាស្រៈដទៃនោះ ដោយច្រើនមកពីពាក្យក្នុងភាសាបាលីនិងសំស្រ្កឹត, ឯក្នុងកម្ពុជភាសាយើង ដែលជាភាសាលាយឡំដោយភាសាបាលី-សំស្រ្កឹតជាច្រើន ក៏មានវិធីផ្លាស់ខ្លះដែរ ដូចពោលតទៅតាមលំដាប់ :

www.elibraryofcambodia.org

ផ្លាស់ស្រៈ "អ" ជា "អា" ដូច ស័ណ្ឋ ជា សាណ្ឋៈ, សស្ត្រ ជា សាស្ត្រ, អសត្យៈ ជា អាសត្យៈ (ប្រើក្នុងបទប្រព័ន្ធខ្លះ ដូចជា ព្រឹក្សជាតិ មច្ឆជាតិ ទៅជា ព្រឹក្សាជាតិ មច្ឆាជាតិ ។ល។)

ផ្លាស់ស្រៈ "អ" ជា "អិ" ដូចជា ក្ស័ណភេទៈ ជា ក្សណភេទៈ, លក្សណវិទ្យ ជា លក្សិណវិទ្យ, បត្តបូរ ជា បិត្តបូរ, វិជរ ជា វិជិរ ។ល។

ផ្លាស់ស្រៈ "អ" ជា "ឧ" ដូចជា អគុល ជា ឧគុល, ឧបោសថ ជា ឧបោសុថ, មហោសថ ជា មហោសុថ, ជេតពន ជា ជេតុពន, លោកបាល ជា លោកុបាល, វិតក្ក ជា វិតុក្ក, គោកនទៈ ជា គោកនុទៈ ។ល។

ផ្លាស់ "អ" ជា "ឩ" ដូច កបាល ជា កូបាល, ខរ ជា ខូរ, បពិត្រ ជា បូពិត្រ, បទុម ជា បូទុម, កមារទ្រ ជា កូមារទ្រ, កមុ ជា កូមោ, កមរី ជា កូមរី, មធុរ ជា មូធូរ, យមបាល ជា យមូបាល, សម័យ ជា សូម័យ, សរីរៈ ជា សូរីរៈ, អសនី ជា អសូនី, អស្សតរ ជា អស្សូតរ ។ល។

ផ្លាស់ "អ" ជា "អើ" ដូចជា ប្រសដ្ឋ ជា ប្រសើដ្ឋ, ប្រហារ

www.elibraryofcambodia.org

ជា ប្រហើរ, សត៌ ជា សតើ, សម ជា សមើ, សរ ជា សើរ, សវ ជា សើវ ។

ផ្លាស់ "អ" ជា "អឿ" ដូច ជា គណ ជា គឿណ, ភណ ជាភឿណ, ណោរត្ត ជា ណឿរត្ត ។ល។

ផ្លាស់ "អ" ជា "ឯ" ដូចជា កោណ្ឌញ្ញ ជា កោណ្ឌេញ្ញ, គណ ជា គេណ, បញ្ចម ជា បេញ្ចម, ពចន៍ ជា ពេចន៍, ពជ្រ ជា ពេជ្រ, ពជ្ឈឃាតក៍ ជា ពេជ្ឈឃាតក៍, វច្ចកុដិ ជា វេច្ចកុដិ ។ល។

ផ្លាស់ "ុ, ូ" ជា "ូវ" ដូចជា គ្រុ ជា គ្រូវ, ធ្នូ ជា ធ្នូវ, គុ ជា គូវ, ទុ ជា ទូវ-ទៅ, ចុ ជា ចូវ-ចៅ, រិបុ ជា រិបូវ, សត្រុ ជា សត្រូវ ។ល។

ផ្លាស់ "ឯ" ជា "អៀ" ដូចជា ជេស្ឋជ័យ ជា ជៀស្ឋជ័យ, ចាំ-ពេក៍ ជា ចាំពៀក៍, ពេរ ជា ពៀរ, អាពេស ជា អាពៀស ។ល។

ផ្លាស់ "អៃ" ជា "អែ" ដូចជា ចៃត្យ ជា ចែត្យ, ចៃត្រ ជា ចែត្រ, ទៃត្យ ជា ទែត្យ, ពៃទ្យ ជា ពែទ្យ, ពៃទ្យស្ថាន ជា ពែទ្យ-ស្ថាន, ពៃស្យ ជា ពែស្យ, ពៃស្យា ជា ពែស្យា, វៃស្យា ជា វែស្យា, អៃរាវណ ជា អែរាវណ, សៃន្យានុភាព ជា សែន្យានុភាព ។ល។

www.elibraryofcambodia.org

សម្លេងស្រៈ "អៈ" ក្លាយទៅជាស្រៈ "អ" កាលបើមានតួ "រ" ប្រកបដូច វរៈ ជា វរ, សញ្ចារៈ ជា សញ្ចារ ។ល។ បើផ្សំចូលជាមួយព្យញ្ជនៈខាងចុង ពាក្យដែលប្រើជាតួប្រកបសម្លេងស្រៈ "អ" ច្រើនតែលេចបាត់ទៅ ដូចជា សុខៈ ជា សុខ (សុក), ភយៈ ជា ភ័យ (ភៃ), វិធៈ ជា វិធ (វិត) ។ល។ បើផ្សំចូលជាមួយព្យញ្ជនៈចុងពាក្យ ច្រើនផ្លាស់ស្រៈ "អ" ទៅជា "អា, អ័, អិន, អេស" ឬក៏ផ្លាស់ទៅជាស្រៈដទៃទៀតខ្លះក៏មាន (ច្រើនប្រើក្នុងពាក្យកាព្យ និងពាក្យប្រព័ន្ធ ដើម្បីឲ្យចាប់សម្ផស្សគ្នា ដូច កាយៈ ជា កាយា, កាយ័, កាយិន, កាយេស ។ល។)

លុបស្រៈ "អ" ដែលនៅខាងដើមពាក្យចេញក៏មាន ដូច អនុជ ជា នុជ, អកិរម ជា កិរម ។ល។

បើមានតួ "ម" នៅខាងក្រោយ ផ្លាស់ស្រៈ "អ" ជា "អំ" មានតួ "វ" នៅខាងក្រោយ ផ្លាស់ស្រៈ "អ" ជាស្រៈ "អៅ" ដូចជា អមាត្យ, អមរិន្ទ្រ ទៅជា អំមាត្យ, អំមរិន្ទ; នវ, ជវនៈ ទៅជា នៅៈ, ជៅនៈ ។ល។

ស្រៈ "អា" បើផ្សំចូលជាមួយនឹងព្យញ្ជនៈចុងស័ព្ទ លុបចេញ

www.elibraryofcambodia.org

ខ្វះតែមាន ដូច សាលា ទៅជា សាល, ធាយា ទៅជា ធាយៈ ។ល។

ស្រៈ "អ" ផ្លាស់ជាស្រៈ (ឹ) ដូចជា លិង្គៈ ទៅជា លឹង្គ, អតិត ទៅជា អតឹត, សិក្សា ទៅជា សឹក្សា ។ល។

ផ្លាស់ស្រៈ "អ" ជាស្រៈ "េ" ដូចជា សិលា ទៅជា សេលា, វិតាន ទៅជា វេតាន ។ល។

ផ្លាស់ស្រៈ "អ" ជាស្រៈ "ៃ" ដូចជា ពិចិត្រ ទៅជា ពៃចិត្រ, វិហារ ទៅជា វៃហារ ។ល។

ផ្លាស់ស្រៈ "អ" ជាស្រៈ "ៀ" ដូចជា សិរៈ ទៅជា សៀរ, ពាហិរៈ ទៅជា ពាហៀរ, ធម្មិយម ទៅជា ធម្មៀម, បរិញ្ញ ទៅជា បរៀញ្ញ, [illegible] ទៅជា [illegible](១) ។ល។

ផ្លាស់ស្រៈ "ឿ" ជាស្រៈ (ឹ) ដូចជា អាទិក ទៅជា អាទឹក ។ល។

ផ្លាស់ស្រៈ "ឿ" ជាស្រៈ "េ" ដូច សឿម ជា សេម, ជាស្រៈ "ៀ" ដូច ចរៈ ជា ចៀរ, កណ្ណៈ ជា កៀណ្ណៈ ។ល។

ផ្លាស់ស្រៈ "ឿ" ជាស្រៈ "អ" ដូច ទ័ល ទៅជា ទិល; ហ័នជាតិ ជា ហិនជាតិ ។ល។

---

(១) ក្នុងបច្ចុប្បន្ននេះ ប្រើតួ "ទ" ជំនួស "ឡ" ។

www.elibraryofcambodia.org

ស្រៈ "អ" និងស្រៈ "ឿ" នេះ ច្រើនប្រើត្រឡប់ផ្លាស់ប្តូរគ្នាក្នុងពាក្យកាព្យ ឬពាក្យប្រព័ន្ធខ្លះៗ ដើម្បីឲ្យពាក្យទាំងនោះចាប់សម្ពស្សគ្នា និងដើម្បីឲ្យ ជា គរុ លហុ ដែលមានការចាំបាច់ត្រូវប្រើក្នុងពេលតែងពាក្យកាព្យ ។

ស្រៈ "ុ" ផ្លាស់ជាស្រៈ "ូ" ដូចជា វេបុល្យ ទៅជា វេបូល្យ, អាតុរៈ ជា អាតូរៈ ។ល។

ផ្លាស់ស្រៈ "ុ" ជា "អោ" ដូចជា សាធុ ជា សាធោ, ខុមាន ជា ខៈមាន ខុយេស ជា ខោយេស ។ល។

ផ្លាស់ស្រៈ "ុ" ជា "អៅ" ដូចជា សុទ្ធ ជា សៅទ្ធៈ ។ល។

ផ្លាស់ស្រៈ "ុ" ជា "ៅ" ដូចជា សុភាព ជា សៅភាព, សុគន្ធ ជា សៅគន្ធ ។ល។

ផ្លាស់ស្រៈ "ុ" ជាស្រៈ "ោ" ដូចជា បុកណ ជា បោកណ, សុភាគ ជា សោភាគ ។ល។

ផ្លាស់ស្រៈ "ុ" ជា "ឪ" ដូចជា សុភាគ ទៅជា សៅភាគ, សុគន្ធ ជា សៅគន្ធ ។ល។

ស្រៈ "ូ" ច្រើនផ្លាស់ត្រឡប់ជាមួយនឹងស្រៈ "ោ" កាល

www.elibraryofcambodia.org

ណាប្រើក្នុងពាក្យប្រព័ន្ធកាព្យ ។

ស្រៈ "ឯ" ផ្លាស់ជាស្រៈ "អៃ" បើមានក្ដួ "យ" ប្រកបដូចជា វេយ្យាករណ៍ ទៅជា វៃយ្យាករណ៍, វេនយ្យ ជា វៃនយ្យ ។ល។

ស្រៈ "ឯ" ច្រើនផ្លាស់មកពីស្រៈ "ឥ" ហើយផ្លាស់ហូតទៅជាស្រៈ "អៃ" បានទៀតដូចជា ហិរញ្ញ ជា ហេរញ្ញ-ហៃរញ្ញ ។ល។

ស្រៈ "អៃ" បើមានក្ដួប្រកប ផ្លាស់ជាស្រៈ "អែ" ដូច វៃទ្យ ជា ពែទ្យ, សៃទ្យា ជា សែទ្យា, ចៃត្យ ជា ចែត្យ, វៃស្យ ជា ពែស្យ ។ល។

ស្រៈ "ឱ" ផ្លាស់ជា "អៅ" ដូចជា ឱសារៈ ជា អៅសារ, ឱការ ជា អៅការៈ ។ល។

ផ្លាស់ស្រៈ "ឱ" ជាស្រៈ "អៅ" ដូចជា ឱឡារៈ ជា អៅឡារៈ ។ល។

ស្រៈ "ឱ" ច្រើនផ្លាស់មកពីស្រៈ "ឧ" ហើយផ្លាស់ជាស្រៈ "អៅ" មួយជាន់ទៀត ដូចជា បុកណ ជា ប៉ៅកណ ។ល។

## វិធីផ្លាស់ព្យញ្ជនៈ

វិធីផ្លាស់ព្យញ្ជនៈនេះ ពាក់ព័ន្ធមកពីរបៀបសន្ធិក្នុងភាសាបាលីខ្លះ តែគេឃើញក្នុងកម្ពុជភាសាខ្លះ មានរបៀបធ្វើដូចនេះ ៖

www.elibraryofcambodia.org

១– ផ្លាស់ព្យញ្ជនៈតួមុខឲ្យអាស្រ័យនឹងស្រៈ "អំ" ដូចជា ប្រាស់ ជា បំរាស់, ស្វែង ជា សំវែង, គ្រប់ ជា គំរប់, ក្រាប ជា កំរាប ។ល។

២– ប្រកប "អំ.ណា-ន" ចូលជាមួយព្យញ្ជនៈដើម ដូចជា កើត ជា កំណើត, គុណ ជា គំណុន, ចោទ ជា ចំណោទ, ដើរ ជា ដំណើរ, ទូល ជា ទំនូល, ចាស់ ជា ចំណាស់ ។ល។

៣– ផ្លាស់ "ខ" ជា "កំ, កំហ" ដូច ខ្ចរ ជា កំចរ, ខ្លាំង ជា កម្លាំង, ខែង ជា កំហែង, ខក ជា កំហក, ខាន ជា កំហាន, ខាត ជា កំហាត, ខិល ជា កំហិល, ខឹង ជា កំហឹង ខ្ជើយ ជា កំណើយ, ខ្ជល់ ជា កំណល់, ខ្ជិល ជា កំណិល, ខ្ជិត ជា កំណិត, ខ្ជក់ ជា កំណក់ ។ល។

ផ្លាស់ "ខ" ជា "ក្រ" នឹង "ខ្ជ" ក៏បានខ្លះ ដូច ខ្ចាយ ជា ក្រចាយ, ខាន ជា ខ្ជាន, ខក់ ជា ខ្ជក់, ខិត ជា ខ្ជិត, ខិប ជា ខ្ជិប, ខារ ជា ខ្ជាត ។ល។

៤– ផ្លាស់ "ឆ" ជា "ចំ" ដូច ឆ្ងាយ ជា ចម្ងាយ, ឆ្ងាញ់ ជា ចម្ងាញ់, ឆ្ងល់ ជា ចំងល់ ។ល។

www.elibraryofcambodia.org

៥- ផ្លាស់ "ដ" ជា "ដំរ" ដូចជា ដះ ជា ដំរះ, ដឿន ជា ដំរឿន ។ល។

៦- ផ្លាស់ "គ" ជា "ជ" ដូចជា គាក ជា ជាក, ទាគា ជា ទាជា ។ល។

៧- ផ្លាស់ "ថ" ជា "ដំ,តង់" ដូចជា ថ្កល់ ជា ដំកល់, ថ្កាយ ជា តង្កាយ ។ល។

៨- ផ្លាស់ "ទ" ជា "ដំ" ដូចជា ទ្រុត ជា ដំរុត ។ល។

៩- ផ្លាស់ "ប" ជា "ផ្ន" ដូចជា បួក ជា ផ្នួក, បួស ជា ផ្នួស ។ល។

១០- ផ្លាស់ "ផ" ជា "ផ្ន" ដូចជា ផែក ជា ផ្នែក ។ល។

១១- ផ្លាស់ "ត" ជា "តៃ,តី" ដូចជា ត្រោះ ជា តៃកេះ, ជា តីកេះ ។ល។

១២- ផ្លាស់ "រ" ជា "ឫ, រ-ង, រ-ប" ដូចជា រតិ ជា ឫតិ, រំ ជា រងំ, រាំ ជា របាំ ។ល។

១៣- ផ្លាស់ "ល" ជា "ល្ប,ល្ម" ដូចជា លាក់ ជា ល្បាក់, លោក ជា ល្មោក ។ល។

www.elibraryofcambodia.org

១៤– ផ្លាស់ "ស" ជា "ស្ថ" ដូចជា សាន ជា ស្ថាន ។ល។

ព្យញ្ជនៈដែលជាតួប្រកប ទីនជាតួបដិសេធ មានវិធីប្រែផ្សេងអំពីភាសាដើមទៀតក៏មាន, មានសេចក្ដីសំខាន់គួរសង្កេតដូចតៈទៅនេះ ÷

១– ព្យញ្ជនៈដែលជាព្យាង្គចុងរបស់សព្ទដើម ច្រើនផ្លាស់មកជាតួប្រកបក្នុងកម្ពុជភាសាដូច សុខៈ ជា សុខ (សុក), នាគៈ ជា នាគ (នាក), ធាតុ ជា ធាតុ (ធាត) ជាដើម

២- ពាក្យបាលីលុបតួតម្រួតមួយចេញ ទុកតែតួប្រកប ជួនកាលក៏អានចេញសម្លេងផងដែរ ដែលប្រើជាច្រើននោះ គឺពាក្យដែលមានតួតម្រួតមានរូបជា ច្ច, ជ្ជ, ញ្ញ, ដ្ត, ដ្ឋ, ល្ល, ត្តិ, ទ្ទ, ន្ន, ស្ស ដូចជា កិច្ច, វេជ្ជ, បុញ្ញ, វិដ្ត, វិល្លន, សម្បត្តិ, សមុទ្ទ, សោតាបន្ន, សោមនស្ស; យើងប្រើជា កិច, វេជ, បុណ, វិដ, វិល័ន, សម្ប័ត, សមុទ, សោតាប័ន, សោមន័ស ដូច្នេះជាដើម; របៀបនេះច្រើនមានតែក្នុងភាសានិយាយ ។

ដែលលុបចេញដូចនេះ ដើម្បីឲ្យងាយស្រួលដល់ការអាន ព្រោះកម្ពុជភាសាយើង ចេញសម្លេងព្យញ្ជនៈតែមួយតួ តាមពាក្យ

www.elibraryofcambodia.org

ត្រូវប្រែកបឲ្យលាន់សម្លេងបញ្ចេញផងដែរ ដូចជា រាជការ (មកពី រាជៈការ) ជាដើម តែពីបុរាណ មិនដឹងជាថាស័ព្ទដើម ជាតួតម្រួត ឬជាតួពោល ដូចជា កិច, សុចរិត, វិជា, ធជ ទ្វិជ ទាំងអស់នេះ មានស័ព្ទដើមជា កិច្ច ជាសុចរិត, វិជ្ជា, ធជៈ ឯងជា ទ្វិជៈ ជាដើម; កុំពេលដែលត្រូវការឲ្យទៅជា លហុ ប្រើទៅជា កិ-ចៈ, វិ-ជា ដូច្នេះ រឹងរឹតតែធ្វើឲ្យសម្លេងប្លែកពីដើម គឺទៅជា កិច ច, វិជ-ជា តែម្តង ៗ ដូច្នេះ ដើម្បីការពារនូវសេចក្តីភ្ញាត់ខុស ត្រូវតែសរសេរតាមរូបដើម ជាកិច្ច, វិជ្ជា ។ល។ ល្អជាង ។

## ល័ក្ខធៀបពាក្យបាលី និង សំស្ក្រឹត

មានពាក្យច្រើនដែលយើងសរសេរប្រើការបានទាំង២ យ៉ាង ដូចជា និច្ច ឯងសរសេរជា និត្យ ក៏បាន របៀបនេះនាំឲ្យពិបាកសង្កេត មិនដឹងជាពាក្យណាផ្លាស់មកពីភាសាណា ដើម្បីការពារនូវសេចក្តីច្រឡំ អ្នករៀនគប្បីសង្កេតបានដូចតទៅនេះ ៖

១-ស្រៈ "ឫ,ឬ,ឭ,ឮ" ៤ តួនេះ មានក្នុងភាសាសំស្ក្រឹតមិនមានក្នុងភាសាបាលី ពាក្យណាដែលមានស្រៈនេះប្រកបចូលផង ពាក្យនោះមកពីពាក្យសំស្ក្រឹត ។ ឧទាហរណ៍ ដូច ឫក្ស, ឫស្យៈ, ឫទ្ធិ ជាដើម។

www.elibraryofcambodia.org

៤- ពាក្យបាលីមិនសូវមានព្យញ្ជនៈផ្សំ (គឺផ្ញើជើងៈ ក្យ, ក្រ, ខ្យ ។ល។) ច្រើនដូចសំស្ក្រឹត ។ ចំណែកព្យញ្ជនៈដើម និងតួប្រកបក្នុងភាសាបាលី មានលក្ខណៈគួរសង្កេតបានដូចនេះ ៖

ក) តួតម្រួតត្រូវមានតួដទៃអាស្រ័យប្រកបជាមួយផង និងមានតែតួមួយពុំបាន ហើយត្រូវជាព្យញ្ជនៈទី១ ទី៣, ទី៤ និងតួ "យ, ល, វ, ស, ឡ" (តួ "ហ" តម្រួតបានខ្លះ ដូច ព្រហ្ម) ។

១) ចំណែកតួតម្រួតអាស្រ័យជាមួយតួប្រកបនោះ ក៏មានដំណើរគួរសង្កេត ព្យញ្ជនៈទី១, ទី២, តម្រួតអាស្រ័យជាមួយតួប្រកបដែលជាព្យញ្ជនៈទី១ ដូច សក្កៈ ទុក្ខៈ សច្ចៈ អច្ឆៈ ។ល។ ព្យញ្ជនៈទី ៣, ទី ៤, តម្រួតអាស្រ័យក្រោយតួប្រកបដែលជាព្យញ្ជនៈទី៣ ដូចជា វគ្គ, ព្យគ្ឃ, ។ល។ ព្យញ្ជនៈតាំង ៥តួតម្រួតអាស្រ័យខាងក្រោយតួប្រកប ដែលជាព្យញ្ជនៈទី៥ ក្នុងវគ្គជាមួយខ្លួន ដូច វង្ក, បុញ្ញ, ខណ្ឌ, សន្តិ, សម្មា ។ល។ ក្នុងសេសវគ្គ តួ "យ, ល, ស" តម្រួតអាស្រ័យតាមក្រោយតួឯងបាន ដូច សេយ្យ, សល្ល, ផស្ស ។ល។ តែតួ "យ, រ, ល, វ, ហ" តម្រួតអាស្រ័យតាមក្រោយតួប្រកប ឬមិនមែនជាតួប្រកបក៏បានដូច ព្យាបាទ,

www.elibraryofcambodia.org

អគ្យាគារ, ព្រហ្ម, ក្លេស, ន្យាយ, វិទ្យា ។ល។

៣. ចំណែកតួតម្រួតក្នុងភាសាសំស្ក្រឹតនោះ ក៏មានរបៀបដូចគ្នានឹងភាសាបាលីដែរ ប៉ុន្តែភាសាសំស្ក្រឹត មានតែតួមួយក៏តម្រួតបានដែរ ចំពោះតួ "រ" មួយតម្រួតបានជាយច្រើន ហើយមានប្រើជាញឹកញាប់ ដូចជា ធម៌, ការ្យ, ។ល។ ឯតួប្រកបអាស្រ័យតាមក្រោយនោះ មានកំណត់ស្រដៀងនឹងបាលី តែផ្សេងគ្នាក៏តម្រួតបានដែរ ដូចជា ចក្រ, សប្ត ។ល។

ពាក្យបាលីនឹងសំស្ក្រឹត ជាភាសាមានឫសគល់ជាមួយគ្នា តែប្រើតួអក្សរខុសគ្នា នឹងស្រដៀងគ្នា ធៀបគ្នាក្នុងពាក្យខ្លះ ល្មមជាគោលសង្កេតដូចតទៅ ៖

| បាលី | សំស្ក្រឹត | កម្ពុជប្រើ |
|---|---|---|
| អស្សម | អាស្រម | អាស្រម |
| វត្ថ | វស្ត្រ | វស្ត្រ |
| កត | ក្ឫត | កត, ក្រឹត |
| អមត | អម្ឫត | អមត, អម្រឹត |
| ឥទ្ធិ | ឫទ្ធិ | ឫទ្ធិ |

www.elibraryofcambodia.org

| បាលី | សំស្ក្រឹត | កម្ពុជប្រើ |
|---|---|---|
| ឥសិ | ឫសិ | ឫសី, ឥសី |
| ឯរាវណ | ឰរាវណ | ឯរាវ័ណ, ឰរាវ័ណ |
| កេលាស | កៃលាស | កៃលាស, ក្រៃលាស |
| មេត្តិ | មៃត្រិ | មេត្រី |
| ឧតុ | ឫតុ | ឫដូវ |
| ខណ | ក្សណ | ខណៈ, ក្សណ |
| ខយ | ក្សយ | ក្ស័យ |
| សិក្ខា | សិក | សឹក្សា |
| អគ្គ | អគ្រ | អគ្គ |
| វិគ្គហ | វិគ្រហ | ពិគ្រោះ, វិគ្រោះ |
| អគ្គិ | អគ្និ | អគ្គី, អគ្និ |
| សច្ច | សត្យ | សត្យ |
| អាទិច្ច | អាទិត្យ | អាទិត្យ |
| បច្ចិម | បស្ចឹម | បស្ចិម |
| វិជ្ជា | វិទ្យា | វិជ្ជា, វិទ្យា |

www.elibraryofcambodia.org

| បាលី | សំស្រ្កឹត | កម្ពុជប្រើ |
|---|---|---|
| វេជ្ជ | វៃទ្យ | ពេទ្យ |
| បាមោជ្ជ | ប្រមោទ្យ | ប្រាមោទ្យ |
| មជ្ឈិម | មធ្យម | មជ្ឈិម, មធ្យម |
| ឧបជ្ឈាយ | ឧបាធ្យាយ | ឧបជ្ឈាយ៍ |
| ញាតិ | ជ្ញាតិ | ញាតិ |
| បញ្ញត្តិ | ប្រជ្ញប្តិ | បញ្ញត្តិ |
| បុញ្ញ | បុណ្យ | បុណ្យ |
| ការុញ្ញ | ការុណ្យ | ករុណា, ការុណ្យ |
| ធញ្ញ | ធាន្យ | ធញ្ញ |
| សាមញ្ញ | សាមាន្យ | សាមញ្ញ, សាមាន្យ |
| ឋាន | ស្ថាន | ឋាន, ស្ថាន |
| ឋិត | ស្ថិត | ស្ថិត |
| ឋាបនា | ស្ថាបនា | ឋាបនា, ស្ថាបនា |
| គហដ្ឋ | គ្រហស្ថ | គ្រហស្ថ |
| ឱដ្ឋ | ឱស្ឋ | ឱស្ឋ |

www.elibraryofcambodia.org

| បាលី | សំស្រ្កឹត | កម្ពុជប្រើ |
|---|---|---|
| អន្ទបន្ធុ | អន្ទប្រន្ធុ | អន្ទប័ន្ធុ |
| វន្ទន | វន្ទន | វន្ទន៍ |
| កណ្ណ | កណ៌ | កណ:, កាណ៌ |
| បរិបុណ្ណ | បរិបូណ៌ | បរិបូណ៌ |
| មុត្តា | មុក្តា | មុត្តា, មុក្តា |
| សត្ត | សប្ត | សត្ត, សប្ត |
| ខេត្ត | ខេត្រ | ខេត្ត, ខេត្រ |
| បុត្ត | បុត្រ | បុត្រ |
| សត្ត | សត្វ | សត្វ |
| ថាវរ | ស្ថាវរ | ថាវរ, ស្ថាពរ |
| ថូប | ស្តូប | ស្តូប, ស្តូប |
| វិត្ថារ | វិស្តារ | ពិស្តារ |
| សត្ថ | សស្ត្រ | សស្ត្រា |
| បមាទ | ប្រមាទ | ប្រមាទ |
| បមាណ | ប្រមាណ | ប្រមាណ |

www.elibraryofcambodia.org

| បាលី | សំស្ក្រឹត | កម្ពុជប្រើ |
|---|---|---|
| បដិបត្តិ | ប្រតិបត្តិ | បដិបត្តិ, ប្រតិបត្តិ |
| កប្ប | កល្ប | កប្ប, កល្ប |
| សិប្ប | សិល្ប | សិល្ប, សិល្ប៍ |
| ធម្ម | ធម៌ | ធម៌ |
| និម្មល | និម៌ល | និមល, និម្មល |
| អាសយ | អាស្រ័យ | អាស្រ័យ |
| សាមិ | ស្វាមី | សាមី, ស្វាមី |
| សគ្គ | ស្វគ៌ | សួគ៌ |
| អស្ស | អស្វ | អស្សតរ, សេះ |
| ឥស្សរ | ឥស្វរ | ឥស្សរ |
| បុស្ស | បុស្ស | បុស្ស |
| មនុស្ស | មនុស្ស | មនុស្ស |

នៅមានពាក្យដទៃៗទៀតជាច្រើន ដែលមិនបានស្រង់យកមកដាក់ប្រៀបធៀបក្នុងទីនេះ អ្នករៀនត្រូវស្វែងរកដោយខ្លួនឯងផងចុះ ។

www.elibraryofcambodia.org

## សន្ធិដែលប្រើក្នុងកម្ពុជភាសា

សន្ធិគឺវិធីភ្ជាប់ពាក្យនឹងពាក្យឲ្យចូលគ្នាជាពាក្យមួយ ក្នុងភាសាបាលីនិងសំស្ក្រឹត មានវិធីធ្វើផ្សេងៗ តែក្នុងទីនេះ នឹងនិយាយចំពោះសន្ធិដែលប្រើក្នុងកម្ពុជភាសា ដែលជាភាសាទម្លាប់ប្រើជាមួយបាលីប៉ុណ្ណោះ ។ មានលក្ខណ៍ដែលគាប់សង្កេតបានដូចតទៅនេះ ៖

១- ស្រះខាងចុងនៃពាក្យដើមជា "អ,អា" បើភ្ជាប់គ្នាឲ្យទៅជាស្រះមួយគួរតែឲ្យទៅជាស្រះ "អា" តែមួយ នឹងត្រូវធ្វើដូចនេះ ទេវ + អភិបាល > ទេវាភិបាល, មហា + អានិសង្ស > មហានិសង្ស, ជីវ + អាត្ម័ន > ជីវាត្ម័ន, ធម្ម + អាគម > ធម្មាគម ។ល។ បើនឹងភ្ជាប់ជាមួយស្រះ "អ" ដែលមានតួតម្រួតនៅខាងចុង ឲ្យចូលគ្នាទៅជាស្រះ "អ" តែមួយគត់ មានវិធីធ្វើដូចនេះ មហា + អណ្ណវ > មហណ្ណវ, មហា + អស្ចារ្យ មហស្ចារ្យ > ជាដើម;

២- ភ្ជាប់ដោយស្រះ "ឥ" ឬស្រះ "ឯ" ដូចជា កឋ + ឥណ > កឋិណ, នរ + ឥន្ទ > នរិន្ទ, នរ + ឥស្សរ > នរេស្សរ;

www.elibraryofcambodia.org

៣– តភ្ជាប់ដោយស្រៈ "ឥ" មានតួកម្រែតនៅ[illegible] ជា "ឥ" តែមួយតួ ដូចជា ជន+ឥន្ទ្រ > ជនិន្ទ្រ, មហា+ឥទ្ធិ > មហិទ្ធិ;

៤– តភ្ជាប់ដោយស្រៈ "ឦ" ឲ្យទៅជាស្រៈ "ឦ" តែមួយតួ ដូចជា ឧត្តរ+ឦសាណ > ឧត្តរីសាណ;

៥– តភ្ជាប់ដោយស្រៈ "ឧ" ឲ្យទៅជាស្រៈ "ឧ, ឩ, ឱ" ដូចជា មគ្គ+ឧទ្ទេសក > មគ្គុទ្ទេសក, រាជ+ឧបត្ថម្ភ > រាជូបត្ថម្ភ, រាជ+ឧបាយ > រាជ្ជោបាយ, មធ្យ+ឧបាយ > មធ្យោបាយ;

៦– តភ្ជាប់ដោយស្រៈ "ឱ" ដូចជា មហា+ឱឡារ > មហោឡារ ។

ពាក្យខាងដើមមានស្រៈចុងបំផុតជា "ឥ, ឦ" តភ្ជាប់ដូចនេះ៖

១– តភ្ជាប់ដោយស្រៈ "ឥ, ឦ" ឲ្យទៅជាស្រៈ "ឥ, ឦ" តែមួយតួដូចជា មុនិ+ឥន្ទ្រ > មុនិន្ទ្រ, ករី+ឥន្ទ្រ > ករិន្ទ្រ;

២– តភ្ជាប់ដោយស្រៈ "ឥ, ឦ" ផ្លាស់ជា "យ" ដូចជា មតិ + អធិប្បាយ > មត្យាធិបាយ, ឥតិ + អាការ > ឥត្យាការ, អគ្គី+ឧកាស > អគ្គ្យោកាស, សាមគ្គី+អាចារ្យ > សាមគ្យាចារ្យ;

ពាក្យដើមមានស្រៈទីបំផុតជាស្រៈ "ុ" ត្រូវផ្លាស់ធ្វើជាតួ "វ" ជាមុន ហើយសឹមតភ្ជាប់ ដូចជា ធនុ+អាគម > ធន្វាគម, គុ + អាការ > គ្វាការ ។

## សិក្ខាសាកល្បង ទី ២

១ – ដូចម្ដេច ហៅថា វិធីផ្សំអក្សរ? ក្នុងកម្ពុជភាសាមាន របៀបផ្សំស្រៈនឹងព្យញ្ជនៈ ដូចម្ដេចខ្លះ? ស្រៈនឹងព្យញ្ជនៈផ្សំចូលគ្នា ហៅថាអ្វី?

២ បើយកព្យញ្ជនៈនឹងព្យញ្ជនៈផ្សំគ្នា អក្សរដែលផ្សំគ្នាហើយ ហៅថាអ្វី? ព្យញ្ជនៈដែលបំបែកហើយ តម្រួតចូលគ្នាហើយ បង់ទៅជាពាក្យមួយ ១ ហៅថាអ្វី?

៣ - ចូរលើកព្យញ្ជនៈតួណាមួយមកបំបែកផ្សំនឹងស្រៈ តាំងពី អ ដល់ អំ មកមើល?

៤ - ដូចម្ដេចហៅថា អក្សរផ្ញើជើង? ឬអក្សរតម្រួត? ចូរលើកយកអក្សរតួណាមួយមកបំបែកផ្សំនឹងស្រៈមកមើល?

៥ សម្លេងក្នុងកម្ពុជភាសាចែកចេញជាប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ដូចម្ដេច ហៅថា សម្លេងសុទ្ធ? មានសេចក្ដីអធិប្បាយយ៉ាងណា?

www.elibraryofcambodia.org

៦- អក្សរសម្រាប់ប្រើជំនួសសម្លេងសុទ្ធ ឲ្យឈ្មោះដូចម្តេច? មានប៉ុន្មានយ៉ាង ? លើកឧទាហរណ៍មកផង ?

៧ ក្ដីអក្សរតែស្រៈទីឯព្យញ្ជនៈក្នុងកម្ពុជភាសា មានឫសគល់មកពីណា? ចូរលើកឧទាហរណ៍មកបំភ្លឺផង ?

៨- ក្នុងកម្ពុជភាសា មានវិធីផ្សំអក្សរយ៉ាងណាខ្លះ? មានរបៀបផ្សំប៉ុន្មានយ៉ាង? ចូររាប់ឲ្យគ្រប់ហើយ ឲ្យឧទាហរណ៍មកផង?

៩- ពាក្យតទៅនេះ កើតមកពីពាក្យដើមថាម៉េច? កំបោរ, កម្លាំង, កំរៃង, កំពោះ, កំហាន, កំហាត, កំហ័ល, កំហឹង, កំណើយ, កំណល់, កំណិត, កំណត់ ?

១០- ដូចម្តេចហៅថា អក្សរតម្រួតក្នុងកម្ពុជភាសា? មានវិធីតម្រួតអក្សរដូចម្តេច ? មានល័ក្ខគោលសង្កេតបានយ៉ាងណា ?

១១- ពាក្យតទៅនេះ ណាជាបាលី? ណាជាសំស្ក្រឹត? អស្សម, អាស្រម, រដ្ឋ, រាស្ត្រ, ឥទ្ធិ, ឫទ្ធិ, ឥសិ, ឫសី, អេករណ៍, ព្យាករណ៍, ឧតុ, ឫតុ, ខណ, ក្សណ, ខយ, ក្សយ, សិក្ខា, សិក្សា, អគ្គ, អគ្រ, វិគ្គហ, វិគ្រហ ;

www.elibraryofcambodia.org

១២– សន្និកន្ទិកម្ពុជភាសា មានលក្ខណៈគោលការសង្កេតបាន យ៉ាងណា? មហានិសង្ស, ជីវក្ខ័ន, មហណ្ណវ, មហស្ចារ្យ, នរិន្ទ; ចក្ខុសោណា, មានវិធីផ្សំដូចម្តេច? ។

## វិធីសរសេរអក្សរ

ការសរសេរអក្សរត្រឹមត្រូវ តាមបែបផែនដែលនិយមប្រើមកហើយនោះ ត្រូវអាស្រ័យសេចក្តីសង្កេតនិងសេចក្តីចេះចាំជាលក្ខ កន្លែងនេះនឹងប្រមូលលំនាំនរបៀបប្រើស្រៈព្យញ្ជនៈ និងវណ្ណយុត្តិមកនិយាយខ្លះ ដើម្បីជាជំនួយសេចក្តីសង្កេតរបស់អ្នករៀន ដូចតទៅនេះ ៖—

<u>វិធីប្រើស្រៈ</u> ចំពោះស្រៈខ្លះ មានរបៀបប្រើផ្សេងគ្នាដូចនេះ

ស្រៈ មានវិធីប្រើ ២ យ៉ាងគឺ

ក) ប្រើវិសគ៌ៈ ពីមុខចំពោះតែពាក្យខ្មែរសុទ្ធ ១ ដូច "ចេះ, កន្ទុះ, ដុះ, តោះ, ពោះ" ពាក្យទាំងនេះមានសម្លេងខុសគ្នានឹងពាក្យ "ចេស, កន្ទាស់, ដុស, តស់, ពោស" ជាដើម ។ ចំពោះពាក្យបាលីនិងសំស្រ្កឹត ដែលមិនមានពាក្យជាប់គ្នា ពី ពាក្យជាប់ពីគ្នាមួយចុង ត្រូវប្រើយុគលពិន្ទុ ដូចៈ "ចេរៈ, គណៈ,

www.elibraryofcambodia.org

មរណៈ, ព្យញ្ជនៈ, អវយវៈ" ពាក្យបាលីសំស្ក្រឹត ដែលនៅខាងដើម ពាក្យនីមួយៗ ដូច "គណៈ, មរណៈ" តួ "គ" និង "ម, រ" មិនត្រូវប្រើយុគលពិន្ទុទេ ។ល។ តែបើមានពាក្យជាប់គ្នាច្រើនបទ ដែលហៅថាបទសមាស ធ្វើឲ្យពាក្យដែលប្រើយុគលពិន្ទុនោះ មិនមែនជាពាក្យចុង មិនត្រូវប្រើយុគលពិន្ទុទេ ដូចៈ "វេរសមាគម, គណបតិ, មរណភាព" ជាដើម ។ ត្រង់នេះត្រូវសង្កេតឲ្យដឹងថា ពាក្យណាជាបទសមាស ពាក្យណាមិនមែនជាបទសមាស ដោយល្អិតល្អន់ដូចៈ "គណបតិ" ពាក្យនេះជាមាស តែគណៈសព្ទមិនមែនជាពាក្យសមាស គឺ "គណ" ពាក្យមួយ "សព្ទ" ពាក្យមួយ ។

១) ស្រៈ "ឫ, ឬ, ឭ, ឮ" នេះជាស្រៈសំស្ក្រឹត យើងយកមកសរសេរប្រើចំពោះពាក្យសំស្ក្រឹតខ្លះ ពាក្យខ្មែរខ្លះ ឧទាហរណ៍ "អ្នកទៅឬទេ ? ឯងបានឮអញនិយាយទេ ? គេមានឫទ្ធិបារមី, គេរឭកឃើញបាបរបស់គេ" ជួនកាលប្រើ (រលឹក) នេះវិញក៏មាន; ស្រៈ៤ តួនេះនឹងយកទៅសរសេរប្រើក្នុងពាក្យបាលីពុំបានឡើយ ។

<u>វិធីប្រើព្យញ្ជនៈ</u>: ព្យញ្ជនៈ ក្នុងកម្ពុជភាសា លោកចែកចេញជាសិថិល, ធនិត, សិថិលឃោសៈ, សិថិលអឃោសៈ,

www.elibraryofcambodia.org

ធនិតឃោស, ធនិតអឃោសៈ ។ ឲ្យល់សំឡេងនៃអក្សរទាំងអស់នេះ បាននិយាយមកខាងដើមហើយ ។ អ្នករៀនត្រូវពិនិត្យឲ្យបានហ្មត់ចត់ ទើបសរសេរមិនខុស ទាំងកម្ពុជភាសាសុទ្ធ ទាំងកម្ពុជភាសា ។ ចំពោះភាសាសរសេរនេះ ខ្មែរយើងច្រើនតែសរសេរជួរគូព្យញ្ជនៈ គឺយកអក្សរ ដែលមានគូ ជាសិថិលធ្វើជាធនិត, យកអក្សរធនិតធ្វើជាសិថិល ។ មួយទៀត ភាសានិយាយជាធនិតសរសេរជាសិថិល ដូចនិយាយថា "ខ្មេង" សរសេរថា "ក្មេង", និយាយថា "ឃ្មាន" សរសេរថា "គ្មាន"; និយាយថា "ថ្នោត" សរសេរថា "ត្នោត" ។ល។ សរសេរ "បុរស" អាន "ប្រុស", សរសេរ "សតេជ" អាន "ស្តេច", សរសេរ "សំតេជ" អាន "សំដេច" ឬ "សម្តេច", សរសេរ "ស្តេច" អាន "ស្តាច់" ។ល។

<u>ប្រើព្យញ្ជនៈឲ្យត្រូវតាមភាសាដើម</u> ពាក្យក្នុងភាសាបរទេសដែលយកមកប្រើលាយជាមួយភាសាជាតិ ត្រូវសរសេរតួព្យញ្ជនៈឲ្យត្រឹមត្រូវតាមភាសាដើមដូច "សុខ" កុំសរសេរ "សុក", "វង្ស" កុំសរសេរ "វង់", "បុណ្យ" កុំសរសេរ "បុន្យ" ។ល។

ពាក្យណាដែលទំលាប់ប្រើល្អៀងពីភាសាដើមមកហើយ ត្រូវ

www.elibraryofcambodia.org

សរសេរតាមទំលាប់ដូចដើម ដូច ចាកិន, ជប៉ុន ជាដើម ។

ពាក្យសមាស ត្រូវសរសេរឲ្យជាប់គ្នាជាភាសាតែមួយដូច “អធ្យាស្រ័យ” កុំសរសេរជា “អជ្ឈាស្រ័យ” គឺកុំសរសេរជាពាក្យបាលីពាក់កណ្ដាល សំស្រ្កឹតពាក់កណ្ដាល លើកលែងតែពាក្យណាដែលធ្លាប់តែប្រើលាយគ្នាមកហើយ មិនអាចរកពាក្យដទៃមកប្រើជំនួសឲ្យបានស្រួល ឬមិនអាចនឹងផ្លាស់ឲ្យទៅជាភាសាតែមួយ ដែលជាហេតុនាំឲ្យទំនាស់ដល់សេចក្ដីនិយម ពាក្យនោះ ត្រូវសរសេរតាមទំលាប់ដូច “វប្បធម៌” កុំសរសេរជា “វប្បធម្ម” ។

ប្រើតម្រួតឲ្យត្រឹមត្រូវ ក្នុងតម្រួតក្នុងកម្ពុជភាសាសុទ្ធ ។ ឬពាក្យដែលពាក់ព័ន្ធមកពីបាលីនិងសំស្រ្កឹត ត្រូវសង្កេតតាមដែលបានអធិប្បាយក្នុងលក្ខណ៍ប្រៀបធៀបបាលី សំស្រ្កឹត ។ ឯតម្រួតក្នុងកម្ពុជភាសានោះ ក្នុងតម្រួតប្រព្រឹត្តទៅតាមលក្ខណ៍ដើម ឬសំយោគ ដូចបានពោលមកហើយ គឺបើកម្ពុជភាសាសុទ្ធ ព្យញ្ជនៈទី ១ តម្រួតលើទី ១ និងទី២, ទី ៣ តម្រួតលើទី ៣ និងទី ៤,ទី ៥ តម្រួតលើពីទី១ ដល់ទី៥ ក្នុងវគ្គរបស់ខ្លួនៗ ។ បើជាកម្ពុជភាសា ការតម្រួតនឹងមិនប្រព្រឹត្តទៅតាមលក្ខណ៍នេះឡើយ, ដូចៈ ធ្លាប់, ស្ដេច, សម្ដេច,

www.elibraryofcambodia.org

ត្រូវ, តម្រូវ, ស្រេច, សម្រេច, ស្រោច, សំពោច, ស្រង់, សំរង់, ផ្ចាញ់, អញ្ជើញ, ខ្ញុំ, បញ្ជា, ល្ខោន, បណ្ដា, កន្ទុល ។ល។

ធ្នូបដិសេធ ធ្នូបដិសេធ មានវិធីប្រើដែលអាចឲ្យសង្កេតបានគឺ “សញ្ញាទណ្ឌឃាត”, តែមានពាក្យខ្លះ លោកមិនប្រើទណ្ឌឃាតសញ្ញា ។ ដូចនេះ នាំឲ្យអ្នកអានអ្នកសរសេរលំបាក, ដើម្បីងាយសង្កេត ក្នុងពេលអាន ពេលសរសេរ បើពាក្យណាមិនត្រូវការអានត្រូវតែដាក់សញ្ញាទណ្ឌឃាតឧទាហរណ៍ “ប្រយោជន” អាន “ប្រយោជន់”, ដាក់សញ្ញាទណ្ឌឃាតលើអក្សរ “ន” “ប្រយោជន៍” អាន “ប្រយោជ” ។ល។

## វិធីអាន

កម្ពុជភាសាច្រើនអានគ្រន់ៗ មិនសូវលំបាក តែកម្ពុជភាសាសុទ្ធដែលប្រើទៅជា បាលី សំស្ក្រឹត រមែងលំបាកក្នុងការអានមើល ។ ដើម្បីឲ្យបានងាយក្នុងការអានមើល អ្នករៀនត្រូវសង្កេតភាពនៃអាននេះទុកជាលក្ខ ហើយត្រូវចំណាំពាក្យដែលបានជួបក្នុងពេលសរ[illegible] ពេលអាន ឲ្យបានស្ទាត់ជំនាញ ទើបអាចការពារនូវការអានសរសេរមិនឲ្យក្វាំងក្វាត់បាន ។

www.elibraryofcambodia.org

| សព្ទ | អានតាមល័ក្ខ | កម្ពុជអាន |
|---|---|---|
| ទេសនា | ទេសៈនា | ទេស្នា |
| សាសនា | សាសៈនា | សាស្នា |
| ហសនា | ហសៈនា | ហស្នា |
| ស្រ | ស្រៈ | ស្រៈ |
| កនក | កៈនៈកៈ | កៈនៈកៈ |
| កាកនិក | កាកៈនិកៈ | កាកៈនិក |
| សមាស | សៈមាសៈ | សមាស |
| អនាថ | អៈនាថៈ | អនាថា (ថ្ងាស់អថាកា) |
| សក្កជ | សៈកៈកជៈ | សកកជ |
| សមយ | សៈមៈយៈ | សម័យ |
| ចរិត | ចៈរិតៈ | ចរិត |
| សមុទ្រ | សៈមុទ្រៈ | សមុទ្រ |
| សរុប | សៈរុបៈ | សរុប |
| ប្រយោជន | ប្រៈយោជៈនៈ | ប្រយោជន៍ |
| ប្រយោគ | ប្រៈយោគៈ | ប្រយោគ |

www.elibraryofcambodia.org

| ស័ព្ទ | អានតាមល័ក្ខ | កម្ពុជអាន |
|---|---|---|
| ប្រមាទ | ប្រៈមាទៈ | ប្រមាទ |
| ប្រវត្តិ | ប្រៈវត្តិ | ប្រវត្តិ |
| អតិរេក | អៈតិរេកៈ | អតិរេក |
| បញ្ញត្តិ | បញ្ញត្តិ | បញ្ញត្តិ |

ព្យញ្ជនៈផ្ញើជើង ឬតួតម្រួតដូច “ទ” តម្រួតជាមួយ “រ” ជាដើម ដែលមកពីពាក្យបាលី ឬសំស្ក្រឹត ឬកម្ពុជភាសាសុទ្ធ ត្រូវអានបញ្ចេញសម្លេងកន្លះមាត្រា គឺពាក់កណ្ដាលសម្លេងកន្លែងមួយ ដូច ទិព្រា កុំអាន ទិទៈព, ឥន្ទ្រិយ៍ កុំអាន ឥន្ទៈរិយ៍, ចន្ទ្រា កុំអាន ចន្ទៈរា ។ល។

ពាក្យដែលផ្លាស់មកពីអក្សរផ្ញើជើង វេលាអានរមែងបញ្ចេញសម្លេងប្រើតាមទំនងគួរដើម ដូចៈ ក្រាប ជា កំរាប, ត្រួត ជា តម្រួត, ស្រួច ជា សំរួច, ប្រាប់ ជា បំរាប់, ត្រូវ ជា តម្រូវ, ព្រាន ជា ចំរាន, គ្រាស់ ជា គំរាស់, ស្រេច ជា សំរេច ។ល។

ពាក្យកម្ពុជសុទ្ធ ឬបាលី សំស្ក្រឹត ដែលផ្សំជាមួយស្រៈ “អ” មិនមានរេះមុខ សរសេរតែតួព្យញ្ជនៈរៀងតាមលំដាប់ ដូចៈ ជនបទ,

www.elibraryofcambodia.org

ជនទី ៗ ល ៗ ត្រូវអានបញ្ចេញសម្លេងស្រៈ "អ" ជា "ជន-នៈបទ, ជន-នៈទី" ដូចបាននិយាយមកហើយក្នុងវិធីផ្លាស់ស្រៈ ឬមិនអាន បញ្ចេញសម្លេងស្រៈគ្រប់តួទាំងអស់ក៏បាន ដូចៈ "កុសល" អាន "កុៈសៈលៈ", "អកុសល" អាន "អៈកុៈសៈលៈ", "ជនបទ" អាន "ជៈនៈបៈទៈ", "ជនទី" អាន "ជៈនៈទី" ជាដើម ឬអាន បញ្ចេញសម្លេងជាតួស្រៈ "អ" ខ្លះ ជាតួប្រកបខ្លះក៏បាន ដូច "ជនបទ" អាន "ជន-នៈបទ ឬជៈនៈបទ" ៗ ល ៗ ដើម្បីអានឲ្យបានត្រឹម ត្រូវនោះ អ្នករៀនត្រូវសង្កេតល័ក្ខណ៍ដូចតទៅនេះ ៖

ក) <u>ពាក្យជាបទសមាស</u> ចំពោះពាក្យបាលីនិងសំស្ក្រឹត ដែលមានប្រើក្នុងកម្ពុជភាសាយើង ច្រើនប្រើព្យាង្គចុងជាតួប្រកប ដូច "រាជ, កម្ម, ធាតុ" ៗល ៗ និយមអានថា "រាជ, កម្ម, ធាត;" មិនសូវអានថា "រាជៈ, កម្មៈ, ធាតុ"; តែបើមានពាក្យតភ្ជាប់ខាងចុង ទៀត ដែលហៅថា "បទសមាស" ត្រូវអានបញ្ចេញសម្លេងតួប្រកប នៃពាក្យដើមផង ដូច "រាជការ, កម្មសាស្ត្រ, ធាតុសញ្ញា"; ត្រូវ អាន "រាជ-ជៈការ, កម្ម-មៈសាស, ធា-តុ-សញ្ញា" ជាដើម ៗ បើព្យាង្គចុងពាក្យមុខជាតួមានបដិសេធ ត្រូវលុបបដិសេធចេញ

www.elibraryofcambodia.org

ព្រោះត្រូវការតាមតួបដិសេធនោះ ដូច "ចេតិយ៍" បើជាពាក្យសមាស ត្រូវសរសេរជា "ចេតិយស្ថាន" អានថា "ចេ-តិ-យៈ-ស្ថាន" ដូច្នេះជាដើម លើកលែងតែពាក្យប្រព័ន្ធខ្លះ ដែលត្រូវការឲ្យមានព្យាង្គតិចចុះមកនោះ មិនត្រូវអានតាមន័យនេះទេ ត្រូវសរសេរដាក់សញ្ញាទណ្ឌឃាតលើពាក្យ ដែលត្រូវឈប់អាន ដូច "សុរិយ៍វង្ស" ឲ្យអានថា "សុ-រិ-វង្ស" ។ល។

១) ពាក្យប្រព័ន្ធកាព្យ ពាក្យប្រព័ន្ធកាព្យ ត្រូវការឲ្យមានសម្ផស្សតាមគ្នា ត្រូវការឲ្យមានព្យាង្គតិច ឬព្យាង្គច្រើនខ្លះ ត្រូវការឲ្យមាន គរុ លហុខ្លះ ទើបមានវិធីអានខុសប្រក្រតី ដូចពាក្យថា "ចន្ទ្រ", បើត្រូវការឲ្យមានព្យាង្គច្រើន ឬឲ្យមានសម្ផស្សទទួលពាក្យដើម អានថា "ចន-ទ្រៈ", បើមិនត្រូវការទេ អានថា "ច័ន", ពាក្យថា "ចរ" បើត្រូវការឲ្យទៅជាលហុទាំងពីរតួ អានថា "ចៈរៈ" បើត្រូវការឲ្យទៅជាគរុតែមួយ អានថា "ចរ" បើត្រូវការឲ្យគរុនៅមុខ, លហុនៅក្រោយ អាន "ច-រៈ" ដូច្នេះជាដើម ។

### វគ្គសរាបន ទី ៣

១- មានល័ក្ខសន្តិកយ៉ាងណា ដើម្បីសរសេរពាក្យឲ្យបាន

www.elibraryofcambodia.org

ត្រឹមត្រូវ ?

២- ចំពោះតួស្រៈ មានរបៀបប្រើផ្សេងគ្នាយ៉ាងណា ?

៣- ស្រៈ "អ" មានវិធីប្រើប៉ុន្មានយ៉ាង? មានសេចក្ដីអធិប្បាយដូចម្ដេច? លើកឧទាហរណ៍មកផង ?

៤- ស្រៈ ៤ តួគឺ ឫ ឬ ឭ ឮ ជាស្រៈអ្វី? ប្រើបានចំពោះពាក្យណាខ្លះ ? មានឧទាហរណ៍ដូចម្ដេច ?

៥- ព្យញ្ជនៈមានរបៀបប្រើយ៉ាងណា? ព្យញ្ជនៈអ្វីដែលធ្វើឲ្យអ្នកនិយាយក្ដី សរសេរក្ដី ខុសដោយមិនដឹងខ្លួន?

៦- ភាសាបរទេសដែលយកមកប្រើក្នុងភាសាជាតិយើង ត្រូវសរសេរអក្សរយ៉ាងណា ?

៧- ពាក្យដែលជាបទសមាស មានរបៀបសរសេរដូចម្ដេច? អត្ថាស្រ័យ និងអត្ថស្រ័យ ពាក្យទាំងពីរនេះ ណាខុសណាត្រូវ?

៨- អក្សរតួណាដែលចាត់ជាអក្សរតួតម្រួត ? ក្នុងកម្ពុជភាសា មានរបៀបតម្រួតអក្សរយ៉ាងណា ?

៩- អក្សរតម្រួតក្រោមរបៀបល័ក្ខមានដែរឬទេ ? បើមានសូមឲ្យឧទាហរណ៍មកផង ?

www.elibraryofcambodia.org

១០- ពាក្យតាំងអស់នេះ អានតាមលំនាំដូចម្ដេច ? ទេសនា, សាសនា, ភាសា ;

១១- អក្សរគម្រូ ឬអក្សរផ្សេងៗដែលទំលាប់ប្រើក្នុងកម្ពុជភាសាជាមួយភាសាបាលី-សំស្ក្រឹត មានរបៀបអានយ៉ាងណា ?

១២- ពាក្យដែលផ្លាស់មកពីអក្សរផ្សេងៗនេះ មានសម្លេងអានដូចម្ដេច? សំរួច, ចំណង, បំរើន មានកំណើតដើមដូចម្ដេច?

អ្នកសិក្សាបានស្គាល់អក្សរនិងរបៀបប្រើអក្សរដូចបានពោលមកហើយ តទៅនេះ ត្រូវស្គាល់ "វណ្ណយុត្តិ" និង "របៀបប្រើវណ្ណយុត្តិ" ។

បទទី ៣

## វណ្ណយុត្តិ

វណ្ណយុត្តិ មាន ១១ ក្បួន

១- រស្សសញ្ញា ឬ បន្តក់ ( ់ )

២- មូសិកទន្ត ឬ ធ្មេញកណ្ដុរ ( ៉ )

៣- ត្រីសព្ទ ( ៊ )

៤- សំយោគសញ្ញា ( ័ )

www.elibraryofcambodia.org

៥- របាទ ឬ រេផៈ ( ៌ )

៦- ទណ្ឌឃាត ឬ បដិសេធ ( ៍ )

៧- លេខអស្ដ ( ៏ )

៨- វិសជ្ជនីយ ឬ វិសគ្គៈ ឬ រះមុខ ( ះ )

៩- យុគលពិន្ទុ ( ៈ )

១០- កាកបាទ ឬ ជើងក្អែក ( ៎ )

១១- លេខទោ ឬ កាមេណ្ឌុតសញ្ញា ( ៗ )

យើងបានស្គាល់ "វណ្ណយុត្តិ" តែបើមិនស្គាល់ "ខណ្ឌ-សញ្ញា" ផងទេ ក៏ពុំបានគ្រប់គ្រាន់តាមសេចក្ដីត្រូវការ ក្នុងពេលសរសេរ ឬនិយាយ ដូច្នេះ យើងត្រូវស្គាល់ "ខណ្ឌសញ្ញា" ផង ។

## ខណ្ឌសញ្ញាមាន ២០ គឺ

១ - កុក្កដនេត្រ ឬ ភ្នែកមាន់ ( ៖ )

២- ខណ្ឌ ឬ ល្បះ ( ។ )

៣- ល្បះចប់ ឬ ល្បះបរិយោសាន ( ៕ )

៤ គោមូត្រ ( ៚ )

៥- ក៏ក់ ឬ ឃ្នាប (accolade) ( { )

www.elibraryofcambodia.org

៦ វជ្ជសញ្ញា (យតិភង្គ, ខណ្ឌសញ្ញា) (trait) (–)

៧ [illegible]សញ្ញា ឬ ពងក្រពើ (point de suspension) (...)

៨ - បេយ្យាល (។ប។ ឬ ។ល។)

៩ - [illegible]សង្កត (.)

១០ – ក្បៀស (Virgule) ( , )

១១ - ចំណុចក្បៀស (point virgule) ( ; )

១២ – ចំណុចពីរគូស ឬ ទ្វិបិន្ទុលេខ ( : )

១៣ – បុច្ឆាសញ្ញា (point d'interrogation) (?)

១៤ – ឧទានសញ្ញា (អច្ឆរិយសញ្ញា, វិម្ហយ-, សំវេគ-) (!)

១៥ វិគ្គហសញ្ញា ឬ អញ្ញប្រកាស (guillemets (" " ឬ « »)

១៦ – អន្តរសញ្ញា (' ')

១៧ – វង់ក្រចក ឬ ខណ្ឌសញ្ញា (parenthèses) (( ))

១៨ – វង់ដង្កៀប (Crochets) ( [ ] )

១៩ - វង់ក្រចកចំហៀង ឬ អឌ្ឍខណ្ឌសញ្ញា (demi-parenthés) ( ) )

២០ អវគ្រហសញ្ញា (ះ)

គន្ធីទេះ: នឹងនិយាយអំពីវិធីប្រើវណ្ណយុត្តជាមុន ឯវិធីប្រើ

www.elibraryofcambodia.org

ខណ្ឌសញ្ញា និងនិយាយទៅក្នុងភាគសម្ពន្ធមាលាខាងមុន ព្រោះក្នុងភាគសម្ពន្ធមាលានោះ មានរបៀបសម្ពន្ធពាក្យរួមជាមួយខណ្ឌសញ្ញាផង ។ ក្នុងភាគអក្ខរាវិធីនេះ មាននិយាយចំពោះតែរបៀបប្រើអក្សរ របៀបអាន និងរបៀបប្រើប្រាស់អក្សរ ដែលទាក់ទងដល់វណ្ណយុត្តិ ទើបលើកយកវណ្ណយុត្តិមកនិយាយក្នុងភាគនេះ ដើម្បីឲ្យអ្នករៀនបានស្គាល់ព្រមគ្នាតែម្ដង ។

## វិធីប្រើវណ្ណយុត្តិ

### បន្តក់ ឬ ស្យេសញ្ញា ( ')

សម្រាប់ប្រើបំបែរសម្លេងវែងឲ្យខ្លីកំបុតចុង ដាក់បានតែលើតួអក្សរប្រកបពាក្យខ្មែរចំពោះស្រៈ "អ, អា" ហើយតួប្រកបនោះត្រូវជាអក្សរ ក, ង, ច, ញ, ត, ន, ប, ល, ស, ឧទាហរណ៍: កក់, កង់, ដាក់, ចាញ់ [illegible]

មួយវិញទៀត ស្រ[illegible] "ង" ក៏មិនត្រូវប្រើបន្តក់ ( ') ត្រូវប្រើ[illegible] ឧទាហរណ៍ : ក្ដាំង, ខ្លាំង, ច្បាំង, ឆ្នាំ[illegible]

www.elibraryofcambodia.org

## ធ្មេញកណ្ដុរ ឬ មូសិកទន្ត ( ៉ )

សម្រាប់ប្រើដាក់ពីខាងលើដើម្បីបម្លែងអក្សរឃោសៈ ឲ្យទៅជាអឃោសៈវិញ ។ ឧទាហរណ៍: ង៉ំ, ញ៉ា, ម៉;.. ។ សម្រាប់ប្រើដាក់លើស្រះ ( ិ ) ឲ្យទៅជាស្រះ ( ី ) ។ ឧទាហរណ៍: ក៊ី, ខ៊ី, ប៊ី;... ។ បើមានស្រះ ឬ ទន្តហាក ( ុ ) នៅពីលើ ត្រូវប្ដូរធ្មេញកណ្ដុរ ( ៉ ) ទៅជាក្បៀសក្រោម ( ុ ) វិញ ។ ឧទាហរណ៍: មុង, រុង, ញាំង, ប៉ុង;... ។ ត្រូវចំណាំថា ចំពោះ "ប" ដែលជាអឃោសៈស្រាប់ កាលបើដាក់មូសិកទន្ត ( ៉ ) នៅពីលើ ក៏គង់នៅជាអឃោសៈដដែល តែសម្លេងប្ដូរទៅជា "ប៉" វិញ ។

ពាក្យពីរព្យាង្គ បើព្យាង្គដើមជាអឃោសៈ ព្យាង្គខាងចុងមិនត្រូវប្រើ មូសិកទន្ត ( ៉ ) ពីលើឡើយ ។ ឧទាហរណ៍: កញ្ញា, ក្រមា, ក្រវែមក្រវ៉ម, ក្រវល់ក្រវ៉ាយ,... ។

## ត្រីស័ព្ទ ( ៊ )

វណ្ណយុត្តិត្រីស័ព្ទ ( ៊ ) នេះ សម្រាប់ដាក់លើអក្សរ ៤ តួគឺ ប, ស, ហ, អ ឲ្យមានសម្លេងជា ប៊, ស៊, ហ៊, អ៊ ។ ឧទាហរណ៍: ឈ្មោះ ប៊ិន, ស៊ិនស្វា, ក្រុមហ៊ុន, មាត់អ៊ូអា ជាដើម ។ ត្រូវ

www.elibraryofcambodia.org

ចំណាំថា សញ្ញាត្រីស័ព្ទ (៊) នេះ បើមានស្រៈនិស្ស័យគឺ ( ិ), ( ី), ( ឹ), ( ឺ), ( ើ), ( ុំ), ( ាំ) នេះនៅពីលើ ត្រូវប្រើដូចតទៅនេះ ៖

ក) តួ "ប៊" បើមានស្រៈនិស្ស័យនៅពីលើ មិនត្រូវផ្លាស់ត្រី-ស័ព្ទ (៊) ទៅជាភ្នៀស (ុ) ក្រោមទេ ត្រូវទុកឲ្យនៅពីខាងលើដដែល ដើម្បីកុំឲ្យក្លាយទៅជាអក្សរសម្លាប់ ឧទាហរណ៍: ឈ្មោះ ប៊ិន បើផ្លាស់ត្រីស័ព្ទ ( ៊ ) ទៅជាភ្នៀស (ុ) ក្រោម នឹងក្លាយពាក្យ ប៊ិន នេះទៅជា បុិន វិញ,...។

ខ) តួ "ស៊" បើមានស្រៈនិស្ស័យនៅលើ ត្រូវផ្លាស់ត្រីស័ព្ទ (៊) នេះទៅជាភ្នៀស (ុ) ក្រោមវិញ, ឧទាហរណ៍: ឈ្មោះ សុិន, សុីបាយ, ដើរសុីកា, សុើបការណ៍, សុាំចិត្ត ជាដើម ។

គ) តួ "ហ៊" បើមានស្រៈនិស្ស័យនៅពីលើ ប្រើបានទាំងពីរយ៉ាងគឺដាក់ត្រីស័ព្ទ (៊) ពីលើក៏បាន ភ្នៀស (ុ) ពីក្រោមក៏បាន ឧទាហរណ៍ : យំហ៊ឹង ឬ ហុឹង ជាដើម ។

តួ "ស៊" និងតួ "ហ៊", កាលបើមានស្រៈ(ុំ)ប្រកបផ្សំផង ត្រូវផ្លាស់និគ្គហិត (ំ) ទៅជា " ម " វិញ (ផ្លាស់ ស៊ុំ ទៅជា ស៊ុម, ផ្លាស់ ហ៊ុំ ទៅជា ហ៊ុម); ឧទាហរណ៍ : ផ្លាស់ ស៊ុំ ជា ស៊ុម ដូចជា

www.elibraryofcambodia.org

ស៊ិវផ្កាវ, ព្រៃស៊ុមទ្រុម, ផ្ទាស់ ហ៊ឹ ផា ហ៊ុម៏ ផុច ឈរហ៊ុមផិត, ទីមានហ៊ុមហ ជាដើម ។

បើជាស្រៈ ( ំ ) វិញ ចំពោះតួ “ ស ” ត្រូវផ្លាស់ត្រីស័ព្ទ (៊) ទៅជាក្បៀស (ុ) ក្រោមវិញ ឧទាហរណ៍ : ស៊ុំបិត្ត [illegible] ស៊ុំផែល ផូបេះជាដើម ។

ឃ) ចំពោះតួ “អ” ទុកណាជាមានស្រៈ ឬនិគ្គហិត (ំ) នៅពីលើ ក៏មិនត្រូវប្រើក្បៀសពីក្រោមឡើយ ត្រូវទុកត្រីស័ព្ទ (៊) នៅដដែល ឧទាហរណ៍ : អ៊ី, អ៊ីកអ៊ាក, អ៊ីបេះ, អ៊ុះ, អ៊ិះអ៊ុះ ជាដើម ។

ពាក្យពីរព្យាង្គ បើព្យាង្គខាងដើមជាឃោសៈ ព្យាង្គខាងចុងមិនត្រូវប្រើត្រីស័ព្ទឡើយ ឧទាហរណ៍: គុហា, ជំហរ, ជំហាន, ទំហូ, ព្រហូត, វិហារ; . . . ។

សំយោគសញ្ញា (័)

វណ្ណយុត្តិនេះ ជាគ្រឿងសំគាល់នៃអក្សរតម្រួត ។ យើងយកមកប្រើជាឈ្មោះវណ្ណយុត្តិ ជំនួសអក្សរសំយោគ សម្រាប់ប្រើដាក់លើកម្ពុជភាសា (ពាក្យមគធៈ) ឬសំស្រ្កឹតពួកខ្លះ ដែលប្រើមកជាភាសាខ្មែរ ដើម្បីកន្សោលនាំស្រៈ “អ” ឲ្យតង់ទៅតាមសំនៀងដើម

www.elibraryofcambodia.org

ផ្សំទៅនឹងតួប្រកប ឧទាហរណ៍ៈ ក្ស័ណក្ស័យ, ជ័យ, និស្ស័យ ។ល។ ពោះបើពាក្យដែលមានសំយោគស្រាប់ហើយ បើមិនដាក់សំយោគសញ្ញា(៏) នេះផ្សំផងទេ នឹងនាំឲ្យពិបាកថា ដូច្នេះត្រូវប្រើសំយោគសញ្ញា(៏) នេះទៀតក៏មានខ្លះ; ឧទាហរណ៍ៈ ប័ក្ក័ន, បល្ល័ង្ក, ស័ត្រូ ។ល។ សម្រាប់ប្រើក្នុងភាសាខ្មែរសុទ្ធក៏មានខ្លះ, ឧទាហរណ៍ៈ ខ្ញ័រ, ជ័រ, ញ័រ ជាដើម ឬប្រើស្រៈ(េ៉) នឹងតួ "រ" ប្រកបផងក៏បាន ដូចជា កុន្ត្រលើរ, សុបើរ,.. ជាដើម ។

របាទ ឬ រេផៈ ( ៌ )

សម្រាប់ដាក់លើអក្សរតួគុន ឲ្យអក្សរតួដើមបន្ទាប់នោះមានសូរសម្លេងញ័រ, ប្រើចំពោះតែភាសាសំស្ក្រឹត ឬសំស្ក្រឹតក្លាយ ដូចជាៈ គតិ, ទុគិត, ទុពិល ជាដើម, តែបើមានស្រៈដែលទើសនាំឲ្យពិបាកសរសេរនោះ ត្រូវដាក់អក្សរ "រ" ពេញតួ ពីលើជើងអក្សរខាងចុងវិញ ឧទាហរណ៍ៈ ទុរ្ភិក្ស, កមករ្តិ, កេរ្តិ៍ឈ្មោះ ជាដើម, ដូចកាលមិនមានស្រៈទើសទែងទេ ប៉ុន្តែគួរឲ្យច្រឡំពិបាកអាន ក៏ត្រូវដាក់តួ "រ" លើជើងអក្សរខាងចុងបានដែរ ដើម្បីឲ្យងាយស្រួលអាន ដូចជា កម៌ន៍, ម៉ែន៍, អស្ចារ្យ៍, គាហាយ៍

www.elibraryofcambodia.org

ប្រើជា ករ៉ុន, វ៉ុន, អស្ចារ្យ, ភាពារ្យ ជាដើម ។

បើមានអក្សរ "រ" ជាតួប្រកបពីខាងចុង មិនប្រើបាទ (៉) នេះពុំបានឡើយ, ត្រូវប្រើសំយោគសញ្ញា (័) វិញ ឧទាហរណ៍: ទ្វ័រ, ជ័រ, ញ័រ ជាដើម ។

## បដិសេធ ឬ ទណ្ឌឃាត (៍)

វណ្ណយុត្តិនេះ សម្រាប់ប្រើដាក់ឃាត់អក្សរដែលជាចុងពីបាលីឬសំស្ក្រឹតខ្លះមិនឲ្យមានសម្លេង ឧទាហរណ៍: កិរិយាវិសេសន៍ ក្សត្រិយ៍, វៃស្រាពណ៍ ជាដើម ។ ពាក្យខ្មែរសុទ្ធ ក៏ប្រើបដិសេធនេះខ្លះដែរ គឺប្រើតាមសំដីសាមញ្ញ ឬពាក្យផ្សារ ឬពាក្យៗព្យ ឧទាហរណ៍: មកពីណា, បើឃើញវាមក៍ រាប់រក៍ផង៍?... ។

ខាងភាសាសំស្ក្រឹត បើមានបដិសេធ(៍) នៅពីលើតួអក្សរណា តួអក្សរនោះទុកជាតួប្រកប គ្រាន់តែមិនបញ្ចេញសម្លេងប៉ុណ្ណោះ, ឧទាហរណ៍: កម៌ន៍, វម៌ន៍, គបស៍, គេជស៍, កាក្ខន៍ ត្រូវគេថា ករ្ម័ន, គៈបុ័ស, គេជ័ស, កាក្ខ័ន ជាដើម ។

សម្រាប់ប្រើក្នុងភាសាដទៃក៏មានខ្លះ ដូច ស៊ុម៉ង៍ក៍, ទ៉ះបក៍, ឡូក៍ ជាដើម ។

www.elibraryofcambodia.org

## លេខអស្ដា (៨)

វណ្ណយុត្តិនេះ សម្រាប់ប្រើដាក់លើអក្សរពោល នាំអក្សរឲ្យមានសម្លេងកញ្ចក់ខ្លីហើស, ច្រើនដាក់លើអក្សរ ៤ តួ គឺ: ក, ទ, ដ, ហ ។

១- ដាក់លើតួ " ក " ដូចជា: ក៏គង់តែ, ក៏ទៅដែរ ជាដើម;

២- ដាក់លើតួ " ដ " ដូចជា: ដ៏បវរ, ដ៏ប្រសើរ ជាដើម;

៣- ដាក់លើតួ " ទ " ដូចជា: ទ៏, ទុះទ៏! ជាដើម;

៤- ដាក់លើតួ " ហ " ដូចជា ហ៏!, ហ៏យកចុះ ជាដើម ។

## វិសជ្ជនីយ ឬរះមុខ ឬវិសគ្គ: (ះ)

វណ្ណយុត្តិនេះ មានសូរសម្លេងស្រដៀងនឹងខ្យល់អក្សរ "ស" ដែលជាតួប្រកប, ប៉ុន្តែមិនចេញសូរសម្លួសព្រោមប្រចល់ចេញដូចតួ "ស" ទេ ជាសម្លេងកំបុតខ្លី ឧទាហរណ៍: កែះ, កន្ទុះ, ខ្ទះ, ពេះ, ផុះ, បោះ, តោះ ពាក្យទាំងនេះ មានសូរសម្លេងខុសនឹងពាក្យថា: កែស, កន្ទាស់, ខ្ទាស់, ពេស, ផុស, បស់, ពស់ ជាដើម ។

វិសគ្គ (ះ) នេះយកទៅប្រើប្រកបនឹងស្រៈនិស្ស័យបាន ១២ តួ គឺ: ា, ិ, ឹ, ឺ, ុ, ូ, ុ, េ, ៀ, េ, ែ, ោ;

www.elibraryofcambodia.org

១- ប្រើប្រកបនឹងស្រៈ " ់ " ដូចជា: ខះ, គះ, ជះ;...

២- ប្រើប្រកបនឹងស្រៈ " ា " ដូចជាពាក្យឆ្លើយថា: ចាះ! អាះ! ជាដើម;

៣- ប្រើប្រកបនឹងស្រៈ " ិ " ដូចជា: ជិះ, រិះ, វិះ ជាដើម;

៤- ប្រើប្រកបនឹងស្រៈ « ៉ » ដូចជា យ៉ះ, ក្នុងពាក្យថា: យ៉ះ! ខ្មោចលង! ជាដើម;

៥- ប្រើប្រកបនឹងស្រៈ « ឹ » ដូចជា: កឹះគ្នា, ក្ដឹះ, អំណឹះ, ខ្ទឹះ ជាដើម;

៦- ប្រើប្រកបនឹងស្រៈ « ឺ », ដូចជា ខ្ទិចក្បាលចឺស, ដកកឺះ, ឆ្លើយរឺះ! ជាដើម ;

៧- ប្រើប្រកបនឹងស្រៈ " ុ " ដូចជា កុះ, ជុះ, ដុះ ជាដើម,

៨- ប្រើប្រកបនឹងស្រៈ « ើ » ដូចជា បង្កើះ, ក្កើះ, អំណើះ ជាដើម;

៩- ប្រើប្រកបនឹងស្រៈ « ៀ », ដូចជា វៀះវៀន;

១០. ប្រើប្រកបនឹងស្រៈ " េ " ដូចជា បេះ, របេះ, វេះ, សេះ. ជាដើម;

www.elibraryofcambodia.org

១១- ប្រើប្រកបនឹងស្រៈ "ែ" ដូចជា ចំអែះ, គ្រែះ, តក្អែះ, ប្រែះ ។ ជាដើម;

១២- ប្រើប្រកបនឹងស្រៈ "ោ" ដូចជា, កោះ, គោះ, ពោះ ជាដើម ។

ពាក្យសំស្ក្រឹតប្រើមកជាភាសាខ្មែរដែលមានតួ «ហ» ប្រកប នៅខាងចុង ត្រូវផ្លាស់តួ «ហ» ជាវិសគ៌ (ះ) នេះវិញ, គ្ឫហ ទៅ ជា គ្ឫះ ឬ គ្រឹះ, អនុគ្រហ ទៅជា អនុគ្រោះ ។ល។ កុំសរសេរ ជា គ្រឹះហ៍, អនុគ្រោះហ៍, ដូច្នេះឡើយ ។

## យុគលពិន្ទុ (:)

វណ្ណយុត្តិនេះ សម្រាប់ប្រើចុចពីខាងមុខពាក្យបាលី ឬ សំស្ក្រឹត ដែលមានសម្លេងកើតអំពីស្រៈ « អៈ » ឲ្យមានសម្លេង នៅពេញមាត្រាដដែល, ឧទាហរណ៍ៈ ខមៈ, គារៈ, ឃោសៈ ជាដើម ។ សម្រាប់ប្រើចុចពីខាងមុខពាក្យខ្មែរសុទ្ធដែលមាន សម្លេងកើតពីស្រៈ "អ, អា, អេ" ក៏មានខ្លះ ឧទាហរណ៍ : រយៈ, ករៈ, កាលៈ, ទេសៈ, ។ល។

ពាក្យណាដែលជាឧទានសព្ទ ឬជាសព្វនាម មិនត្រូវប្រើ

www.elibraryofcambodia.org

យុគលពិន្ទុ (:) នេះនៅចំពាក់កណ្ដាលព្យាង្គឡើយ ឧទាហរណ៍ៈ កម្ពុជរដ្ឋ, ខេមរជាតិ, ខេមរភាសា, មគធភាសាជាដើម ។

តែបើមានពាក្យមិនមែនជាបទសមាស ជាពាក្យដែលមានព្យាង្គដោយឡែកពីគ្នា ត្រូវចុចកណ្ដាល ដូចជា គណៈមហានិកាយ, គណៈធម្មយុត្តិ, គណៈរដ្ឋមន្ត្រី ។ល។

មួយវិញទៀត យុគលពិន្ទុ(:)នេះ មិនមានសម្លេងទេ, សម្រាប់ប្រើជាសញ្ញាដាក់គ្រឿងសំគាល់ខាងចុងពាក្យ ឬចុងឃ្លាសេចក្ដីខាងមុខ ដែលជាឧទាហរណ៍ ឬជាកម្ពុតានជាដើមៈ ឧទាហរណ៍ៈ គ្រូនិយាយទៅកាន់កូនសិស្សថាៈ «ចូរឯងទាំងប្រឹងរៀនសូត្រកាន់ខ្លួននៅក្មេងនេះ អាកំណា!» ឬប្រើចុចពីមុខមេពាក្យ ដូចជាៈ

វចនាធិប្បាយ :

អក្ខរាវិរុទ្ធ :

ពាក្យ[illegible] :

នាម :

គុណនាម :

កិរិយាស័ព្ទ : ជាដើម

www.elibraryofcambodia.org

បើប្រើក្នុងក្បួនគណិតសាស្ត្រ យុគលពិន្ទុ ( : ) នេះ ប្រែថា "ចែកនឹង" ជាសញ្ញាសម្រាប់សំគាល់ថា ត្រូវរកចំណែក ឬភាគ ដែលត្រូវចែក, ឧទាហរណ៍: ៤ : ២ = ២ ។

កាកបាទជើងក្អែក (+)

វណ្ណយុត្តិនេះ សម្រាប់ប្រើទាញសម្លេងអក្សរឲ្យខ្ពស់ជាងប្រក្រតីដើម, ឧទាហរណ៍: ប៉ះ! ឡស (ពាក្យបម្រាប់ឆ្លើយ), សម្រាប់ជៀតអក្សរដែលសរសេរក្តួច ហើយសរសេរជ្រៀតចង្កូមពីលើឬពីក្រោម, ឧទាហរណ៍: ប្រស័ទ្ធម,... ។

សម័យឥឡូវ ប្រើគំនូស(⌒)នេះ ជំនួសកាកបាទ (÷) ក៏មានខ្លះ, ឧទាហរណ៍: ប្រើខ្ទង់ហាន, កុំបីមានចន្លៃ... ។

កាកបាទ (÷)នេះ ប្រើបានទៀត សម្រាប់សំគាល់ពាក្យថា "នឹង" ឬ "ហើយនឹង" ឧទាហរណ៍: តត្រាយមាទិ <តត្រ+អយំ+អាទិ (អានថា តត្រាយមាទិ មកពី តត្រ នឹង អយំ នឹង អាទិ) តត្រ÷អយំ÷អាទិ > តត្រាយមាទិ ។

សម្រាប់ប្រើលេខបូកក្នុងក្បួនឧត្តុក៏មាន ដូចជា ១÷២=៣, ៣÷៤=៧, ៧÷៣=១០ ។

www.elibraryofcambodia.org

## លេខទោ ឬ អាមេណ្ឌិតសញ្ញា (ៗ)

សម្រាប់ប្រើសរសេរខាងចុងពាក្យ ដែលត្រូវថាជួនពីរដង, ឧទាហរណ៍ : ក្មេងៗ, ចាស់ៗ, ផ្សេងៗ ជាដើម ។

ពាក្យបាលីយកមកប្រើជាខ្មែរ ទុកឈ្មោះជាពាក្យដដែលគ្នា ក៏មិនត្រូវយកលេខទោ (ៗ) នេះ ទុកដាក់ពីមុខឡើយ ឧទាហរណ៍ : នានាជាតក, វិវិធកណ្ឌ, នានាប្រទេស ។ល។ កុំសរសេរថា នាៗជាតក, វិៗធកណ្ឌ, នាៗប្រទេស ដូច្នេះឡើយ ។

## អក្កុសភបទ ទី ២

១– ដូចម្ដេចហៅថា វណ្ណយុត្តិ? វណ្ណយុត្តិមានប៉ុន្មានយ៉ាង? ហៅអ្វីខ្លះ? ចូររាប់ឈ្មោះមកមើល? លេខអស្ដានិងទណ្ឌឃាត មានទ្រង់ទ្រាយដូចគ្នា ឬប្លែកគ្នា? វិសគ៌ៈ និងយុគលពិន្ទុ មានទ្រង់ទ្រាយដូចគ្នា ឬ ផ្សេងគ្នា? ចូរនាំយកប្រភេទសញ្ញាដែលសួរខាងលើនេះមកសរសេរពន្យល់ ហើយប្រាប់ឈ្មោះឲ្យសព្វគ្រប់មកផង ?

២– បន្តក់មានសណ្ឋានដូចអ្វី? សម្រាប់ប្រើយ៉ាងណាខ្លះ? ប្រើបានចំពោះតែលើស្រៈអ្វី? ប្រកបនឹងអក្សរប៉ុន្មានតួ? អក្សរអ្វីខ្លះ? ដូចឧទាហរណ៍ថាម៉េច? ពាក្យដែលជាប់មកពីបាលីប្រើបន្តក់

www.elibraryofcambodia.org

បានឬទេ? មានឧទាហរណ៍ដូចម្តេច? ស្រៈ “ក” ប្រកបនឹងខ្យល់ “ត” ដាក់បន្តក់បានឬទេ ?

៣– ធ្មេញកណ្តុរមានទ្រង់ទ្រាយដូចម្តេច? សម្រាប់ប្រើយ៉ាងណាខ្លះ? អក្សរឃោសៈដែលត្រូវប្តូរឲ្យទៅជាអឃោសៈ មានប៉ុន្មានតួ? ឈ្មោះអ្វីខ្លះ? បើមានស្រៈ ឬនិគ្គហិតនៅពីលើ ត្រូវផ្លាស់ធ្មេញកណ្តុរទៅជាអ្វី? ដូចឧទាហរណ៍ដូចម្តេច? បើមានពាក្យពីរព្យាង្គៈ ព្យាង្គខាងដើមជាអឃោសៈ ព្យាង្គខាងចុងត្រូវសម្លាប់ឬទេ ?

៤– ត្រីស័ព្ទ មានសណ្ឋានដូចអ្វី? សរសេរដាក់លើតួអក្សរណាខ្លះ? សម្រាប់ធ្វើសម្លេងអ្វីឲ្យទៅជាសម្លេងអ្វី? ឧទាហរណ៍ដូចម្តេចខ្លះ? បើមានស្រៈនិស្ស័យ នៅពីលើ ត្រូវផ្លាស់ត្រីស័ព្ទទៅជាអ្វី? ផ្លាស់បានគ្រប់អក្សរទាំង ៤ តួ ឬមានតួខ្លះផ្លាស់មិនបានដែរ? ចូរលើកឧទាហរណ៍មកពន្យល់ផង? តួ “សិ” នឹង “ហិ” បើមានស្រៈ (ុ) នេះប្រកបផង ត្រូវផ្លាស់និគ្គហិតទៅជាអ្វី? មានឧទាហរណ៍យ៉ាងណា? បំពោះពាក្យពីរព្យាង្គ បើព្យាង្គដើមមានសម្លេងជាឃោសៈ ផ្គួលទៅលើព្យាង្គខាងចុង តើព្យាង្គខាងចុងត្រូវដាក់ត្រីស័ព្ទ (៊) នេះពីលើដែរ ឬទេ? តេឧទាហរណ៍មកពន្យល់ផង ?

www.elibraryofcambodia.org

៥- សំយោគសញ្ញា មានទ្រង់ទ្រាយដូចអ្វី? សម្រាប់ប្រើជំនួសអក្សរអ្វី? ប្រើបានយ៉ាងណាខ្លះ? ត្រូវដាក់បានលើពាក្យអ្វីខ្លះ? លើកឧទាហរណ៍មកពន្យល់ផង?

៦- របាទ មានទ្រង់ទ្រាយដូចអ្វី? សម្រាប់ប្រើយ៉ាងណាខ្លះ ចំពោះពាក្យបាលីនិងពាក្យសំស្រ្កឹត? ចូរលើកឧទាហរណ៍មកពន្យល់ផង? បើបានអក្សរ "រ" ជាតួប្រកបនៅខាងចុង និងប្រើរបាទ ( ៌ ) នេះនឹងបានឬទេ? ប្រើដាក់ក្នុងពាក្យដូចឧទាហរណ៍ជាម៉េច?

៧. បដិសេធ មានទ្រង់ទ្រាយដូចអ្វី? សម្រាប់ប្រើយ៉ាងណាខ្លះ ក្នុងពាក្យបាលីនិងពាក្យសំស្រ្កឹត? ក្នុងពាក្យខ្មែរមានប្រើឬទេ? ចូរលើកឧទាហរណ៍មកពន្យល់ផង?

៨- លេខទស្ដា មានទ្រង់ទ្រាយដូចអ្វី? ប្រើបានយ៉ាងម៉េចខ្លះ? ដាក់លើតួអក្សរណាខ្លះ? ចូរកឧទាហរណ៍មកពន្យល់ផង?

៩- វិសគ៌ៈ មានទ្រង់ទ្រាយដូចម្ដេច? មានសូរសម្លេងស្រដៀងនឹងខ្យល់អក្សរអ្វី? មានបញ្ចេញសម្លេងតាមប្រពលធ្មេញឬទេ? សម្រាប់ប្រើប្រកបនឹងស្រៈបានប៉ុន្មានតួ? ស្រៈអ្វីខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់គ្រប់ស្រៈទាំងអស់មកមើល? ពាក្យសំស្រ្កឹតប្រើមកជា

www.elibraryofcambodia.org

ខ្មែរដែលមានតួ "ហ" ប្រកបនៅខាងចុង ត្រូវផ្លាស់ "ហ" ទៅជាអ្វីវិញ? ចូរលើកឧទាហរណ៍មកមើល ?

១០- យុគលពិន្ទុ មានទ្រង់ទ្រាយដូចម្ដេច ? សម្រាប់ប្រើដូចម្ដេចខ្លះ ក្នុងពាក្យបាលីនិងពាក្យសំស្ក្រឹត? ពាក្យខ្មែរសុទ្ធមានប្រើយុគលពិន្ទុនេះឬទេ ? ពាក្យដូចម្ដេចដែលលោកហាមមិនឲ្យប្រើយុគលពិន្ទុ ? យុគលពិន្ទុនេះ មានន័យបន្ទាប់ឲ្យប្រើយ៉ាងណាខ្លះទៀត ? ចូរនាំឧទាហរណ៍មកបំភ្លឺឲ្យល្មមស្ដាប់បានផង ?

១១- កាកបាទមានសណ្ឋានដូចអ្វី ? សម្រាប់ប្រើបានយ៉ាងណាខ្លះ? ចូរលើកឧទាហរណ៍មកពន្យល់ផង ?

១២- លេខទោ មានទ្រង់ទ្រាយដូចម្ដេច ? សម្រាប់ប្រើយ៉ាងណាខ្លះ ក្នុងការសរសេរ ? លេខទោប្រើបានចំពោះតែពាក្យខ្មែរសុទ្ធឬ ? ពាក្យបាលី ប្រើលេខទោបានដែរឬទេ ? ចូរលើកឧទាហរណ៍មកពន្យល់ផង ?

ចប់អក្ខរាវិធី ភាគទី ១

---

កាលបើបានរៀន "អក្ខរាវិធី (Orthographe)" ដែលជាគម្រោស្ដែងអំពីតួអក្សរ សម្រាប់ប្រើសរសេរ តាងជួសសម្លេងពាក្យ

www.elibraryofcambodia.org

និយមន័យ ហើយយកប្រើបានតែពីនោះមក គឺត្រូវតែដឹងដល់វិធីនិយាយ វិធីប្រើពាក្យសម្ដីខ្លួនខាងកណ្ដាលភាពផ្សេង ១ថា ពាក្យណាត្រូវទីនៅខាងមុខ ពាក្យណាត្រូវទីនៅខាងក្រោយ ពាក្យណាត្រូវទីនៅកណ្ដាល ពាក្យណាជាចំណែកណារបស់ពាក្យនិយាយ ដែលជាហេតុឱ្យកើតមានវេយ្យាករណ៍ឡើង ដើម្បីស្ដែងលក្ខការតាមលំដាប់ពាក្យនិយាយ ឱ្យដឹងជាក់ប្រាកដដល់របស់ដែលបង របស់ដែលប្រកប ។ល។ ក្នុងគម្រោកម្ពុជវេយ្យាករណ៍របស់យើង បានឱ្យឈ្មោះគម្រោបែបនេះថា: “វចីវិភាគ (Etymologie)” ។

ពាក្យថា “វចីវិភាគ” ជាឈ្មោះគម្រោកម្ពុជវេយ្យាករណ៍របស់យើង ហើយវចីវិភាគនេះ បើនឹងប្រែសេចក្ដីឱ្យឃើញស្ទើរស្ដប្រាកដទៅបានសេចក្ដីថា “គម្រោនិយាយអំពីចំណែករបស់ពាក្យ” ឬ “សាស្ត្រស្ដែងអំពីឫសគល់, គោលដារើករបស់ពាក្យ” ដូច្នោះ ពាក្យថាវចីវិភាគ គឺការចែកញែកពាក្យសំដីនោះឯង; វចីវិភាគជាគម្រោវេយ្យាករណ៍ដែលស្ដែងអំពីភាសាសម្រាប់ប្រើនិយាយស្ដីគ្នាថា មានលក្ខណមកយ៉ាងណា? កម្ពុជវេយ្យាករណ៍ ឬវេយ្យាករណ៍ខ្មែរ គឺតំរិះជាស្ដែងអំពីលក្ខណរបស់កម្ពុជភាសា ឬភាសាខ្មែរនោះឯង ។

www.elibraryofcambodia.org

# ភាគទី ២

## វចីវិភាគ (Etymologie)

---

### បទទី ៤

### លក្ខណៈកម្ពុជពាក្យ សំគាល់របស់ពាក្យ

ដែលហៅថា "ពាក្យ"នោះ បានដល់តួអក្សរដែលប្រកបផ្សំគ្នាឲ្យមានកើតជាសេចក្ដីស្ដាប់បានហៅថា "ពាក្យ" គឺភាសា, សំដី ឬប្រយោគសំដី ។

ពាក្យក្នុងគម្រោងវេយ្យាករណ៍នេះ មានសំគាល់បែងជា ៣ យ៉ាងគឺ

១- សំដៅសេចក្ដីថា : ព្យាង្គមួយៗ ពាក្យពួកនេះបានដល់ពាក្យក្នុងអក្ខរាវិធី ដែលមានព្យញ្ជនៈនិងស្រៈ ព្រមទាំងវណ្ណយុត្តិផ្សំចូលគ្នា ហើយកើតជាសម្លេងឡើង សម្លេងនោះឯងបញ្ចេញសូរមកម្ដងៗ ហ្នឹងទុកជាពាក្យមួយ ដូចដែលមានប្រើក្នុងគម្រោងអក្ខរាវិធីថា :

ក) ដំពាក្យ បានដល់ពាក្យថា : មាន, បាន, ចង់, ជួនជាដើម;

ខ) មតពាក្យ បានដល់ពាក្យថា : មក, ចក, ចខ ជាដើម

www.elibraryofcambodia.org

ទីនៃដែលមានប្រើក្នុងគម្រាបកេសុភាផ្នែកពាក្យវិលាសទីថា :

ក) ពាក្យគរុ បានដល់ពាក្យថា : មិន, មក, សង្ឃ, ស្រង់ ជាដើម;

ខ) ពាក្យលហុ បានដល់ពាក្យថា: កំ, ជំ, ល្អ, កេះ, បេះ ជាដើម;

ហើយទីនៃចំនួនពាក្យ ដែលរាប់ក្នុងវគ្គមួយ ១ ឬបទមួយ ១ ក្នុងកំណាព្យផ្សេងៗ ថា: ស្មោះឃ្លានោះមានប៉ុណ្ណោះពាក្យៗ , គាថាបាទនោះមានប៉ុណ្ណោះពាក្យៗ ដូច្នេះជាដើម ។

៤- សំដៅសេចក្ដីថា : ពាក្យច្រើនមួយចង្កោម គឺពាក្យក្នុង៤វគ្គ រាប់ថាជាពាក្យ១ ដូចដែលមានប្រើក្នុងពាក្យកូនបទលោ្មង ផ្សេងៗ គឺសំដៅសេចក្ដីថា : ពាក្យក្នុង៤វគ្គ ជាពាក្យមួយ ដូចជា:

“មកខ្ញុំនឹងពោលបទពៅ ដល់អន្តសាមលរឿងប្អូន ...”

ទាំងអស់នេះរាប់ថាជាពាក្យមួយ ។

៥- សំដៅសេចក្ដីថា សូរសម្លេងដែលខ្ញុំនិយាយចេញមក បានសេចក្ដីទៅជាអ្វីម្យ៉ាងៗ គឺសេចក្ដីត្រូវការរបស់អ្នកនិយាយ នោះបើជាប៉ុន្មានពាក្យក្ដីដោយ ក៏ហៅថា ពាក្យមួយម៉ាត់ ព្រោះថា

www.elibraryofcambodia.org

ពាក្យពួកខ្លះកំមានត្រឹមព្យាង្គមួយ ពាក្យពួកខ្លះកំមានច្រើនព្យាង្គ ដូចគួយ៉ាងតទៅនេះ៖

"នា" រាប់ថា ជាពាក្យមួយម៉ាត់បាន ដោយសំណាបដែលស្តាប់សេចក្តីបានថា "ពុធ" មានព្យាង្គ ១ ។

"នាក់" នេះរាប់ថាជាពាក្យមួយម៉ាត់បាន ដោយសំណាបដែលស្តាប់សេចក្តីបានថា "ខ្លួក, សំពៅ, កប៉ាល់" ជា២ព្យាង្គ ។

"នាឡិកា" នេះក៏រាប់ថាជាពាក្យមួយម៉ាត់បានដែរ ដោយសំណាបដែលស្តាប់សេចក្តីបានថា "ម៉ោង" ឬ "គ្រឿងសំគាល់ពេល" ជា ៣ ព្យាង្គ ។

## ព្យាង្គ (Syllabe)

តួអក្សរដែលប្រកបផ្សំចូលគ្នាជាពាក្យ តាមពាក្យដែលបានចង្អុលឲ្យឃើញជាតួយ៉ាងមកនោះ គប្បីឃើញបានថា បើទុកណាជាខ្នងហៅដោយកំណត់ថា ពាក្យមួយ ៗ នោះកំនៅតែមិនស្មើ ព្រោះថា ពាក្យខ្លះមានតែមួងក៏គ្រប់ពាក្យ ដូចពាក្យថា "នា" ជាដើម, ពាក្យខ្លះមានដល់ទៅ២ដង ទើបនឹងគ្រប់ពាក្យ ដូចពាក្យថា "នាវ៉ា"ជាដើម, ពាក្យខ្លះមានដល់ទៅ៣ដង ទើបបានគ្រប់ពាក្យ

www.elibraryofcambodia.org

ដូចពាក្យថា "នាឡិកា" ជាដើម, ពាក្យដែលផ្សំគ្នាដោយសំណាន (ការគាន) គឺចងនិងទីងច្រើនជងជាន់គ្នាដូច្នេះឯង ហៅថា ផ្សំគ្នាដោយព្យាង្គ (Syllabe) គឺអង្គរបស់ពាក្យ ឬសង្កាត់ពាក្យ មាន ៤ យ៉ាងគឺ

១- ពាក្យដែលអានចេញមកតែម្ដង ក៏គ្រប់ពាក្យដូចពាក្យថា: នៅ, ចាស់, ថ្លាស់ យ៉ាងនេះ ហៅថា ពាក្យមានព្យាង្គមួយ ឬមួយព្យាង្គ ឬកំព្យាង្គទោល ពុំនោះ ហៅថា ឯកព្យាង្គ (Monosyllabes);

២- ពាក្យដែលអានចេញមកដល់ទៅ ២ ដង ទើបគ្រប់ពាក្យ ដូចពាក្យថា: លំនៅ, ចំណាស់, បន្លាស់ យ៉ាងនេះហៅថា ពាក្យមានព្យាង្គ ២ ឬពីរព្យាង្គ ឬកំទ្វេព្យាង្គ (Dissyllabes) ;

៣- ពាក្យដែលអានចេញមកដល់ទៅ ៣ ដង ទើបបានគ្រប់ពាក្យ ដូចពាក្យថា: បម្រាជក, កន្ទាទូក, កន្ទុត្រ, ជំនោរស យ៉ាងនេះ ហៅថា ពាក្យមានព្យាង្គ ៣ ឬ ៣ ព្យាង្គ ឬកំត្រៃព្យាង្គ ឬថាត្រៃព្យាង្គ (Trisyllabes) );

៤- ពាក្យដែលអានចេញមកច្រើនដង តាំងពីបួនសង្កាត់ឡើងទៅ ទើបទីងគ្រប់ពាក្យបាន ដូចពាក្យថា: អំពិលអំពែក, គ្រលេង

www.elibraryofcambodia.org

គ្រលាន, ទោសានុទោស, ថេកនុគ្រោះ, កិច្ចានុកិច្ច ជាដើម ហៅថា ពាក្យមានព្យាង្គច្រើន ឬច្រើនព្យាង្គ ឬពហុព្យាង្គ (polysyllabes) ។

ពាក្យនេះ បើចែកចេញដោយល្អិតទៅទៀត ក៏មាន៤ យ៉ាងគឺ

១- មុខពាក្យ ពាក្យចំ ឬពាក្យចំពោះ (Sens propre) ពាក្យដែលមានសេចក្ដីត្រង់ៗ មិនប្រៀបធៀប ដូចជា: ចាក់ស្លុត គឺចាក់ចំនោះភ្នែកឲ្យគេតក់ស្លុត;

២- ឧបមាពាក្យ ពាក្យប្រៀប (Sens Figuré) ពាក្យដែលមានសេចក្ដីមិនត្រង់ចំពោះ គ្រាន់តែប្រៀបប្រដូច, ដូចជាសំដីសាញចាក់ស្លុត គឺសំដីដែលសាញពេកហួសទំនង, ជំពាក់ចាក់ស្លុត គឺជំពាក់ទ្រាក់ចាក់ស្រេះ ប្រហែលដូចគេចាក់បន្ទោះភ្នែកស្លុត;

៣- សុភាសិត ពាក្យទំនឹម (Proverbes) ពាក្យដែលផ្ទឹមនឹងពាក្យឯទៀត គឺពាក្យដែលលោកចាស់ជាប្រស្នា ប្រៀបផ្ទឹមទៅរកសេចក្ដីណាមួយ, ច្រើនតែជាពាក្យសុភាសិត, ដូចពាក្យមានដើមថា: ចិត្តជាទេវទត្ត មាត់ជាទេវតា, ឆ្មាមិននៅកណ្ដុរឡើងរាជ្យ;

៤- អន្តនាម វិបរីតពាក្យ ពាក្យផ្ទុយ (Antonymes) ពាក្យ

www.elibraryofcambodia.org

ដែលជាចំទាស់នឹងគ្នា ឬពាក្យផ្ទុយគ្នា, ដូចជា: ខ្ពស់ជាពាក្យផ្ទុយនឹងទាប, អក្រក់ជាពាក្យផ្ទុយនឹងល្អ, ខុសជាពាក្យផ្ទុយនឹងត្រូវ, បាបជាពាក្យផ្ទុយនឹងបុណ្យ, គុណជាពាក្យចំទាស់នឹងទោស,...;

៥- សុទនាម, វេវចនៈ, វេពាក្យ(១) (Synonymes) ពាក្យដែលប្រើផ្លាស់ប្តូរគ្នា ឬជំនួសគ្នាបាន គឺពាក្យដែលមានសូរសម្លេងខុសគ្នា តែមានសេចក្តីត្រូវគ្នា ឬស្របគ្នា, ដូចជា: ពេស្យា, វេសិយា, វេសី, នគរសោភិនី, លញ្ជិកា, រូបជីវិនី, រូបដក់, រូបូបជីវិនី, វណ្ណទាសី, គណិកា, សំផឹង, ស្រីពីងពាង, ស្រីខូច, ស្រីពេនវែង ទាំងអស់នេះប្រែថា "ស្រីផ្កាមាស" ដូចគ្នា;

៦- ហោមោសនាម(២) (Homonymes) ពាក្យដែលមានសូរសម្លេងដូចគ្នា តែអក្សរប្រកបខាងចុងខុសគ្នា នឹងមានសេចក្តីខុសគ្នា ដូចជា: ចណ្ឌ, ចន្ទ, ចន្ទន៍, ចាន់; វត្ត, វត្ស, វត្សរ៍; វ័ឍ, វត់; សត្វ, សត្យ, ស័ព, សាត់; បដ, បត់, បថ, បទ;...

៧- បរិនាម (Paronymes) ពាក្យដែលមានសំណួរគាន

---

(១). វេពាក្យ ហៅថា សទិសពាក្យ ក៏បាន ។ (២) ហោមោសនាម ហៅថា ភសទិសនាមក៏បាន ។

www.elibraryofcambodia.org

ស្រដៀងគ្នា តាំងពីព្យញ្ជនៈតួប្រកបខាងចុងក៏ប្រហែលគ្នា។ តែមានសេចក្ដីខុសគ្នា ដូចជា: ក្រាស=ក្រាស់, ប្រស់=ប្រុស, ប្រីក្សា=ប្រឹក្សា, ពំនិត=ពិនិត្យ, វិចិត្រ=វិជិត;...

## ឫសគល់របស់ពាក្យ

កម្ពុជពាក្យសុទ្ធ តាំងតែពីដើមមកនិយាយគ្នាជាព្យាង្គពោលតែមួយៗ ក៏មាន ដូចជា: ឪ, ម៉ែ, តា, យាយ, ទឹក, ភ្លើង, ខ្យល់, បង, ប្អូន, មីង, មា, ពូ ជាដើម; និយាយគ្នាជាទ្វេព្យាង្គក៏មាន ដូចជា: ឪពុក, ជីតា, ជីដូន, តាទើ, ប្រពៃ, ប្រាក់, ប្រាក់, អន្សម ជាដើម; និយាយគ្នាជាត្រីព្យាង្គក៏មាន ដូចជា: កន្ទាទូក, ទុក្ខ·សោក, ឧបោសថ, រាជបុត្រ, បរិសុទ្ធ, បរិបូណ៌ ជាដើម; និយាយគ្នាជាពហុព្យាង្គក៏មាន, ដូចជា: គ្រេលេងគ្រេលោង, រកាក់រអួល, រឡិករឡក់, រឡិងរឡង់, រឡិបរឡប់ ជាដើម; កម្ពុជពាក្យយើងនេះ មានដើមពាក្យតាំងពីឯកព្យាង្គ រហូតដល់ពហុព្យាង្គ តែបើទុកជាយ៉ាងនេះ ក៏នៅតែប្រើមិនគ្រប់គ្រាន់ ដូច្នេះបានជាមានជាក់ថែមពាក្យខ្លះពីខាងចុងនៃព្យាង្គនីមួយៗ ដើម្បីឱ្យបានប្រើគ្រប់គ្រាន់ឡើង បើតាមន័យនេះ ពាក្យត្រូវបែកចេញទៅជា ២ ទៀត គឺ មូលពាក្យ១

www.elibraryofcambodia.org

យោគពាក្យ ១ ។

## មូលពាក្យ

ពាក្យមូល ឬឫសគល់របស់ពាក្យ ឬក៏ពាក្យដើមនោះ បានដល់ពាក្យដែលមានសេចក្ដីចំពោះខ្លួន គឺមានសេចក្ដីជាប់ស្រេចក្នុងខ្លួន មិនចាំបាច់ថែមពាក្យដទៃមក ក៏ស្ដាប់បានកែម្ដង យ៉ាងនេះហៅថា មូលពាក្យ ឬមូលវចនៈ ដូចជា : ទៅ, មក, កណ្ដាស់, កណ្ដឹង, កណ្ដៀទៀ, កញ្ញា, ត្រលែងត្រលោង ជាដើម ។

## យោគពាក្យ

គឺពាក្យផ្សំ ឬពាក្យប្រកប បានដល់ពាក្យដែលយើងយកពាក្យមូលនោះមក ហើយកើតឡើងជាពាក្យមួយផ្សេងដោយឡែកទៀត ពាក្យផ្សំនោះ ទោះបើពាក្យមូលជាឯកព្យាង្គក្ដី ទ្វេព្យាង្គក្ដី ត្រីព្យាង្គក្ដី ពហុព្យាង្គក្ដី ឲ្យយកមករួមគ្នា បានជាពាក្យមួយផ្សេងដោយឡែក គឺខាងសំគាល់ផ្សេងគ្នាពីពាក្យមូល ហើយក៏ហៅថា ពាក្យផ្សំតាំងអស់ កាលបើផ្សំចូលគ្នាហើយ ក៏មានសំគាល់បានជា ៤ យ៉ាងគឺ :

១- មានសេចក្ដីខុសគ្នាពីសេចក្ដីដើម ដូចពាក្យមូលថា :

www.elibraryofcambodia.org

“ក្ដែ” នឹង “ស្រែង” ផ្សំចូលគ្នាជា “ក្ដែស្រែង” បានសេចក្ដីថា ឈើមួយយ៉ាងសម្បកក្រាស់សាច់ផូរជ្រោក ប្រើជាថ្នាំចង្អុយដំបៅដែលកើតដោយរបួស ឬរូសកោស; “សែន” នឹង “កាចិត្យ” ផ្សំចូលគ្នាជា “សែនកាចិត្យ” បានសេចក្ដីថា: ប្រពាលមួយយ៉ាងសន្ដានត្រាវ តែធាងនិងស្លឹកតូចជាងត្រាវ ។

៦. មានសេចក្ដីគង់នៅតាមរូបដើម គឺពាក្យផ្សំដែលយកពាក្យមូលច្រើនពាក្យ មករួមចូលគ្នាជាពាក្យមួយ ហើយមានសេចក្ដីគង់នៅតាមរូបដើម តែនាំទៅប្រើជាពាក្យផ្សេងដោយឡែកទៅខ្លះ ឬដើម្បីឲ្យមានសេចក្ដីឆ្ងាយទូលាយចេញទៅទៀតខ្លះ ដូចតួយ៉ាងពាក្យមូល “ក្អែក” នឹង “ខ្វាក់” ដែលជាពាក្យផ្សេងគ្នាដោយឡែកដោយយ៉ាង តែយកមករួមគ្នាចូលជាពាក្យមួយ ប្រើជាពាក្យគុណប្រាប់លក្ខណៈរបស់មនុស្ស នឹងសត្វថា: “មនុស្សក្អែកខ្វាក់, ពពែក្អែកខ្វាក់” ជាដើម ហើយតួយ៉ាងដទៃៗនៅមានគេទៅទៀតជាច្រើន ដូចជា:

ក្ដៅ-បាក់ តួយ៉ាង មនុស្ស ក្ដៅបាក់

ក្ដៅ-ចិត្ត ,, គេ ក្ដៅចិត្ត

www.elibraryofcambodia.org

កំ – ដោយ   ក្នុងយ៉ាង   អង្គុយកំដោយ ដេកកំដោយ

ជ្រុល – ខាន   ,,   ជ្រុលខានភក់ម៉ក់

ព្រោះថា   ,,   គេមិនចេះ ព្រោះថាមិនបានរៀន,...

ពាក្យផ្សំពួកនេះ ជួនកាលក៏នៅឃ្លាតៗ ពីគ្នា មានពាក្យដទៃនៅកណ្ដាលដូចជា: មិនបាន-ក៏ទេ, ទាំង-ទាំង ដូចក្នុងឃ្លា: [illegible]បាននៅជាមួយខ្ញុំក៏ទេ, គេរៀនទាំងលេខទាំងអក្សរ ទាំងនេះជាដើម ។

៣. ពាក្យផ្សំដែលយកពាក្យមូល មានរូប ឬសេចក្ដីស្រដៀងគ្នា មករួមជាពាក្យមួយ; ពាក្យអន្លូលនេះ ជួនកាលក៏មានសេចក្ដីប្រហែលគ្នានឹងពាក្យមូលដើម ជួនកាលក៏ប្លែកផ្សេងខ្លះទៅបន្តិចបន្តួច, ដូចជា: ខ្មៅៗ, សៗ, យឺតៗ, ឆាប់ៗ ដូច្នេះ មានសេចក្ដីខុសពីពាក្យមូលដែលមិនដូនគ្នាខ្លះបន្តិចបន្តួច គឺ "ខ្មៅៗ" សំដៅសេចក្ដីថា ខ្មៅខ្លះៗ ដូច្នេះជាដើម; មួយយ៉ាងទៀត ប្រើពាក្យមូលរូបមិនដូចគ្នា តែមានសេចក្ដីដូចគ្នាតែម្យ៉ាង រួមចូលគ្នាជាពាក្យផ្សំ ដូចជា: ពាក្យពេចន៍, ពាក្យសំដី, ថែរក្សា, ស្ដីថា, ទ្រព្យធន ដូច្នេះជាដើម;

៤. ពាក្យផ្សំដែលបង្រួញមកពីសេចក្ដីច្រើន ពាក្យពួកនេះបានដល់[illegible]ហៅថា សមាសនាម ឬ កន្ទិតនាម (មិនមាន

www.elibraryofcambodia.org

មិយាយក្នុងខាងមុខ) ដូចជា: "មនុស្សព្រៃ" បង្រួញមកពី "មនុស្សនៅក្នុងព្រៃ", "អ្នកក្រុង" បង្រួញមកពីពាក្យថា "មនុស្សនៅក្នុងក្រុងពេញ" ជាដើម រួមទាំងពាក្យ អាការនាម ដែលមានពាក្យថា "ការ" ឬ "សេចក្ដី" នាំមុខ ដែលមិនមានពោលក នៅក្នុងខាងមុខផង ។

ពាក្យផ្សំពួកនេះ មានពាក្យដូចតទៅនេះ ប្រកបនៅខាងដើមគឺ

"អ្នក" ដូច អ្នកក្រុង, អ្នកស្រែ, អ្នកប្រែ, អ្នកចំការ ។ល។

"ជាង" ដូច ជាងមាស, ជាងប្រាក់, ជាងដែក, ជាងឈើ ។ល។

"ការ" ដូច ការស៊ី (១) (សំទី), ការនៅ (លំនៅ), ការដេក ។ល។

"សេចក្ដី" ដូច សេចក្ដីស្លាប់, សេចក្ដីកើត, សេចក្ដីគិត ។ល។

"គ្រឿង" ដូច គ្រឿងប្រើ, គ្រឿងដៃ, គ្រឿងសរសេរ ។ល។

"របស់" ដូច របស់ស៊ី, របស់លេង, របស់ប្រើ, ។ល។

"ទី" ដូច ទីដេក, ទីសង្ឃឹម, ទីនៅ, ទីតាំង, ។ល។

ប៉ុណ្ណេះជាដើម ។

ពាក្យអម្បាលនេះ ច្រើនប្រើប្រកបជាក់ខាងដើមពាក្យផ្សំពួក

(១) កិរិយាសព្ទ "ស៊ី" ពាក្យនាមជា "សំទី" ប្រើជាចំណីមិនស៊ីនឹងកិរិយា ។

www.elibraryofcambodia.org

នេះតែម្យ៉ាង នឹងញែកប្រើចំពោះពាក្យមួយៗ ពោលៗ មិនបាន ដូចនឹងប្រើថា: "ខ្ញុំឃើញការ" ដូច្នេះមិនបានសេចក្ដី ត្រូវប្រើប្រកបជាមួយនឹងពាក្យដទៃថា: "ការធ្វើ"(១) ឬ "ការឈរ" ទើបបានសេចក្ដីពេញ ព្រោះហេតុដូច្នោះ បានជាភ្ជាប់រួមគ្នាចូលជាពាក្យ ហើយពាក្យផ្សំអម្បាលនេះ ចែកចេញទៅជាចំណែកផ្សេងដូចនាម សព្វនាម ។ល។ បានដូចគ្នានឹងមូលពាក្យនោះដែរ ។

## ឥក្ខាសាបទ ទី ១ (Exercice)

១— វិបរិភាគ ប្រែថាម៉េច? ក្នុងទីនេះសំដៅសេចក្ដីដល់អ្វី ?

២— ហេតុដូចម្ដេចបានជាចាត់តម្រា អក្ខរវិធី ទុកជាខាងដើមតម្រាវិបរិភាគ ?

៣— អ្វីហៅថា ពាក្យ? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូរអធិប្បាយ!

៤ "ពាក្យ" ក្នុងតម្រាវេយ្យាករណ៍ទូទៅ សំគាល់សេចក្ដីបានប៉ុន្មានយ៉ាង? យ៉ាងណាខ្លះ? ហើយក្នុងវិបរិភាគនេះ សំគាល់សេចក្ដីជាអ្វី?

---

(១) កិរិយាសព្ទនេះ ប្រើទើរក៏បាន ប្រើជានាមទំហើ ។ ប្រើធ្វើត្រូវជាងធ្វើ ព្រោះនាមថា ទំហើ មិនមែនអំពើទេ ។

www.elibraryofcambodia.org

៥– ព្យាង្គ ប្រែដូចម្ដេច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់ ហើយអធិប្បាយ ។

៦ - ចូររកពាក្យឯកព្យាង្គឲ្យបាន ១០ ពាក្យ, ពាក្យទ្វេព្យាង្គ៥ ពាក្យ, ពាក្យត្រីព្យាង្គ ៤ ពាក្យ, ពាក្យពហុព្យាង្គ គឺពាក្យមាន ព្យាង្គ ៤ ឲ្យបាន ៣ ពាក្យ, ពាក្យមានព្យាង្គ ៥ ឲ្យបាន ២ ពាក្យ,ពាក្យមានព្យាង្គ ៦ ឲ្យបាន ១ ពាក្យ តែប្រយ័ត្នកុំឲ្យប្រទាំ នឹងពាក្យច្រើនដែលនៅរៀងគ្នា !

៧– មូលពាក្យនោះ គឺពាក្យចំណែកណា? យោគពាក្យគឺ ពាក្យចំណែកណា? ចូររកតួយ៉ាងក្នុងមួយ ១ ឲ្យបាន ៥ ពាក្យ។

៨ ពាក្យផ្សំមានលក្ខណៈប៉ុន្មានយ៉ាង? យ៉ាងណាខ្លះ?

៩– យោគពាក្យដែលយកមូលពាក្យដូចគ្នា មករួមគ្នាចូលជា ពាក្យមួយនោះ មានប៉ុន្មានយ៉ាង? យ៉ាងណាខ្លះ? នឹងញែកចេញ ជាមូលពាក្យមួយម៉ាត់ នឹងដាក់ជាយោគពាក្យមិនបានឬ? ព្រោះ ហេតុអ្វី?

១០– ពាក្យសមាស ប្រែថាម៉េច? បានដល់ពាក្យចំណែក ណា? អធិប្បាយហើយរកតួយ៉ាងមកប្រៀបធៀបផង។

www.elibraryofcambodia.org

១៧– ពាក្យសមាសផ្សេងពីពាក្យផ្សំត្រួតគ្នាដែរ យ៉ាងណា?

១៨– ចូរប្រាប់ពាក្យតទៅនេះថា ណាជាពាក្យមូល ទីង ណាជាពាក្យផ្សំយ៉ាងណា? គឺយ៉ាងទី១ ឬទី២ ឬក៏ទី៣ ពុំនោះទី៤, ព្រោះហេតុអ្វី?

ឈើគូស, ឈើពាល, គ្រឿងប្រកប, មនុស្សកាច, សា-កយ, ដាវរឿង, រឿយៗ, ទីស្នាក់, គ្រឿងផឹក, លក់មុខ, កិតអាចម៍, កន្ទ្រង់ប្រេង, អ្នកប្រាជ្ញ, អ្នកស្រុក, សាលាវត្ត, យ៉ាងណាក៏ដោយ ៗ

(ឥត្ថុសភាពថ យ៉ាងទី១-២នេះ គួរតែពាក្យឲ្យគេរៀន(អ្នករៀន) ចេះឲ្យច្រើន ព្រោះជាប្រយោជន៍ក្នុងការញែកពាក្យ តែកុំឲ្យលំបាក ហួសចំណោះដែលបានអធិប្បាយក្នុងបទនេះ ជាហេតុនឹងធ្វើឲ្យក័ន្ត ច្រឡំហើយធុញទ្រាន់)

## បទទី ៨

## លក្ខណៈពាក្យផ្សេងៗ

ពាក្យដែលនិយាយគ្នាក្នុងភាសាមួយៗ មានមិនមែនតិចទេ សុទ្ធតែកប់ដោយពាន់ ដោយម៉ឺន ដោយសែនជាប្រមាណ; ដូច្នេះ ទុះទៅតាំងពីកតលោក, កម្ពុជភាសាក៏មានពាក្យសំដីសម្រាប់

www.elibraryofcambodia.org

និយាយជាច្រើនដូចគេ ដូច្នោះដែរ បានចង្អុលបញ្ជាក់ឲ្យចូលចិត្ត មកហើយថា ដែលហៅថា "ពាក្យ" នោះ ព្រោះអាស្រ័យសំដីដែលជាភាសា សំគាល់សេចក្ដីចូលចិត្តបានយ៉ាងណាមួយ បើប្រសិនជាសំគាល់សេចក្ដីយ៉ាងណាមួយមិនបាន ស្ដាប់មិនចូលចិត្តហើយ នោះមិនគួរហៅថា "ពាក្យ" ក៏មិនកើត ព្រោះហេតុដូច្នោះ ការដែលមិនរៀនឲ្យស្គាល់លក្ខណៈពាក្យសំដី ដែលមាននៅក្នុងភាសានោះ ត្រូវសិក្សាឲ្យចូលចិត្តលក្ខណៈថា ពាក្យយ៉ាងណា មានសេចក្ដីសម្រាប់សំគាល់យ៉ាងណានោះជាដើមទៅ ។

ពាក្យសម្រាប់និយាយក្នុងភាសា, កាលបើពិចារណាមើលដោយលក្ខណៈទៅ ក៏ឃើញថាផ្សេងគ្នាដល់ទៅ ១០ចំណែកគឺ

១- "នាម" ជាពាក្យសម្រាប់ប្រាប់ឈ្មោះមនុស្ស, សត្វ និងរបស់ជាដើម;

២- "គុណ" ជាពាក្យសម្រាប់ថែមនាមនិងសព្វនាមឲ្យមានសេចក្ដីប្លែកចេញទៅ;

៣- "គុណវិសេសនៈ" ជាពាក្យសម្រាប់ថែមពាក្យគុណឲ្យមានសេចក្ដីប្លែកផ្សេងទៅទៀត;

www.elibraryofcambodia.org

៤- "សព្វនាម" ជាពាក្យសម្រាប់ប្រើជំនួសឈ្មោះផ្សេងៗ;

៥- "កិរិយា" ជាពាក្យសម្រាប់ប្រាប់អាការកិរិយារបស់មនុស្ស, សត្វជាដើម;

៦- "កិរិយាវិសេសនៈ" ជាពាក្យសម្រាប់ប្រកបពាក្យកិរិយាឲ្យមានសេចក្ដីផ្សេងចេញទៅ;

៧- "កិរិយាកិរិយាវិសេសនៈ" ជាពាក្យសម្រាប់ប្រកបពាក្យកិរិយាវិសេសនៈ ឲ្យមានសេចក្ដីប្លែកជាងប្រក្រតីទៅទៀត;

៨- "បុព្វបទ" ជាពាក្យសម្រាប់នាំមុខនាមនិងសព្វនាម;

៩- "សន្ធាន" ជាពាក្យសម្រាប់ភ្ជាប់សេចក្ដីឲ្យជាប់គ្នា;

១០- "ឧទាន" ជាពាក្យសម្រាប់ប្រាប់សំឡេងផ្សេងៗ ។

## ១- នាម (Le nom)

បណ្ដាពាក្យដែលជាឈ្មោះនៃវត្ថុ ឬរបស់គ្រប់យ៉ាងគ្រប់ពពួក ចាត់ជាពពួក ១ ហៅថា នាម ។ នាមនេះបើប្រែចេញមកឲ្យចំ គឺ "ឈ្មោះ" បានដល់ពាក្យសម្រាប់ប្រាប់ឈ្មោះរបស់ ដែលមានរូប ដូច មនុស្ស សត្វ ផ្ទះ ស្រុក ប្រទេស ក្រុង ជាដើមក្ដី ឬដែលឥតរូប ដូច វេលា អាយុ ចិត្ត អំណាច បាប បុណ្យ ជាដើមក្ដី រាប់ថាជានាម

www.elibraryofcambodia.org

តាំងអស់, ព្រោះពាក្យថា មនុស្ស ក៏ជាឈ្មោះមនុស្សយើងនេះឯង, សត្វ ក៏ជាឈ្មោះតិរច្ឆាន ១ ចំពួកនៅក្នុងព្រៃឬក្នុងស្រុក, ផ្ទះ ក៏ជាឈ្មោះទីកន្លែងដែលមនុស្សយើងនៅអាស្រ័យ, ស្រុក ក៏ជាឈ្មោះតំបន់ដែលគេមានតាំងផ្ទះសម្បែងមានមនុស្សអាស្រ័យនៅជាច្រើនផ្ទះ, ប្រទេស ក៏ជាឈ្មោះដែនដែលមានប្រជាជនអាស្រ័យនៅ មានរាជការ ឬរដ្ឋាភិបាលតាំងទីកន្លែង ស្ដេចផ្ដាច់លើអាណាប្រជារាស្ត្រជាដើម, ក្រុង ក៏ជាឈ្មោះទីប្រជុំជនដែលមានមនុស្សកុះករ មានផ្សារលក់ចេញទិញចូលជាដើម ។ ពាក្យទាំងនោះសុទ្ធតែជាឈ្មោះសម្រាប់ហៅរបស់ឯណានិមួយ គឺថាជាឈ្មោះរបស់ណានិមួយទាំងនោះ បានជាហៅថា "នាម" ។

ព្រោះហេតុដូច្នោះ គប្បីសង្កេតថា ពាក្យណាដែលជាឈ្មោះសម្រាប់ហៅរបស់ឯណា ពាក្យនោះនៅក្នុងពួកនាមទាំងអស់ ដូចពាក្យក្នុងប្រយោគថា: "តាមីស្លៀកខោ កាន់ក្រប៊ី ជិះសេះនាំប្រពន្ធទៅស្រុកគងពិសី" ពាក្យថា: តាមី ខោ ក្រប៊ី-សេះ ប្រពន្ធ ស្រុកគងពិសី នេះសុទ្ធតែជានាមទាំងអស់, ព្រោះ តាមី ក៏ជាឈ្មោះរបស់មនុស្ស, ខោ ក៏ជាឈ្មោះរបស់គ្រឿងស្លៀក, ក្រប៊ី ក៏ជាឈ្មោះ

www.elibraryofcambodia.org

របស់គ្រឿងកាប់ចាក់, សេះ ក៏ជាឈ្មោះរបស់សត្វជាពាហនៈសម្រាប់ជិះ, ប្រពន្ធ ក៏ជាឈ្មោះរបស់ស្រីដែលមានប្ដី, ស្រុកគងពិសី ក៏ជាឈ្មោះរបស់ប្រទេស ១ កន្លែង ។ បើពាក្យណាមិនមែនជាឈ្មោះទេ, ពាក្យនោះក៏មិនមែនជានាមដែរ, គប្បីសន្និដ្ឋានដោយសង្ខេប ៗ ថា:

“ពាក្យដែលប្រើជាឈ្មោះគឺ ‘នាម’

‘នាម’ គឺពាក្យដែលប្រើជាឈ្មោះ” ។

នាមបានអធិប្បាយមកហើយពីខាងដើមថា: អ្វីជានាម ? បានដល់អ្វីខ្លះ ? បានពន្យល់ដោយសព្វគ្រប់ល្មមតែស្ដាប់បាន; តែនាមនោះ បើចែកដោយល្អិតទៅទៀត ក៏មានដល់ទៅ ១៤ យ៉ាងគឺ

១– សាមាន្យនាម ឬ សាធារណនាម (Nom Commun);

២– វិសាមាន្យនាម ឬ អសាធារណនាម (Nom Propre);

៣– គុណនាម ;

៤– អាការនាម ;

៥– កិរិយានាម ;

៦– ឋាននាម ;

៧– ករណនាម ;

www.elibraryofcambodia.org

៨- ការកនាម ;

៩- រូបនាម (Nom Concret au Physique) ;

១០- អរូបនាម (Nom Abstrait) ;

១១- សមូហនាម (Nom Colbetif) ;

១២- លក្ខណនាម ;

១៣- សមាសនាម (Nom Composé) ;

១៤- តទ្ធិតនាម ។

សាមាន្យនាម ឬ សាធារណនាម (Nom Commun)

នាមដែលគ្រាន់តែសម្គាល់ឈ្មោះរបស់ ដែលមានជីវិត ឬមិនមានជីវិតមិនប្រាកដ នៅសាធារណៈទូទៅទៀតបាន ដូចពាក្យថា: មនុស្ស, សត្វ, ដែន, ក្រុង ជាដើម គ្រាន់តែមានពាក្យឲ្យសង្កេតបានថាជានាម តែនៅមិនទាន់ប្រាកដនៅឡើយ ព្រោះថា នាមតែមនុស្សជាតិណា ក៏ហៅថា មនុស្ស បានទាំងអស់ ។ នាមតែសត្វអ្វីនោះជាគោ, ក្របី, ដំរី, សេះ, ជ្រូក, មាន់ ក៏ដោយ ក៏ហៅថាសត្វ បានទាំងអស់ ។ នាមតែដែនណា ក៏ហៅថា ដែន បានទាំងអស់ ។ នាមតែក្រុងណារបស់ប្រទេសនា ក៏ហៅថា ក្រុង

www.elibraryofcambodia.org

បានទាំងអស់ ។ មិនមានកំណត់ចុះចំពោះថា មនុស្សជាក់នេះ, សត្វនេះ ទីដីកន្លែងនេះជាដើម ។ នាមដែលនៅសាធារណៈទូទៅទៀតបាន ដូច្នេះហៅថា "សាមាន្យនាម ឬ សាធារណនាម (Nom Commun)" ។

## វិសាមាន្យនាម ឬ អសាធារណនាម (Nom propre)

នាមដែលសំដៅឈ្មោះប្រាកដ មិនសាធារណៈទូទៅទៀតបាន គឺពាក្យនាមដែលជាឈ្មោះចំពោះ ដែលសន្មតតាំងឡើងសម្រាប់ហៅ មនុស្ស, សត្វ ទីដីរបស់ខ្លះ ដើម្បីឲ្យដឹងជាក់ប្រាកដថា មនុស្សនេះ, សត្វនេះ, របស់នេះជាដើម ហៅថា "វិសាមាន្យនាម ឬអសាធារណនាម (Nom propre)" ដូចគួយ៉ាងឈ្មោះ មនុស្ស សៅ, មៅ, មុំ, មាស; ឈ្មោះបណ្ឌសក្តិញាណភិរម្យ, ឧត្តម-ចិត្ត; ឈ្មោះនាមត្រកូល ភាវិច្ចវង្ស, ជិនវង្ស, វរវង្ស; ឈ្មោះសត្វ ដូច ដំរី-មង្គល, បុស្សព្រហ្មសិទ្ធិ, ស្រីស្រស់; ឈ្មោះស្រុក-មង្គលបុរី, វង្សបុរី, នគរបុរី, ព្រៃស្តី; ឈ្មោះរបស់ដូច កប៉ាល់-បម្រាសក្តិ, ភាព, ស្រីពេម, តម្រង់ពង្ស ទីនៃប្រកាចិក្ស, បទ្រុំ, អង្គារ ប៉ុណ្ណោះ ជាគួយ៉ាង ហើយវិសាមាន្យនាមដែលប្រើក្នុងកម្ពុជភាសាយើងនេះ

www.elibraryofcambodia.org

ដោយច្រើន ត្រូវមានសាមាន្យនាមនៅខាងដើមផងដូច នាយ-សៅ លោក-ញាណកិរម្យ, ជំរ-មង្គល, ប្រុក-មង្គលបុរី, ថៃ្ងតាចិត្យជាដើម; វៀរលែងតែពាក្យខ្លះដែលមានប្រើជាច្រើន ទាល់តែដឹងគ្រប់គ្នាហើយ ទើបប្រើហៅទទេៗទៅបាន ដូចពាក្យនិយាយថា "សៅម(១)នេះ, ខ្ញុំនឹងទៅ ភ្នំពេញ, គេមពីបាត់ដំបង" ដូច្នេះជាដើម ។

វិធីសង្កេត វិសាមាន្យនាមនេះ ត្រូវជាពាក្យប្រើសម្រាប់មនុស្សម្នាក់, សត្វ១តួ និងរបស់មួយរបស់ ហេតុណាជាឈ្មោះរបស់ពួក,គណៈ ក៏ត្រូវតែជាពួកមួយ, គណៈមួយ ដូច"កម្ពោជៈ" សំគាល់សេចក្ដីដល់កម្ពោជៈជាតិមួយ និង"សាមគ្គសមោសរ" នេះ ក៏សំគាល់សេចក្ដីដល់ទីសមោសរនោះតែ១កន្លែង ហេតុណាជានឹងមានឈ្មោះស្របគ្នាខ្លះ ក៏គង់តែសំគាល់សេចក្ដីចំពោះមនុស្ស, ចំពោះរបស់ មិនទូទៅដល់គ្នានឹងគ្នាបាន ប្រសិនបើនៅជិតគ្នាក៏ត្រូវថែមបរិវារ ឬប្រាប់គ្រឿងសំគាល់ខាងចុងឈ្មោះ ឲ្យសង្កេតបានថាៈ មនុស្សនេះ របស់នេះ ដូចនាយ-ម៉ុក(តូច),នាយ-ម៉ុក(ធំ),

(១) ពាក្យ "ម" នេះ ដែលធ្លាប់ប្រើមកហើយថា "មក" តែឃើញថាប្រើ "ម" ញយជាង សូមមើលក្នុងពាក្យផ្នែកកិរិយានិងនាម ក្នុងខាងមុខ ។

www.elibraryofcambodia.org

វត្តព្រះធាតុ(ក្រោម), វត្តព្រះធាតុ(លើ) ជាដើម ។

## គុណនាម

នាមដែលជាឈ្មោះរបស់ដំណើរមួយយ៉ាង ដែលធ្វើឲ្យចំរើនកើនឡើង ហៅថា គុណនាម ។ គុណនាមនេះ បើនិយាយឲ្យចូលចិត្តងាយ ៗទៅ ក៏គឺពាក្យគុណដែលយកមកប្រើធ្វើជានាមនោះឯង គឺកំណើតរបស់ពាក្យដើមដំបូងនោះ ជាគុណសុទ្ធ មិនមាននាមទេ តែអ្នកប្រាជ្ញកម្ពុជៈ បានបង្កើតឲ្យមានជានាមឡើង ដើម្បីឲ្យសម្បូណ៌នាមឡើង និងងាយប្រើក្នុងកម្ពុជភាសា ។

ដើម្បីឲ្យងាយចូលចិត្តក្នុងរឿងគុណនាមនោះ ចូរសង្កេតមើលឧទាហរណ៍តទៅនេះ ៖

| ពាក្យគុណ | ចេញទៅជា | គុណនាម |
|---|---|---|
| ខុស | ” | កំហុស |
| ខ្មៅ | ” | កំមៅ |
| ខូច | ” | កំហូច |
| ខិល | ” | កំហិល |
| ខ្ពក | ” | កំបក |

www.elibraryofcambodia.org

| គុណនាម | ចេញទៅជា | ពាក្យគុណ |
|---|---|---|
| ខ្ចី | ” | កំចី |
| ខ្ជិល | ” | កំជិល |
| ខ្ពស់ | ” | កំពស់ |
| ខ្លាំង | ” | កំលាំង |
| ខ្សោយ | ” | កំសោយ |
| ខ្សត់ | ” | កំសត់ |
| ក្រ | ” | កំរ |
| ក្រាស់ | ” | កំរាស់ |
| ស្ដើង | ” | សំដើង |
| ទាប | ” | ទំនាប |
| ខ្មុំ | ” | កំមុំ |
| ខ្លោះ | ” | កំលោះ |
| បោច | ” | បំណោច |
| ពោក | ” | បំពោក |
| ឆ្កួត | ” | បំកួត |

www.elibraryofcambodia.org

| គុណនាម | [illegible] | [illegible]គុណ |
|---|---|---|
| តូច | [illegible] | តំណូច |
| ធំ | [illegible] | ទំហំ |
| វ្ដែក | ,, | ចំវែក |
| ធាត់ | ,, | ចំធាត់ |
| ស្គម | ,, | សំគម |
| ជូរ | ,, | ជំនូរ |
| បត់ | ,, | បំណត់ |
| ជ្រៅ | ,, | ជម្រៅ |
| ស្កក | ,, | សំកក |

អម្បាលនេះជាដើម ពាក្យសង្កត់ខាងមុខថា: ខ្ពុស, ខ្មៅ, ខ្ចូច, ខិល, ខ្ចក, ខ្ចី, ខ្ជិល, ខ្ពស់, ខ្លាំង, ខ្សោយ, ខ្សត់, ក្រ, ក្រាស់, ស្ដើង, ពាប, ខ្ទំ, ខ្វោះ, ហោច, ធោក, ឆ្ងត់, តូច, ធំ, វ្ដែក, ធាត់, ស្គម, ជូរ, បត់, ជ្រៅ, ស្កក ទាំងអស់នេះ ជាពាក្យគុណៗ ពាក្យសង្កត់ខាងក្រោយថា: កំហុស, កំមៅ, កំហូច, កំហិល, កំបក, កំបី, កំជិល, កំពស់, កម្លាំង, កំសោយ, កំសត់, កម្រ,

www.elibraryofcambodia.org

កម្រាស់, សំពើង, ទំនាប, កំពុំ, កំលោះ, បំណោច, បំហោក, បំកួត, តំណូច, ទំហំ, ទំពែក, ទំហាត់, សំគម, ជំនូរ, បំណាក់ ជម្រៅ, សំកក ទាំងនេះឯង ដែលហៅថា "គុណនាម" ដោយហេតុយកពាក្យដែលចេញមកពីគុណធើជានាម ។ ពាក្យដែលជាគុណនាមនេះ និយាយ ឬសរសេរបានតែត្រឹមសព្ទប៉ុណ្ណោះឯង នឹងយកពាក្យដទៃមកដាក់ថែមថា: សេចក្ដីកំហុស, សេចក្ដីកំហូច, សេចក្ដីកំផិល ដូច្នេះជាដើម មិនបានជាដាច់ខាត, ព្រោះពាក្យថា "សេចក្ដី" ឬ"ការ" សម្រាប់យកមកភ្ជាប់ខាងដើមសព្ទដែលជាគុណ ឬកិរិយាឲ្យក្លាយទៅជានាម, ចុះបើពាក្យថា: កំហុស, កំហូច, កំផិលជាដើមនោះ ជានាមស្រេចទៅហើយ ទៅយក " សេចក្ដី " ឬ " ការ " នោះមកដាក់ឲ្យក្លាយទៅជាអ្វីទៀត ?

## អាការនាម

ពាក្យដែលជាឈ្មោះ នៃលក្ខណៈជាគ្រឿងសំគាល់, ជាគ្រឿងសង្កេត ឬសេចក្ដីប្រាកដកើតផ្សេងៗ នៃមនុស្ស, សត្វ នឹងរបស់ដែលជាប់មកអំពីពាក្យគុណ ហៅថា "អាការនាម" ។ អាការនាមនេះ បើនិយាយឲ្យឆ្ងាយចូលចិត្តទៅ ក៏គឺនាមមួយយ៉ាង

www.elibraryofcambodia.org

ដែលយកពាក្យគុណមកប្រើធ្វើជានាម គឺថាពាក្យដែលនៅជាគុណសុទ្ធ មិនទាន់ក្លាយទៅជាគុណនាមនៅឡើយ ហើយត្រូវការយកមកប្រើជានាមនោះ លោកឲ្យយកពាក្យពីរម៉ាត់គឺ "ការ" និង "សេចក្ដី" ណាមួយក៏បាន យកមកដាក់ខាងដើមពាក្យដែលជាគុណនោះ ពាក្យគុណនោះឯង ក៏អាចនឹងប្រើជានាមបាន ។ ពាក្យគុណសុទ្ធដែលយកពាក្យថា "ការ" ឬ "សេចក្ដី" មកដាក់ខាងដើមឲ្យទៅជានាមនេះឯង ហៅថា "អាការនាម" ។ ដូចពាក្យគុណថា: ល្អ, អាក្រក់, ត្រូវ, ខុស, ខ្ពស់, ទាប, ស្គម, ធាត់, ខ្ជិល, ស, ខ្មៅ, នេះជាគុណសុទ្ធ យកពាក្យថា "សេចក្ដី" មកដាក់ខាងដើមថា: សេចក្ដីល្អ, សេចក្ដីអាក្រក់, សេចក្ដីត្រូវ, សេចក្ដីខុស, សេចក្ដីខ្ពស់, សេចក្ដីទាប, សេចក្ដីស្គម, សេចក្ដីធាត់, សេចក្ដីខ្ជិល, សេចក្ដីស, សេចក្ដីខ្មៅ ឬយកពាក្យ "ការ" មកដាក់ខាងដើមថា: ការល្អ, ការអាក្រក់, ការត្រូវ, ការខុស, ការខ្ពស់, ការទាប, ការស្គម, ការធាត់, ការខ្ជិល, ការស, ការខ្មៅ នេះឯងហៅថា "អាការនាម" ។ អាការនាមនេះក៏មានចំនួនប្រហែលគ្នានឹងពាក្យផ្សេងៗ ដែលមាន "សេចក្ដី" ឬ "ការ" នៅខាងដើម តែចំពោះតែពាក្យដែលជាគុណនោះដែរ ។

www.elibraryofcambodia.org

## កិរិយានាម

នាមដែលជាឈ្មោះនៃដំណើរប្រាប់ទំហើ, លំនាំ ឬស្ថានហេតុឲ្យសម្រេចកិច្ចការនោះ ឬសេចក្តីកើតប្រាកដផ្សេងៗ នៃមនុស្ស, សត្វទីទៃរបស់ដែលជាប់មកអំពីពាក្យកិរិយា ដូចពាក្យថា ការស៊ី, ការនៅ, សេចក្តីស្លាប់, សេចក្តីទៅ, សេចក្តីមក, សេចក្តីនាំ អម្បាលនេះជាដើមហៅថា "កិរិយានាម" ។ ឯពាក្យកិរិយានាមនេះ ត្រូវតែយកពាក្យថា "ការ" ឬ "សេចក្តី" នាំមុខជាដកបខានមិនបាន ។

កិរិយានាមនេះ ក៏មានទំនងដូចគ្នានឹងគុណនាមដែរ ព្រោះត្រូវមានពាក្យថា "ការ, សេចក្តី" នៅខាងដើមជាដរាប ដែរ តែគុណនាម "ការ" ឬ "សេចក្តី" ត្រូវនាំមុខពាក្យគុណ, ឯគុណកិរិយានាមនេះ "ការ" ឬ "សេចក្តី" ត្រូវនាំមុខពាក្យកិរិយាវិញប៉ុណ្ណោះ ពាក្យកិរិយាសព្វៗនោះឯង បើកាលណាយើងត្រូវការយកមកប្រើជានាម គឺឲ្យយើងយកពាក្យថា "ការ" ឬ "សេចក្តី" ណាមួយមកដាក់ភ្ជាប់ពីខាងមុខកិរិយានោះ, កិរិយានោះក៏ក្លាយទៅជានាមស្រេច ហៅថា "កិរិយានាម" ហ្នឹងឯង, ដូចពាក្យកិរិយាសព្វថា: ដើរ, ដេក, ឈរ, អង្គុយ, ស៊ី, ផឹក,

www.elibraryofcambodia.org

ស្តាប់, គិត, ជឿ, ឲ្យ, ទៅ, នៅ, មក ប៉ុណ្ណោះជាដើមនេះជាពាក្យកិរិយាសព្ទ, បើកាលណាយើងដំឡើងមកជានាមនោះ យើងត្រូវយកពាក្យទាំង២ នាក់ណាមួយ មកដាក់ខាងដើមនាំមុខកិរិយាទាំងនោះ [illegible] ការដើរ, ការដេក, ការឈរ, ការអង្គុយ, ការស៊ី, ការផឹក ការស្តាប់, ការគិត, ការជឿ, ការឲ្យ, ការទៅ, ការនៅ, ការមក, ឬ សេចក្ដីដើរ, សេចក្ដីដេក, សេចក្ដីឈរ, សេចក្ដីអង្គុយ, សេចក្ដីស៊ី, សេចក្ដីផឹក, សេចក្ដីស្តាប់, សេចក្ដីគិត, សេចក្ដីឲ្យ, សេចក្ដីទៅ, សេចក្ដីនៅ, សេចក្ដីមក ។ កិរិយាណាដែលមានពាក្យថា "ការ" ឬ "សេចក្ដី" នាំមុខដូច្នេះឯង កិរិយានោះហៅថា "កិរិយានាម" ។

ពាក្យកិរិយានាមទាំងអស់ ត្រូវមានពាក្យកិរិយាប្រចាំជាលក្ខណ៍ហើយមានពាក្យ "ការ" ឬ "សេចក្ដី" ប្រកបនៅខាងមុខជាដរាប ទើបរាប់ថាជាកិរិយានាមបាន បើមិនមានពាក្យកិរិយានៅប្រចាំជាលក្ខណ៍ផងទេ បើទុកណាជាគឺងមានពាក្យថា "ការ" ឬ "សេចក្ដី" នាំមុខក៏ដោយ ក៏មិនរាប់ថាជាកិរិយានាមឡើយ, ដូចគ្នាយ៉ាងថា: ការផ្ទះ, ការស្រុក, ការប្រែ, ការព្រៃ, ការថ្នល់, ការកផការ, ការបំការ ជាដើម នេះបាត់ជា "នាមនាម" ទៅវិញ

www.elibraryofcambodia.org

មិនមែនជា "កិរិយានាម" ឡើយ ។

## នាមនាម

ឈ្មោះដែលជាឈ្មោះនៃវត្ថុរបស់គ្រប់យ៉ាងគ្រប់ចំពូក ហៅថា "នាមនាម គឺឈ្មោះរបស់ឈ្មោះ ឬ នាមរបស់នាម" ។ នាមនាមនេះ បើនិយាយឲ្យចូលចិត្តឆាប់ៗ ទៅ គឺពាក្យនាមដែលយ.ម.(១) ប្រើធ្វើជាពាក្យនាមមួយជាន់ទៀតនោះឯង គឺកំណើតរបស់ពាក្យដើមនោះជានាមនៅក្នុងខ្លួនស្រេចទៅហើយ តែលោកយ.ពាក្យនាមនោះឯង ម.បញ្ចេញឲ្យចេញទៅជាពាក្យនាមមួយជាន់ទៀត ដូច្នេះបានជាហៅពាក្យនាមបែបនេះថា "នាមនាម" ។ នាមដើមរបស់នាមនាមបែបនេះ ច្រើនតែជាសាមាន្យនាម ចែកចេញជា២យ៉ាងទៀត គឺ ករណនាមនាម ១, ការកនាមនាម ១ ។

ករណនាមនាម គឺឈ្មោះរបស់ឈ្មោះនៃទំហើ ដែលបុគ្គលត្រូវធ្វើ បានដល់នាមនាមទី១ ។ ការកនាមនាមនោះ គឺឈ្មោះ

---

(១) កិរិយាថា "យ" ធ្លាប់ប្រើថា "យក" ក៏បាន មិនទាស់អ្វីទេ តែមិនស៊ីនឹងនាម សូមមើលក្នុងតារាងញែកនាមនឹងកិរិយា ក្នុងខាងមុខ ។

www.elibraryofcambodia.org

ដែលជាឈ្មោះនៃបុគ្គលអ្នកសម្រេចនូវកិច្ចហៅ ថាកត្តានាមនាម ទី២ ។ ដើម្បីឲ្យងាយយល់ក្នុងរឿងនាមនាមទាំង ២ ប្រការនោះ ចូរសង្កេតមើលឧទាហរណ៍ ដូចតទៅនេះ ៖

| សាមញ្ញនាម | ករណនាមនាម | ពាក្យប្រែ | កត្តានាមនាម | ពាក្យប្រែ |
|---|---|---|---|---|
| កល់ | កំណល់ | ពាក្យកល់ | ខ្នល់ | អ្នកតែងកល់ |
| កាព្យ | កំណាព្យ | ពាក្យកាព្យ | ខ្នាព្យ | អ្នកតែងកាព្យ |
| ក្បួន | កំលួន | ពាក្យក្បួន | ក្ងួន | អ្នកតែងក្បួន |
| គោ | គំគោ | ភាពជាគោ | ឃ្នោ | អ្នកធើជាគោ |
| ខ្ញុំ | កំញុំ | ភាពជាខ្ញុំ | ខ្នុំ | អ្នកជាខ្ញុំគេ |
| ឃ្លោង | ឃំលោង | ពាក្យឃ្លោង | ឃ្មុះទោង | អ្នកតែងឃ្លោង |
| ទឹក | ទំនឹក | ការទឹក | ធ្នឹក | អ្នកធើការទឹក |
| ដី | ដំណី | ការដី | ឋ្នី | អ្នកធើការដី |
| ទាន | ទំនាន | ការឲ្យទាន | ធ្នាន | អ្នកឲ្យទាន |
| ទុក្ខ | ទំនុក្ខ | សេចក្ដីទុក្ខ | ធ្នុក្ខ | អ្នកមានទុក្ខ |
| សុខ | សំណុខ | សេចក្ដីសុខ | ស្នុខ | អ្នកមានសេចក្ដីសុខ |
| ភ្លេង | ពន្លេង | ការភ្លេង | ភ្លុះខេង | អ្នកលេងភ្លេង |
| ក្មួន | កំមួន | ភាពជាក្មួន | ខ្មួន | បុគ្គលដែលជាក្មួន |
| ថ្នល់ | តំណល់ | ការថ្នល់ | ថ្មះល់ | អ្នកធើការថ្នល់ |
| ព្រៃ | ពង្រៃ | ការព្រៃ | ព្រះខៃ | អ្នកធើការព្រៃ |
| ស្រុក | សម្រុក | ការស្រុក | ស្រះមុក | អ្នកធើការស្រុក |
| ស្រូវ | សម្រូវ | ការស្រូវ | ស្រមូវ | អ្នកធើការស្រូវ |

www.elibraryofcambodia.org

| សាមាន្យនាម | ករណនាមនាម | ពាក្យប្រែ | កត្តនាមនាម | ពាក្យប្រែ |
|---|---|---|---|---|
| ស្រែ | សម្រែ | ការស្រែ | ស្រមែ | អ្នកធ្វើការស្រែ |
| ថ្វៃ | ជំវៃ | ការថ្វៃ | ថ្វីមៃ | អ្នកធ្វើការថ្វៃ |
| ខំ | លំខំ | ការខំ | ខម់ | អ្នកធ្វើការខំ |
| ជាង | ជំនាង | ការជាង | ឈ្មាង | អ្នកធ្វើការជាង |
| សិល្ប | សំណិល្ប | ការសិល្ប | ស្និល្ប | អ្នកមានសិល្ប |
| ថ្នាំ | តំណាំ | ការថ្នាំ | ថ្នមាំ | អ្នកធ្វើថ្នាំ |

នេះចំពោះតែពាក្យសាមាន្យនាម ដែលបានបំបែកចេញទៅពីពាក្យដើម តែសព្វថ្ងៃពាក្យដែលមិនបានបំបែកចេញពីពាក្យដើមទេ គ្រាន់តែយ.ពាក្យ "ការ" ឬ "អ្នកការ" ម.ដាក់ខាងដើមពាក្យសាមាន្យនាមប៉ុណ្ណោះ ពាក្យសាមាន្យនាមនោះៗ ក៏ហៅថា ករណនាមនាម និង កត្តនាមនាម ទាំងពីរនោះដែរ ដូចគួយ៉ាងតទៅនេះ ៖

| សាមាន្យនាមដើម | ករណនាមនាម | កត្តនាមនាម |
|---|---|---|
| ថ្នល់ | ការថ្នល់ | អ្នកការថ្នល់ |
| ព្រៃ | ការព្រៃ | អ្នកការព្រៃ |
| ផ្ទះ | ការផ្ទះ | អ្នកការផ្ទះ |
| ស្រុក | ការស្រុក | អ្នកការស្រុក |

www.elibraryofcambodia.org

| [illegible]នាមៈដើម | ករណនាមនាម | ការកនាមនាម |
|---|---|---|
| រដ្ឋ | ការរដ្ឋ | អ្នកការរដ្ឋ |
| ទាហាន | ការទាហាន | អ្នកការទាហាន |
| សិក្សា | ការសិក្សា | អ្នកការសិក្សា |
| សូត្រ | ការសូត្រ | អ្នកការសូត្រ |
| ពែទ្យ[១] | ការពែទ្យ | អ្នកការពែទ្យ |
| ស្រី | ការស្រី | អ្នកការស្រី |
| ប្រុស | ការប្រុស | អ្នកការប្រុស |
| ឈើ | ការឈើ | អ្នកការឈើ |

## ករណនាម

ពាក្យដែលជាឈ្មោះនៃទំហើ ដែលគេត្រូវធ្វើ ឬជាគ្រឿងធ្វើរបស់គេ, បានដល់កិច្ចការណាមួយដែលគេត្រូវធ្វើ កិច្ចការនោះឯង ហៅថា ករណៈ, ឈ្មោះរបស់ករណៈនោះឯង ហៅថា ករណនាម· តែបើនិយាយឲ្យស្ដាប់បានងាយៗ គឺពាក្យកិរិយាដែលយ.ម.ប្រើ

(១) ពាក្យនេះមិន "ពែទ្យ" ធ្លាប់ប្រើមកជា "ពេទ្យ" ក្នុងទីនេះផ្លាស់ "េ" ជា "ែ" ជា ពែទ្យ ប្រើដោយដូចគ្នា សូមពិនិត្យមើលក្នុងភាគអក្ខរវិធី ។

www.elibraryofcambodia.org

ធ្វើជានាមនាមនោះឯង គឺកំណើតរបស់ពាក្យដើមដំបូងនោះជាកិរិ-យាសុទ្ធ ៗ មិនមាននាមទេ តែអ្នកប្រាជ្ញកម្ពោជៈបានបង្កើតឲ្យមានជានាមឡើង ដោយការបង្វែរពាក្យកិរិយានោះ ឲ្យក្លាយប្លែកពីលំនាំដើមបន្តិចទៅ តែមិនមានពាក្យថា "ការ" ឬ "សេចក្តី" ដូចកិរិយានាមនោះទេ ។ ករណនាមនេះក៏មានចំនួនដូចគ្នានឹងគុណនាមដែរ ប្លែកតែគុណនាមនោះ បង្វែរពាក្យគុណឲ្យក្លាយមកជានាម ឯករណនាមនេះ បង្វែរពាក្យកិរិយាឲ្យក្លាយមកជានាមប៉ុណ្ណោះ ដើម្បីឲ្យឃើញថា តួកិរិយាសុទ្ធនោះដូចម្តេច ក្លាយទៅជាករណនាមនោះដូចម្តេចនោះ ចូរមើលឧទាហរណ៍តទៅនេះ :

| ពាក្យកិរិយាដើម | ចេញទៅជា | ករណនាម |
|---|---|---|
| ចង់ | " | ចំណង់ |
| ចាប់ | " | ចំណាប់ |
| ចេះ | " | ចំណេះ |
| ចាំ | " | ចំណាំ |
| ជាប់ | " | ជំនាប់ |
| ជិះ | " | ជំនិះ |

www.elibraryofcambodia.org

| ពាក្យកិរិយាដើម | ចេញទៅជា | ករណនាម |
|---|---|---|
| ជួញ | ” | ជំនួញ |
| ជឿ | ” | ជំនឿ |
| ឈប់ | ” | ជំហប់ |
| ឈរ | ” | ជំហរ |
| ឈាន | ” | ជំហាន |
| ឈឺ | ” | (១)ជំហឺ-ជម្ហឺ |
| ឈ្នះ | ” | ជំនះ |
| ដល់ | ” | ដំណល់ |
| ដើរ | ” | ដំណើរ |
| ដេក | ” | ដំណេក |
| ទិញ | ” | ទំនិញ |
| ទាក់ | ” | ទំនាក់ |
| ទួញ | ” | ទំនួញ |
| ទើ | ” | ទំហើ |

(១) ប្រើជា ជន្ទី ក៏បាន តែមិន ស៊ីនឹងកិរិយាដើម

www.elibraryofcambodia.org

| ពាក្យកិរិយាដើម | ចេញទៅជា | ករណនាម |
|---|---|---|
| (១)រេ | " | រ.ប |
| បើ | " | បើប |
| រៀន | " | របៀន |
| លក់ | " | ល្បក់ |
| លើក | " | ល្បើក |
| សិត | " | សំណិត |
| សូក | " | សំណូក |

អម្បាលនេះជាដើម ពាក្យសង្កត់ខាងមុខទាំងអស់នោះ សុទ្ធតែជាពាក្យកិរិយា, ពាក្យសង្កត់ខាងក្រោយទាំងអស់នុ៎ះឯង ដែលហៅថា ករណនាម ដោយហេតុយ.ពាក្យដែលចេញម.ពីកិរិយាម.កើតជានាមនេះឯង ពាក្យដែលជាករណនាមនេះ និយាយ ឬសរសេរ បានតែត្រឹមសព្ទប៉ុណ្ណោះឯង នឹងយកពាក្យថែម.ដាក់ថែមពីខាងដើមថា: ការចំណាន់ ឬសេចក្ដីចំណាន់ ដូច្នេះជាដើម មិនបានជាដាច់ខាត, ព្រោះពាក្យថា "ការ" ឬ "សេចក្ដី"

(១) ប្រើជា "រេក" ក៏បាន តែមិនស៊ីគ្នានឹងនាមថា រ.ប

www.elibraryofcambodia.org

សម្រាប់យ.ម ភ្ជាប់ដាក់ពីខាងដើមពាក្យដែលជាកិរិយាសព្ទ ឲ្យក្លាយទៅជានាម, ដូចជាពាក្យថា : ចំណង់, ចំណាំ, ជំនួញ, ជំនះ ជាដើមនេះ ជានាមស្រេចទៅហើយ បើយើងទៅយ. "ការ" ឬ "សេចក្តី" ម.ដាក់ថែមខាងមុខពាក្យដែលជានាមស្រេចទៅហើយនេះ ឲ្យក្លាយទៅជាអ្វីទៀត ? តែសម្រាប់ពាក្យនាមជាសាមាន្យៈ ឬ សាធារណៈនេះ គាប់ដាក់ប្តូរមិនបានហាម តែចំពោះគុណនាមទីងករណាខាងនេះដាក់មិនបានឡើយ ។

## ការកនាម

ពាក្យដែលជាឈ្មោះនៃបុគ្គលអ្នកសម្រេចនូវកំហើ; បុគ្គលណាធ្វើនូវកំហើណាមួយឲ្យសម្រេច, កំហើដែលសម្រេចនោះហៅថា ករណៈ; បុគ្គលអ្នកធ្វើនោះបានឈ្មោះហៅថា ការកៈ ប្រែថា "អ្នកធ្វើនូវកំហើ" ។ ការកនាម គឺនាមដែលជាឈ្មោះនៃបុគ្គលអ្នកសម្រេចនូវកំហើ, បើនិយាយឲ្យស្តាប់បានឆាប់នោះ ក៏គឺពាក្យកិរិយាដែលយ.ម.ប្រើធ្វើជានាម ប៉ុន្តែជាឈ្មោះរបស់អ្នកធ្វើ, អ្នកសម្រេច គឺកំណើតរបស់ពាក្យដើមដំបូងនោះ ជាកិរិយាសព្ទ ។ មិនមែនជានាមទេ តែលោកបានបំបែរពាក្យកិរិយានោះឲ្យបែរក្លាយម.ពីលំនាំ

www.elibraryofcambodia.org

ដើមបន្ថែមទៀតទៅជានាម២ យ៉ាងគឺ ករណនាម និង ការកនាម ។ នាមទាំង២ យ៉ាងសុទ្ធតែចេញមកពីកិរិយាដូចគ្នា, ដូចពាក្យថា ធើ ជាកិរិយា, ចំហើ ជា ករណនាម, ចំមើ ជា ការកនាម, ដើរ ជា កិរិយា, ដំណើរ ជា ករណនាម, ថ្មើរ ជា ការកនាម ជាដើម, អ្នកសម្រេចឱ្យចំហើ ឬសម្រេចឱ្យដំណើរនោះឯងហៅថា ការកនាម គឺកិរិយាក្លាយទី២; ការកនាមនោះ មាន ២ យ៉ាងទៅទៀតគឺ កិរិយាការកនាម១, នាមការកនាម ១ ។ កិរិយាការកនាមនោះគឺនាមដែលយកពាក្យកិរិយាសុទ្ធមកប្រើ ហើយដាក់ពាក្យថា "អ្នក" នាំខាងមុខ, ដូចពាក្យថា: អ្នកធើ, អ្នកដើរ, អ្នកដួញ, អ្នកផឹក ដូច្នេះ ជាដើម ។ ឯនាមការកនាម គឺនាមដែលលោកបំប្លែងឱ្យប្រែក្លាយពីកិរិយាមក. ជានាមតែម្តង ហើយមិនបាច់មានពាក្យថា " អ្នក " ថែម មកឡើយ គ្រាន់តែបំប្លែងពីកិរិយាមក.ក៏គាប់ដឹងបានថា នាមការកនាមតែម្តង ។ ដើម្បីឆាប់ងាយយល់ ចូរសង្កេតឧទាហរណ៍ ដូចតទៅនេះ :

| កិរិយាដើម | កិរិយាការកនាម | នាមការកនាម |
|---|---|---|
| កាន់ | អ្នកកាន់ | ខ្នាន់ |
| កាប់ | អ្នកកាប់ | ខ្នាប់ |

www.elibraryofcambodia.org

| កិរិយាដើម | កិរិយាការកនាម | នាមការកនាម |
| --- | --- | --- |
| គិត | អ្នកគិត | ឃ្មិត |
| ចាំ | អ្នកចាំ | ឆ្មាំ |
| ជួញ | អ្នកជួញ | ឈ្មួញ |
| ជួល | អ្នកជួល | ឈ្មួល |
| ដើរ | អ្នកដើរ | ថ្មើរ |
| ដេក | អ្នកដេក | ថ្មេក |
| តាន់ | អ្នកតាន់ | ថ្មាន់ |
| ទាក់ | អ្នកទាក់ | ធ្មាក់ |
| ទាញ | អ្នកទាញ | ធ្មាញ |
| នាំ | អ្នកនាំ | នមាំ |
| នឹក | អ្នកនឹក | នមឹក |
| បាញ់ | អ្នកបាញ់ | ផ្មាញ់ |
| បួស | អ្នកបួស | ផ្មួស |
| ផឹក | អ្នកផឹក | បំមឹក |
| ព | អ្នកព | ភ្ម |

www.elibraryofcambodia.org

| កិរិយាដើម | កិរិយាការកនាម | នាមការក… |
|---|---|---|
| កូត | អ្នកកូត | កង្កូត |
| ភូត | អ្នកភូត | ពំមូត |
| កើត | អ្នកកើត | កំណើត |
| មាន | អ្នកមាន | មមាន |
| មើល | អ្នកមើល | មមើល |
| យល់ | អ្នកយល់ | យោមល់ |
| រៀន | អ្នករៀន | រមៀន |
| លួច | អ្នកលួច | លង្វូច |
| រាយ | អ្នករាយ | រមាយ |
| ស្រែក | អ្នកស្រែក | សង្វ្រែក |
| សូន | អ្នកសូន | សង្វូន |
| ហ៊ាន | អ្នកហ៊ាន | ហមាន |
| អាន | អ្នកអាន | អមាន |
| អោយ | អ្នកអោយ | អមោយ |

អម្បាលនេះជាដើម ស្ទើរគ្រប់កិរិយាឯទៀតៗ ក៏គប្បីចូលបក្ខដូចជា

www.elibraryofcambodia.org

កិរិយាដែលចាញម.ជាគួយ៉ាងនេះដែរ តែសម្រាប់គុណកិរិយាការក-នាម និងនាមការកនាមនេះ មានរឿងត្រូវហាមខ្លះគឺ គុណកិរិយា-ការកនាម ហាមមិនឲ្យយ.ពាក្យថា "អ្នក" ទៅដាក់ភ្ជាប់ខាងដើម ករណនាមថា អ្នកចំណាំ, អ្នកចំបាំង, អ្នកជំនួញ, អ្នកដំណើរ, អ្នកកំណាង,.. ជាដើមជាដាច់ខាត ហើយមិនហាមមិនឲ្យយ.ពាក្យថា "អ្នក" នោះទៅដាក់ខាងដើមថា: អ្នកខ្មាន់, អ្នកឆ្មាំ, អ្នកឈ្មួល, អ្នកប្មើរ, អ្នកច្មាំង, អ្នកបំមឹក,... ជាដើមជាដាច់ខាត ។

នាម ៤ យ៉ាងគឺ កិរិយានាម, ករណនាម, កិរិយាការកនាម និងនាមការកនាមនេះ មានដំណើរស្រដៀងៗ គ្នា ព្រោះចេញម. អំពីកិរិយាដើមជាមួយគ្នា បើមិនពិនិត្យសង្កេតឲ្យមែនទែន ក៏អាចនឹងច្រឡំគ្នាទៅបាន ដូច្នេះនឹងពញគួយ៉ាងយ.ម.បង្ហាញ ឲ្យរៀនរៀន ធៀបមើលទៅ :

| កិរិយាដើម | កិរិយានាម | ករណនាម | កិរិយាការកនាម | នាមការកនាម |
|---|---|---|---|---|
| កាន់ | ការកាន់ | កំណាន់ | អ្នកកាន់ | ខ្មាន់ |
| ខឹង | ការខឹង | កំហឹង | អ្នកខឹង | កំមឹង |
| គិត | ការគិត | គំនិត | អ្នកគិត | ឃ្មិត |

www.elibraryofcambodia.org

| កិរិយាដើម | កិរិយានាម | ករណនាម | កិរិយាការកនាម | នាមការកនាម |
|---|---|---|---|---|
| ឃើញ | ការឃើញ | គំហើញ | អ្នកឃើញ | គំមើញ |
| ដឹក | ការដឹក | លំដឹក | អ្នកដឹក | ម្ដុក |
| ចង់ | ការចង់ | ចំណង់ | អ្នកចង់ | ឆ្មង់ |
| ច្បាំង | ការច្បាំង | ចំបាំង | អ្នកច្បាំង | ច្បមាំង |
| ឆក់ | ការឆក់ | ចំហក់ | អ្នកឆក់ | ចំមក់ |
| ជិះ | ការជិះ | ជំនិះ | អ្នកជិះ | ឈ្មិះ |
| ជួញ | ការជួញ | ជំនួញ | អ្នកជួញ | ឈ្មួញ |
| ញាស់ | ការញាស់ | [illegible] | អ្នកញាស់ | ម្ញាស់ |
| ញៀន | ការញៀន | [illegible] | អ្នកញៀន | មៀន |
| ដឹង | ការដឹង | ដំណឹង | អ្នកដឹង | ប្ដឹង |
| ដើរ | ការដើរ | ដំណើរ | អ្នកដើរ | ប្ដើរ |
| បិត | ការបិត | ដំហិត | អ្នកបិត | ដំមិត |
| [illegible] | ការឌី | ឌំនី | អ្នកឌី | ណ្មី |
| ណាយ | ការណាយ | លំណាយ | អ្នកណាយ | [illegible] |
| តាន់ | ការតាន់ | តំណាន់ | អ្នកតាន់ | ថ្មាន់ |

www.elibraryofcambodia.org

| កិរិយាដើម | កិរិយានាម | ករណនាម | កិរិយាការកនាម | នាមការកនាម |
|---|---|---|---|---|
| តាំង | ការតាំង | តំណាំង | អ្នកតាំង | ថ្នាំង |
| ថប់ | ការថប់ | តំហប់ | អ្នកថប់ | តំមប់ |
| ចា | [illegible] | [illegible]ហា | អ្នកចា | តំមា |
| ទុក | [illegible] | ទំនុក | អ្នកទុក | ផ្នុក |
| ជុំ | ការជុំ | ទំហុំ | អ្នកជុំ | ជ្នុំ |
| ទឹក | ការទឹក | លំទឹក | អ្នកទឹក | ម្ទឹក |
| នៅ | ការនៅ | លំនៅ | អ្នកនៅ | ន្ទៅ |
| នាំ | ការនាំ | លំនាំ | អ្នកនាំ | ម្នាំ |
| បិទ | ការបិទ | បំទិត | អ្នកបិទ | ផ្ទិទ |
| ផឹក | ការផឹក | បំហឹក | អ្នកផឹក | បំមឹក |
| ពួន | ការពួន | ពំនួន | អ្នកពួន | ភ្នួន |
| ក័ន្ត | ការក័ន្ត | ពំហ័ន្ត | អ្នកក័ន្ត | ពំម័ន្ត |
| កួត | ការកួត | តំហួត | អ្នកកួត | ពំមួត |
| ម | ការម | លំម | អ្នកម | ម.ម |
| មួល | ការមួល | លំមួល | អ្នកមួល | ម.មួល |

www.elibraryofcambodia.org

| កិរិយាដើម | កិរិយានាម | ករណនាម | កិរិយាការកនាម | នាមការកនាម |
|---|---|---|---|---|
| យំ | ការយំ | យោនំ | អ្នកយំ | យោមំ |
| រ | ការរ | រ. ប. | អ្នករ | រ.ម |
| រស់ | ការរស់ | រនស់ | អ្នករស់ | រមស់ |
| លើក | ការលើក | ល្បើក | អ្នកលើក | ល្មើក |
| លេង | ការលេង | ល្បែង | អ្នកលេង | ល្មែង |
| វាស់ | ការវាស់ | រង្វាស់ | អ្នកវាស់ | វមាស់ |
| វាយ | ការវាយ | រង្វាយ | អ្នកវាយ | វមាយ |
| សូក | ការសូក | សំណូក | អ្នកសូក | ស្មូក |
| សូម | ការសូម | សំណូម | អ្នកសូម | ស្មូម |
| ដាក់ | ការដាក់ | ដំណាក់ | អ្នកដាក់ | ដមាក់ |
| ដើរ | ការដើរ | ដំណើរ | អ្នកដើរ | ដមើរ |
| ជ្រក | ការជ្រក | ជំរក | អ្នកជ្រក | ជម្រក |
| អួត | ការអួត | អំនួត | អ្នកអួត | អមួត |
| ឲ្យ(អោយ) | ការឲ្យ | អំណោយ | អ្នកឲ្យ | អមោយ |

www.elibraryofcambodia.org

## រូបនាម (le nom concert au Physique)

ពាក្យដែលជាឈ្មោះនៃរបស់ដែលមានរូប របស់នោះទោះបី មានវិញ្ញាណក្ដី ឥតវិញ្ញាណក្ដី មានជីវិតក្ដី ឥតជីវិតក្ដី ឲ្យតែមាន រូបដែលយើងអាចប៉ះពាល់បាន, ចាប់កាន់កើត, ស្ទាបអង្អែលត្រូវ របស់នោះ ហៅថា ធម្មជាតិមានរូប; នាមឬឈ្មោះនៃធម្មជាតិមាន រូបនោះឯង ហៅថា រូបនាម (le nom concert au Physique) ដូចឧទាហរណ៍ថា: មនុស្ស, សត្វ, ដី, ទឹក, ដើមឈើ, គម្ពីរ, ដែក, សៀវភៅ ជាដើម ។

## អរូបនាម (le nom abstrait)

ពាក្យដែលជាឈ្មោះនៃរបស់ដែលឥតរូប, តាមធម្មតារបស់ ដែលឥតរូបច្រើនតែជារបស់ដែលឥតវិញ្ញាណ ឥតជីវិត ជារបស់ ដែលយើងគ្រាន់តែស្គាល់ឈ្មោះទទេ ។ តែមិនអាចនឹងមើលឃើញ បាន, មិនអាចនឹងប៉ះពាល់កើត, មិនអាចនឹងស្ទាបអង្អែលត្រូវ របស់ដែលមើលមិនឃើញ, ប៉ះពាល់មិនកើត, ស្ទាបអង្អែលមិន ត្រូវនេះឯង ហៅថា របស់ឥតរូប ។ ពាក្យដែលជាឈ្មោះនៃរបស់ ឥតរូបនោះឯង ហៅថា អរូបនាម (le nom abstrait) ដូចពាក្យ

www.elibraryofcambodia.org

ជា: ចិត្ត, វិញ្ញាណ, វេទនា, សញ្ញា, សភាព, សេចក្តី, ចំណង់ចំណង់, សម្លេង, សេចក្តីក្តៅក្រខ្វះ តាមដែលពិតនោះ, របស់ដែលមើលមិនឃើញ ប៉ះពាល់មិនកើត ស្ទាបអង្អែលមិនត្រូវនោះ គាបទឹងស្ទើរសេចក្តីអស់ពួកគួរដូចសាច,ទេវតា, ព្រះឥន្ទ្រ, ព្រះព្រហ្ម, ព្រះយមរាជ ជាដើមអស់នេះក៏ជាអរូបនាមនេះ លោកមិនសំដៅដល់ពួកបិសាចជាដើមឡើយ ព្រោះរបស់ទាំងអស់នោះ សុទ្ធតែមានវិញ្ញាណ មានចិត្ត មានជីវិត ដូចជាមនុស្សលោកដែរ ដោយហេតុដូច្នេះ របស់ទាំងនោះក៏នៅតែសង្គ្រោះចូលក្នុងនាមអរូបនាមដដែល គឺអរូបនាមនោះសំដៅយកតែរបស់ដែលមិនមានជីវិត មិនមានវិញ្ញាណ ជាឈ្មោះសេចក្តីទទេ ហើយដោយច្រើនតែជាប់ទាក់ទងនឹងកាយរបស់មនុស្ស, បានដល់ចិត្ត, ចេតសិក ជាដើមនោះផង ។

## សមុហនាម (Le nom Collectif)

នាមដែលប្រាប់សេចក្តីប្រជុំ, ប្រមូល, រួបរួម បានដល់ពាក្យដែលជាឈ្មោះរបស់មនុស្ស, សត្វនឹងរបស់ ដែលនៅរួមជាមួយគ្នាច្រើនហៅថា សមុហនាម (Le nom Collectif) ដូចសុតេច្រើននៅរួបរួមគ្នា ហៅថា "គណ"; កិច្ចុតាំងពី ៤ រូបឡើង

www.elibraryofcambodia.org

ទៅ ហៅថា "សង្ឃ"; ដំរីច្រើនរៀងនៅរួមគ្នាហៅថា "ខ្នាង"; សត្វស្លាបនៅប្រជុំគ្នាច្រើនហៅថា "ហ្វូង" នឹងពាក្យដែលសំគាល់ដល់ចំនួនច្រើនដទៃ ៗ ទៀត ដូចជា: ពួក, បន, គណៈ, ក្រុម, កោម្យនា, បរិស័ទ, និកាយ, ផ្លាកំបាល, ស្ទើរ, ត្របក, ដប, ផ្គូន, ស៊ីក, កំបង់, តាយ់, ក្តាប, បង្កោម, ស្នោង, ស្នង, ក្រមាល់, ស្ទូង, ដំណាត, គំនរ, បាច់, កណ្តាប់, ស្ទឹម, កណ្តាប ជាដើមនេះ ហៅថា សមូហនាម ។

សមូហនាមនេះ ផ្សេងដោយឡែកពីសាមាន្យនាម គឺសាមាន្យនាមជាឈ្មោះរបស់ចំណែកដូចមនុស្ស ទោះជាមនុស្សម្នាក់ឬច្រើននាក់ក៏បាន កំណត់ចំនួនជានាក់ៗ ទៅ តែសមូហនាមនេះ មិនមែនដូច្នោះទេ គឺជាឈ្មោះរបស់ពួកកងនៃចំណែកនោះ ១មួយលើកទៀត កំណត់ចំនួននៅរួមគ្នាជាច្រើន ៗ គឺសំគាល់សេចក្តីថា: ចំនួនមួយក៏ពិតមែន ប៉ុន្តែមានច្រើននាក់ច្រើនវត្ថុ បើទុកណាជាទីងប្រើសមូហនាមនោះ ជាឯកវចនៈថា: ១ ពួក, ១ កង, ១ ក្រុមក៏ដោយចុះ ក៏ត្រូវតែមានច្រើននាក់ ច្រើនរបស់រួមគ្នានៅក្នុងពួកក្នុងកងនឹងក្នុងក្រុមនោះ ហើយសមូហនាមនោះ បើចង់ដឹងល្អិតទៅ

www.elibraryofcambodia.org

ទៀតនោះ ក៏ត្រូវថែមសាមាន្យនាម ឬវិសាមាន្យនាម ចូលមកភ្ជាប់ខាងចុងទៀត ដូចគួយ៉ាង ហ្វូងបក្សី, ពួកលេង, ក្រុមញាតិ, គណៈកស្ត្រ, រដ្ឋាភិបាល, កម្ពោជៈ ដូច្នេះជាដើម ។

មួយវិញទៀត ពាក្យដែលជាឈ្មោះរបស់ទីកន្លែងដូច ស្រុកទេស, សាលា, សមោសរ ទាំងនេះ បើសំដៅសេចក្ដីដល់ទីកន្លែងនោះៗ ក៏កប់ថាជាសាមាន្យនាម ដូចដែលបានពោលរួចមកហើយ, តែបើសំដៅសេចក្ដីដល់ប្រជុំជន ដែលធ្វើការរួមគ្នា នៅក្នុងទីកន្លែងនោះត្រូវកប់ថាជា សមូហនាម គួយ៉ាងដូចគេនិយាយថា: "ស្រុកទេសក្ដីប្រែ; សាលាវិនិច្ឆ័យឲ្យលើកទោស; សមោសរនេះត្រូវការមនុស្សល្អ ដូច្នេះពាក្យថា: ស្រុកទេស, សាលា, សមោសរ ក្នុងទីនេះជាសមូហនាម ។

## លក្ខណនាម

នាមដែលស្ដែងឲ្យឃើញគ្រឿងសំគាល់, គ្រឿងចំណាំ, គ្រឿងកំណត់ ហៅថា "លក្ខណនាម" បានដល់ពាក្យនាមដែលប្រើប្រាប់លក្ខណៈរបស់សាមាន្យនាមមួយលើកទៀត ដូចពាក្យហៅ កិច្ចភាពណោះ ថា: "រូប", ហៅ សត្វ ថា: "តួ", ហៅ ទូកថា:

www.elibraryofcambodia.org

“នាគ”ជាដើម ទាំងនេះហៅថា “លក្ខណនាម” ។ តាមធម្មតា សាមាន្យនាមក្នុងកម្ពុជភាសា មិនយ. ពាក្យគុណ[illegible] ម. ប្រកបចូលខាងចុងស្រួលៗ តែម្ដងថា: ភិក្ខុ ៣, [illegible] ១ ដូច្នេះម៉េចនឹងកើត? ត្រូវតែមានពាក្យនាម១ ចំពូកទៀត ម. ប្រកបខាងចុងពាក្យគុណទាំងនោះ ទើបនឹងបានសេចក្ដីបរិបូណ៌, ដូចគួរយ៉ាងថា:ភិក្ខុ ៣ រូប, សេះ ២ គូ, ទូក ១ នាគ ដូច្នេះទើបបានពាក្យថា:“រូប, គូ, នាគ” អម្បាលនេះហៅថា“លក្ខណនាម” ។

ឯលក្ខណនាមនេះ គឺគេយកសាមាន្យនាម ឬ សមុហនាមខ្លះដែង តែដល់យ.ម. ប្រើក្នុងទីដែលប្រាប់លក្ខណៈរបស់នាមខាងមុខទៅ ក៏ក្លាយប្រែហែលគ្នានឹងពាក្យគុណទៅ ដូច្នេះ បានជាហៅឈ្មោះផ្សេងចេញ[illegible]ម្យ៉ាងទៀតទៅ ! ដើម្បីនឹងឲ្យអ្នករៀនរៀនឲ្យសង្កេតយល់បានងាយនោះ ចូរសង្កេតមើលឧទាហរណ៍តទៅខាងមុខ ។ ក៏លក្ខណនាមនោះ បើចែកចេញជាយ៉ាងល្អិតទៅទៀត[illegible]មានដល់ទៅ៦ប្រការ គឺលក្ខណនាមប្រាប់ចំណែក១, លក្ខណនាមប្រាប់ពួកកង១, លក្ខណនាមប្រាប់សណ្ឋាន១, លក្ខណនាមប្រាប់ប្រមាណ១, លក្ខណនាមប្រាប់អាការៈ១, លក្ខណនាមផ្ទួនឈ្មោះ១ ។

www.elibraryofcambodia.org

# ១–លក្ខណនាមប្រាប់ចំណែក

| លក្ខណនាម | សម្រាប់ប្រើ |
|---|---|
| ព្រះអង្គ | អ្នកជាទីគោរពកោតក្រែងខ្ពង់ខ្ពស់ដូចព្រះពុទ្ធ, ព្រះករុណា, ទេវតាដែលធំ, ព្រះអង្គម្ចាស់ជាន់ខ្ពស់ ៗ |
| អង្គ | ព្រះអង្គម្ចាស់, អ្នកអង្គម្ចាស់, ម្ចាស់, ទេវតា, របស់ដែលគេគោរពដោយព្រះពុទ្ធ, ព្រះករុណា, ព្រះអង្គម្ចាស់ ដូចអវយវៈក្នុងកាយ, គ្រឿងប្រើប្រាស់ជាដើម ៗ |
| រូប | ភិក្ខុ, សាមណេរ, ឥសី, តាបស, យាយជី, តាជី, អ្នកព្រត្តផ្សេង ៗ |
| ខ្ទម | យក្ស, ភូតបិសាច, ព្រាយ, អ្នកសំខាន់ដូចពិធីបា ៗ |
| នាក់ | មនុស្សធម្មតាទូទៅ ៗ |
| ផល | ផ្លែឈើផងទាំងពួងទូទៅ ៗ |
| តួ | សត្វតិរច្ឆាន, របស់ខ្លះដូចគ្រឿងផ្ទះ, តុ, ទូ, កៅអី, ជើងម៉ា, ដែកគោល, ប៉ាកកា, តុកតា ។ល។ |
| ភាជន៍ | ភាជនៈទាំងពួង ចាន, ឆ្នាំង, ថ្ពល, ចាក្រ, ពែង, កែវ ។ល។ |

| លក្ខណនាម | សម្រាប់ប្រើ |
|---|---|
| សន្លឹក | ស្លឹកឈើ, ស្លឹកស័ទា ។ |
| រឿង | រឿងការ, និទាន, សេចក្តី, ក្តីក្តាំ, ច្បាប់ ជាដើម ។ |
| ស៊ុត | ពងមាន់, ពងទា, ពងក្ងាន ជាដើម ។ |
| សិង | ទ្រព្យសម្បត្តិ, វត្ថុ, របស់, កិច្ចការដែលជាសាមញ្ញទូទៅ ។ |
| ខ្សៅ | ខ្លុយ, ប៉ី, ស្រឡៃ, ប៉ីអ, ប៉ីពក, ទ្រ, ចាប៉ី ជាដើម ។ |
| ខ្សែ | ដំរីស្រុក ។ |
| ក្បួនឬខ្សែ | អយស្ម័យយាន, រថក្រាំវៃ ។ |
| យន្ត | រថយន្ត (ឡាន) ។ |
| ផ្ទះ | នាឡិកា ។ |
| ក្បាល | សៀវភៅ, រទេះ, សស្ត្រាផ្សេងៗ, ទៀន, ម្ជុល, កន្ត្រៃ, ពន្លាក, ញញួរ, ដង, ដែកឆាប, ដែកឈូស ដែកអន្ទ្រើស, អំណារ ។ល។ |
| ច្បាប់ | សម្បុត្រ, និក្សារ, ឯកសារផ្សេងៗ ។ |

www.elibraryofcambodia.org

## ២- លក្ខណនាមប្រាប់ពួកកង

| លក្ខណនាម | សម្រាប់ប្រើ |
|---|---|
| កង | ទ័ព, ពាហនៈ, មនុស្សដើរការួមគ្នា ។ |
| គំនរ | របស់ដែលគរទុករួមគ្នា ដូចឥដ្ឋ, អុស, ស្បៀង, គ្រាប់ ។ល។ |
| ពួក | មនុស្ស, សត្វ, របស់ទ្រព្យដែលនៅរួមគ្នា និងមានលក្ខណៈដូចគ្នា ។ |
| បន | មនុស្ស, សត្វ, របស់ទ្រព្យ, ដែលយកមករួមគ្នា ។ |
| ក្រុម | មនុស្ស, សត្វ, របស់ទ្រព្យ ដែលនៅរួមគ្នាជាដុំៗ ។ |
| ហ្វូង | សត្វពួកជាមួយគ្នា ដែលទៅជាមួយគ្នាជាពួកៗ មនុស្សច្រើនៗ ក៏ប្រើដែរ ។ |
| គណៈ | មនុស្សដែលនៅក្នុងទីសំណាក់១ ឬក្នុងក្រុមការ ធ្វើការមួយយ៉ាង ឬក្នុងកម្រងរួមគ្នា ។ |
| និកាយ | អ្នកបួសសាសនាជាមួយគ្នា ដែលញែកគ្នាចេញទៅជាពួកៗ មនុស្សឬសត្វក្រុមធំៗ ក៏ប្រើដែរ ។ |
| សម្រាប់ឈុត | មនុស្ស ឬរបស់ដែលមានគ្រប់គ្រាន់តាមគ្រា ។ |

www.elibraryofcambodia.org

| លក្ខណនាម | សម្រាប់ប្រើ |
| --- | --- |
| វេន | អ្នកលេងមហោស្រពដែលមានវេនលេងដូចល្ខោន, របាំ, លិកេ, អាយ៉ៃ, អាយ៉ង ។ល។ |
| វង់ | មនុស្ស ១ ឈុតដែលឡោមៈជាវង់គ្នា ដូចចាត់ស៊ី, ចាត់ប៉ាល់, លេងគ្រ្ទី, លេងភ្លេង, លេងសកកី ។ល។ |
| ក្រាស | របស់ដែលដាក់ឲ្យជាប់រៀងគ្នា ដូចក្រ៊ែឆ្មើជាដើម ។ |
| គាប់ | របស់ដែលធ្វើឲ្យជាប់រៀងគ្នាជាជួរៗ ដូច ចាក, ចន្លាស់, គ្រាប់កាំភ្លើង ។ល។ |
| ស្និត | របស់ដែលជាចង្កោមៗ ដូចផ្លែចេក ជាដើម ។ |
| ធ្លាយ | ផ្លែដូង, ស្លា, ត្នោតជាដើម ។ |

## ៣. លក្ខណនាមប្រាប់សណ្ឋាន

| លក្ខណនាម | សម្រាប់ប្រើ |
| --- | --- |
| វង់ | របស់ដែលមានរូបជាវង់ដូច ចិញ្ចៀន, កង ។ល។ |
| ខ្នង | របស់ដែលមានរូបជាដំបូល ដូច ផ្ទះ, ខ្ទម, ប៉ហ្គ, ផ្សារ, កុដិ, បុស្សបុក, មុង ។ល។ |

www.elibraryofcambodia.org

| លក្ខណនាម | សម្រាប់ប្រើ |
|---|---|
| ផែន, បន្ទះ | របស់ដែលមានរូបសំប៉ែតៗ ដូចក្រដាស, ក្តារ, ឥដ្ឋ, ក្បឿង ។ល។ |
| ផ្ទាំង | របស់ដែលមានរូបសំប៉ែតស្តើងទូលាយធំដូចសំពត់, កន្ទេលព្រំកម្រាស, ស្បែកសត្វដែលគេប្រើក្រាល ។ល។ |
| ថែប | របស់ដែលសំប៉ែតស្តើងចង្អៀត តែវែងដូចសំពត់ចង្អៀតៗ តែវែង ។ល។ |
| ចាំង | របស់ជាផែនដែលមានក្របដូចទ្វារ, បង្អួច, កញ្ចក់ទូ, ក្របរូប ។ល។ |
| ដៃ | របស់ដែលមានរូបទ្រវែង ៗ ដូចកូនបង្កត់ ។ល។ |
| ខែង | របស់គាន់ទទ្ធមានរូបវែងៗ ដូចដែក, សំណ ។ល។ |
| បណ្តូល | របស់ដែលមានបណ្តូល ដូច ដីខ្មៅ ជាដើម ។ |
| ដុំ | របស់ដែលមានរូបជាដុំ ដូចយ៉ាង ដុំដី, ថ្ម, ឥដ្ឋបែក, នំបុ័ង ។ល។ |
| ដក់ | សម្រាប់កញ្ជើ, ល្អី, កន្ត្រាំង ។ |
| កូន | សម្រាប់ដីសជាដើម ។ |

www.elibraryofcambodia.org

| លក្ខណនាម | សម្រាប់ប្រើ |
| --- | --- |
| ដង | របស់ ដែលមានចំណែកសម្រាប់កាន់នឹងពាក្យរូបវែងៗ ដូច ឆត្រ, កាំងយូរ, ធ្នូ, ស្លាបព្រា, សម, ព្រួ, សន្ទូច(ដែលមានដង)ៗ ឆ្នាក់, ខន្តិល, រនាស់ ។ល។ |
| ខាត | សម្រាប់ទូក, សំពៅ, នាវា, កប៉ាល់ ។ |
| ដើម | របស់ដែលជាដើម ដូចដើមឈើ, សសរ, បង្គោល, បង្អោន ។ល។ |
| គ្រឿង | របស់ដែលហោះលើអាកាសដូចយន្តហោះ ។ល។ |
| ដួង | របស់ដែលជាស្នាមមូល ៗ ដូចស្នាមពពាល, ត្រាផ្សេងៗ, របស់ដែលមានពន្លឺដូចថ្ងៃ, ខែ, ផ្កាយ, ភ្លើង, ចិត្ត, វិញ្ញាណ ។ល។ |
| បំពង់ | របស់មូលវែងតែប្រហោងដូច ថ្នាំងឫស្សី, ក្រឡាន, កាំភ្លើង ។ល។ |
| សរសៃ | របស់ដែលជាសរសៃឆ្មារវែងដូច ខ្សែ, លួស, [illegible], អំបោះ ។ល។ |
| បន្ទាត់ | របស់ដែលជាផ្លូវវែងដូច ថ្នល់, ផ្លូវ, ឆ្នារទឹក ។ល។ |

www.elibraryofcambodia.org

## ៦– លក្ខណនាមប្រាប់ប្រមាណ

| លក្ខណនាម | សម្រាប់ប្រើ |
|---|---|
| មាត់ | គ្រឿងរាំងដាក់សត្វមានរូបជាមាត់ខ្លាយដូចសំណាញ់, អួន, ព្រួល, ផ្ទាំងផាំង ។ល។ |
| គូ | របស់ដែលមានទីឈុត២សិងដូចស្បែកជើង, ស្រោមជើង,(១) ចៅកាន់, ជើងទៀន, សមទីងស្លាបព្រា ។ល។ |
| ឡូចសកៈឡូ | របស់ដែលរួមគ្នា ១២ សិង ច្រើនតែមកពីអឺរ៉ុប ។ |
| គុលិ, វិសកៈ | សំ[illegible]កញ្ចប់ដែលរួមគ្នា ២០ ផ្លាំង ។ |
| ហោ | ពេះរូប ១ កញ្ចប់ចំនួន ១០ ប្រអប់ ; ទៀនមួយកញ្ចប់ចំនួន ១០ ដើម ។ល។ |

## ៧– លក្ខណនាមប្រាប់អាការៈ

| លក្ខណនាម | សម្រាប់ប្រើ |
|---|---|
| ជិត | របស់ដែលជិត ដូចខ្ញូ ក្រដាស់, សំពត់ ។ល។ |
| មូរ | របស់ដែលមូរ ដូច បារី, ស្លា, កន្ទេល ។ល។ |
| បាច់ | របស់ដែលចងជាបាច់ៗដូច ចស, បន្លែ, ត្រកួន ។ល។ |

(១) ជ្ជូតាក់ន្លា

| លក្ខណនាម | សម្រាប់ប្រើ |
| --- | --- |
| ផ្នត់, ផាប់ | របស់ដែលចងទុកដូចសំពត់ផ្សេង ៗ |
| រុំ | របស់ដែលមូរប្រមូលទុកដូចថ្នាំជក់, ក្រដាស ។ល។ |
| កណ្តាប់ | របស់ដែលធ្វើជាកណ្តាប់ជាបាច់ល្មមចាប់កាន់បានដូចស្បូវ, សំណាបដែលដកចង, ស្រូវដែលច្រូតហើយ ។ល។ |
| កណ្តាប | ស្បូវដែលក្រងហើយនិងស្លឹកត្នោតដែលវេរហើយ ។ |
| [illegible] | របស់ដែលធ្វើជាកញ្ចុំ ១ ដូចអំពោះ, ផ្កា ។ល។ |

## ៦– លក្ខណនាមផ្ទួនឈ្មោះ

សាមាន្យនាមពាក្យខ្លះ ដែលមិនត្រូវការនឹងប្រាប់លក្ខណៈដូចខាងលើនេះ កាលបើនឹងប្រើជាមួយនឹងពាក្យគុណដូច្នោះ ត្រូវយកពាក្យសាមាន្យនាមដើមនោះឯង មកប្រើជាលក្ខណនាម ប្រកបនឹងពាក្យគុណនោះ ៗ ដូចពាក្យថា: ប្រទេស ២ ប្រទេស, ស្រុក ២ ស្រុក, ភូមិ ២ ភូមិ, វត្ត ៤ វត្ត ដូច្នេះជាដើម ពាក្យសាមាន្យនាម ដែលផ្ទួននឹងឈ្មោះខាងដើម គឺប្រទេស, ស្រុក, ភូមិ, វត្ត នោះ ហៅថា លក្ខណនាម ដូចគ្នា ។

www.elibraryofcambodia.org

វិធីសង្កេត លក្ខណនាមនេះ កប់ថាជាចំណែកសំខាន់ដែល ត្រូវសង្កេតឲ្យមែនទែន ទីនេះប្រើប្រែប្រួលព្រមគ្នាដូចជា មនុស្សមិត្ត, តែង ២ សិទ្ធដូច្នេះជាដើម មិនភ្ញាក់ឡើយ លក្ខណនាមពួក ដែលដូចឈ្មោះខាងដើមនោះ ប្រើមួយទៅបានច្រើន តែច្រើនប្រើចំ ពោះកន្និកាពើបញ្ញី ព្រោះជាការប្រែប្រួលឆាយទីនេះ តែក៏ប្រើមិន បានមួយទៅគ្រប់ពាក្យ ដូចពាក្យថា "ភិក្ខុ, ទេវតា" ទីនេះប្រើថា "២ ភិក្ខុ, ២ ទេវតា" ដូច្នេះក៏មិនបានដែរ គោងតែប្រើឲ្យត្រូវ តាមរបៀបវិធីបាន ។

## សមាសនាម (Nom Composé)

សមាសនាម គឺពាក្យដែលផ្សំឈ្មោះពីរឬទៅដែលបង្រួញចូល គ្នាជាពាក្យមួយ ការដែលបង្រួញពាក្យពីរឬពីរទៅឡើងទៅឲ្យជាប់ ចូលគ្នា ជាបទតែមួយ ហៅថា សមាស; ឈ្មោះដែលសមាសនោះ ឯង ហៅថា សមាសនាម (Nom Composé) ។ សមាសនាម នេះ មានទំនាក់ទំនងគ្នាក៏ដោយភាសាពាក្យ ឬពាក្យផ្សំ ប្រសិនណា បើដូច គឺដូចតែបន្តិចបន្តួច ត្រូវតែសង្កេតបានដោយឆាយ ព្រោះជាលោកពាក្យនោះ គឺគេយកមូលពាក្យ ឬពាក្យមូលម.

www.elibraryofcambodia.org

ផ្សំគ្នា ឲ្យក្លាយទៅជាឈ្មោះអ្វីមួយទៅ ឬនៅមានសេចក្ដីតាម លំនាំដើមដូចដែល ឬក៏មានប្លែកពីលំនាំដើមបន្តិចបន្តួចប៉ុណ្ណោះ មិនមែនដល់លុបបុព្វបទណាមួយឡើយ ហើយបង្រួញចូលជាពាក្យផ្សំនោះទេ ចំណែកខាងសមាសនាមនេះមិនមែនដូច្នោះឡើយ គឺពាក្យតាំងពីពីរម៉ាត់ឡើងទៅ, ពាក្យនោះសុទ្ធតែមានបុព្វបទសម្រាប់តភ្ជាប់ ហើយគេត្រូវលុបបុព្វបទរបស់ពាក្យនោះៗចេញ រួចទើបគេបង្រួញចូលគ្នាជាបទមួយ, លិង្គ, វចនៈ សម្រេចនឹងបទខាងចុង ហើយជាពាក្យសាមាន្យនាម ឬវិសាមាន្យនាមបានទាំងពីរ, បទដែលបង្រួញចូលគ្នានោះ ជានាមដូចគ្នាទាំងអស់ក្ដី ជាគុណទាំងអស់ក្ដី ជានាមនឹងគុណក្ដី ជានាមនឹងកិរិយាក្ដី ក៏បានដូចគ្នាមិនខាន ដាក់នាមមុន គុណក្រោយក៏បាន ដាក់នាមក្រោយ គុណមុនក៏បាន ដាក់នាមមុន កិរិយាក្រោយក៏បាន ដាក់នាមក្រោយ កិរិយាមុនក៏បាន យ៉ាងនេះឯង ហៅថា សមាសនាម មានច្រើនបែបច្រើនយ៉ាងណាស់ តែបើនិយាយ យ៉ាងសង្ខេបក៏មានត្រឹម ៦ យ៉ាងគឺ កម្មធារយសមាស១, ទិគុសមាស១, តប្បុរិសសមាស១, ទ្វន្ទ្វសមាស១, អព្យយីភាវសមាស១,

www.elibraryofcambodia.org

ពហុព្វីហិសមាស១ ។

កម្មធារយសមាស : បទពីរបទដែលមានបុព្វបទនឹងវិបនៈ សេដ្ឋា បទ១ជានាមជាតួប្រធាន, បទមួយជាគុណ ឬជានាមជាតួវិសេសនៈ ឬក៏ជាគុណនាមពីរបទ មានបទឯទៀតជាប្រធាន ដែលបង្រួញចូលជាបទ១ ហៅថា កម្មធារយសមាស; ដូចពាក្យថា: មហាបុរស, មហាស្ត្រី, មហាទុក្ខ, មហាលំបាក, មហាផល, មហាកំសត់, មហាព្រៃ, មហាជន, មហាបុគ្គល, មហាប្រទេស មហានគរ, មហាអំណាច, មហាមេឃ, មហា[illegible], មហាទឹក, មហាជ័យ, មហាធំ, មហាសនៈ, មហាសប្បុរស, មហាថេរ, មហានិសង្ស, មហាមិត្រ, មហាកថ, មហាទាន, មហាសីល, មហាជាតក៍, មហានិបាត, ឧត្តមបុរស, ទីឃសនៈ, អនុត្តរៈ, បុរិសុត្តម, បុរសុត្តម, បុរិសលាមក, បុរសលាមក, បុរសបាប, នរាសភៈ, នររៈ, នរៈប្រសើរ, មនុស្សទលិទ្ទ, សត្វណ្ហាហ៊ាន, អន្ធពាលបុរស, ខញ្ញខុញ្ញបុរស, កិសខុទ្ទកបុរស, សន្ធិបណ្ណាកៀរ, កាកស្សបុរស, ទិព្វចក្ខុ, ធម្មចក្ខុ, បេតមនុស្ស, និរយមនុស្ស, នរសីហៈ, មនុស្សប្រេត, ញាណចក្ខុ, បញ្ញាបសាទ, ប្រាជ្ញ

www.elibraryofcambodia.org

គ្រោសាខ: ខត្តិយមាន:, សមណបព្វជ្ជា, សត្តសញ្ញា, មំស-សញ្ញា, បណ្ឌិតសញ្ញា, ការុសញ្ញា; ពុទ្ធគេហ:, ធម្មគេហ:, សង្ឃគេហ:, សទ្ធាធន:, សីលធន:, បញ្ញាធន:, បញ្ញាចក្ខុ ។

ទិគុសមាស: បទពីរបទ, មួយជាគុណវិសេសន:នៅខាងដើម, មួយជានាមជាគុណប្រធាន, តែបទវិសេសន:នោះជាគុណកតិសង្ខ្យា, បង្រួញចូលជាបទជាមួយគ្នា ហៅថា ទិគុសមាស; ដូចពាក្យថា: ត្រៃលោក, ត្រៃភព, ត្រៃកូដ, ត្រៃធម៌, ត្រៃមគ្គ, ត្រៃផល, ត្រៃវេទ, ត្រៃភូមិ, ចតុទិស, ចតុមគ្គ, ចតុមុខ, ចាតុម្មហារាជិក, ចតុទ្វារ, បញ្ចិន្ទ្រិយ, ចតុរាបាយ, ឆទ្វារ, ឯកចក្ខុ, ឯកបុគ្គល, ឯកជន, ចតុទ្ទិសា, បញ្ចពលា, សត្តវេលា, បញ្ចសុទ្ធាវាសា, ឆកាមា ។

កប្បុរិសសមាស: បទដែលផ្សំជាមួយនឹងបុព្វបទមានដើមថា: “ទុ, កាន់, ញ៉ាំង, ឥត, អសំ, ចំពោះ” ជាដើម ហើយបង្រួញចូលជាមួយគ្នានឹងបទខាងចុង ដែលមានបុព្វបទផ្សេងគ្នា ហៅថា កប្បុរិសសមាស; ដូចពាក្យថា: សុខប្បត្តជន, នាមគត-បុរស, អញ្ញាតកកិច្ច, សព្វត្ថិសោកទ, ទុវត្តិត, សុគតជន, សល្លីវិទ្ធម្រឹគ, អស្សរថ, មគ្គចិត្ត, ផលចិត្ត, រាជទ្ធិ, រាជទ្ធិនាម,

www.elibraryofcambodia.org

រាជវេទ្យ, រាជនិពន្ធ, ពុទ្ធតម្រាស់, ពុទ្ធទំនាយ, ពុទ្ធធម៌, ពុទ្ធប្បញ្ញត្តិ, ពុទ្ធានុញ្ញាត, ពុទ្ធព្យាករណ៍, ពុទ្ធភាសិត, សាវក-ភាសិត, ឥសិភាសិត, ទេវតាភាសិត, កឋិនទុស្ស, អាគន្តុកភត្ត, គមិកភត្ត, សង្ឃភត្ត, គិលានភត្ត, គិលានុបដ្ឋាកភត្ត, រាជភ័យ, ចោរភ័យ, អគ្គិភ័យ, ឧទកភ័យ, ពន្ធនមុត្តសត្វ, មេថុនាបេក-បត្ថិត, រាជទូត, រាជធានី, រាជបំរើ, រាជប្រកាស, រាជកម្ម, រាជការ, រាជកិច្ច, រាជក្រឹត្យ, រាជកញ្ញា, រាជទ្រព្យ, រាជកុមារ, រាជកុមារី, រាជកុសល, រាជទណ្ឌ, រាជកំណត់, រាជគ្រឹហា, រាជគ្រូ, រាជព្រឹទ្ធិ, រាជជននី, រាជដំណាក់, រាជដំណើរ, រាជតេជៈ, រាជ-តេជោគុណ, រាជអំណាច, រាជតម្រាស់, រាជត្រកូល, រាជទាន, រាជទេវី, រាជទ្វារ, រាជធម៌, រាជធីតា, រាជធិបតិ, រាជធុរៈ, រាជនត្តា, រាជងាក់, រាជបុត្រ, រាជបុត្រី, រាជបន្ទូល, កុលបុត្រ, កុលធីតា, ជិនបុត្រ, ជិនវង្ស, ជិនោរស, កាកបាទ, សារីបុត្រ, រូបសញ្ញា, សង្សារទុក្ខ, វដ្តទុក្ខ, កាមគុណ, កាមតណ្ហា, កាមយោគ, ចូលិភត្ត, ឧទម្ពា ។

ទ្វន្ទ្វសមាស : នាមតាំងពីពីរបទឡើងទៅ ដែលមាន

www.elibraryofcambodia.org

បុព្វបទ ដូចគ្នា បង្រួញចូលជាបទមួយ ហៅថា ទ្វន្ទ្វសមាស; ដូចពាក្យថា: សមថវិបស្សនា:, កាកោលូក:, បណ្ណបុប្ផផល, ហត្ថិអស្ស-រថបត្តិក:, មាតាបិតា, កុមារកុមារី, បុរសស្ត្រី, សមណព្រាហ្មណា, ភិក្ខុសាមណេរ, បណ្ណបុប្ផផលា, ទេវមនុស្សនាគាសុរគន្ធព្វា ។

អព្យយីភាវសមាស: សមាសដែលមានឧបសគ្គ: ឬនិបាតនៅខាងដើម ហើយជានបុំសកលិង្គ, បើទុកជាពហុវចន: ក៏មានអាការ:ជា នបុំសកលិង្គ ឯកវចន: ហៅថា អព្យយីភាវ-សមាស; ដូចពាក្យថា: ឧបនគរ, ឧបសាលា, ឧបវន, និទ្ទរថ, និម្មកស, បតិសោត, អជ្ឈត្ត, យថាព្រឹទ្ធិ, យថាកម្ម, យថាកាម, យថាក្រម, យថាឋាន, យថានុក្រម, យថានុរូប, យថាផាសុក, យថាលាភ, តិរោបព្វត, អន្តោប្រាសាទ, បច្ឆាភត្ត, បុរេភត្ត, អន្តោបុរ, អន្តោគ្រាម, អន្តោជន, អន្តោគ្រឹះ, អន្តោជាត; អន្តោសារ ។

ពហុព្វីហិសមាស: សមាសដែលមានបទឯទៀត ស្ទុះ ពីក្នុងវិគ្គហ:ចេញមកជាប្រធាន ហៅថា ពហុព្វីហិសមាស; ដូចពាក្យថា: អាគតសមណ:, រុឡ្ហលត:; សម្បត្តភិក្ខុ, អភិរុឡ្ហ-

www.elibraryofcambodia.org

ពានរ, ផិតទ្រើយ, កតញ្ញូ, អហិតត្ថ, ទុស្សន្ធិ, កតវណ្ណកម្ម, សញ្ញាតសំរេត:, ទុយ្យស, ទុ..., ទុព្ភាន, ទុស្សត្ត, ទុគ្គត-ផល, ទុគ្គតសោត, ទុសេព្ល..., ..., វិកត, វិតទោស, វិ-មោហ:, អប...សិរ, ទីណាស្រែត, សន្តចិត្ត, ឥទ្ធហត្ថ, ហត្ថបិន, សម្បន្នសស្ស, តប្បុនទឹក, បិតសិរ, បិតសីល, បិតពាន, បិតបេមៗ

## តទ្ធិតនាម

គឺពាក្យដែលជាឈ្មោះនៃបទតទ្ធិត ដែលយ.ម.ប្រើជានាមៗ នេះបានដល់បទនាមមួយយ៉ាង ដែលមានបទប្រជុំគ្នាច្រើន ហើយបានសេចក្ដីផ្សេងៗគ្នា គេមិនត្រូវការបទប្រជុំគ្នាច្រើន គេចង់ឲ្យមានបទតិចទៅវិញ ទើបគេលុបបទចោលខ្លះ ហើយគេដាក់អ្វីថែមជាជំនួយបន្ថែម.តែគឺនៅបានសេចក្ដីពេញដដែលដូចដើមដូចដែល; បទដែលគេលុបចោលខ្លះហើយ ដាក់អ្វីថែមខាងដើម ឬខាងចុង នេះឯង ដែលហៅថា តទ្ធិត, ពាក្យដែលជាឈ្មោះតទ្ធិតនោះហៅថា តទ្ធិតនាម ប៉ុន្តែដោយកិច្ចដែលត្រូវធ្វើ គឺត្រូវលុប ឬផ្លាស់ ឬក៏ចុះបច្ច័យនោះមាន២យ៉ាងគឺ អប្បច្ចយិក: ១, បច្ចយិក: ១ ។

អប្បច្ចយិក: តទ្ធិតនាមដែលមិនបានចំណុះបច្ច័យថែម

www.elibraryofcambodia.org

ម.ពីខាងចុង  មានតែតំហែមពាក្យពីខាងដើម·វិញជាជំនួសបង
ដែលលុបចោលនោះៗ  អព្យួចយិកកត្តិនាមនេះ  មានចំនួនដូចគ្នា
នឹងយោគពាក្យទី ៤ ត្រង់ដែលថា  “ពាក្យផ្សំដែលបង្រួញម.ពី
សេចក្ដីច្រើន, ពាក្យពួកនេះ  មានលក្ខណៈដូចគ្នានឹងកត្តិនាម”
ខ្លះតែក្នុងយោគពាក្យនោះ គ្រាន់តែបង្រួញពាក្យឱ្យខ្លីចុះ មិនមាន
អ្វីជាក់ថែម·ប៉ុណ្ណោះ  ឯក្នុងអព្យួចយិកកត្តិនាមនេះ  ត្រូវលុប
ពាក្យដែលគួរលុបនោះចោល  ;ហើយថែមពាក្យដែលគួរថែមម.
នោះពីខាងដើម  ហើយឱ្យនៅមានសេចក្ដីប្រហែលគ្នា  ក្នុងកាល
ដែលមិនទាន់លុបនោះដូចដើមប៉ុណ្ណោះឯង ។  ពាក្យដែលគួរដាក់
ថែមខាងដើមនៃអព្យួចយិកកត្តិនាមនោះ  ក៏ឃើញមានតែពាក្យ
មួយម៉ាត់គឺ “អ្នក”នោះឯង  ដែលប្រើញឹកញាប់ជាងពាក្យឯទៀត
ដើម្បីឱ្យឃើញថា  ពាក្យដើមនោះច្រើនប៉ុន្មាន  និងដែលលុប
ចោលខ្លះ  ហើយថែមពាក្យថ្មី.នោះទៅជាយ៉ាងណាទៅវិញនោះ
ចូរមើលឧទាហរណ៍តទៅនេះ :

| ពាក្យដើម | ពាក្យដែលលុបចោល | ពាក្យដែលថែមថ្មី |
|---|---|---|
| មនុស្សនៅក្នុងភ្នំពេញ | មនុស្សនៅក្នុង | អ្នកភ្នំពេញ |

www.elibraryofcambodia.org

| ពាក្យដើម | ពាក្យដែលលុបចោល | ពាក្យដែលថែមថ្មី |
|---|---|---|
| មនុស្សនៅក្នុងបាត់ដំបង | មនុស្សនៅក្នុង | អ្នកបាត់ដំបង |
| មនុស្សនៅក្នុងកំង | មនុស្សនៅក្នុង | អ្នកកំង |
| មនុស្សនៅក្នុងព្រៃ | មនុស្សនៅក្នុង | អ្នកព្រៃ |
| មនុស្សធ្វើនូវស្រែ | មនុស្សធ្វើនូវ | អ្នកស្រែ |
| មនុស្សធ្វើនូវចំការ | មនុស្សធ្វើនូវ | អ្នកចំការ |
| មនុស្សប្រព្រឹត្តនូវធម៌ | មនុស្សប្រព្រឹត្តនូវ | អ្នកធម៌ |
| មនុស្សប្រុងប្រង់នូវវិន័យ | មនុស្សប្រុងប្រង់នូវ | អ្នកវិន័យ |
| មនុស្សចេះនូវច្បាប់ | មនុស្សចេះនូវ | អ្នកច្បាប់ |
| មនុស្សស្រឡាញ់នូវជាតិ | មនុស្សស្រឡាញ់នូវ | អ្នកជាតិ |
| មនុស្សគោរពនូវសាសនា | មនុស្សគោរពនូវ | អ្នកសាសនា |
| មនុស្សមាននូវកាសែត | មនុស្សមាននូវ | អ្នកកាសែត |
| មនុស្សលេងនូវប័ល្ល | មនុស្សលេងនូវ | អ្នកប័ល្ល |
| មនុស្សលេងនូវភ្លេង | មនុស្សលេងនូវ | អ្នកភ្លេង |
| មនុស្សលេងនូវបៀ | មនុស្សលេងនូវ | អ្នកបៀ |
| មនុស្សផឹកនូវសុក | មនុស្សផឹកនូវ | អ្នកសុក |

www.elibraryofcambodia.org

| ពាក្យដើម | ពាក្យដែលលុបចោល | ពាក្យដែលថែមចូល |
|---|---|---|
| មនុស្សជួយធ្វើក្តី | មនុស្សជួយធ្វើ | អ្នកក្តី |
| មនុស្សគិតធ្វើជីកដី | មនុស្សគិតធ្វើ | អ្នកជីកដី |
| មនុស្សពេញចិត្តសៀវភៅ | មនុស្សពេញចិត្ត | អ្នកសៀវភៅ |

អម្បាលនេះជាដើម សូម្បីពាក្យដទៃៗ ក៏មានទំនងដូចគ្នានេះដែរ

ពាក្យថា "អ្នក" ក្នុង[illegible]កត្តិនាមនេះ ជាក់ភ្ជាប់បាន តែនឹងពាក្យដែលបល់[illegible] ដែលលុបចោលអស់ទៅនោះប៉ុណ្ណោះឯង ដូចពាក្យថា "មនុស្សនៅក្នុងភ្នំពេញ" ,លុបពាក្យថា: "មនុស្សនៅក្នុង" ចេញ ទុកតែពាក្យថា: "ភ្នំពេញ" ដែលជាបទវិសាមញ្ញនាម ហើយទើបយ.ពាក្យថា: "អ្នក" ទៅជាក់ភ្ជាប់ថា: "អ្នកភ្នំពេញ" ដូច្នេះទើបបាន យ៉ាងនេះទើបហៅថាកត្តិនាម, បើមិនដាក់ពាក្យថា "អ្នក" ម.ទេ គ្រាន់តែភ្ជាប់ពាក្យថា: "មនុស្សភ្នំពេញ, មនុស្សព្រៃ, មនុស្សបាត់ដំបង" ដូច្នេះនេះ មិនហៅថា កត្តិនាមទេ ត្រូវហៅថា យោគពាក្យ ឬពាក្យផ្សំ[illegible] ។ មួយវិញទៀត ពាក្យថា: "អ្នក" នេះ បើយ.ទៅភ្ជាប់នឹងពាក្យកិរិយា ដូចជា "អ្នករៀន, អ្នកអាន, អ្នកមើល,

www.elibraryofcambodia.org

អ្នកចិញ” ដូច្នេះក៏មិនបានឈ្មោះថា គុណនាមដែរ ទង់ក្លាយទៅជា កិរិយាការកនាមទៅវិញ ។ ក្នុងអប្បច្ចយិកគុណនាមនេះ ក៏មាន ដំណើរប្រហែលគ្នានឹងនាមការកនាមនោះដែរ ព្រោះអនុញ្ញាតឲ្យ យកពាក្យថា: “អ្នក” នេះ ទៅដាក់ភ្ជាប់ បានតែនឹងពាក្យដែល ជាសាមញ្ញនាម ឬវិសាមញ្ញនាមប៉ុណ្ណោះ ហើយហាមមិនឲ្យ យ.ពាក្យថា: “អ្នក” ទៅដាក់ភ្ជាប់នឹងពាក្យដែលជាករណនាម ជា ដាច់ខាត; ដូចពាក្យថា : “ចំណាំ, ចំប៉ាំង, ជំនួញ, ដំណើរ, ដំណឹង, ដំណាង, គម្រោះ, ល្បេង ទៅភ្ជាប់ថា : “អ្នកចំណាំ, អ្នកចំប៉ាំង, អ្នកជំនួញ, អ្នកដំណើរ, អ្នកដំណឹង, អ្នកដំណាង, អ្នក គម្រោះ, អ្នកល្បេង, ...” ដូច្នេះនេះមិនបានឡើយ ដែលត្រូវតែ. នាមការកនាមនោះតែបន្តិច គឺក្នុងនាមការកនាមនោះ ត្រូវយ. ពាក្យថា : “អ្នកការ” ទៅភ្ជាប់នឹងពាក្យដែលជាសាមញ្ញនាម ឬ វិសាមញ្ញនាម ដូចជា: អ្នកការរដ្ឋ, អ្នកការស្រុក, អ្នកការ-សិក្សា,...ជាដើម ។ ឯក្នុងអប្បច្ចយិកគុណនាមនេះ មិនមានពាក្យ ថា “ការ” ទេ មានតែពាក្យថា “អ្នក” ប៉ុណ្ណោះឯង ។

**បច្ចយិកគុណនាម.** គឺគុណនាមដែលមានចំណុះ

www.elibraryofcambodia.org

បច្ច័យខាងចុងបទនាម ក្នុងវេលាដែលលុបបទឯទៀតចោលខ្លះ ហើយដោយសេចក្ដីអធិប្បាយថា: សព្ទមានចំនួនតាំងពីពីរឡើងទៅ, ចុះបច្ច័យជាជំនួយម. ហើយលុបសព្ទខាងដើម ឬខាងចុង ដែលមិនត្រូវការ, ទុកតែសព្ទខាងដើម ឬកណ្ដាល ឬក៏ខាងចុង ដែលត្រូវការឲ្យជាមួយនឹងបច្ច័យ ដើម្បីឲ្យខ្លីស្រួលថា, ស្រួលហៅ ដូចថា: "(ជន) កើតហើយក្នុងដែនកម្ពុជ: ", ចុះ ណ បច្ច័យជា ជំនួសសព្ទទាំងឡាយថា: "កើតហើយក្នុងដែន" ហើយលុប សព្ទទាំងនេះចេញ ទុកតែសព្ទថា "កម្ពុជ:" លុប "ណ" ចេញ ទុកតែស្រៈដែល "ណ" អាស្រ័យនៅ ជា "កម្ពោជ:" ក៏គង់នៅ បាននូវសេចក្ដីថា: "កើតហើយក្នុងដែនកម្ពុជ:" ដូចដើមដូចដែល; សព្ទយ៉ាងនេះ ដែលហៅថា បច្ច័យតទ្ធិតនាម; និយាយដោយ សង្ខេបក៏មានត្រឹម ៣ យ៉ាង គឺសាមញ្ញតទ្ធិត ១, ភាវតទ្ធិត ១. អព្យយតទ្ធិត ១ ។

សាមញ្ញតទ្ធិត គឺតទ្ធិតធម្មតា បានដល់តទ្ធិតនាមដែល ក្នុងវេលាប្រែ វេលានិយាយ, ប្រែឬនិយាយត្រង់ៗ តែម្ដង មិនមានពាក្យថា: "ភាវ:" នៅនោះផង ហើយក្នុងសាមញ្ញតទ្ធិតនេះ

www.elibraryofcambodia.org

មានបច្ច័យជាច្រើន តែក្នុងទីនេះ នឹងនិយាយតែត្រឹមបច្ច័យ ៣ គឺ ណ, ណិក, ណេរ; ដើម្បីងាយយល់នោះ សូមសង្កេតមើលឧទាហរណ៍ដូចតទៅនេះ :

| សព្ទដើម | សព្ទដែលលុបចោល | បច្ច័យ | សព្ទសម្រេច |
|---|---|---|---|
| កើតហើយក្នុងដែនកម្ពុជ: | កើតហើយក្នុងដែន | ណ | កម្ពោជ: |
| កើតហើយក្នុងដែនមគធ: | " " | ណ | មាគធ: |
| កើតហើយក្នុងដែនជវ | " " | ណិក | ជាវិក: |
| កើតហើយក្នុងដែនណាវ | " " | " | ណាវិក: |
| កើតហើយក្នុងដែនកុមា | " " | " | កុមិក: |
| កើតហើយក្នុងដែនសៀម | " " | " | សៀមិក: |
| កើតហើយក្នុងដែនឥណ្ណាម | " " | " | មណ្ណាមិក: |
| កើតហើយក្នុងក្រុងឥន្ទបត្ត | " ក្នុងក្រុង | " | ឥន្ទបត្តិក: |
| កូនរបស់វិធវា: | កូនរបស់ | ណេរ | វេធវេរ: |
| កូនរបស់សមណ: | កូនរបស់ | " | សាមណេរ: |

ភាវតទ្ធិត គឺតទ្ធិតចុះក្នុងអត្ថនៃសព្ទថា: "កើត, មាន, ជា" បានលុបបទតទ្ធិតមួយយ៉ាង ដែលក្នុងពេលប្រែ មានបញ្ចេញពាក្យ

www.elibraryofcambodia.org

[illegible] "[illegible] សេចក្ដីកើត, សេចក្ដីមាន, សេចក្ដីជា" ។ ក្នុង [illegible] ច្រើនគួរ តែខ្ញុំពោលក្នុងទីនេះ តែត្រឹម [illegible] មើលឧទាហរណតាំងឡាយតទៅនេះ :

| សព្ទៈដើម | បទដែលលុបចោល | បច្ច័យ | បទសម្រេចហើយ |
|---|---|---|---|
| ភាវៈនៃបណ្ឌិត | ភាវៈនៃ | ណ្យ | បណ្ឌិច្ច=បណ្ឌិត្យ |
| ភាវៈនៃព្រះរាជ | " | " | រជ្ជ = រជ្យ |
| ភាវៈនៃសមណ | " | " | សាមញ្ញ=សាមាន្យ |
| ភាវៈនៃសហាយ | " | តា | សាហាយតា |
| ភាវៈនៃកតញ្ញូ | " | " | កតញ្ញុតា |
| ភាវៈនៃមុទុចិត្ត | " | " | មុទុតា |
| ភាវៈនៃសាមគ្គី | " | " | សាមគ្គិតា |
| ភាវៈនៃបុថុជ្ជន | " | ត្តន | បុថុជ្ជនត្តន : |
| [illegible] | [illegible] | " | វេទនត្តន : |

[illegible] គឺតទ្ទិតដែលចុះក្នុងអត្ថនៃអព្យយសព្ទ [illegible] ប្រែដោយលិង្គ, វចនៈ, បុរុស [illegible] ថា អព្យយសព្ទ (Mots invariables) ;

www.elibraryofcambodia.org

តទ្ធិតដែលចុះក្នុងអង្គនៃសព្វនាមសព្ទនោះ ហៅថា សព្វនាមតទ្ធិត ។ ក្នុងតទ្ធិតនេះក៏មានបច្ច័យចុះជាច្រើនដែរ តែក្នុងទីនេះ នឹងស្ដែងតែត្រឹម ៣ គឺ ថា, ថំ, ធា ។ តទ្ធិត ៦ ខាងដើម គឺសាមញ្ញតទ្ធិត នឹងការតទ្ធិតនោះ ត្រូវលុបសព្ទខ្លះចោល ហើយចុះបច្ច័យថែមម. តែក្នុងតទ្ធិតនេះ ឲ្យផ្លាស់សព្ទពីទម្រាយទៅជាសព្ទផ្សេង ហើយឲ្យចុះបច្ច័យថែមម. ចូរមើលតួយ៉ាងដែលផ្លាស់សព្ទ នឹងចុះបច្ច័យខាងចុងសព្ទដែលផ្លាស់ថ្មីនោះ ដូចតទៅនេះ :

| សព្ទដើម | ផ្លាស់ជា | បច្ច័យ | សព្ទសម្រេចហើយ |
|---|---|---|---|
| ប្រការឯណា | យ | ថា | យថា |
| ប្រការនោះ | ត | ,, | តថា |
| ប្រការដទៃ | អញ្ញ | ,, | អញ្ញថា |
| ប្រការក្រៅនេះ | ឥតរ | ,, | ឥតរថា |
| ប្រការទាំងពួង | សព្វ | ,, | សព្វថា |
| ប្រការដូចម្ដេច | ក | ថំ | កថំ |
| ប្រការនេះ | ឥ | ,, | ឥត្ថំ |
| ប្រការមួយ | ឯក | ធា | ឯកធា |

www.elibraryofcambodia.org

| សព្ទដើម | ផ្លាស់ជា | បច្ច័យ | សព្ទសម្រេចហើយ |
|---|---|---|---|
| ប្រការពីរ | ទុ | " | ទុវិធ |
| ប្រការបី | តិ | " | តិវិធ |
| ប្រការបួន | ចតុ | " | ចតុព្វិធ |
| ប្រការដប់ | ទស | " | ទសវិធ |

## វិញ្ញាសាបទទី ២

១— ពាក្យនិយាយក្នុងភាសាទីមួយៗ មានច្រើនដល់ប៉ុន្មានពាក្យទៅ? ក្នុងភាសាយើង មានពាក្យច្រើនប្រហែលនឹងសៀវភៅ ប្រហែលប៉ុណ្ណា?

២— ពាក្យនិយាយមានច្រើនដូច្នោះមែនហើយ ប៉ុន្តែបើយើងរើសយកផ្ញើជាក្រុមៗ ដោយសំដៅយកតែមេពាក្យធំៗ បានឬទេ? បើមិនបានក៏ហើយទៅ តែបើបានតើមានប៉ុន្មាន? អ្វីខ្លះ? ចូររាប់មើល!

៣— នាមប្រែថាម៉េច? អ្វីហៅថា នាម? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

៤ សព្វនាម ប្រែយ៉ាងណា? បានដល់អ្វី? ចូរពាញ

www.elibraryofcambodia.org

ឧទាហរណ៍! ហើយយើងមិនចង់ហៅថា សាមាន្យនាម នឹងហៅថាម៉េចទៅវិញ?

៥ - វិសាមាន្យនាម គឺនាមយ៉ាងម៉េច? ខ្មែកពីសាមាន្យនាមយ៉ាងណា? ចូរទាញឧទាហរណ៍មកឲ្យលំផង! ហើយយើងមិនត្រូវការហៅថា វិសាមាន្យនាម នឹងហៅថាម៉េចទៅវិញ?

៦ -- មនុស្សឈ្មោះម៉ុក ដល់ទៅ៦នាក់ យើងគិតរក្សាដូចម្តេចកុំឲ្យច្រឡំគ្នា? ចូរនិយាយឲ្យល្អស្តាប់បាន!

៧ – នាមនាមប្រែថាម៉េច? បានដល់អ្វី? ឧទាហរណ៍យ៉ាងណា? មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

៨ - ការណនាមនាមបានសេចក្តីដូចម្តេច? ខ្មែកពីករណនាមធម្មតាយ៉ាងណា? ចូរទាញឧទាហរណ៍ឲ្យបាន៥យ៉ាងម.ផង!

៩ - ការកនាមនាម គឺនាមនាមយ៉ាងម៉េច? ខ្មែកពីការកនាមធម្មតាយ៉ាងណា? ចូរទាញឧទាហរណ៍ឲ្យបាន៥យ៉ាងម.ផង!

១០ – ឧទាហរណ៍ខាងក្រោមនេះ ណាជានាមអ្វី? ការថ្នល់ ណាល់, អ្នកថ្នល់, ថ្នល់, អ្នកការថ្នល់; អ្នកព្រៃ, ការព្រៃ, ពាំព្រៃ, អ្នកការព្រៃ, ព្រៃម; ការដ្ឋ, វេជ្ជ, ម៉េជ្ជ, អ្នកដ្ឋ,

www.elibraryofcambodia.org

អ្នកការវដ្ដ ។

១១ – គុណនាម គឺនាមយ៉ាងណា? បានដល់អ្វី? ចូរទាញឧទាហរណ៍ឲ្យបាន៥-៦ យ៉ាងម.ផង!

១២ – គុណនាមផ្នែកពីអាការនាមយ៉ាងណា? ចូរអធិប្បាយអាងឧទាហរណ៍!

១៣ – ចូរបំប្លែកពាក្យគុណទាំងឡាយនេះ ឲ្យ[illegible]-នាម : ខ្ពំ, ខ្វប, ទុំ, ខ្លៅ, ខ្ជាប, ខ្ជះ, ខ្ជៅ, ថ្លឹង, [illegible], [illegible], ថ្លៃ, ល្ងង់, ក្អើ, ព្រើល, ស្រោល ហើយចូរត្រឡប់ពាក្យគុណ-នាមទាំងឡាយនេះ ឲ្យទៅជាពាក្យគុណវិញ : កំលើ, កំលាំង, កំសោយ, ជំនួរ, សំកូវ, សំណា, សំណាប, តំណើង, ចំហូរ, កម្រង់, កម្រៅ ។

១៤ – អាការនាមនោះ គឺនាមយ៉ាងណា? បានដល់អ្វី?

១៥– មានពាក្យជាមេប៉ុន្មាន: ដែលសម្រាប់យ.ម.ភ្ជាប់នឹងពាក្យគុណសុទ្ធឲ្យក្លាយទៅជាអាការនាម? ចូរលើកទាំងឧទាហរណ៍ណាម.ផង!

១៦- ចូរត្រឡប់ពាក្យគុណនាមទាំងឡាយនេះ ឲ្យទៅជាអា

www.elibraryofcambodia.org

ការនាមៈ ដំរែអ, កម្រេក, តម្រូវ, កំហុស, កំពៅ, ចំណែក, កំពុំ, កំពោះ, តម្ងន់ ចម្ងល់, សម្រាល ។

១៧- នាមយ៉ាងម៉េច ហៅថា កិរិយានាម? ចូរអធិប្បាយ

១៨– កិរិយានាម ប្លែកពីការនាមយ៉ាងណា? ចូរទាញឧទាហរណ៍

១៩- ឧទាហរណ៍តទៅនេះ ណាជាការនាម ណាជាកិរិយានាម? ការដើរ, ការធំ, ការហាប់, ការជាត់, ការខ្ពស់, ការល្អ, ការដេ, ការរញ្ញ, ការឈាន, ការឈប់, ការកក្រក់, ការខ្លាច, ការឲ្យ, ការខ្ជិល ។

២០- ពាក្យថា : ការផ្ទះ, ការស្រុក, ការស្រែ, ការចំការ, ការជំនិត, ការសាសនា, ការទឹកដី នេះជាកិរិយានាមមែនឬទេ? អ្វី?

២១- ករណនាមនោះតើអ្វី? ផ្អួនដល់អ្វី?

២២ ករណនាមផ្សេងពីកិរិយានាមយ៉ាងណា? ដើរ ដេ បើជាកិរិយានាមថាម៉េច? បើជាករណនាមថាម៉េច?

២៣- ចូរកំណាយពាក្យកិរិយាទាំងឡាយតទៅនេះ ឲ្យក្លាយទៅជាករណនាម? កាត់, កើត, ទឹង, ដោត, គាប, គួរ, យាត់, ឃើញ,

www.elibraryofcambodia.org

ដើម, ចិក, ចៀរ, ជី, ដេះ, ជាន់, ជាប់, ឈើ, ឈោង, ញៀន, ដុះ,

ផោល, បិក, ឱ, ណៃ, គោន, គាំង, ថើប, ថែម, ទើង, ទៅ, ធើ,

ទឹក, នាំ, បាក់, ចៅ, ផាក់, ធុន, ពួន, ដាំ, ករ, កើប, ម, មាន,

យោក, យោង, រែក, កំ, លាន, លិច, កំយ, វះ, សើច, សើយ,

ហោះ, ហៅ, ខ្សែក, ទៀន, អរ, គោប ។

២៤- ការកនាម គឺនាមយ៉ាងណា? ចេញមកពីអ្វី ?

២៥- ការកនាមផ្សេងពីករណនាមយ៉ាងម៉េច? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? អធិប្បាយ!

២៦- កិរិយាការកនាមបានសេចក្ដីជាម៉េច? ចូរទាញឧទាហរណ៍ ?

២៧- នាមការកនាម គឺការកនាមយ៉ាងណា? ផ្សេងពីកិរិយាការកនាមដូចម្ដេច ?

២៨- ឧទាហរណ៍តទៅនេះ ណាជានាមអ្វី? អ្នកដើរ, ថ្នើរ, អ្នកទុក, ធ្នុក, អ្នកទប់, ទ្នប់, អ្នកដេក, ប្នេក, អ្នកតាំង, ត្នាំង, អ្នកផឹក, បំផឹក, អ្នកបង់, ផ្នង់, អ្នកបាញ់, ផ្នាញ់, អ្នកបួស, ផ្នួស, អ្នកជួញ, ឈ្នួញ, អ្នកចាំ, ឆ្នាំ, អ្នកកាន់, ខ្នាន់, អ្នកដាល់, ហ្នាល់,

www.elibraryofcambodia.org

អ្នកលោត, ល្នោត, អ្នកចាក់, ច្នាក់, អ្នកចោង, ច្នោង, អ្នកសរសេរ, ស្នេរ, អ្នកលេង, ល្នេង, អ្នកដេក, ដេក, អ្នកសូត្រ, ស្នូត្រ, អ្នកសូទ, ស្នូទ, អ្នកសូម, ស្នូម, អ្នកសុំ, ស្នុំ ។

២៩ – [illegible]នសេចក្តីថាម៉េច? ចូរអធិប្បាយហើយ ទា[illegible]

៣០ – អរូបនាមនោះយ៉ាងណា? សំដៅដល់អ្វី? ចូរអធិប្បាយ ហើយទាញ ១ ឧទាហរណ៍ !

៣១ – ទេវតា, ព្រះឥន្ទ្រ, ព្រះព្រហ្ម, ព្រះយមរាជ ក៏ជាអរូបនាមដែរមែនទេ ឬ?

៣២ – សមូហនាមនោះ បានដល់ពាក្យថាម៉េច? អធិប្បាយយ៉ាងម៉េច? បានដល់អ្វី?

៣៣ – សមូហនាមផ្សេងពីសាមាន្យនាមយ៉ាងណា?

៣៤ – សមូហនាម បើយើងចង់ដឹងឲ្យល្អិតទៅទៀត តើត្រូវធ្វើដូចម្ដេច?

៣៥ – ពាក្យថា: ស្រុកទេស, សាលា, សមោសរ នេះ តើយ៉ាងណាជាសាមាន្យនាម? យ៉ាងណាជាសមូហនាម?

www.elibraryofcambodia.org

៣៦ – លក្ខណនាម ប្រែដូចម្ដេច? បានដល់អ្វី?

៣៧ – លក្ខណនាមនិងសាមាន្យនាមផ្សេងគ្នាយ៉ាងណា?

៣៨-លក្ខណនាមនិងសមុហនាមៈផ្សេងគ្នាឬដូចគ្នា? អធិប្បាយ!

៣៩ – លក្ខណនាម មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

៤០– លក្ខណនាមប្រាប់ចំណែក បានដល់ពាក្យថាម៉េចខ្លះ? សិង, ទៀត, ក្បាល សម្រាប់ប្រើនឹងពាក្យអ្វីបានខ្លះ? ចូរទាញឧទាហរណ៍!

៤១ – លក្ខណនាមប្រាប់ពួកគង បានដល់ពាក្យថាម៉េចខ្លះ? ពេន, គាប់, ក្រាស់ សម្រាប់ប្រើនឹងពាក្យអ្វីខ្លះ? ចូរទាញឧទាហរណ៍!

៤២ – លក្ខណនាមប្រាប់សណ្ឋាន បានដល់ពាក្យថាម៉េចខ្លះ? ពាក្យថាៈ បាំង, ដង, មាត់ សម្រាប់ប្រើនឹងពាក្យថាម៉េចខ្លះ? ចូរទាញគួយ៉ាង!

៤៣ – លក្ខណនាមប្រាប់ប្រមាណ បានដល់ពាក្យថាម៉េចខ្លះ? ពាក្យថាៈ កុលិនិងហោ សម្រាប់ប្រើនឹងពាក្យថាម៉េចខ្លះ? ចូរទាញគួយ៉ាង!

www.elibraryofcambodia.org

៤៤– លក្ខណនាមប្រាប់អាការៈ មានពាក្យថាម៉េចខ្លះ ពាក្យថាប៉ុ, ម្ដេច សម្រាប់ប្រើនឹងពាក្យថាម៉េចខ្លះ? ចូរទាញឧទាហរណ៍!

៤៥– លក្ខណនាមផ្ទុយឈ្មោះ គឺលក្ខណនាមយ៉ាងម៉េច? បានផ្សំពាក្យប៉េះងណា? ចូរទាញឧទាហរណ៍!

៤៦ – បើយើងនិយាយថា: កក្កុកក្កុក, ទៅតាញទៅតា ដូច្នេះបានឬទេ? ព្រោះហេតុអ្វី?

៤៧. សមាសនាមបានសេចក្ដីដូចម្ដេច? នាមយ៉ាងណាទើបបានហៅថា សមាសនាម? ចូរអធិប្បាយ!

៤៨. សមាសនាមនឹងយោគពាក្យនោះផ្សេងគ្នា ឬដូចគ្នា? ចូរទាញឧទាហរណ៍ សមាសនាមនឹងយោគពាក្យបាន ២-៣ ឧទាហរណ៍មើល?

៤៩. សមាសនាមនោះ មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

៥០. កម្មធារយសមាស គឺសមាសដូចម្ដេច? ឧទាហរណ៍យ៉ាងណាខ្លះ?

៥១. ទ្វិគុសមាសនោះ ដូចម្ដេច? អធិប្បាយយ៉ាងណា? ឧទាហរណ៍ម៉េចខ្លះ?

www.elibraryofcambodia.org

៤២-បទណាផ្សំនឹងបទណា ទើបហៅថាតប្បុរិសសមាស ? អធិប្បាយ ហើយទាញឧទាហរណ៍ !

៤៣-ដូចម្ដេច ហៅថា ទ្វន្ទសមាស ? ឧទាហរណ៍ដូចម្ដេច?

៤៤- អព្យយីភាវសមាសអធិប្បាយដូចម្ដេច ? ឧទាហរណ៍ យ៉ាងណា ?

៤៥- មានសេចក្ដីអធិប្បាយដូចម្ដេច ពហុព្វីហិសមាស ? ឧទាហរណ៍យ៉ាងណា ?

៤៦-នាមដូចម្ដេចដែលហៅ តទ្ធិតនាម? អធិប្បាយម.មើល!

៤៧- តទ្ធិតបានសេចក្ដីដូចម្ដេច? តទ្ធិតនាមស្ដែងដោយកិច្ច មានប៉ុន្មានយ៉ាង? អ្វីខ្លះ ?

៤៨- អប្បច្ច័យកតទ្ធិតនាមនោះ គឺតទ្ធិតដូចម្ដេច? ផ្សេងពីយោគពាក្យដូចម្ដេចខ្លះ ?

៤៩- ពាក្យយ៉ាងណាដែលគួរយ.ម.ដាក់ខាងណាពាក្យណា ទើបហៅថាអ្វី? ចូរទាញគួរយ៉ាងឲ្យបាន១០ ឧទាហរណ៍ម.មើល !

៥០- ពាក្យថា: មនុស្សកំពង់ស្ពឺ, អ្នកកំពង់ស្ពឺ នេះណា ជាពាក្យអ្វី ?

www.elibraryofcambodia.org

៦១- ពាក្យថា: អ្នករៀន, អ្នកលក់, អ្នកទិញ, អ្នកមើល នេះហៅថា អប្បច្ចយិកតទ្ធិតនាមបានឬទេ? បើបានក៏ហើយទៅ? បើមិនបានតើព្រោះហេតុអ្វី ?

៦២-បច្ចយិកតទ្ធិតនាម គឺតទ្ធិតដូចម្តេច? ពាក្យថា: កម្ពោជ: នេះសម្រេចមកពីសព្ទដើមថាម៉េច? ចូរអធិប្បាយ !

៦៣- បច្ចយិកតទ្ធិតនាមនោះ ដោយសង្ខេបមានប៉ុន្មានយ៉ាង? អ្វីខ្លះ ?

៦៤- សាមញ្ញតទ្ធិត គឺតទ្ធិតដូចម្តេច? មានបច្ច័យប៉ុន្មានយ៉ាង? អ្វីខ្លះ?

៦៥- កម្ពោជ: នេះជា ណ បច្ច័យ, តែបើចុះ ណិក បច្ច័យវិញបានឬទេ? សម្រេចរូបជាយ៉ាងម៉េចទៅវិញ? ចូរអធិប្បាយ !

៦៦. សៀមិក:, ភូមិក:, អណ្ណាមិក: សម្រេចមកពីរូបដើមថាម៉េច ? ទីដ៏ជាបច្ច័យអ្វី ? ចូរអធិប្បាយ !

៦៧. ភាវតទ្ធិតនោះយ៉ាងណា? មានបច្ច័យប៉ុន្មានតួ? អ្វីខ្លះ?

៦៨- ពាក្យថា: បណ្ឌិច្ច, សោវច្ច, រាជ្យទីនកតញ្ញុតា, កតវេ-ទិតា, សាមគ្គិតា នេះណាចុះបច្ច័យអ្វី? សម្រេចមកពីពាក្យដើមថាម៉េច?

www.elibraryofcambodia.org

៦៩- ដូចម្ដេច ហៅថា អព្យយកត្តិក? វិធីសម្រេចរូបក្នុង អព្យយកត្តិកនេះ មានវិធីផ្សេកពីកត្តិកទាំងពីរខាងដើមដូចម្ដេចខ្លះ ? ឲ្យផ្លាស់សព្វណាជាអ្វីខ្លះ ?

## លិង្គ (Genre)

ក្នុងពេលដែលទើបនឹងនិយាយអំពីនាមរួចនោះ មានរបស់ដែលសំខាន់ ហើយត្រូវមានដំណើរជាប់ទាក់ទងជាមួយគ្នានឹងនាមនោះផង, របស់សំខាន់នោះ ក៏គឺលិង្គនឹងវចនៈ: របស់ទាំង ២ យ៉ាងនេះ នាមនឹងសព្វនាម ទីងពេលបោះបង់មិនបានឡើយ ត្រូវតែជាប់ទាក់ទងជាមួយផង, ដូច្នេះ តទៅនេះ នឹងត្រូវនិយាយអំពីលិង្គជាមុន ។

ភេទ ឬ លក្ខណៈសម្រាប់សំគាល់ នាម ឬ សព្វនាម ដែលប្រព្រឹត្តទៅដោយអាការៈផ្សេក ៗ គ្នា ហៅថា លិង្គ; ក្នុងកម្ពុជៈ មាន ៤ យ៉ាងគឺ បុល្លិង្គ ១, ឥត្ថីលិង្គ ១, នបុំសកលិង្គ ១, អលិង្គ ១ ។

បុល្លិង្គ "ភេសបុរស[១] (Masculin)" នេះបានដល់ពួក

(១) ពាក្យថា "ភេស" ធ្លាប់ប្រើមកថា "ភេទ" ខ្លះ "ប្រភេទ" ខ្លះ ដែលត្រូវគួរប្រើថា "ភេស" ។ ចំពោះពាក្យដែលសម្រាប់ញែកឲ្យឃើញសភាពផ្សេកគ្នា នៃមនុស្សប្រុសស្រី សត្វញីឈ្មោល ។

www.elibraryofcambodia.org

សវិញ្ញាណកជនដូចយ៉ាងៈ ទេវបុត្រ, មនុស្ស, យក្ស, គន្ធព្វ, បិសាច នាគ, គ្រុឌ, ឬសត្វតិរច្ឆាន ដែលមានទ្រង់ទ្រាយ ឬសណ្ឋានជាប្រុស, មានគ្រឿងប្រដាប់ប្លែកខ្លួនពីស្រី ឬពីញី ។ ជនពួកនេះឯងរាប់ថាជាបុល្លិង្គ ព្រោះមានភេទជាប្រុស ឬមានភេទដូចប្រុស ។ ពាក្យសម្រាប់សំគាល់ឲ្យដឹងថាជាបុល្លិង្គនោះ មានពាក្យខ្លះមានដើមកំណើតជាបុល្លិង្គស្រេចតែម្ដង, ពាក្យខ្លះជាពួកអលិង្គ កាលណាបើយកពាក្យជាបុល្លិង្គទៅដាក់ភ្ជាប់ពីខាងមុខ ឬពីខាងក្រោយហើយក៏ក្លាយទៅជាបុល្លិង្គទៅ ។ មានពាក្យខ្លះជានបុំសកលិង្គ ប៉ុន្តែកាលណាបន្ថែមស្រៈវិបផុតខាងចុង ឬប្ដូរព្យញ្ជនៈខាងចុង ឲ្យខ្លួនផ្សេងបន្តិចទៅ ក៏ទៅជាបុល្លិង្គទៅ ។

ឥត្ថីលិង្គ "ភេទស្រី (féminin)" នេះបានដល់ពួកសវិញ្ញាណកជនមួយយ៉ាងដូចជាៈ ទេវតា, មនុស្ស, យក្ស, គន្ធព្វ បិសាច, គ្រុឌ ឬសត្វតិរច្ឆាន ដែលមានសណ្ឋានទ្រង់ទ្រាយជាស្រី, មានអង្គជាតិ ឬយោនីទុកនៅខ្លួនពីប្រុស ឬពីឈ្មោល; ជនពួកនេះឯង រាប់ថាជាឥត្ថីលិង្គ ព្រោះមានភេទជាស្រី ឬមានភេទដូចជាស្រី ។ ពាក្យសម្រាប់សំគាល់ឲ្យដឹងថាជាឥត្ថីលិង្គនោះ, មាន

www.elibraryofcambodia.org

ពាក្យខ្លះមានដើមកំណើតជាឥត្ថីលិង្គស្រេចតែម្តង, ពាក្យខ្លះជាពាក្យពួកឥលិង្គ កាលណាយ.ពាក្យជាឥត្ថីលិង្គទៅដាក់ភ្ជាប់ពីខាងដើម ឬពីខាងចុង ក៏ក្លាយទៅជាឥត្ថីលិង្គទៅ, មានពាក្យខ្លះជានបុំសកលិង្គ ឬជាឥលិង្គ ប៉ុន្តែកាលណាបន្ថែមស្រៈអីបំផុតខាងចុង ឬចុះបច្ច័យខាងចុងឲ្យប្លែកផ្សេងពីបទដើមទៅ ក៏ក្លាយទៅជាឥត្ថីលិង្គទៅ?

ឃ. នបុំសកលិង្គ: "មិនមែនភេទបុរស មិនមែនភេទស្ត្រី (Neutre)" នាមដែលមិនមែនភេទបុរស មិនមែនភេទស្ត្រីគឺភេទឡើយ នេះបានដល់សវិញ្ញាណកជនទាំងពួក ដូចជា មនុស្ស, យក្ស, នាគ, គ្រុឌ ឬតិរច្ឆានពួកខ្លះ ដែលមានភេទមិនប្រាកដជាជាបុរស ជាស្ត្រី ជាឈ្មោល ជាញី. ។ ប្រុស ឬឈ្មោលក៏ស្មើរស្រី ឬញី ក៏ស្មើរ គឺមានភេទគ្រាន់តែបន្ទាប់បន្សំព្រោះកើតតែប្រើការសេពសម្គមមិនកើតនេះឯងហៅថា នបុំសកលិង្គ, ដោយហេតុមានភេទមិនប្រាកដជាប្រុស ឬស្រី ពាក្យសម្រាប់សំគាល់ឲ្យដឹងថា ជានបុំសកលិង្គ នោះបានដល់ពាក្យដែលជាឈ្មោះនៃអវិញ្ញាណកវត្ថុ គឺរបស់ដែលមិនមានវិញ្ញាណ មិនមានចិត្តគំនិត ដូចជា: ឈើ, ព្រៃ, ស្មៅ, វល្លិ, បន្លែ, ភូមិ, ស្រុក,

www.elibraryofcambodia.org

ប្រទេស, ដែន, នគរ, ក្រុង, ដី, ទឹក, ភ្លើង, ខ្យល់, ដៃ, ជើង, ក្អែក, ក្រចៀក, ច្រមុះ, មាត់ អម្បាលនេះជាដើម នាមផ្នែកនេះ ត្រូវតែជានបុំសកលិង្គមួយយ៉ាងប៉ុណ្ណោះឯង ។

អលិង្គ "នាមដែលមិនមានភេទ សម្រាប់សំគាល់ គឺនាមដែលមានភេទរួម" គឺពាក្យនាមដែលមិនប្រាកដថាជាលិង្គអ្វីដែលមិនមានគ្រឿងសំគាល់ គ្រឿងចំណាំ ឬជាពាក្យនាមដែលមានភេទរួមគ្នា គឺជាជាបុល្លិង្គក៏បាន ជាឥត្ថីលិង្គក៏បាន នេះបានដល់ពាក្យដែលជាឈ្មោះនៃសព្វញ្ញាណកជនទាំងផ្នែកដែលមានភេទប្រាកដជាបុរស ឬស្ត្រី ដូច្នោះដែរ ប៉ុន្តែពាក្យដែលជាឈ្មោះសម្រាប់ហៅសព្វញ្ញាណកជនពួកនោះ សុទ្ធតែបានទាំង ២ លិង្គ គឺជាបុល្លិង្គក៏បាន ជាឥត្ថីលិង្គក៏បាន មិនប្រាកដថាជាបុរស ឬជាស្ត្រីឲ្យទៀងទាត់ ទាល់តែយ.ពាក្យដែលមានកំណើតជាបុល្លិង្គ ឬជាឥត្ថី-លិង្គស្រាប់នោះ នៅដាក់ភ្ជាប់ពីខាងមុខ ឬពីខាងក្រោយ នោះទើបប្រាកដទៅជាបុល្លិង្គ ឬជាឥត្ថីលិង្គទៀងទាត់បាន ពាក្យបែបនេះឯង ដែលហៅថា អលិង្គ ។ ព្រោះមានសភាពមិនប្រាកដឲ្យដាច់ខាតថាជាបុល្លិង្គ ឬជាឥត្ថីលិង្គបាន ដូចជាពាក្យថា: កូនកុល

www.elibraryofcambodia.org

ឬប៉ុនគល់, ជីទួត, ជីលា, ជីលួត, ជីខ្មួត, កូន, ចៅ, ចៅ, ក្មួយ, ក្មេង, បង, ប្អូន, លោក, អ្នក, ខ្ញុំ, សត្តាន, ក្រៀងលាន, សេះ, ដំរី, ក្របី, ខ្លា, ទន្សោង, ទន្សាយ, ទន្សង, ពពែ, ចៀម, ឆ្កែ, ឆ្មា, មាន់, ទា ជាដើម អម្បាលនេះជា អលិង្គ ព្រោះមិនទាន់ប្រាកដជាភេទអ្វីនៅឡើយ, លុះតែមានពាក្យថា: ប្រុស, ស្រី, ឈ្មោល, ញី ម.ផ្សំផង ទើបប្រាកដថាជាបុល្លិង្គ ឬជាឥត្ថីលិង្គបាន ពាក្យទាំងអម្បាលនេះ មិនមានបច្ច័យសម្រាប់បង្វែរឲ្យទៅជាបុល្លិង្គ ឬជាឥត្ថីលិង្គឡើយ មានតែពាក្យទាំង ៤ ម៉ាត់ គឺប្រុស, ស្រី, ឈ្មោល, ញីម.ផ្សំប៉ុណ្ណោះ ទើបនឹងក្លាយទៅជាបុល្លិង្គ ឬជាឥត្ថីលិង្គបាន ។

ពាក្យតទៅនេះ គឺពាក្យដែលមានកំណើតជាបុល្លិង្គ ឬឥត្ថីលិង្គស្រេចតែម្ដង:

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| ជីតា | ជីដូន | អា | ហន |
| តា | យាយ | ម៉ឹង | នែង |
| ឪពុក | ម្ដាយ | ពញា | |
| ឪ, ប៉ៃ | ម៉ែ | ម៉ឺន | |

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| ប៉ា,ប៉ះ | ម៉ះ | ហ្លួង | |
| ពុ. | មេ | ឧកហ្លួង | |
| បិតា | មាតា | ព្រះ | |
| ឪពុកធំ | ម្ដាយធំ | ឧកញ៉ា | ជំទាវ |
| ឪពុកមា | ម្ដាយមីង | ឈ្មោល | ញី |
| មា,ពូ | មីង | ពានហ្លួង | |
| បុរស | ស្ត្រី | ចៅហ្វាយ | |
| ប្រុស | ស្រី | គេ | គី |
| កំលោះ | កំមុំ | គេ | គី |
| ប្ដី | ប្រពន្ធ | អមោរី | អមោរិនី |
| នាយ | នាង | អចលគេរី | អចលគេរិនី |
| ក្លើ | ម្រាក់ | សមុទ្ររី | សមុទ្ររិនី |
| ពុកម៉ាយ | មេម៉ាយ | ពាតុប | ពាតា |

ពាក្យតទៅនេះជាអលិង្គ កាលណាយ.ពាក្យដែលមានកំ-ណើតជាបុល្លិង្គ ឬឥត្ថីលិង្គម.ដាក់ភ្ជាប់ខាងដើម ឬខាងចុង ក៏

www.elibraryofcambodia.org

ក្លាយទៅជាបុល្លិង្គ ឬឥត្ថីលិង្គទៅ ។

| ពាក្យអលិង្គដើម | ប្រែកបឲ្យជាបុល្លិង្គ | ប្រែកបឲ្យជាឥត្ថីលិង្គ |
|---|---|---|
| ចុងកុល ឬ | ចុងកុលប្រុស ឬ | ចុងកុលស្រី ឬ |
| ចុងគល់ | ចុងគល់ប្រុស | ចុងគល់ស្រី |
| ជីប៉ា | ជីប៉ាប្រុស | ជីប៉ាស្រី |
| ជីលា | ជីលាប្រុស | ជីលាស្រី |
| ជីលួត | ជីលួតប្រុស | ជីលួតស្រី |
| ជីទួត | ជីទួតប្រុស | ជីទួតស្រី |
| បង | បងប្រុស | បងស្រី |
| ប្អូន | ប្អូនប្រុស | ប្អូនស្រី |
| អូន | អូនប្រុស | អូនស្រី |
| កូន | កូនប្រុស | កូនស្រី |
| ចៅ | ចៅប្រុស | ចៅស្រី |
| ចៅ | ចៅប្រុស | ចៅស្រី |
| ក្មួយ | ក្មួយប្រុស | ក្មួយស្រី |
| ក្មេង | ក្មេងប្រុស | ក្មេងស្រី |

www.elibraryofcambodia.org

| ពាក្យអលិង្គដើម | ប្រកបឲ្យជាបុល្លិង្គ | ប្រកបឲ្យជាឥត្ថីលិង្គ |
|---|---|---|
| ជនួង | ជនួងប្រុស | ជនួងស្រី |
| ក្មេក | ឪពុកក្មេក | ម្ដាយក្មេក |
| ប្រសា | កូនប្រសាប្រុស | កូនប្រសាស្រី |
| សន្ដាន | សន្ដានប្រុស | សន្ដានស្រី |
| ព្រៀងលាន | ព្រៀងលានប្រុស | ព្រៀងលានស្រី |
| លោក | លោកប្រុស | លោកស្រី |
| អ្នក | អ្នកប្រុស | អ្នកស្រី |
| អុំ | អុំប្រុស | អុំស្រី |
| ក្របី | ក្របីឈ្មោល | ក្របីញី |
| សេះ | សេះឈ្មោល | សេះញី |
| ដំរី | ដំរីឈ្មោល | ដំរីញី |
| ជ្រូក | ជ្រូកឈ្មោល | ជ្រូកញី |
| ឆ្កែ | ឆ្កែឈ្មោល | ឆ្កែញី |
| ឆ្មា | ឆ្មាឈ្មោល | ឆ្មាញី |
| ទន្សោង | ទន្សោងឈ្មោល | ទន្សោងញី |

www.elibraryofcambodia.org

| ពាក្យសព្ទដើម | ប្រកបឲ្យជាបុល្លិង្គ | ប្រកបឲ្យជាឥត្ថីលិង្គ |
|---|---|---|
| ទន្សាយ | ទន្សាយឈ្មោល | ទន្សាយញី |
| ទន្សោង | ទន្សោងឈ្មោល | ទន្សោងញី |
| កុក | កុកឈ្មោល | កុកញី |
| ក្រសា | ក្រសាឈ្មោល | ក្រសាញី |
| ក្អែក | ក្អែកឈ្មោល | ក្អែកញី |
| ក្ងោក | ក្ងោកឈ្មោល | ក្ងោកញី |
| ក្ងាន | ក្ងានឈ្មោល | ក្ងានញី |

ក្រៅពីពាក្យទាំងពីរពួក ដែលបាននិយាយមកហើយនោះ, ដើម្បីនឹងឲ្យស្គាល់បានថា ពាក្យណាជាលិង្គណានោះ ត្រូវស្គាល់បានដោយសារបច្ច័យ, កាលបើនិយាយអំពីបច្ច័យនោះ កុំគប្បីជ-ភាសាយើងនេះ មានបច្ច័យ ១៧ គឺ (១) អា,ក្បៀ,ឥនី; ឥយៀនី,នៈបន អាំង,ឯន,អេស,អែស,អុង,អោន,ឥស្ម,ឯរ,ឯរេស,ឥក,អានៈ ឥរ

---

(១) បច្ច័យទាំង ១៧ នេះ អ្នកប្រាជ្ញកម្ពុជបង្កើតឡើង សម្រាប់ប្រើក្នុងកម្ពុជភាសាឲ្យចំរើនទាន់អារ្យភាសាតនានាប៉ុណ្ណោះ ប្រសិនបើមិនប្រើទាំងអស់ [illegible]ងាយ ចំពោះបច្ច័យណាមួយក៏បាន បើមិនប្រើទាំងអស់ ក៏មិនជាអ្វី តែកម្ពុជភាសានឹងមិនអាចចំរើនទាន់អារ្យភាសាតនានាបានឡើយ ។

www.elibraryofcambodia.org

នេះដោយមិនកប់បច្ច័យក្នុងគត្តិតនាមទឹងបទបូណោបច្ច័យខ្លះ ដែលទឹងមាននិយាយក្នុងពាក្យវិលាសិទចូលផង ។

ក- បច្ច័យសម្រាប់ចុះខាងចុងពាក្យដែលមានរូបដើមបុល្លិង្គជា "អ" ហើយលុប "អ" នេះចោល ដើម្បីឲ្យពាក្យនោះ ក្លាយទៅជាឥត្ថីលិង្គ ។

ពាក្យតទៅនេះជាទ្វិលិង្គិកៈ គឺបុល្លិង្គនឹងឥត្ថីលិង្គ ពាក្យចំបផុតបុល្លិង្គជា "ក" ត្រូវចុះ "កា" បច្ច័យ ហើយផ្លាស់ "អ" នៃព្យញ្ជនៈខាងដើម "ក" ជា "ឥ" :

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| អយ្យក | អយ្យិកា | សមាជក | សមាជិកា |
| ទាយក | ទាយិកា | សាវក | សាវិកា |
| កុមារក | កុមារិកា | ទេសាសក | ទេសាសិកា |
| ទារក | ទារិកា | ប្រកាសក | ប្រកាសិកា |
| ឧបាសក | ឧបាសិកា | មគ្គទេសក | មគ្គទេសិកា |
| អនុសាសក | អនុសាសិកា | មគ្គុទ្ទេសក | មគ្គុទ្ទេសិកា |

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| នាយក | នាយិកា | យាចក | យាចិកា |
| មគ្គនាយក | មគ្គនាយិកា | រសក | រសិកា |
| ឧបត្ថមក | ឧបត្ថមិកា | ពេបក | ពេបិកា |
| ទាបក | ទាបិកា | សាកុដក | សាកុដិកា |
| សាវក | សាវិកា | ទាយក | ទាយិកា |
| អាជីវក | អាជីវិកា | យាយក | យាយិកា |
| បរិព្វាជក | បរិព្វាជិកា | វធក | វធិកា |
| អចេលក | អចេលិកា | ខាទក | ខាទិកា |
| សាសក | សាសិកា | សញ្ញាទទក | សញ្ញាទទិកា |
| លេខក | លេខិកា | ឃាតក | ឃាតិកា |
| លុម្ពក | លុម្ពិកា | ពេជ្ជឃាតក | ពេជ្ជឃាតិកា |
| ភត្តុរក | ភត្តុរិកា | គោឃាតក | គោឃាតិកា |
| ភទក | ភទិកា | ញាតក | ញាតិកា |
| វិចារក | វិចារិកា | លេបក | លេបិកា |
| វិទូបក | វិទូបិកា | វិលាសក | វិលាសិកា |

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| វិនាយក | វិនាយិកា | កត្តការក | កត្តការិកា |
| វិភាជក | វិភាជិកា | សូបការក | សូបការិកា |
| កត្តុទ្ទេសក | កត្តុទ្ទេសិកា | កម្មការក | កម្មការិកា |
| ការក | ការិកា | កិត្តុទូសក | កិត្តុទូសិកា |
| ភាសក | ភាសិកា | ពុទ្ធមាមក | ពុទ្ធមាមិកា |
| សិក្ខក | សិក្ខិកា | ធម្មកថក | ធម្មកថិកា |
| គាយក | គាយិកា | សាធក | សាធិកា |
| ភាវក | ភាវិកា | ភាសបរិវត្តក | ភាសបរិវត្តិកា |

ឦ- បច្ច័យ សម្រាប់ចុះខាងចុងពាក្យដែលមានរូបដើមបុល្លិង្គ ជាសរៈ"អ" ដើម្បីឲ្យពាក្យនោះ ក្លាយទៅជាឥត្ថីលិង្គ ។ កាលបើចុះ"អា"បច្ច័យហើយ ត្រូវលុបសរៈ "អ" ដើមនោះចោល ។

ពាក្យតទៅនេះ ជាទ្វិលិង្គិកៈ គឺបុល្លិង្គ និងឥត្ថីលិង្គ ។ បុល្លិង្គ ចំផុតពាក្យជាសរៈ"អ"ដល់ទៅជាឥត្ថីលិង្គ ត្រូវចុះ "ឦ"បច្ច័យ:

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| អយ្យក | អយ្យកី | កិន្នរ | កិន្នរី |

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| ម្រឹគ | ម្រឹគី | នាគ | នាគី |
| ព្យគ្ឃ | ព្យគ្ឃី | គ្រុឌ | គ្រុឌី |
| សកុណ | សកុណី | មាណព | មាណវី |
| តរុណ | តរុណី | ព្រាហ្មណ | ព្រាហ្មណី |
| ទេវ | ទេវី | មហិស | មហិសី |
| ចោរ | ចោរី | កុក្កុដ | កុក្កុដី |
| ថេរ | ថេរី | មជ្ជារ | មជ្ជារី |
| កុមារ | កុមារី | បុត្រ | បុត្រី |
| នរ | នារី | ក្សត្រ | ក្សត្រី |
| មនុស្ស | មនុស្សី | តាបស | តាបសី |
| អរហន្ត | អរហន្តី | ពានរ | ពានរី |
| សមណ | សមណី | បិសាច | បិសាចី |
| សាមណេរ | សាមណេរី | ប្រេត | ប្រេតី |

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| ភាគិនេយ្យ | ភាគិនេយ្យី | គុណវន្ត | គុណវន្តី |
| ពាល | ពាលី | ឥណវន្ត | ឥណវន្តី |
| ភមរ | ភមរី | គោតម | គោតមី |
| ពក្យស | ពក្យសី | វសិដ្ឋ | វសិដ្ឋី |
| លោហការ | លោហការី | សុទ្ធ | សុទ្ធី |
| ពក្កុល | ពក្កុលី | វេស | វេសី |
| បញ្ញវន្ត | បញ្ញវន្តី | អសុរ | អសុរី |
| សតិមន្ត | សតិមន្តី | សុនខ | សុនខី |

ឥនី- បច្ច័យ សម្រាប់ចុះកាន់ចុងពាក្យដែលមានរូបដើមបុល្លិង្គ ជាសរៈដទៃ ក្រៅពីសរៈ "អ" កាលបើចុះម.ហើយ ត្រូវតែលុបសរៈ "អ" ចេញ ទុកតែ "នី", តែសរៈរបស់ពាក្យដើមនោះ មិនលុបទេ ។

ពាក្យតទៅនេះ ជាទ្វិលិង្គកៈ គឺបុល្លិង្គ និងឥត្ថីលិង្គ ។ បុល្លិង្គ ទីបំផុតពាក្យជាសរៈដទៃ ក្រៅពីសរៈ "អ" ត្រូវចុះ "ឥនី" បច្ច័យ :

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីល្លិង្គ | បុលិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| រាជា | រាជិនី | គ្រូ | គ្រូនី |
| សេដ្ឋី | សេដ្ឋិនី | អាចារ្យ | អាចារយិនី |
| គហបតី | គហបតានី | ព្រហ្មចារី | ព្រហ្មចារិនី |
| ក្សត្រិយ | ក្សត្រិយានី | យោគី | យោគិនី |
| ភិក្ខុ | ភិក្ខុនី | តបស្សី | តបស្សិនី |
| មេធាវី | មេធាវិនី | វិប្បដិសារី | វិប្បដិសារិនី |
| មេធី | មេធិនី | បិតុល | បិតុលានី |
| វិការី | វិការិនី | មាតុល | មាតុលានី |
| លេខការី | លេខការិនី | ភាគី | ភាគិនី |
| រាជាធិការី | រាជាធិការិនី | សាមី | សាមិនី |
| រូបី | រូបិនី | ពិលាសី | ពិលាសិនី |
| រោគី | រោគិនី | មច្ឆរី | មច្ឆរិនី |
| ឧបការី | ឧបការិនី | ករី | ករិនី |
| វេស្សវេស្សី | វេស្សវេស្សិនី | ហត្ថី | ហត្ថិនី |
| វេជ្ជខស្សី | វេជ្ជខស្សិនី | ភាជី | ភោជិនី |

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| វាទី | វាទិនី | រត្តញ្ញូ | រត្តញ្ញុនី |
| បក្សី | បក្សិនី | រសញ្ញូ | រសញ្ញុនី |
| វិភាវី | វិភាវិនី | មធរី | មធរិនី |
| វេរី | វេរិនី | មេធាវី | មេធាវិនី |
| ភត្តការី | ភត្តការិនី | មេក្ខី | មេក្ខិនី |
| វេទី | វេទិនី | មធទី | មធទិនី |
| វេធី | វេធិនី | គេហាណី | គេហាណិនី |
| សកវាទី | សកវាទិនី | មិត្តបញ្ញី | មិត្តបញ្ញិនី |

បច្ច័យ ៦ ពួកគឺ អ្យៀង, អ្យែន, អាំង, អែន, អេស, អែស នេះទាក់ទងដោយជាតិកំណើត របស់មនុស្សជាតិនីមួយ ៗ ត្រូវចុះបានតែខាងចុងពាក្យដែលជានបុំសកលិង្គ ហើយពាក្យនោះជាឈ្មោះរបស់ទ្វីប, ប្រទេស, រដ្ឋ, នគរ, ខេត្ត, ខណ្ឌ, ស្រុក, ឃុំ, ភូមិ, ទើបបាន នឹងចុះខាងចុងពាក្យត្រង់នេះពុំបានទៀង ៗ តាំង ៦ បច្ច័យនេះ ជាបុល្លិង្គ ៣ គឺ អ្យៀង, អាំង, អេស; ជាឥត្ថីលិង្គ ៣ ពួក គឺ អ្យែន, អែន, អែស ។ បើកាលណាក្នុងបុល្លិង្គ

www.elibraryofcambodia.org

ចុះ "ផ្ទៀង" ហើយ ផល់ម.ផ្ដួលដ្ឋ ត្រូវតែចុះ "ផ្ទែន" ទឹង

ចុះបច្ច័យក្រៅពីនេះមិនបាន ៗ បើក្នុងបុល្លិង្គចុះ "ដាំង" ហើយ

ផល់ម.ផ្ដួលដ្ឋត្រូវតែចុះ "តែន" រួចបាន ទឹងចុះបច្ច័យដទៃក្រៅ

ពីនេះមិនបាន ៗ បើក្នុងបុល្លិង្គចុះ "ដេស" ហើយ ផល់ម.ផ្ដួលដ្ឋ

ត្រូវតែចុះ "តែស" រួចបាន ទឹងចុះបច្ច័យអ្វីដទៃក្រៅពីនេះមិន

បានៗ សម្រាប់ "ផ:ឃៀង, ដេស, ដាំង" នេះ បើចុះខាងចុងពាក្យ

ណាពាក្យនោះសំដៅសេចក្ដីបាន ៣ យ៉ាង គឺ ១- សំដៅដល់ជាតិ

ដែលនៅក្នុងទីបនោះៗ ឬប្រទេសនោះៗ ជាដើម, ២- សំដៅដល់

មនុស្សប្រុសរបស់ជាតិនោះ, ៣- សំដៅដល់ភាសារបស់ជាតិនោះ

តួយ៉ាងដូចជា "ដចុំន" នេះជាឈ្មោះរបស់ប្រទេស, ប្រកបនឹង

"ដេស" បច្ច័យជា "ដចុំនេស" នេះប្រែថា: "ជនជាតិដចុំន,

មនុស្សប្រុសរបស់ដចុំន, ភាសារបស់ដចុំន" ដូច្នេះជាតួយ៉ាង ៗ

សូម្បីពាក្យឯទៀតៗ ក៏គប្បីប្ដូលចិត្តដូចគ្នាដូច្នេះដែរ ៗ ចំណែក

ខាងបច្ច័យផ្ដួលដ្ឋញ ក្ដី បើចុះម.ហើយក៏សំដៅសេចក្ដីដល់មនុស្ស

ស្រីរបស់ជាតិនោះតែមួយយ៉ាង ៗ

ពាក្យតទៅនេះ ជានចុំសកលិង្គ សុទ្ធតែជាឈ្មោះរបស់ទីប,

www.elibraryofcambodia.org

ប្រភេទ ស, វេ, ខត ទីង៏ខត្ត ៗ "ឥយៀន" បច្ច័យក្នុងបុល្លិង្គ ហើយទីងទុះ "ឥយែន" បច្ច័យក្នុងឥត្ថីលិង្គ :

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| កាស៊ី | កាស៊ីយៀន | កាស៊ីយែន |
| ទុះសេយាទី | ទុះសេយាទិយៀន | ទុះសេយាទិយែន |
| ទុរូប | ទុរូបិយៀន | ទុរូបិយែន |
| សៀម | សៀមិយៀន | សៀមិយែន |
| លាវ | លាវិយៀន | លាវិយែន |
| កូមា | កូមិយៀន | កូមិយែន |
| យួន | យួនិយៀន | យួនិយែន |
| បូរណាវ | បូរណាវិយៀន | បូរណាវិយែន |
| សុមាត្រា | សុមាត្រិយៀន | សុមាត្រិយែន |
| នវកា·ឡេដូនី | នវកាឡេដូនិយៀន | នវកាឡេដូនិយែន |
| សេឡូប៍ | សេឡូបិយៀន | សេឡូបិយែន |
| កៅលី | កៅលិយៀន | កៅលិយែន |
| មញ្ជូរី | មញ្ជូរិយៀន | មញ្ជូរិយែន |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| មង្គោលី | មង្គោលិយៀន | មង្គោលិយែន |
| ឥណ្ឌៀ | ឥណ្ឌិយៀន | ឥណ្ឌិយែន |
| ស៊ីបេរី | ស៊ីបេរិយៀន | ស៊ីបេរិយែន |
| ស៊ីរី | ស៊ីរិយៀន | ស៊ីរិយែន |
| អស្សីរី | អស្សីរិយៀន | អស្សីរិយែន |
| ច្ហាលដេ | ច្ហាលដិយៀន | ច្ហាលដិយែន |
| មាដាគស្ការ | មាដាគស្ការិយៀន | មាដាគស្ការិយែន |
| បាបិឡោន | បាបិឡោនិយៀន | បាបិឡោនិយែន |
| អាលហ្សេរី | អាលហ្សេរិយៀន | អាលហ្សេរិយែន |
| តុនិស៊ី | តុនិសិយៀន | តុនិសិយែន |
| លីបេរិយា | លិបេរិយិយៀន | លិបេរិយិយែន |
| សុមាលី | សុមាលិយៀន | សុមាលិយែន |
| ដាហូមី | ដាហូមិយៀន | ដាហូមិយែន |
| បុសនី | បុសនិយៀន | បុសនិយែន |
| លីប៊ី | លិប៊ិយៀន | លិប៊ិយែន |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| នីហ្សេរ | នីហ្សេរ៉ិយៀន | នីហ្សេរ៉ិយែន |
| ស៊ីអេរ៉ាឡេអូន | ស៊ីអេរ៉ាឡេអូនិយៀន | ស៊ីអេរ៉ាឡេអូនិយែន |
| និកាក័យ | និកាក័យ៉ិយៀន | និកាក័យ៉ិយែន |
| ហៃទី | ហៃទិយៀន | ហៃទិយែន |
| ប្រេស៊ីល | ប្រេស៊ីលិយៀន | ប្រេស៊ីលិយែន |
| បូលីវី | បូលីវិយៀន | បូលីវិយែន |
| អេក្វាទ័រ | អេក្វាទ័រិយៀន | អេក្វាទ័រិយែន |
| កូឡុំប៊ី | កូឡុំប៊ិយៀន | កូឡុំប៊ិយែន |
| ប៉េរូ | ប៉េរុវិយៀន | ប៉េរុវិយែន |
| គុយ៉ាន | គុយ៉ានិយៀន | គុយ៉ានិយែន |
| ប៉ារ៉ាក័យ | ប៉ារ៉ាក័យ៉ិយៀន | ប៉ារ៉ាក័យ៉ិយែន |
| កាណាដា | កាណាដ៉ិយៀន | កាណាដ៉ិយែន |
| ហុម៉ុប | ហុម៉ុសិយៀន | ហុម៉ុសិយែន |
| ឈីលី | ឈីលិយៀន | ឈីលិយែន |
| ឧរុក័យ | ឧរុក័យ៉ិយៀន | ឧរុក័យ៉ិយែន |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| វេលសឺ | វេលសិយៀន | វេលសិយែន |
| រុស្សី | រុស្សិយៀន | រុស្សីយែន |
| ឥតាលី | ឥតាលិយៀន | ឥតាលិយែន |
| ហុនគ្រី | ហុនគ្រិយៀន | ហុនគ្រិយែន |
| អូទ្រីឈ្ស | អូទ្រិឈ្សៈយៀន | អូទ្រិឈ្សយែន |
| ប៊ុលគារី | ប៊ុលគារិយៀន | ប៊ុលគារិយែន |
| អេស្តូនី | អេស្តូនិយៀន | អេស្តូនិយែន |
| លិថូនី | លិថូនិយៀន | លិថូនិយែន |
| សុអែដ | សុអែដិយៀន | សុអែដិយែន |
| ឡាប៉ូនី | ឡាប៉ូនិយៀន | ឡាប៉ូនិយែន |
| នរវែហ្ស៍ | នរវែហ្សិយៀន | នរវែហ្សិយែន |
| ស៊ីស៊ីល | ស៊ីស៊ីលិយៀន | ស៊ីស៊ីលិយែន |
| ឧក្រែន | ឧក្រែនិយៀន | ឧក្រែនិយែន |
| កោរស៍ | កោរសិយៀន | កោរសិយែន |
| គីកេល | គីកេលិយៀន | គីកេលិយែន |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| មោណកូ | មោណកុរៃយៀន | មោណកុរៃយែន |
| អូស្ត្រាលី | អូស្ត្រាលិយៀន | អូស្ត្រាលិយែន |
| តាសមានី | តាសមានិយៀន | តាសមានិយែន |
| ហាវ៉ៃ | ហាវ៉ៃឥយៀន | ហាវ៉ៃឥយែន |
| សុវណ្ណភូមិ | សុវណ្ណភូមិយៀន | សុវណ្ណភូមិយែន |

ពាក្យគេទាំងនេះ ជានបុំសកលិង្គ សុទ្ធតែជាឈ្មោះរបស់ទ្វីប, ប្រទេស, ទីនរដ្ឋ ចុះ “កាំង” បច្ច័យក្នុងបុល្លិង្គ ហើយខឹងចុះ “អែន” បច្ច័យក្នុងឥត្ថីលិង្គ :

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| អាហ្វ្រិក | អាហ្វ្រិកាំង | អាហ្វ្រិកែន |
| អាមេរិក | អាមេរិកាំង | អាមេរិកែន |
| ឧត្តកមេរិក | ឧត្តកមេរិកាំង | ឧត្តកមេរិកែន |
| ទក្ខិណាមេរិក | ទក្ខិណាមេរិកាំង | ទក្ខិណាមេរិកែន |
| មជ្ឈិមាមេរិក | មជ្ឈិមាមេរិកាំង | មជ្ឈិមាមេរិកែន |
| ហ្វិលិពិន | ហ្វីលិពីង | ហ្វិលិពែន |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| ទីបេត | ទីបេតាំង | ទីបេតែន |
| អាប៊ិស៊ីនី | អាប៊ិស៊ីនាំង | អាប៊ិស៊ីណែន |
| អេហ្ស៊ីប្ត | អេហ្ស៊ីប្តៀង | អេហ្ស៊ីប្តែន |
| ម៉ារ៉ុក | ម៉ារ៉ុកាំង | ម៉ារ៉ុកែន |
| អាហ្សេរបៃជ | អាហ្សេរបៃជាំង | អាហ្សេរបៃជែន |
| ត្រីប៉ូលី | ត្រីប៉ូលាំង | ត្រីប៉ូលែន |
| សទក្ខិណាហ្វ្រិក | សទក្ខិណាហ្វ្រិកាំង | សទក្ខិណាហ្វ្រិកែន |
| ភ្នំពេញ | ភ្នំពេញាំង | ភ្នំពេញែន |
| សៀមរាប | សៀមរាបាំង | សៀមរាបែន |
| បាំងកក | បាំងកកាំង | បាំងកកែន |
| សិង្គបូរ | សិង្គបូរាំង | សិង្គបូរែន |
| ឧត្តរសរដ្ឋាមេរិក | ឧត្តរសរដ្ឋាមេរិកាំង | ឧត្តរសរដ្ឋាមេរិកែន |
| អាឡាស្កា | អាឡាស្កាំង | អាឡាស្កែន |
| ម៉ោសម្ពិក | ម៉ោសម្ពិកាំង | ម៉ោសម្ពិកែន |
| មេក្ស៊ិក | មេក្ស៊ិកាំង | មេក្ស៊ិកែន |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
| --- | --- | --- |
| ក្វាតេម៉ាឡា | ក្វាតេម៉ាឡាំង | ក្វាតេម៉ាឡែន |
| គុបា | គុបាំង | គុបែន |
| កុស្តារិកា | កុស្តារិកាំង | កុស្តារិកែន |
| ប៉ាណាម៉ា | ប៉ាណាម៉ាំង | ប៉ាណាម៉ែន |
| វេណេសុអេឡា | វេណេសុអេឡាំង | វេណេសុអេឡែន |
| អារហ្សង់ទីន | អារហ្សង់ទីនាំង | អារហ្សង់ទីនែន |
| បែលហ្ស៊ិក | បែលហ្ស៊ិកាំង | បែលហ្ស៊ិកែន |
| រូម៉ានី | រូម៉ានាំង | រូម៉ានែន |
| ពេរូ | ពេរុយ៉ាំង | ពេរុយ៉ែន |
| ក្រិក | ក្រិកាំង | ក្រិកែន |
| ឡែតូនី | ឡែតូនាំង | ឡែតូនែន |
| ស្វិស | ស្វិសាំង | ស្វិសែន |
| ដាណឺម៉ាក | ដាណឺម៉ាកាំង | ដាណឺម៉ាកែន |
| ហ៊ង្គ្រនី | ហ៊ង្គ្រនាំង | ហ៊ង្គ្រនែន |
| កស៊ីរៈ | កស៊ីកាំង | កស៊ីកែន |

www.elibraryofcambodia.org

ពាក្យតទៅនេះ ជានបុំសកលិង្គ សុទ្ធតែជាឈ្មោះរបស់វត្ថុ, ... ថែមនឹងទៅក ចុះ “េស” បច្ច័យ ក្នុងបុល្លិង្គ ហើយថែមចុះ “ែស” បច្ច័យ ក្នុងឥត្ថីលិង្គ :

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| គ្រោអង់ឡង់ដ៍ | គ្រោអង់ឡង់ដេស | គ្រោអង់ឡង់ដែស |
| ជប៉ុន | ជប៉ុនេស | ជប៉ុនែស |
| ចិន | ចិនេស | ចិនែស |
| ប៉ាគិស្ថាន | ប៉ាគិស្ថានេស | ប៉ាគិស្ថានែស |
| នវេហ្ស៊ីឡង់ដ៍ | នវេហ្ស៊ីឡង់ដេស | នវេហ្ស៊ីឡង់ដែស |
| នវតេណ | នវតេណេស | នវតីណែស |
| ផក់ | ផវេស | ផវែស |
| មលយ | មលយេស | មលយែស |
| គុវេកស្ថាន | គុវេកស្ថានេស | គុវេកស្ថានែស |
| ភូហាន | ភូហានេស | ភូហានែស |
| នេប៉ាល់ | នេប៉ាលេស | នេប៉ាលែស |
| ស៊ិង្ហល | ស៊ិង្ហលេស | ស៊ិង្ហលែស |

www.elibraryofcambodia.org

| ឧបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| អហ្យាយាទិស្ឋាន | អហ្យាយាទិស្ឋានេស | អហ្យាយាទិស្ឋានែស |
| ឥកន | ឥកនេស | ឥកនែស |
| ឥកក | ឥកកេស | ឥកកែស |
| ឝាក៉ប | ឝាក៉បេស | ឝាក៉បែស |
| ទុះគី | ទុគេស | ទុគែស |
| លីបាន | លីបានេស | លីបានែស |
| ពលុចិស្ឋាន | ពលុចិស្ឋានេស | ពលុចិស្ឋានែស |
| គុនកិន | គុនកិនេស | គុនកិនែស |
| សុជាន | សុជានេស | សុជានែស |
| សេណោគិល | សេណោគលេស | សេណោគលែស |
| កុគ្គោ | កុគ្គេស | កុគ្គែស |
| កូតដីឡ្យរ | កូតដីឡ្យរេស | កូតដីឡ្យរែស |
| កូតឌីវរ | កូតឌីវរេស | កូតឌីវរែស |
| អគ្គោឡ្យ | អគ្គោឡ្យេស | អគ្គោឡ្យែស |
| អេរីប្រថ | អេរីប្រថេស | អេរីប្រថែស |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
| --- | --- | --- |
| ហ្គាបុន | ហ្គាបុនេស | ហ្គាបុនែស |
| កេណោសេ | កេណោសេស | កេណាសែស |
| កាមីរុង | កាមីរុនេស | កាមីរុនែស |
| ក្រន៍សក់ល | ក្រន៍សក់លេស | ក្រន៍សក់លែស |
| កេនយា | កេនយេស | កេនយែស |
| ហុនឌុរ៉ាស់ | ហុនឌុរ៉ាសេស | ហុនឌុរ៉ាសែស |
| ដូមីនិកែន | ដូមីនិកែនេស | ដូមីនិកែនែស |
| អង្គល: | អង្គលេស | អង្គលែស |
| អេកុស | អេកុសេស | អេកុសែស |
| អៀរឡនដ៍ | អៀះឡនដេស | អៀរឡនដែស |
| អល្លឺមនដ៍ | អល្លឺមនដេស | អល្លឺ[illegible] |
| ហ្វាំនឡនដ៍ | ហ្វាំនឡនដេស | ហ្វាំន[illegible] |
| ហុល្លនដ៍ | ហុល្លនដេស | ហុល្ល[illegible] |
| ឥស្លនដ៍ | ឥស្លនដេស | ឥស្ល[illegible] |
| ចាកំនស៍ | ចាកំនសេស | ចាកំន[illegible] |

www.elibraryofcambodia.org

| នបុំសកលិង្គ | បុល្លិង្គ | ឥត្ថីលិង្គ |
| --- | --- | --- |
| ប៉ោឡូញ | ប៉ោឡូញេស | ប៉ោឡូញែស |
| អេស្ប៉ាញ | អេស្ប៉ាញេស | អេស្ប៉ាញែស |
| ប៉ោរតុគិះ | ប៉ោរតុគេស | ប៉ោរតុគែស |
| លុក្សម្បួរគ៍ | លុក្សម្បួរគេស | លុក្សម្បួរគែស |
| យូគោស្លាវី | យូគោស្លាវេស | យូគោស្លាវែស |
| ចេកូស្លូវ៉ាគី | ចេកូស្លូវ៉ាគេស | ចេកូស្លូវ៉ាគែស |
| អល្បានី | អល្បានេស | អល្បានែស |
| សារដែញ | សារដែញេស | សារដែញែស |
| លិច្ឆតេនសតេន | លិច្ឆតេនសតេនេស | លិច្ឆតេនសតេនែស |
| ផន៍ក់ហ្វ្រិក | ផន៍ក់ហ្វ្រិកេស | ផន៍ក់ហ្វ្រិកែស |
| វៀតណាម | វៀតណាមេស | វៀតណាមែស |
| ប៉េណាំង | ប៉េណាំងេស | ប៉េណាំងែស |
| កន្តាំង | កន្តាំងេស | កន្តាំងែស |

“អុង,អោន” បច្ច័យ ២ តួនេះ សម្រាប់ប្រើខាងចុងពាក្យសា-មាន្យនាមទីងវិសាមាន្យនាមខ្លះ ដែលជាសញ្ញាណកៈ កាលបើ

www.elibraryofcambodia.org

ចុះម. ហើយឲ្យប្រែថា "កូន" ច្រើនតែចុះខាងចុងពាក្យដែលជាឈ្មោះរបស់សត្វតិរច្ឆាន ដូច "ម្រឹគ, បក្ស" ជាដើម; "អុន" បច្ច័យចុះក្នុងបុល្លិង្គ, ហើយ "អោន" បច្ច័យចុះក្នុងឥត្ថីលិង្គ ។

ពាក្យតទៅនេះ ជាសាមាន្យនាម ឬ វិសាមាន្យនាម ចុះអុន បច្ច័យម. ឲ្យប្រែថា "កូនឈ្មោល" ឯងចុះ "អោន" បច្ច័យម. ឲ្យប្រែថា "កូនញី" របស់សត្វនោះៗ :

| សាមាន្យនាម ឬ វិសាមាន្យនាម | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| សីហៈ | សីហុន | សីហោន |
| ក្ងោក | ក្ងោកុន | ក្ងោកោន |
| ប៉ោលគោក | ប៉ោលគោកុន | ប៉ោលគោកោន |
| ក្ងាន | ក្ងានុន | ក្ងានោន |
| កុក | កុកុន | កុកោន |
| ក្អែក | ក្អែកុន | ក្អែកោន |
| សំពោច | សំពោចុន | សំពោចោន |
| ទន្សាយ | ទន្សាយុន | ទន្សាយោន |

www.elibraryofcambodia.org

| សាមញ្ញនាម ឬ វិសាមញ្ញនាម | បុល្លិង្គ | ឥត្ថីលិង្គ |
|---|---|---|
| ប្រើស | ប្រើសុន | ប្រើសោន |
| ព្រាយ | ព្រាយុន | ព្រាយោន |
| មោស | មោសុន | មោសោន |
| ចោប | ចោបុន | ចោបោន |
| កំប្រុក | កំប្រុកុន | កំប្រុកោន |

“ឥស្ស” បច្ច័យ កាលបើចុះម. ខាងចុងពាក្យណា ពាក្យនោះត្រូវប្រែថា “លទ្ធិ, ជំនឿ, សេចក្ដីប្រកាន់, សេចក្ដីកប់កាន, សេចក្ដីគោរព, សេចក្ដីប្រតិបត្តិ” ដូចតួយ៉ាងថា: “ពុទ្ធ” កាលណាបើចុះ “ឥស្ស” បច្ច័យម. សម្រេចរូបជា “ពុទ្ធិស្ស” នេះប្រែថា: “លទ្ធិព្រះពុទ្ធ, ជំនឿព្រះពុទ្ធ, សេចក្ដីប្រកាន់ព្រះពុទ្ធ, សេចក្ដីកប់កានព្រះពុទ្ធ, សេចក្ដីគោរពព្រះពុទ្ធ, សេចក្ដីប្រតិបត្តិព្រះពុទ្ធ” នេះជាឥស្សាធិដ្ឋាន; បើជាបុគ្គលាធិដ្ឋានវិញ: បុល្លិង្គត្រូវចុះ “ឦ” បច្ច័យថែមលើ “ឥស្ស” សម្រេចរូបជា “ពុទ្ធិស្សី”; ឥត្ថីលិង្គត្រូវចុះ “ឥនី” បច្ច័យថែមលើ “ឥស្ស” សម្រេចរូបជា “ពុទ្ធិស្សិនី” ប្រែថា បុរស,-ស្ត្រី អ្នកកាន់

www.elibraryofcambodia.org

លទ្ធិពុទ្ធ, អ្នកជឿព្រះពុទ្ធ, អ្នកមានសេចក្ដីប្រកាន់ព្រះពុទ្ធ, អ្នកមានសេចក្ដីរាប់អានព្រះពុទ្ធ, អ្នកមានសេចក្ដីគោរពព្រះពុទ្ធ, អ្នកមានសេចក្ដីប្រតិបត្តិព្រះពុទ្ធ ។

ពាក្យគំរូនេះជាសាមាន្យនាម ឬ វិសាមាន្យនាម ចុះ ឥស្ដ បច្ច័យហើយ, ក្នុងបុល្លិង្គ ចុះ "ឦ" បច្ច័យថែម, ក្នុងឥត្ថីលិង្គចុះ "ឥនី" បច្ច័យថែម :

| នបុំសកលិង្គ ឥស្ដ បច្ច័យ | បុល្លិង្គ ឦ បច្ច័យ | ឥត្ថីលិង្គ ឥនី បច្ច័យ |
|---|---|---|
| ពុទ្ធិស្ដ | ពុទ្ធិស្ដី | ពុទ្ធិស្ដិនី |
| យេស៊ូឥស្ដ | យេស៊ូឥស្ដី | យេស៊ូឥស្ដិនី |
| ឥស្លាមិស្ដ | ឥស្លាមិស្ដី | ឥស្លាមិស្ដិនី |
| ព្រាហ្មណិស្ដ | ព្រាហ្មណិស្ដី | ព្រាហ្មណិស្ដិនី |
| ជេនិស្ដ | ជេនិស្ដី | ជេនិស្ដិនី |
| ជិនតោឥស្ដ | ជិនតោឥស្ដី | ជិនតោឥស្ដិនី |
| តៅឥស្ដ | តៅឥស្ដី | តៅឥស្ដិនី |
| ខុងជឺឥស្ដ | ខុងជឺឥស្ដី | ខុងជឺឥស្ដិនី |
| ឡាមិស្ដ | ឡាមិស្ដី | ឡាមិស្ដិនី |

www.elibraryofcambodia.org

| នបុំសកលិង្គ ឥស្ស បច្ច័យ | បុល្លិង្គ ឦ បច្ច័យ | ឥត្ថិលិង្គ ឥនី បច្ច័យ |
|---|---|---|
| សាកុសិស្ស | សាកុសិស្សី | សាកុសិស្សិនី |
| ទេវតាឥស្ស | ទេវតាឥស្សី | ទេវតាឥស្សិនី |
| បិសាចិស្ស | បិសាចិស្សី | បិសាចិស្សិនី |
| សារក្យិស្ស | សារក្យិស្សី | សារក្យិស្សិនី |
| អ្នកតាឥស្ស | អ្នកតាឥស្សី | អ្នកតាឥស្សិនី |
| កជិស្ស | កជិស្សី | កជិស្សិនី |
| ជាតិស្ស | ជាតិស្សី | ជាតិស្សិនី |
| ប្រជាធិបិស្ស | ប្រជាធិបិស្សី | ប្រជាធិបិស្សិនី |
| ធុទិស្ស | ធុទិស្សី | ធុទិស្សិនី |
| សេរិស្ស | សេរិស្សី | សេរិស្សិនី |
| សន្តមិស្ស | សន្តមិស្សី | សន្តមិស្សិនី |
| ឯកាធិបិស្ស | ឯកាធិបិស្សី | ឯកាធិបិស្សិនី |
| អភោធិបិស្ស | អនាធិបិស្សី | អនាធិបិស្សិនី |
| លោកាធិបិស្ស | លោកាធិបិស្សី | លោកាធិបិស្សិនី |

www.elibraryofcambodia.org

បច្ច័យ ២ តួគឺ "ឯរ, ឯរេស" នេះ សម្រាប់ចុះខាងចុងពាក្យគុណស័ព្ទពួកខ្លះ, "ឯរ" បច្ច័យចុះម. ហើយ អាចធ្វើឲ្យពាក្យ បកតិ-គុណសព្ទ ក្លាយទៅជាវិសេសៈបាទ; "ឯរេស" បច្ច័យចុះឧ. ហើយ អាចធ្វើឲ្យពាក្យបកតិគុណសព្ទ ក្លាយទៅជាអតិវិសេសៈបាទ នឹងមាននិយាយក្នុងផ្នែកពាក្យគុណសព្ទឯណោះ ។

"ឥក" បច្ច័យសម្រាប់ចុះខាងចុងពាក្យនាមធម្មតា ដើម្បីធ្វើឲ្យក្លាយទៅជាកិរិយា នឹងមាននិយាយក្នុងផ្នែកកិរិយាឯណោះ ។

"អាក" បច្ច័យសម្រាប់ចុះខាងចុងពាក្យនាមធម្មតា ។ បច្ច័យនេះកាលបើចុះម. ហើយ អាចឲ្យប្រែបានជា ២ យ៉ាងគឺប្រែថា "អ្នកខ្វង" មួយយ៉ាង ប្រែថា "សិល្បៈ-" មួយយ៉ាង ដូចក្នុងយ៉ាងថា: "គាវ-តោក" ប្រែថា "ការតែងសៀវភៅ" ឬ "សិល្បៈនៃការតែងសៀវភៅ", សូម្បីពាក្យនាមឯទៀតៗក៏គប្បីចូលចិត្តតាមទំនងនេះដូចគ្នា ។

ដើម្បីឲ្យឃើញថា: ពាក្យនាមមួយៗ ផ្លាស់ប្តូរទៅតាមបច្ច័យយ៉ាងម៉េចៗ ខ្លះនោះ សូមទាញឧទាហរណ៍ ម. ឲ្យគ្រប់បច្ច័យទាំងអស់ ដើម្បីងាយប្រៀបធៀប :

www.elibraryofcambodia.org

| ពាក្យខាងដើម | ឦបច្ច័យបុ. | ឥនីបច្ច័យឥត្ថី. | ឥតបច្ច័យកិរិយា | អាតបច្ច័យបុំ. |
|---|---|---|---|---|
| ការ | ការី | ការិនី | ការិត | ការាត |
| កីឡា | កីឡី | កីឡិនី | កីឡិត | កីឡាត |
| ភិទៈ | ភិទី | ភិទិនី | ភិទិត | ភិទាត |
| ជាឋកចា | ជាឋកចី | ជាឋកចិនី | ជាឋកចិត | ជាឋកចាត |
| កិលេមលោវ | កិលេមលោវី | កិលេមលោវិនី | កិលេមលោវិត | កិលេមលោវាត |
| ទោរលោវ | ទោរលោវី | ទោរលោវិនី | ទោរលោវិត | ទោរលោវាត |
| ទោរសទ្ធ | ទោរសទ្ធី | ទោរសទ្ធិនី | ទោរសទ្ធិត | ទោរសទ្ធាត |
| សាប្ព | សាបី | សាបិនី | សាបិត | សាបាត |
| បភាលោវ | បភាលោវី | បភាលោវិនី | បភាលោវិត | បភាលោវាត |
| អាវតោរា | អាវតោរី | អាវតោរិនី | អាវតោរិត | អាវតោរាត |
| ហេតុរា | ហេតុរី | ហេតុរិនី | ហេតុរិត | ហេតុរាត |
| លិបិរា | លិបិរី | លិបិរិនី | លិបិរិត | លិបិរាត |
| សុលិបរា | សុលិបរី | សុលិបរិនី | សុលិបរិត | សុលិបរាត |
| បរោសា | បរោសី | បរោសិនី | បរោសិត | បរោសាត |
| ភូមិលោតា | ភូមិលោតី | ភូមិលោតិនី | ភូមិលោតិត | ភូមិលោតាត |
| មិត្តបញ្ញា | មិត្តបញ្ញី | មិត្តបញ្ញិនី | មិត្តបញ្ញិត | មិត្តបញ្ញាត |
| ព្រឹក្សរា | ព្រឹក្សរី | ព្រឹក្សរិនី | ព្រឹក្សរិត | ព្រឹក្សរាត |
| ដីវវណ្ណនា | ដីវវណ្ណនី | ដីវវណ្ណនិនី | ដីវវណ្ណនិត | ដីវវណ្ណនាត |
| ភូមិវណ្ណនា | ភូមិវណ្ណនី | ភូមិវណ្ណនិនី | ភូមិវណ្ណនិត | ភូមិវណ្ណនាត |
| ហាំងវណ្ណនា | ហាំងវណ្ណនី | ហាំងវណ្ណនិនី | ហាំងវណ្ណនិត | ហាំងវណ្ណនាត |
| គេហាណា | [illegible]ហាណី | គេហាណិនី | គេហាណិត | គេហាណាត |
| ចមនា | [illegible] | ចមនិនី | ចមនិត | ចមនាត |

www.elibraryofcambodia.org

| ពាក្យតាមដើម | ឦបច្ច័យបុ. | ឥនីបច្ច័យឥត្ថី. | ឥតបច្ច័យកិរិយា | អាគ.បច្ច័យខំ. |
|---|---|---|---|---|
| មេត្តា | មេត្តី | មេត្តិនី | មេត្តិត | មេត្តាត |
| មចឆា | មចឆី | មចឆិនី | មចឆិត | មចឆាត |
| តេចឆា | តេចឆី | តេចឆិនី | តេចឆិត | តេចឆាត |
| ការុណា | ការុណី | ការុណិនី | ការុណិត | ការុណាត |
| ទេសបាល | ទេសបាលី | ទេសបាលិនី | ទេសបាលិត | ទេសបាលាត |
| ព្យាបាល | ព្យាបាលី | ព្យាបាលិនី | ព្យាបាលិត | ព្យាបាលាត |
| សិក្សា | សិក្សី | សិក្សិនី | សិក្សិត | សិក្សាត |
| មិត្តលោភា | មិត្តលោភី | មិត្តលោភិនី | មិត្តលោភិត | មិត្តលោភាត |
| សត្វលោភា | សត្វលោភី | សត្វលោភិនី | សត្វលោភិត | សត្វលោភាត |
| បសុត្វលោភា | បសុត្វលោភី | បសុត្វលោភិនី | បសុត្វលោភិត | បសុត្វលោភាត |
| សោរលោទ | សោរលោទី | សោរលោទិនី | សោរលោទិត | សោរលោទាត |
| ការលោភា | ការលោភី | ការលោភិនី | ការលោភិត | ការលោភាត |
| ភេសរមា | ភេសរមី | ភេសរមិនី | ភេសរមិត | ភេសរមាត |
| មេទសា | មេទសី | មេទសិនី | មេទសិត | មេទសាត |
| ភមឆា | ភមឆី | ភមឆិនី | ភមឆិត | ភមឆាត |
| សង្គម | សង្គមី | សង្គមិនី | សង្គមិត | សង្គមាត |
| សមាគម | សមាគមី | សមាគមិនី | សមាគមិត | សមាគមាត |
| សរទាន | សរទានី | សរទានិនី | សរទានិត | សរទានាត |
| បាយតិកា | បាយតិកី | បាយតិកិនី | បាយតិកិត | បាយតិកាត |
| ពោយា | ពោយី | ពោយិនី | ពោយិត | ពោយាត |
| ឧត្តុស្សរា | ឧត្តុស្សរី | ឧត្តុស្សរិនី | ឧត្តុស្សរិត | ឧត្តុស្សរាត |
| កសិកម្ម | កសិកម្មី | កសិកម្មិនី | កសិកម្មិត | កសិកម្មាត |
| មោសុកា | មោសុកី | មោសុកិនី | មោសុកិត | មោសុកាត |

www.elibraryofcambodia.org

“ឥរ” បច្ច័យសម្រាប់ចុះខាងចុងពាក្យដែលជាឈ្មោះ“ឈើ ឬស្មៅ” កាលបើចុះម.ហើយ ឲ្យប្រែថា: “ដើម” គួរយកដូចជា “ស្វាយ” នេះសំដៅផលផ្លែស្វាយ កាលបើចុះ “ឥរ” បច្ច័យម. ក៏សម្រេចរូបជា “ស្វាយិរ” ប្រែថា: “ដើមស្វាយ” សូម្បីពាក្យដទៃៗ ក៏គប្បីចូលចិត្តតាមន័យនេះ ។

ពាក្យតទៅនេះ ជាឈ្មោះឈើឬស្មៅ កាលបើចុះ“ឥរ”បច្ច័យម. ឲ្យប្រែថា: “ដើម” ។

| ពាក្យដើម | ឥរបច្ច័យ | ពាក្យដើម | ឥរបច្ច័យ | ពាក្យដើម | ឥរបច្ច័យ |
|---|---|---|---|---|---|
| ស្វាយ | ស្វាយិរ | ស្លាយ | ស្លាយិរ | ពិល | ពិលិរ |
| ទុរ | ទុរិរ | អង្គាដី | អង្គាដី‌រ | បង្គៅ | បង្គៅ‌រ |
| ចេក | ចេកិរ | ក្របៅ | ក្របៅ‌រ | ល្មុត | ល្មុតិរ |
| គម្ពិល | គម្ពិលិរ | ញៀ | ញៀ‌រ | មង្ឃុត | មង្ឃុតិរ |

ក្រៅពីពាក្យចុះបច្ច័យបន្ទែរ ដែលបាននិយាយម.ហើយនោះ មានពាក្យជាច្រើនទៀត ដែលមានទីបំផុតពាក្យជាសរៈ “អា” សម្រាប់គ្រប់លិង្គទាំង ៤ ។

ពាក្យតទៅនេះ សុទ្ធតែមាន “អា” ជាទីបំផុតគ្រប់លិង្គទាំង៤ ចូរចាំកុំភ្លេច ។

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | អលិង្គ |
|---|---|---|---|
| រាជា | ភរិយា | សាលា | ទេវតា |
| សាស្តា | ជាយា | ពសុធា | ស្វា |
| ភស្តា | កញ្ញា | ធន | ពា |
| បិតា | មាតា | ធាក់ | ក្រុម |
| ភាតា | ធីតា | កេត្រា | ប្រសា |
| ជាមាតា | អច្ឆរា | ធម្មសភា | ដីលា |
| កត្តា | អង្គនា | ធម្មសាលា | ដីបាំ |
| ទត្តា | ឥក្ខណិកា | កុសិនារា | ប្រមា |
| ញាតា | វេសិយា | ប្រាជ្ញា | កាំប្រមា |
| ទាតា | ពេស្យា | ចេតនា | សាលិកា |
| ឧត្តា | គណិកា | សញ្ញា | ទទា |
| នេតា | ជនិកា | វេទនា | ខ្លា |
| វត្តា | ទុហិតា | ហឹសា | សៀវភា |
| សោតា | ទេវធីតា | សទ្ធា | ឆ្មា |
| ឋាត្តា | ទេវកញ្ញា | កថា | ឆ្មាប៉ា |

www.elibraryofcambodia.org

| បុល្លិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | អលិង្គ |
|---|---|---|---|
| ជេដ្ឋភាណា | សុណិសា | ភាសា | កំព្រា |
| កនិដ្ឋភាតា | សុណ្ហា | គពា | ឆាំ |
| ហាហា | អម្មា | ទអា | រាំ |
| ភគក់ | អម្ពកា | ឧដ៉ា | លា |
| អរហា | អម្ពា | យាចនា | ក្រសា |
| សុគក់ | អម្ពាណា | លីលា | ក្រពា |
| បញ្ញាក់ | អម្ពាលិកា | សាខា | កាចុំ(ព) |
| សេនា | វម្ភា | ភូមា | តាក |
| ទកញ្ញាំ | កល្យា | ចម្ប៉ា | នាក់ |
| ចុា | កនិដ្ឋា | ផក់ | ក់ |

## ឥក្ខុសាបទទី ៣

១. អ្វីហៅថាលិង្គ? សម្រាប់សំគាល់អ្វីខ្លះ?

២. ក្នុងកម្ពុជភាសាមានលិង្គប៉ុន្មានយ៉ាង? អ្វីខ្លះ?

៣. ក្នុងភាសានីមួយៗ បើកុំតាំងបាច់ឲ្យមានលិង្គទៅបានឬទេ? ភាសាដែលមិនមានលិង្គសំគាល់នោះ នឹងទៅជាភាសាអ្វីទៅវិញ?

www.elibraryofcambodia.org

សំណួរប្រឡង ៖

៤- [illegible]ផងដូចម្ដេចខ្លះ? ចូរបរិយាយ:

៥- បុល្លិង្គ គឺលិង្គដូចម្ដេច? សំដៅយកអ្វីជាប្រមាណ? មានពាក្យសម្រាប់សំគាល់ដូចម្ដេចខ្លះ ទើបនឹងកាចសង្កេតដឹងបានថាជាបុល្លិង្គ? អធិប្បាយ!

៦- ឥត្ថីលិង្គយ៉ាងណា? បានដល់ពាក្យពួកណា? មានសណ្ឋានប្រែប្រួលប្លែកពីបុល្លិង្គដូចម្ដេចខ្លះ ? ចូរសាធក!

៧- តើដូចម្ដេចទើបនឹងកាចដឹងបានថា ពាក្យនេះជាបុល្លិង្គ ឬជាឥត្ថីលិង្គ? ឥត្ថីលិង្គមានពាក្យដូចម្ដេចខ្លះ សម្រាប់សំគាល់ ? ចូរប្រាប់ឲ្យអស់!

៨- នបុំសកលិង្គនោះ គឺលិង្គបែបម៉េច ? ព្រោះហេតុអ្វី?

៩- មានពាក្យដូចម្ដេចខ្លះ សម្រាប់សំគាល់ក្នុងនបុំសកលិង្គ? ពាក្យដែលជានបុំសកលិង្គនោះ មានផ្លាស់ប្រែទៅជាលិង្គអ្វីទៀតបានឬទេ? ចូរទាញពាក្យនោះមកមើល ឲ្យបាន ១០ ពាក្យគ្រប់ៗលិង្គ ?

១០- នាមយ៉ាងណាដែលហៅថា អលិង្គ? ប្រែថាម៉េច?

www.elibraryofcambodia.org

១១- នាមដែលជាអលិង្គនោះ នៅតែជាអលិង្គដូច្នោះ ជាដរាបតទៅ ឬ មានផ្លាស់ប្រែទៅជាលិង្គអ្វីទៀតបានដែរ ? ពាល់តែធើយ៉ាងម៉េច ? ធើទៅមើល !

១២-ពាក្យដែលមានដើមកំណើតជាបុល្លិង្គស្រេច មានប៉ុន្មានពាក្យ? ជាឥត្ថីលិង្គស្រេចមានប៉ុន្មានពាក្យ ? ចូរវាញគួយ៉ាងឲ្យអស់ពាក្យគ្រប់លិង្គទាំងពីរ ?

១៣- ពាក្យដែលជាអលិង្គនោះដូចម្ដេចខ្លះ ? ចូរស្មូត្រឲ្យបាន១០ ពាក្យម.មើល ?

១៤-ចូរយ.ពាក្យដែលមានកំណើត ជាបុល្លិង្គ ១០ ពាក្យ, ឥត្ថីលិង្គ១០ ពាក្យ ម.ផ្សំនឹងពាក្យជាអលិង្គនោះ ដាក់ពីខាងមុខបុល្លិង្គឲ្យបាន១០ពាក្យ? ឥត្ថីលិង្គឲ្យបាន ១០ពាក្យ? រួចហើយដាក់ផ្សំពីខាងក្រោយបុល្លិង្គឲ្យបាន ១០ ពាក្យ ? ឥត្ថីលិង្គឲ្យបាន ១០ ពាក្យ ? ចូរផ្សំឲ្យសមសេចក្ដីផង !

១៥- ក្រៅពីពាក្យទាំងពីរពួក ដែលសម្រាប់សំគាល់ឲ្យស្គាល់លិង្គបាននោះ គេនៅមានអ្វីជាគ្រឿងសម្រាប់សំគាល់ឲ្យស្គាល់លិង្គបានទៀត ?

www.elibraryofcambodia.org

១៦- បច្ច័យក្នុងកម្ពោជៈ ដោយមិនរាប់បច្ច័យក្នុងវិភត្តនាមពូលផង មានប៉ុន្មានគូ? អ្វីខ្លះ ?

១៧- អា បច្ច័យសម្រាប់ចុះខាងណាពាក្យ? ពាក្យនោះមានរូបដើមជាយ៉ាងម៉េចទើបចុះបាន ? កាលបើចុះម.ហើយ សរៈក្នុងដើមនោះត្រូវធ្វើដូចម្ដេចទៅ ?

១៨- ពាក្យដែលប្រព្រឹត្តទៅបានតាំងពីរលិង្គដូច្នេះ ហៅថាអ្វី? ចូរទាញឧទាហរណ៍ដែលចុះ អា បច្ច័យឲ្យបាន១០ពាក្យ?

១៩- ឿ បច្ច័យ សម្រាប់ចុះខាងណាពាក្យ ? បច្ច័យនេះប្រព្រឹត្តទៅបានប៉ុន្មានលិង្គ? កាលបើចុះម.ហើយសរៈក្នុងដើមត្រូវធ្វើដូចម្ដេច? ចូរទាញឧទាហរណ៍ដែលចុះ ឿ បច្ច័យក្នុងឥត្ថីលិង្គឲ្យបាន១០ពាក្យ ?

២០- ពាក្យមានទីបំផុតយ៉ាងម៉េច ? ទើបចុះ ឥនី បច្ច័យបាន? កាលបើចុះម.ហើយ សរៈក្នុងដើមត្រូវធ្វើដូចម្ដេច? ចូរទាញឧទាហរណ៍ដែលចុះ ឥនី បច្ច័យឲ្យបាន ១០ ពាក្យ ?

២១- បច្ច័យក្រៅពី អា, ឿ, ឥនី ប៉ុន្មានបច្ច័យទៀត ដែលចុះបានតែខាងចុងពាក្យដែលជានបុំសកលិង្គ ហើយទាក់ទងដោយ

www.elibraryofcambodia.org

ទ្វីប, ប្រទេស, រដ្ឋ, នគរ, ខេត្ត, ខណ្ឌ, គមៈ ភូមិ ?

៦២– បច្ច័យសម្រាប់ចុះក្នុងបុល្លិង្គមានប៉ុន្មាន? ក្នុងឥត្ថីលិង្គប៉ុន្មាន? គឺអ្វីខ្លះ?

៦៣– បុល្លិង្គចុះបច្ច័យអ្វី? ហើយឥត្ថីលិង្គត្រូវចុះបច្ច័យអ្វីទើបបាន? បើចុះក្រៅពីកំរិតនេះបានឬទេ? ព្រោះហេតុអ្វី?

៦៤– ឥយេន, កាំង, គេស បច្ច័យ ៣ នេះ ចុះម. ខាងចុងពាក្យណាហើយ ពាក្យនោះឲ្យប្រែថាអ្វីបានខ្លះ? ចូរភាញគួយ៉ាង!

៦៥– អុន, តោន បច្ច័យ ចុះបានតែខាងចុងពាក្យយ៉ាងម៉េច? ទឹងចុះម. ហើយឲ្យប្រែថាអ្វី?

៦៦– អុន, តោន បច្ច័យនេះណាជាបុល្លិង្គ ណាជាឥត្ថីលិង្គ? អុន ដូចឧទាហរណ៍យ៉ាងណា? ឧទាហរណ៍យ៉ាងម៉េចទើបចុះតោន បច្ច័យបាន?

៦៧– ឥស្ស បច្ច័យសម្រាប់ចុះខាងចុងពាក្យដូចម្ដេច? ចុះម. ហើយ ត្រូវប្រែថាម៉េចបានខ្លះ? ចូរតបឲ្យអស់!

៦៨– ឥស្ស បច្ច័យជាធម្មាធិដ្ឋាន, តែបើយើងត្រូវការឲ្យជាបុគ្គលាធិដ្ឋានវិញ តើត្រូវធើដូចម្ដេចទៀត? ក្នុងបុល្លិង្គចុះបច្ច័យ

www.elibraryofcambodia.org

ណា ឥត្ថីលិង្គចុះបច្ច័យណា ?

២៩— ពាក្យថា បញ្ញវន្តុ [illegible] នេះបើជាឥត្ថីលិង្គ សម្រេចរូបជាយ៉ាងម៉េច? ប្រែថា [illegible] ជាបុល្លិង្គ សម្រេចរូបជាយ៉ាងណា? ប្រែថាម៉េចបានខ្លះ ? ចូរតបឲ្យសព្វគ្រប់ !

៣០— ឯរ, ឯរេស បច្ច័យ សម្រាប់ចុះខាងចុងពាក្យណា? ចុះម.ហើយសម្រេចរូបជាយ៉ាងម៉េច?

៣១— ឯរ, ឯរេស បច្ច័យ ចុះម.ហើយមានសេចក្ដីផ្សេងគ្នាយ៉ាងណា ?

៣២— ឥក បច្ច័យ សម្រាប់ចុះខាងចុងពាក្យណា? ចុះម.ហើយសម្រេចរូបជាយ៉ាងណា? ចូរទាញឧទាហរណ៍ជាតួយ៉ាង !

៣៣— ណក បច្ច័យ សម្រាប់ចុះខាងចុងពាក្យណា? ចុះម.ហើយ ប្រែថាម៉េចបានខ្លះ ? ចូរទាញតួយ៉ាង !

៣៤· ចូរយ.ពាក្យថា "សាប៊ូ" ទៅផ្សំនឹងបច្ច័យទាំងឡាយដែលបានរៀនរួចម.ហើយ ក្នុងសេចក្ដីថា: "ប្រុសអ្នកធ្វើសាប៊ូ ឬ លក់សាប៊ូ; ស្រីអ្នកធ្វើសាប៊ូ ឬ លក់សាប៊ូ; ធ្វើសាប៊ូ ឬ លក់សាប៊ូ; កន្លែងធ្វើសាប៊ូ ឬលក់សាប៊ូ, ..." តើសម្រេចរូបជាយ៉ាងណាខ្លះ?

www.elibraryofcambodia.org

៣៥– ឥរ បច្ច័យ សម្រាប់ចុះខាងចុងពាក្យយ៉ាងម៉េចបាន ខ្លះ? ចូរនាំគ្នាគិតមើល!

៣៦_ពាក្យដែលមានស្រៈ "ក" ជាទីបំផុត ក្នុងលិង្គទាំង៤ នោះ គេតែងពាក្យជាយ៉ាងម៉េចខ្លះ? ចូរសួរគ្រូមើល!

## វចនៈ (Le nombre)

ប្រភេទរបស់ពាក្យសម្រាប់ប្រាប់ចំនួន ឲ្យដឹងថាតិច ឬច្រើន ដែលកំណត់តាមរបៀបផែនវេយ្យាករណ៍ សម្រាប់ភាសាមួយៗ ដើម្បីឲ្យប្រើឲ្យត្រូវចំនួនរបស់នាម ឬសព្វនាមនោះៗ ហៅថា វចនៈ (Le nombre) ។ ក្នុងអស់ភាសាមួយៗនោះ, វចនៈមានចំនួនមិនស្មើគ្នាទេ ភាសាខ្លះមានតែពីរ, ខ្លះមានបី ស្រេចហើយតែទំនងវេយ្យាករណ៍របស់ភាសានោះៗ គ្រាន់ទុក ។ តែសម្រាប់ក្នុងកម្ពុជភាសានេះ វចនៈមានកំណត់ត្រឹម ៣ យ៉ាង គឺឯកវចនៈ ១, ពហុវចនៈ ១, អវចនៈ ១ ។

ឯកវចនៈ (Le singulier) ពាក្យដែលប្រាប់ចំនួនតិច គឺ ប្រាប់ដំណើររបស់ពាក្យថា មានតែមួយ ឬប្រាប់ដំណើររបស់ពាក្យ ដែលប្រមូលចំនួនច្រើនរួមបញ្ចូលគ្នាជាមួយ នេះឯងហៅថា

www.elibraryofcambodia.org

ឯកវចនៈ (Le singulier) ដូចពាក្យថា: “បុរស, ជន, បុគ្គល” នេះគឺសំគាល់ថា: “បុរស មួយនាក់, ជន មួយនាក់, បុគ្គល មួយនាក់” ឬដូចពាក្យថា: “មហាជន, ប្រជុំជន, ក្រុមពាហន, ក្រុមជំនុំ, ហ្វូងសត្វ, គណៈវេជ្ជមន្ត្រី” ជាដើម នេះក៏សំគាល់ថាជាឯកវចនៈដែរ ព្រោះរបស់ច្រើនមែន ប៉ុន្តែប្រមូលរួបរួមឲ្យទៅជាពាក្យតែមួយម៉ាត់ទៅវិញ ។

ពហុវចនៈ (Le pluriel) ពាក្យសម្រាប់ប្រើក្នុងវេយ្យាករណ៍ប្រាប់ចំនួនរបស់នាម ឬសព្វនាម ឲ្យដឹងថាមានច្រើន គឺអ្វីៗដែលមានច្រើនចាប់តាំងពីត្រឹមចំនួនពីរជាដើមឡើងទៅ នេះឯងហៅថាពហុវចនៈ (le pluriel) ដូចពាក្យថា: “បុរសទាំងឡាយ, ជនទាំង-ឡាយ, បុគ្គលទាំងឡាយ” នេះគឺសំគាល់ថា: “បុរសច្រើននាក់, ជនច្រើននាក់, បុគ្គលច្រើននាក់” ឬដូចពាក្យថា: “បុរសា, ជនា, បុគ្គលា, មនុស្សា, កុមារា, ទាសកា” នេះក៏សំគាល់ថាជាពហុ-វចនៈដែរ មិនមានពាក្យថា “— ទាំងឡាយ” ឬ “ច្រើន” ក៏មែន ប៉ុន្តែសរៈ “អ” ខាងចុងពាក្យទាំងនោះ ផ្លាស់ទៅជាសរៈ “អា” ទៅហើយ ក៏អាចនឹងសំគាល់ដឹងបានថា: “បុរស, ជន, បុគ្គល,

www.elibraryofcambodia.org

មនុស្ស, កុមារ, ទាសក" នោះមានចំនួនច្រើននាក់ ដូចជា មានពាក្យថា "–ទាំងឡាយ" នៅខាងចុងដូច្នោះដែរ ។

អវ្យយៈ[១] ក្នុងកម្ពុជភាសាមានពាក្យមួយបែបទៀត ដែលខុសពីវចនៈទាំងពីរ គឺឯកវចនៈ និងពហុវចនៈ ដែលបានពោលរួចម.ហើយពីខាងដើម ។ ពាក្យដែលមិនអាចនឹងប្រាប់ថា: មានចំនួនតិច ឬចំនួនច្រើនបាន, បានដល់ពាក្យដែលក្នុងកាលពីដើមមានកំណើតយ៉ាងម៉េច ក៏នៅតែជាយ៉ាងនោះដូចដែល មិនមានប្រែប្រួលទៅតាមលិង្គ, មិនដូរទៅតាមវចនៈទាំង ២ ។ ពាក្យដែលមានសភាពដូច្នេះឯង ហៅថា អវ្យយៈ នេះបានដល់ពាក្យពួកខ្លះដែលប្រើជាសន្ធានដូចពាក្យថា: "ក៏, និង, ឯង, តែ, ប៉ុន្តែ, ឯ, បំណែក, ចំណែកខាង" និងពាក្យជាឧទាន ដូចជា "អើ, យ៉ាអើ, ឱ, ឱហ្ន៎, ព្រយ៉ា, ជើសជើ!" ពាក្យទាំងនេះឯង សុទ្ធតែជាអវ្យយៈទាំងអស់ ដោយហេតុមិនមានវចនៈទាំង ៦ ម.ផ្លាស់ឲ្យដូរទៅតាមបាន ។

---

(១) ក្រៅពីពាក្យសន្ធាន និងឧទាន មានពាក្យខាងខ្លះទៀត ក៏លោកហៅថាអវ្យយៈដែរ ចូរសង្កេតមើលក្នុងភាគសម្ពន្ធមាណ ។

www.elibraryofcambodia.org

វិធីប្រើអវ័យវៈ តាមសណ្តាប់ធ្នាប់ ឬបែបផែនរបស់សទ្ទភាសា ឬអវ័យភាសាទីមួយៗ នោះ សុទ្ធតែមានវិធីកំណត់ប្រើវចនៈខុសៗគ្នា ស្រេចហើយតែទំនងវេយ្យាករណ៍កត់កំណត់: ភាសាខ្លះ, មានវិធីកំណត់ខាងដើមពាក្យ គឺបន្ថែមស្រៈខាងដើមពាក្យឲ្យប្លែកផ្សេងពីធម្មតាបន្តិចៈទៅជាពហុវចនៈ ឬថែមពាក្យអ្វីខាងដើមបន្តិចម.ក៏ក្លាយទៅជាពហុវចនៈទៅ ។ ភាសាខ្លះ មានកំណត់ខាងចុងពាក្យ គឺផ្លាស់ស្រៈខាងចុងពាក្យឲ្យប្លែកផ្សេងបន្តិចទៅជាពហុវចនៈ ឬថែមព្យញ្ជនៈអ្វីមួយតួខាងចុង ក៏កត់ថាជាពហុវចនៈទៅ ឬក៏ថែមពាក្យផ្សេងម.ទៀត រួចកត់ថាជាពហុវចនៈទៅ ។ មានភាសាខ្លះផ្លាស់ពាក្យទាំងស្រុងតែម្តង គឺជាឯកវចនៈមួយយ៉ាង ដល់ទៅជាពហុវចនៈ ក៏ផ្លាស់ទៅជាពាក្យមួយយ៉ាងផ្សេងទៀតទៅ ។ ឯក្នុងកម្ពុជភាសាយើង ក៏មានវិធីកំណត់ផ្សេងៗដូចភាសាគេដូច្នោះដែរ គឺវិធីប្រើវចនៈក្នុងកម្ពុជភាសាយើងមានកំណត់ឲ្យប្រើជា ៤ បែបគឺ ។

១-កំណត់ឲ្យផ្លាស់ទីបំផុតព្យញ្ជនៈ ដែលជាតួប្រកបនៃពាក្យជាឯកវចនៈ ឲ្យប្លែកផ្សេងបន្តិចទៅ គឺបើជាស្រៈ "អ" ឲ្យទីឃៈទៅ

www.elibraryofcambodia.org

ជាសរៈ "អា" ក្នុងលិង្គទាំង ៤;

២- បើចុងបំផុតពាក្យជាឯកវចនៈនោះជាសរៈដទៃផ្សេងក្រៅពីសរៈ "អ" នោះ បើត្រូវការឲ្យទៅជាពហុវចនៈនោះ ត្រូវថែមដូច្នេះ : ក្នុងបុល្លិង្គត្រូវថែម "នោ" ម. ខាងចុង, ក្នុងឥត្ថីលិង្គត្រូវថែម "យោ" ម.ខាងចុង, ក្នុងនបុំសកលិង្គត្រូវថែម "និ" ម.ខាងចុង, ក្នុងអលិង្គត្រូវថែម "សំ" ម.ខាងចុង;

៣- ឲ្យផ្លាស់ពាក្យឯកវចនៈទាំងមូលទៅជាពាក្យផ្សេងដោយឡែកក្នុងកាលដែលត្រូវការជាពហុវចនៈ;

៤. បើមិនបានធើតាមវិធីកំណត់ទាំង៣ ហ៊ឹង ដូចដែលបានពោលមហើយខាងដើមនោះទេ ត្រូវថែមពាក្យថា "-ទាំងឡាយ" នៅខាងចុងពាក្យឯកវចនៈនោះៗ តែពាក្យណាដែលជាពាក្យពហុវចនៈស្រាប់ ដូចជា "យើង" ជាដើមនេះ ហាមមិនឲ្យដាក់ពាក្យថា "–ទាំងឡាយ" ថែមខាងចុងម.ទៀត ជាដាច់ខាត វៀរលែងតែក្នុងកំណាព្យ ។

ពាក្យគេទាំងនេះ ត្រូវផ្លាស់សរៈ "អ" ចុងបំផុតពាក្យប្រកបឲ្យជាសរៈ "អា" ក្នុងកាលដែលត្រូវការជាពហុវចនៈ :

www.elibraryofcambodia.org

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| អមរ | អមរា | ខីណាស្រព | ខីណាស្រពា |
| ឥន្ទ្រ | ឥន្ទ្រា | សមណៈ | សមណា |
| ចន្ទ្រ | ចន្ទ្រា | សាមណេរ | សាមណេរា |
| ព្រហ្ម | ព្រហ្មា | ថេរ | ថេរា |
| មនុស្ស | មនុស្សា | ក្សត្រ | ក្សត្រា |
| យក្ស | យក្សា | ខត្តិយ | ខត្តិយា |
| គន្ធព្វ | គន្ធព្វា | ឧបាសក | ឧបាសកា |
| នាគ | នាគា | កុមារ | កុមារា |
| គ្រុឌ | គ្រុឌា | ទារក | ទារកា |
| បិសាច | បិសាចា | នរ | នរា |
| បព្វគ | បព្វគា | ចោរ | ចោរា |
| អរហន្ត | អរហន្តា | សហាយ | សហាយា |
| អាជីវក | អាជីវកា | មិត្ត | មិត្តា |
| បរិព្វាជក | បរិព្វាជកា | ព្រឹក្ស | ព្រឹក្សា |
| អចេលក | អចេលកា | ម្រឹគ | ម្រឹគា |

www.elibraryofcambodia.org

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| ខិត្រជ្ញ | ខិត្រជ្ញា | មច្ច | មច្ចា |
| តិរ្យ | តិរ្យា | តិរច្ឆាន | តិរច្ឆានា |
| ប្រេត | ប្រេតា | សុនខ | សុនខា |
| នរក | នរកា | មហឹសះ | មហឹសា |

ពាក្យតទៅនេះ ជាឯកវចនៈ បុល្លិង្គ, ត្រូវថែម "នោ" ម.ទានី ចុង ក្នុងកាលដែលត្រូវការឲ្យទៅជាពហុវចនៈ ៈ

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| មុនិ | មុនិនោ | បារគូ | បារគូនោ |
| ឥសិ | ឥសីនោ | មគ្គញ្ញូ | មគ្គញ្ញូនោ |
| ភិក្ខុ | ភិក្ខុនោ | វេទគូ | វេទគូនោ |
| គ្រូ | គ្រូនោ | សយម្ភូ | សយម្ភូនោ |
| សេដ្ឋី | សេដ្ឋីនោ | សព្វញ្ញូ | សព្វញ្ញូនោ |
| គហបតី | គហបតីនោ | ការី | ការីនោ |
| អនុជីវី | អនុជីវិនោ | សាមី | សាមីនោ |
| អគ្គិសី | អគ្គិសីនោ | មេធាវី | មេធាវីនោ |

www.elibraryofcambodia.org

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| តបសី | តបសីនោ | លិបី | លិបីនោ |
| ព្រហ្មចារី | ព្រហ្មចារីនោ | សុខី | សុខីនោ |
| មេធាវី | មេធាវីនោ | កវិ | កវីនោ |
| សូលី | សូលីនោ | មតី | មតីនោ |
| វិទូសី | វិទូសីនោ | ទក្ខី | ទក្ខីនោ |
| ព្យាបាលី | ព្យាបាលីនោ | អគ្គញ្ញី | អគ្គញ្ញីនោ |
| ទេសបាលី | ទេសបាលីនោ | សិសន្ទិយី | សិសន្ទិយីនោ |
| កតញ្ញូ | កតញ្ញូនោ | ពលី | ពលីនោ |
| សាមគ្គី | សាមគ្គីនោ | សេវកុមី | សេវកុមីនោ |

ពាក្យគេពោះនៈ ជាឯកវចនៈ, ឥត្ថីលិង្គ ត្រូវថែម "យោ" ម.

ខានចុន ក្នុងកាលដែលត្រូវការឲ្យទៅជាពហុវចនៈ៖

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| កញ្ញា | កញ្ញាយោ | សេដ្ឋិនី | សេដ្ឋិនីយោ |
| អច្ឆរា | អច្ឆរាយោ | គជិនី | គជិនីយោ |
| ធីតា | ធីតាយោ | ក្សត្រិយានី | ក្សត្រិយានីយោ |

www.elibraryofcambodia.org

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| កុលធីតា | កុលធីតាយោ | កុមារី | កុមារីយោ |

ពាក្យទាំងនេះ ជាឯកវចនៈ នបុំសកលិង្គ ត្រូវថែម "ន"

ម.ការផ្សំ ក្នុងកាលដែលត្រូវការឲ្យជាពហុវចនៈ :

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| អក្ខិ | អក្ខីនិ | អដ្ឋិ | អដ្ឋីនិ |
| អច្ចិ | អច្ចីនិ | សប្បិ | សប្បីនិ |

ពាក្យទាំងនេះ ជាឯកវចនៈ . អលិង្គ ត្រូវថែម "ស៍"

ម.ការផ្សំ ក្នុងកាលដែលត្រូវការឲ្យទៅជាពហុវចនៈ :

| ឯកវចនៈ | ពហុវចនៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|---|
| សេះ | សេះស៍ | ខ្លា | ខ្លាស៍ |
| ដំរី | ដំរីស៍ | ពពែ | ពពែស៍ |
| ក្របី | ក្របីស៍ | ឆ្កែ | ឆ្កែស៍ |

ឥក្ខុសព្ទក្នុងវិធីនេះមិនមានទេ អ្នករៀនគប្បីធ្វើឥក្ខុសព្ទ ដោយខ្លួនឯងផងចុះ ព្រោះវចនៈទាំងឡាយដែលបានស្តែងម.នេះ បានកែញែកដោយច្បាស់លាស់ដែរហើយ ។

www.elibraryofcambodia.org

## ២–គុណ

គុណ ជាពាក្យសម្រាប់ធ្វើនាមនិងសព្វនាមឲ្យមានសេចក្ដីប្លែក ចេញទៅ ៗ ពាក្យគេនោះ ជាពាក្យគុណសុទ្ធ មិនទាន់ផ្សំជាមួយនាមនិងសព្វនាម :

ខុស, ខ្មៅ, ខូច, ខិល, ខ្ចក, ខ្ចី, ខ្ជិល, ខ្ពស់, ខ្លាំង, ខ្សោយ, ខ្សត់, ក្រ, ក្រាស់, ស្ដើង, រាប, ទុំ, ខ្ជោះ, ពោក, គោក, ឆ្កួត, តូច, ធំ, ថ្លែក, ជាក់, ស្គម, ជូរ, បត់, ជ្រៅ, ស្អក, ។ល។

ពាក្យគុណនេះ បើប្រកបចូលនឹងនាម ឬស្ដែងលក្ខណនាម លោកហៅថា គុណនាម ចែកបានជា ៣ ជាន់ គឺបកតិគុណនាម១, វិសេសគុណនាម១, អតិវិសេសគុណនាម១ ។ គុណដែលស្ដែងលក្ខណនាមតាមប្រក្រតីធម្មតា ដូច "បុរសធំ" ហៅថា បកតិគុណ-នាម, គុណដែលស្ដែងលក្ខណនាមវិសេសលើសប្រក្រតីធម្មតា ដូច "បុរសធំជាង" ហៅថា វិសេសគុណនាម, គុណដែលស្ដែងលក្ខណនាមវិសេសបំផុតដូច "បុរសធំបំផុត,- "ធំបណ្ដាច់" ហៅថា អតិវិសេសគុណនាម ។

ពាក្យគុណសព្ទ មិនមានចុះបច្ច័យ "ឯរ" និង "ឯរេស" ជា

www.elibraryofcambodia.org

គុណសំដែងលក្ខណនាមជាធម្មតា, បើត្រូវការឲ្យទៅជាវិសេស-គុណនាមត្រូវបុះ "ឯរ" បច្ច័យ, បើត្រូវការឲ្យទៅជាអតិវិសេស-គុណនាមត្រូវបុះ "ឯរេស" បច្ច័យម.ខាងចុង ដូច "មនុស្សស្គម" ជាបកតិគុណនាម, បុះ "ឯរ" បច្ច័យ ជា "មនុស្សស្គមេរ" ជាវិសេសគុណនាម, បុះ "ឯរេស" បច្ច័យ ជា "មនុស្សស្គមេរេស" (១) ជាអតិវិសេសគុណនាម ។ បច្ច័យទាំង ២ នេះសម្រាប់ធ្វើបកតិ-គុណសព្ទឲ្យទៅជាវិសេសគុណសព្ទ និងអតិវិសេសគុណសព្ទ ។

### ៣ – វិសេសនៈ

វិសេសនៈជាពាក្យសម្រាប់ធ្វើពាក្យគុណនាម, សព្ទនាម, កិរិយាឲ្យប្លែកផ្សេងទៅទៀត ដូចពាក្យគុណថា "ស, ខ្មៅ, ខ្ពស់, ទាប ។ល។" ទៅជាពាក្យគុណវិសេសនៈថា "សស្គុស, ខ្មៅយ៉ឺក, ខ្ពស់ត្រដាច, ទាបកន្ទញ ។ល។"; មុននឹងស្គាល់នូវពាក្យគុណវិសេ-សនៈ ត្រូវស្គាល់ពាក្យវិសេសនៈសិន ។ ពាក្យវិសេសនៈជាពាក្យសម្រាប់ធ្វើពាក្យនាម, ពាក្យសព្ទនាម, ពាក្យកិរិយា, ពាក្យវិសេ-

---

(១) ពាក្យថា "មនុស្សស្គមេរ និង ស្គមេរេស" បើមិនប្រើ "ឯរ" និង "ឯរេស" បច្ច័យនេះទេ "ស្គមេរ" ត្រូវនិយាយថា "ស្គមជាង"; "ស្គមេរេស" ត្រូវនិយាយថា "ស្គមបំផុត" ដូចធ្លាប់ប្រើមកស្រាប់ហើយ ។

www.elibraryofcambodia.org

សនៈរបស់កិរិយា ឲ្យមានសេចក្ដីប្លែកវិសេសឡើង, ប្រើប្រកបជាមួយពាក្យនាមដូច "សេះលឿន ។ល។", ប្រើប្រកបជាមួយពាក្យសព្វនាមដូច "អ្នកឯណាខ្លះ ។ល។", ប្រើប្រកបជាមួយកិរិយាដូច "ដើរយូរ ។ល។", ប្រើប្រកបជាមួយពាក្យវិសេសនៈរបស់កិរិយាដូច "រហ័សច្រើន ។ល។"; ពាក្យនាម, ពាក្យសព្វនាម, ពាក្យកិរិយា និង ពាក្យវិសេសនៈរបស់កិរិយា ប្រើជាពាក្យវិសេសនៈប្រកបគ្នា ។ ដែលប្រកបនឹងពាក្យនាម ហៅថា នាមវិសេសនៈ, ដែលប្រកបនឹងពាក្យសព្វនាមហៅថា សព្វនាមវិសេសនៈ, ដែលប្រកបជាមួយពាក្យកិរិយាហៅថា កិរិយាវិសេសនៈ, ដែលប្រកបនឹងពាក្យវិសេសនៈរបស់កិរិយាហៅថា កិរិយាកិរិយាវិសេសនៈ; ក្រៅពីនេះ ពាក្យវិសេសនៈអាចធ្វើនាទីជាអកម្មកិរិយាបានទៀតផង គួយ៉ាងដូច "គេល្អ, គេមិនល្អតទៅ"; ពាក្យវិសេសនៈ ដែលប្រើជាអកម្មកិរិយានោះ នឹងប្រើទៅជាវិក្កតកិរិយា ដែលមានសេចក្ដីថា "ជា" ក៏បាន តាមដំណើរសេចក្ដី ដូច "គេជាទាសៈ, គេជាព្រាហ្មណ៍" ជាដើម។ ពាក្យវិសេសនៈ ដែលធ្វើនាទីជាកិរិយានេះ រមែងប្រើពាក្យកិរិយា

www.elibraryofcambodia.org

នុគ្រោះប្រកបដូចកិរិយាថា: "គេគង់សាក្រក់, គេទីង់ល្អ" ជាដើមៗ

ពាក្យវិសេសនៈចែកចេញជា ១០ ប្រការគឺ

១– លក្ខណវិសេសនៈ ;

២– កាលវិសេសនៈ ;

៣– ស្ថានវិសេសនៈ ;

៤– បរិមាណវិសេសនៈ ;

៥– និយមវិសេសនៈ ;

៦– អនិយមវិសេសនៈ ;

៧– បុច្ឆាវិសេសនៈ ;

៨– ឧបុច្ឆាវិសេសនៈ ;

៩– បដិសេធវិសេសនៈ ;

១០– ប្រភេទវិសេសនៈ ។

លក្ខណវិសេសនៈ គឺពាក្យវិសេសនៈស្ដែងលក្ខណៈ សំដៅដល់ពាក្យវិសេសនៈប្រកបជាមួយនាម ឬសព្វនាម; ដែលប្រើប្រកបចូលជាមួយកិរិយា ទីង់ វិសេសនៈរបស់កិរិយាក៏មាន ។ "លក្ខណៈ" ដៅដល់របស់សំគាល់ដែលអាចឲ្យយើងសង្កេតបាន

www.elibraryofcambodia.org

ដូច "ស, ខ្មៅ, ទាប, ខ្ពស់, ល្ងង់, ឆ្លាត, រហ័ស, យូរ, ក្អកនឹត, សក់វែង" ជាដើម ។ ពាក្យវិសេសនៈពួកនេះ ខ្លះនាំយកពាក្យដទៃមកប្រើជាមួយផងក៏បាន ដូច "ដំរីព្រៃ, ដំរីស្រុក, ជាងឈើ, ជាងប៉ាក់, ជាងស្មិត ។ល។" ; ពាក្យថា "ព្រៃ, ស្រុក, ឈើ" ជាដើម ជាពាក្យនាមទាំងអស់ តែធ្វើជាវិសេសនៈ ប្រកបជាមួយ "ដំរី" ស្តែងលក្ខណៈថាជាដំរីបែបណា ; ពាក្យ "ប៉ាក់, ស្មិត" ជាពាក្យកិរិយា នាំយកមកប្រើជាលក្ខណវិសេសនៈ ប្រាប់ចំណែកផ្សេង ៗ ដូចគ្នា មានឧទាហរណ៍គួរឲ្យសង្កេតបានដូចនេះ :

១– ប្រាប់ចំណែក ឬ ភាគ ដូច "ល្អ, អាក្រក់, ខូច, ចាស់" ជាដើម ;

២– ប្រាប់ខ្នាត ដូច "ធំ, តូច" ជាដើម;

៣– ប្រាប់សណ្ឋាន ដូច "មូល, ជ្រុង" ជាដើម;

៤– ប្រាប់ពណ៌សម្បុរ ដូច "ក្រហម, ស, ខ្មៅ, លឿង" ជាដើម;

៥– ប្រាប់សម្លេង ដូច "តីកេះ" ជាដើម;

៦– ប្រាប់ក្លិន ដូច "ក្រអូប, ស្អុយ" ជាដើម;

www.elibraryofcambodia.org

៧– ប្រាប់រស់ ដូច "សាប, ប្រៃ" ជាដើម;

៨– ប្រាប់ផ្សព្វ ដូច "ក្ដៅ, ត្រជាក់" ជាដើម;

៩– ប្រាប់អាការ ដូច "រហ័ស, យូរ" ជាដើម ។

ពាក្យលក្ខណវិសេសនៈ ដែលប្រាប់អាការនេះ មានប្រើប្រកបជាមួយពាក្យនាម ឬពាក្យសព្វនាម មិនសូវជាច្រើនណាស់ទេ តែដែលប្រើប្រកបជាមួយកិរិយានោះ មានច្រើន ព្រោះពាក្យកិរិយាមាននាទីស្ដែងអាការរបស់នាម ដូច "ដេក, អង្គុយ, រត់, ហោះ។ល។" ដូច្នេះ ពាក្យវិសេសនៈដែលប្រកបកិរិយា ទើបមាននាទីស្ដែងអាការឲ្យប្លែក ៗ ផ្សេងទៅទៀត ដូច "អង្គុយស្ងៀមស្ងប់, ដេកលក់, ដេកយូរ, ហោះហើរ, ស្វាយំព្រះ ៗ, ក្ដៅព្រះឡូ ៗ" ជាដើម ៗ

សំគាល់ហេតុ ពាក្យថា: "លក្ខណ:" គឺគ្រឿងសំគាល់ដែលនាំឲ្យយើងសង្កេតបានថា របស់នេះផ្សេងពីរបស់នោះ ដូចបាននិយាយមកហើយ តែពាក្យថា "អាការ" ជាដំណើរសេចក្ដីប្រព្រឹត្ត, សេចក្ដីប្រព្រឹត្តទៅរបស់មនុស្ស ឬរបស់ផ្សេង ៗ ដែលរួមនៅក្នុងលក្ខណ: នាំឲ្យយើងសង្កេតបានដូចគ្នា ពាក្យនេះក៏សង្គ្រោះចូលក្នុងលក្ខណវិសេសនៈ ផងដែរ គឺពាក្យវិសេសនៈ

www.elibraryofcambodia.org

ស្តែងលក្ខណៈក្តី ពាក្យវិសេសនៈស្តែងអាការទាំងពីរនេះ រួមហៅថា "លក្ខណវិសេសនៈ"

កាលវិសេសនៈ គឺពាក្យវិសេសនៈ ប្រាប់ពេលវេលា ដោយសេចក្តីថា ពាក្យវិសេសនៈ ដែលស្តែងដល់វេលាខាងមុខ ខាងក្រោយ ឬវេលាបច្ចុប្បន្ន ឬវេលាឆាប់ យូរ មុន ក្រោយ ។ល។ តួយ៉ាង :

១– ប្រកបជាមួយនាម ។. មនុស្សបូរាណ, មនុស្សខាងក្រោយ, មនុស្សឥឡូវនេះ, វេលាយូរ, វេលាឆាប់, វេលាព្រឹក, វេលាល្ងាច ។ល។

២– ប្រកបជាមួយកិរិយា ។ ដេកយូរ, ដេកឆាប់, ដេកមុន, ដេកក្រោយ, ដេកឥឡូវនេះ, ដេកល្ងាច, ភ្ញាក់ព្រឹក ។ល។

ពាក្យវិសេសនៈ ដែលប្រកបចូលជាមួយពាក្យសព្វនាម ឬវិសេសនៈ ក៏មានទំនងដូចគ្នានេះដែរ ។

សូមសង្កេតថា : ក្នុងវិធីនេះ លើកមកស្តែងចំពោះតែកាលវិសេសនៈប៉ុណ្ណោះ មិនបានស្តែងដល់ "បទវលី" ដែលស្តែងកាលជាពាក្យច្រើនពាក្យរៀងគ្នាដូច "ថ្ងៃនេះ, ខែនេះ, សករាជនេះ"

www.elibraryofcambodia.org

ដែលយើងត្រូវស្គាល់ទៅក្នុងបទដែលនិយាយពី "វេលា" ។

ស្ថានវិសេសនៈ គឺពាក្យវិសេសនៈប្រាប់ស្ថានទី ឲ្យដល់ពាក្យវិសេសនៈ ដែលស្ថិតដល់ទីលំនៅ ឬ ថិរវេលា ដែលតាំងនៅដូច "ជិត, ឆ្ងាយ, លើ, ក្រោម ។ល។" ដូចតួយ៉ាង:

១– ប្រកបជាមួយនាម ។ ផ្ទះជិត, ផ្ទះឆ្ងាយ, ភូមិក្រោម, ភូមិលើ, សត្វទឹក, សត្វគោក ។ល។

២– ប្រកបជាមួយកិរិយា ។. នៅជិត, នៅឆ្ងាយ នៅក្រោម, នៅលើ ។ល។

សេចក្ដីសង្កេត ពាក្យវិសេសនៈ តែងធ្វើនាទីបុព្វបទបានផងទៀត គឺបើមាននាម ឬពាក្យដែលធ្វើនាទីជានាម ចំពោះពាក្យអស់ទាំងនុ៎ះចេញទៅទៀត ពាក្យនេះក៏ក្លាយទៅជាបុព្វបទប្រាប់ស្ថានទីទៅវិញដូច "ផ្ទះនៅជិតស្រែ, ព្រៃនៅជិតភូមិ ។ល។"; "ជិត" និង "ឆ្ងាយ" ក្នុងទីនេះជាបុព្វបទប្រាប់ស្ថានទី ដែលអ្នករៀនគាប់ដឹងបាន ក្នុងផ្នែកដែលនិយាយដល់រឿងនេះ ។

បរិមាណវិសេសនៈ គឺពាក្យវិសេសនៈប្រាប់ចំនួន

www.elibraryofcambodia.org

ខុសប្លែកគ្នាដូច “ច្រើន, តិច, អស់, គ្រប់ ។ល។” ចំនួនរាប់ដែលហៅថា “សង្ខ្យា” ឬ “ចំនួនលេខ” ដូច “១, ២, ៣, ..; ទី១, ទី២, ..; គំរប់ ១, គំរប់ ២ ។ល។” ព្រមទាំងប្រាប់ចំនួនលើសខ្ទះ ។ល។ នៃពាក្យទាំងនុ៎ះជាដើម ។ ពាក្យវិសេសនៈក្រុមនេះ ចែកចេញជា ៤ ប្រភេទគឺ

១– ប្រាប់ចំនួនដោយឥតមានកំណត់ គឺគ្រាន់តែប្រាប់ប្រមូលផ្តុំៗដោយមិនគាប់កំណត់ចំនួនច្បាស់លាស់ ដូចពាក្យថា : “ច្រើន. តិច, ទាំងពួង, ទាំងឡាយ, ទាំងអស់, ពេញ, ណែន ។ល។” ដូចគួយ៉ាង :

ក) ប្រកបជាមួយនាម ឧ. មនុស្សច្រើន, មនុស្សទាំងឡាយ, មនុស្សពេញណែន, ទូកផ្ទុកពេញ, ទូកផ្ទុកមិនពេញ ។ល។

ខ) ប្រកបជាមួយកិរិយា ឧ. ស៊ីច្រើន, ស៊ីឆ្អែត, ស៊ីមិនឆ្អែត, គេដេកជាមួយគ្នាហើយ ។ល។

២– ប្រាប់ចំនួនផ្តុំៗមានកំណត់ដោយសេចក្តីថា : ប្រាប់ចំនួនផ្តុំៗមានកំរិតទៀងទាត់ឲ្យដឹងថា : មានប៉ុណ្ណេះប៉ុណ្ណោះ ដូចពាក្យ “អស់, ទាំងអស់, ទាំងពួង, បណ្តា ។ល។” ដូចគួយ៉ាង :

www.elibraryofcambodia.org

ក) ប្រកបជាមួយនាម ៖. អស់ប្រាក់ប្រាំរៀល, មនុស្សទាំងអស់ប្រាំនាក់, ច្បាប់ទាំងពួងប្រាំមាត្រា, បណ្ដាជន ១០ នាក់ ។ល។

ខ) ប្រកបជាមួយកិរិយា : ស៊ីអស់ប្រាំចាន, ស៊ីទាំងអស់ប្រាំបង្អាយ, ដេកអស់ ៨ ម៉ោង ។ល។

៣- ប្រាប់ចំនួនមិនទៀង សំដៅសេចក្ដីថា : ស្ដែងចំនួនទៀង ចេញជាពួកៗ ដូចពាក្យថា : ខ្លះ, ផ្សេង, ផ្សេងៗ ។ល។ តួយ៉ាង :

ក) ប្រកបជាមួយនាម ៖. ជនខ្លះ, ជនផ្សេង, ជនផ្សេងៗ ។ល។

ខ) ប្រកបជាមួយកិរិយា ៖. ស៊ីខ្លះ, ធ្វើផ្សេង, ធ្វើផ្សេងៗ ។ល។

សំគាល់ហេតុ ប្រកបជាមួយកិរិយា ច្រើនប្រើជាវិ អ្នករៀនគួរស្ដាប់បានតាមន័យរបស់វា ។

៤- ប្រាប់ចំនួនដោយរាប់ត្រង់ៗ ដៅដល់ការកំណត់រាប់ដោយច្បាស់លាស់តាមចំនួនឈ្មោះដែលនិយាយដល់ថា ប៉ុណ្ណេះ ប៉ុណ្ណោះ មាន ៦ ពួកគឺ

ក) ប្រាប់ចំនួនរាប់តាមលេខធម្មតា (បកតិសង្ខ្យា) បានដល់ចំនួនដែលនិយាយជាលេខ ឬសរសេរជាលេខ ១, ២, ៣, ១០, ១០០, ១.០០០ ជាដើម ។ ប្រកបជាមួយនាមដូច ១ នាក់,

www.elibraryofcambodia.org

២នាក់, ៣នាក់, ៤ដង ។ល។

ខ) ប្រាប់ចំនួនតាមលេខ វិថ្នគំរប់ (បូរណសង្ខ្យា) ដូច ទី១, ទី២, គំរប់៥, គំរប់៦ ។ល។ ច្រើនប្រើប្រកបជាមួយនាម ដូច មនុស្សទី១, ថ្ងៃគំរប់៥ ជាដើម ។

សំគាល់ហេតុ បរិមាណវិសេសនៈនេះ ប្រើប្រកបចូល មុខសព្ទក៏មាន ក្រោយសព្ទក៏មាន ដូចគួយ៉ាងដែលលើកមកហើយ ដូច ច្រើនគេ, គេច្រើន, ច្រើនកញ៉ាល់, កញ៉ាល់ច្រើន ។ល។

និយមវិសេសនៈ គឺពាក្យវិសេសនៈ ប្រាប់សេចក្ដី កំណត់ទុកនូវរបស់ដែលត្រូវសំគាល់ ឬត្រូវនិយាយដល់ឲ្យច្បាស់ លាស់ថាជា "របស់នេះ, របស់នោះ, ដូចនេះ, ដូចនោះ"; មិន មានប្រែប្រួលទៅជាយ៉ាងដទៃដូចពាក្យ "នេះ, នុ៎ះ, នោះ, ដូចនេះ, ដូចនោះ, តែម្ដង, ពិតអ៊ីចឹង, ប្រាកដអ៊ីចឹង" ជាដើម; ពាក្យ វិសេសនៈពួកនេះ ចែកចេញបានជាពីរប្រភេទគឺ

ក) ប្រាប់សេចក្ដីកំណត់ទៀងទាត់ទាក់ទងជាមួយស្ថានទីដូច "នេះ, នុ៎ះ, នោះ" គឺពាក្យ "នេះ" ដៅដល់របស់ ឬកិច្ចការដែល នៅជិត ដូច "ផ្ទះនេះ, ទីនេះ, ការនេះ, មនុស្សរស់ទាំងនេះ;

www.elibraryofcambodia.org

មនុស្សទាំងអស់នេះ, ធ្វើដូចនេះ ។ល។" ពាក្យ "នុ៎ះ" ដៅដល់របស់ដែលនៅឆ្ងាយបន្តិចទៅជាងពាក្យ "នេះ" ដូច "ជននុ៎ះ, ទីនុ៎ះ, ជនអស់នុ៎ះ, ធ្វើដូចនុ៎ះ ។ល។" ពាក្យ "នោះ" ដៅដល់របស់ដែលនៅឆ្ងាយចេញទៅជាង "នុ៎ះ" ទៅទៀត ដូច "ជននោះ, ទីនោះ, ជនអស់នោះ, អ្នកអស់ទាំងនោះ ។ល។";

សំគាល់ហេតុ ពាក្យ "នេះ, នុ៎ះ, នោះ" ច្រើនប្រើផ្សំជាមួយពាក្យដទៃ ដោយយកពាក្យដទៃមកដាក់ពីខាងមុខទៀតជាច្រើនដូច "យ៉ាងនេះ, យ៉ាងនុ៎ះ, យ៉ាងនោះ, ទាំងនេះ, ទាំងនុ៎ះ, ទាំងនោះ, អស់នេះ, អស់នុ៎ះ អស់នោះ" ផ្លាស់ប្តូរឲ្យផ្សេងពីនេះ ហើយច្រើនមាន ដូច "ដូច្នេះ ដូច្នោះ ដូច្នឹង,..." ស្រេចតែការសានិយម ក៏កប់ថា "និយមវិសេសនៈ" ដូចគ្នាទាំងអស់ ។

១) ប្រាប់សេចក្តីកំណត់ពិតប្រាកដទាក់ទងជាមួយសេចក្តីសំគាល់ (គឺមិនទាក់ទងជាមួយស្ថានទី)ដូច "ឯង" ឧទាហរណ៍ : ខ្ញុំឯង, ក្មេងឯង ។ល។

ពាក្យវិសេសនៈ ដែលស្តែងសេចក្តីដៅ មានកំណត់ទៀងទាត់ដូច "តែម្តង, ពិត, ពិតមែន, មែនពិត ។ល។" ពុំផ្ទាផ្ទា

www.elibraryofcambodia.org

និយមវិសេសនៈ" ទាំងអស់ ។

មានពាក្យវិសេសនៈក្នុងពួកជាមួយនេះ ដែលគួរឲ្យសង្កេត គឺ "ចំពោះ" និង "តែ" ដូច "គេឲ្យប្រាក់ចំពោះដល់កូនគេ, "គេឃើញតែដល់កូនគេ" ពាក្យ "ចំពោះ" និង "តែ" ក្នុងទីនេះជានិយមវិសេសនៈប្រាប់សេចក្តីកំណត់សំគាល់ ព្រោះមានបុព្វបទ "ដល់" នៅខាងមុខ, តែបើពុំមានបុព្វបទ, "ចំពោះ" និង "តែ" ធ្វើនាទីជាបុព្វបទ នាំមុខការកផ្សេងៗ ដូច "គេស្រឡាញ់ចំពោះកូនគេ" ឬ "គេស្រឡាញ់តែកូនគេ" ដូចនេះ ពាក្យ "ចំពោះ" និង "តែ" ក៏ជាបុព្វបទជាដរាប ។

សំគាល់ហេតុ ពាក្យ "នេះ, នុះ, នោះ" និងពាក្យដែលផ្សំជាមួយនឹងពាក្យ ៣ នេះ ជួនកាលក៏ប្រើជានិយមសព្វនាម ដូច "នេះរបស់អ្នកណា, ទាំងនេះរបស់អ្នកណា" ក៏មានដែរ, ជួនកាលពាក្យជានិយមសព្វនាម ប្រើទៅជាវិសេសនៈ ដូច "ខ្ញុំមិនគាប់ចិត្តខាយពែងនោះ", ពាក្យផ្សំដែលតាក់ចង់ដោយពាក្យពួកនេះ មានការចាំបាច់ត្រូវឲ្យសង្កេតរូបសេចក្តីថា ពាក្យពួកនេះធ្វើនាទីយ៉ាងណា ក្នុងដំណើរសេចក្តីនោះៗផង ទើបបាច

www.elibraryofcambodia.org

ការពារខ្លួនការកោនប្រឡំបាន ។

អនិយមវិសេសនៈ គឺពាក្យវិសេសនៈ ស្ដែងសេចក្ដីមិនកំណត់ទៀងទាត់ជាប់ខាត ម្ល៉ះសេចក្ដីទូទៅចែកជាពីរពួកគឺ

ក) ពួកពាក្យដែលជួយគំនិយមវិសេសនៈ ដូច "ដទៃ, ដទៃៗ, ក្រុមដទៃ, ពួកដទៃ, យ៉ាងដទៃ" គួយ៉ាងដូច "មនុស្សដទៃ, ជនពួកដទៃ, ក្រុមជនដទៃ, ធ្វើយ៉ាងដទៃ" ដូច្នេះជាដើម ។

ខ) ពួកពាក្យដែលប្រាប់សេចក្ដីមិនប្រាកដ មិនចំ មិនច្រើ ជាពាក្យប្រាប់សេចក្ដីសង្ស័យ មិនប្រើជាពាក្យសួរ តែប្រើទៅកន្លែងពាក្យមិនប្រាកដ មិនចំត្រង់ ដូចពាក្យ "ឯណា, ឯណាៗ, អ្វី, អ្វីៗ, ម្ដេច, ដូចម្ដេចៗ, ណា, ណាៗ, មិច, យ៉ាងមិច, យ៉ាងដូចម្ដេច, ធ្វើមិច ។ល។" ពាក្យផ្សេងដែលចាក់ចងជាមួយនឹងពាក្យ "ប៉ុន្មាន" ឬពាក្យខ្លះទៀតទាំងដើមនោះ ដូច "ប៉ុន្មាននាក់, ប៉ុន្មានគ្រា, ប៉ុន្មានលើក, ប៉ុន្មានដង, ជាកបណា, ដូចម្ដេច ។ល។" ដូចគួយ៉ាង "គេមកវេលាណាក៏បាន, គេដណ្ដប់សំពត់អីបានទាំងអស់, គេនឹងមកធ្វើមិចក៏ដោយ, ឯងធ្វើយ៉ាងមិចបានទាំងអស់, ម៉េចមកជេរខ្ញុំមិនកោតខ្លាចសោះ, អ្នកស៊ីបាយប៉ុន្មានចានក៏បាន,

www.elibraryofcambodia.org

មានឧបមាយ៉ាងណា មានឧបមេយ្យយ៉ាងនោះ" ដូច្នេះជាដើម ។

បុច្ឆាវិសេសនៈ គឺពាក្យវិសេសនៈ ដែលសំដែងសេចក្ដីសង្ស័យ ឬប្រើទៅក្នុងពាក្យសួរ បានដល់ពាក្យអនិយមវិសេសនៈ តែវៀរលែងខ្លះពាក្យដែលមិនសំដែងសេចក្ដីសង្ស័យ ឬប្រើទៅក្នុងពាក្យសួរដូចពាក្យ "ឯណា, អ្វី, ម្ដេច, ដូចម្ដេច, ម៉េច, យ៉ាង-ម៉េច, ប៉ុន្មាននាក់, ហេតុអ្វី, យ៉ាងណា" ដូច្នេះជាដើម ដូចក្នុងយ៉ាង "អ្នកណាហ៊ានធ្វើបាបយើង, នោះជាសត្វអ្វី, ទាស់គ្នាហើយម៉េចមកនិយាយរកខ្ញុំ ធ្វើម៉េចបានល្អហ្ន៎, អ្នកណាជាកូនរបស់លោក, លោកមានកូនប៉ុន្មាននាក់, លោកមានអាយុប៉ុន្មានហើយ" ដូច្នេះជាដើម ។

សេចក្ដីសង្កេត ពាក្យវិសេសនៈពួកនេះ ត្រូវទាក់ទងជាមួយនឹងពាក្យប្រាប់សេចក្ដីសង្ស័យ ឬប្រើជាពាក្យសួរ បើសំដែងសេចក្ដីយ៉ាងដទៃក្រៅពីនេះ នឹងត្រូវទៅជាអនិយមវិសេសនៈទៅវិញ ។

ប្ដេជ្ញាវិសេសនៈ បានដល់ពាក្យវិសេសនៈ ដែលសំដែងការទទួលកប់ក្នុងរឿងនិយាយ ហៅរកនឹងឆ្លើយ ដូចពាក្យ

www.elibraryofcambodia.org

“បាទ, ចា៎ះ, ខ្ញុំបាទ, នាងខ្ញុំ, ខ្ញុំព្រះបាទ, ព្រះបាទ, អើយ” ជាដើម ។

ពាក្យទាំងអស់នេះ បានឈ្មោះថាពាក្យវិសេសនៈ ព្រោះប្រកបនាមនឹងកិរិយា ដូចតួយ៉ាងតទៅនេះ :

ជាមួយនឹងពាក្យហៅគេ ដូច “នាងចា៎ះ, បាទលោក, ឪបអើយ ។ល។” ដូច្នេះ ពាក្យ “ចា៎ះ, បាទ, អើយ” មែនប្រកបជាមួយពាក្យដែលនៅមុខគឺ “នាង, លោក, ឪប” ជាមួយនឹងពាក្យឆ្លើយថា “ចា៎ះ, បាទ, អើយ” ដូច្នេះ ក៏ហៅថា បុច្ឆាវិសេ-សនៈ ដោយមិនចាំបាច់ប្រកបជាមួយពាក្យអ្វីទៀតទេ វេលាណាប្រាប់សម្ពន្ធ, ពាក្យអស់នេះ ត្រូវនៅកណ្ដាលនោះ “បទគ្លាប់” តែបើជាសេចក្ដីឆ្លើយដែលនៅដើមប្រយោគ ដូចពាក្យសួរថា “លោកជាទាហានឬ?” ពាក្យតប “បាទខ្ញុំជាទាហាន” ឬនៅខាងចុងប្រយោគថា “ខ្ញុំជាទាហានបាទ” ដូច្នេះពាក្យ “បាទ” ទាំងពីរប្រយោគនេះ ត្រូវពង្រីកថែមថា “បុច្ឆាវិសេសនៈប្រកបកិរិយាជា” ។

បដិសេធវិសេសនៈ គឺពាក្យវិសេសនៈ ប្រាប់សេចក្ដី

www.elibraryofcambodia.org

ហាមឃាត់ ឬប្រាប់សេចក្ដីមិនពិតវិញ បានដល់ពាក្យ "មិនមែន, មិនត្រូវ, មិនបាន, ពុំបាន" ជាដើម ពាក្យអស់នេះ វេលាប្រកបជាមួយនាមឬកិរិយា នៅខាងមុខក៏មាន នៅខាងក្រោយក៏មាន ដូចគួរឃើញតទៅនេះ : ជាមួយនាម "មិនមែនកិច្ចរបស់អ្នករៀន" ជាមួយកិរិយា "មិនទៅ, មិនបានទៅ, ទៅមិនបាន, មិនទៅទេ, កុំទៅទេ" ជាដើម ។

បដិសេធវិសេសនៈ ប្រើជាពាក្យឆ្លើយក៏មាន ដូចពាក្យថា "ទេ មិនបានទេ" ដូចសួរថា "លោកឃ្លានបាយឬ?" ឆ្លើយថា "ទេ មិនឃ្លានទេ" ពាក្យអស់នេះ បើញែកឲ្យល្អិតទៅទៀត គឺត្រូវហៅឲ្យពេញថា "បដិសេធវិសេសនៈក្នុងអត្ថនៃពាក្យតបឆ្លើយ" ទីនេះប្រើផ្សំជាមួយពាក្យ ប្ដូរជាវិសេសនៈក៏បាន ដូចពាក្យសួរខាងលើនឹងត្រូវឆ្លើយដូចនេះវិញ "ទេបាទ ឬ បាទទេ មិនឃ្លានទេ"ដូច្នេះ ជាដើម ។

ប្រពន្ធវិសេសនៈ គឺពាក្យប្រពន្ធសព្ទនាមដែលយកមកប្រើជាវិសេសនៈ បានដល់ពាក្យ "ដែល, សឹង, ដ៏" ពាក្យដែលផ្សំជាមួយពាក្យអស់នេះ ដូច "យ៉ាងដែល ៗ ល ៗ" សឹងនាំមក

www.elibraryofcambodia.org

ភ្ជាប់ជាមួយពាក្យវិសេសនៈ ឬពាក្យកិរិយា គួរយ៉ាងដូច "ក្មេងរូបនេះល្ងង់ទ្រុក គឺល្ងង់ដែលអធិប្បាយមិន[illegible]វេលាដ៏យូរសឹងប្រមាណមិនបាន" ឬ "ជារបស់ច្រើន[illegible]ពុំបាន" ឬ "គេស៊ីយ៉ាងដែលហៅថាបក្តុះកំពង់" ជាដើម ដូច្នេះពាក្យ "ដែល, សឹង, ដ៏" និងពាក្យ "យ៉ាងដែល" សុទ្ធតែជាពាក្យពង្រីកពាក្យវិសេសនៈនិងកិរិយានោះ ទើបរាប់ថាជា "ប្រពន្ធវិសេសនៈ" ។

ពាក្យដែលជាហេតុនៃសេចក្តីខាងដើម បានដល់ពាក្យថា "ព្រោះ, ដោយ, ហេតុព្រោះ, ហេតុថា, ដោយថា, ព្រោះថា" ជាដើមគួរយ៉ាងដូច "ក្មេងខូចចរិយាមនុស្ស ព្រោះចាស់ប្រៀនប្រដៅមិនល្អ, គេធ្វើបុណ្យដោយជនដទៃដឹកនាំ" ដូច្នេះជាដើម ពាក្យ "ព្រោះ, ដោយ" សុទ្ធតែជាពាក្យពង្រីកកិរិយាទាំងអស់ ទើបរាប់ថាជា "ប្រពន្ធវិសេសនៈ" ។

ពាក្យពង្រីកបទខាងដើម បានដល់ពាក្យដូចតទៅនេះ ៖ "ដើម្បីថា, ដើម្បីឲ្យ". ជាដើម គួរយ៉ាងដូច "គេនិយាយដើម្បីឲ្យយើងខូចចិត្ត, គេចិញ្ចឹមកូន ដើម្បីថាកូននឹងបានចិញ្ចឹមគេវិញ" ពាក្យថា "ដើម្បីឲ្យ, ដើម្បីថា" សុទ្ធតែជាពាក្យពង្រីកកិរិយា

www.elibraryofcambodia.org

ទើបរាប់ថាជា "ប្រពន្ធវិសេសនៈ" ។

សំគាល់ហេតុ ពាក្យប្រពន្ធវិសេសនៈអស់នេះអាចធ្វើនាទី ជាបទគន្លាប់របស់វិសេសនាមប្រយោគក្នុងវិធីប្រាប់សម្ពន្ធនៃសន្ធិប្រយោគក៏បាន ។

## ៩. ត្រួតសារបទទី ៤

១– ពាក្យគុណបានដល់ពាក្យអ្វី? សម្រាប់ប្រើយ៉ាងណា? ខុស, ខ្មៅ, ខូច, ទិល ។ល។ ជាពាក្យគុណមែនឬ?

២- ពាក្យគុណ ដែលគេយកមកធ្វើជាពាក្យ [illegible] ធ្វើសព្វលក្ខណ-នាមហៅថាអ្វី? ចែកជាប៉ុន្មានយ៉ាង? មានឧទាហរណ៍ដូចម្ដេច?

៣- ពាក្យវិសេសនៈ បានដល់ពាក្យអ្វី? សម្រាប់ប្រើជាមួយពាក្យណាខ្លះ? បើប្រើត្រួតជាមួយនឹងពាក្យកិរិយា ហៅដូចម្ដេច?

៤. ពាក្យវិសេសនៈ អាចធ្វើនាទីជាមុខកម្មកិរិយា បានឬទេ? បើមិនបានក៏ហើយទៅ បើបានមានឧទាហរណ៍យ៉ាងណា ?

៥-ពាក្យវិសេសនៈ ដែលធ្វើនាទីជាកិរិយា បើនឹងប្រើទៅជាកិរិយាទុគ្រោះ ប្រកបកិរិយាបានឬទេ ? បើមិនបានក៏ហើយទៅ បើបានមានឧទាហរណ៍យ៉ាងណា?

www.elibraryofcambodia.org

៦. ពាក្យវិសេសនៈ ចែកចេញជាប៉ុន្មានយ៉ាង រាប់ឲ្យគ្រប់មកមើល ?

៧. លក្ខណវិសេសនៈ មានសេចក្ដីអធិប្បាយយ៉ាងណា? ប្រកបចូលជាមួយនឹងពាក្យណាខ្លះ? "លក្ខណ" ដៅដល់អ្វី? សង្កេតបានដូចម្ដេច?

៨. ពាក្យលក្ខណវិសេសនៈ នឹងនាំយកពាក្យដទៃមកប្រើជាមួយផងបានឬទេ? បើប្រើបានមានឧទាហរណ៍ដូចម្ដេចខ្លះ? គួរសង្កេតបានយ៉ាងណា ?

៩. កាលវិសេសនៈ ស្ដែងដល់អ្វី? ចូរអធិប្បាយឲ្យយ៉ាងពិស្ដារ !

១០. កាលវិសេសនៈ ប្រកបចូលនឹងពាក្យណាបានខ្លះ ? ចូរនាំយកពាក្យដែលកាលវិសេសនៈនេះ ប្រកបជាមួយ ព្រមទាំងឧទាហរណ៍មកផង!

១១. ស្ថានវិសេសនៈ បានដល់ពាក្យដូចម្ដេច? ដៅដល់អ្វី? ប្រកបជាមួយពាក្យណាបានខ្លះ? ចូរនាំឧទាហរណ៍មកផង !

១២. ស្ថានវិសេសនៈ នឹងធ្វើនាទីជាបុព្វបទបានឬទេ? បើ

www.elibraryofcambodia.org

បាន តើបានក្នុងទំដូចម្ដេច? លើកឧទាហរណ៍មកផង!

១៣- បរិមាណវិសេសនៈ បានដល់ពាក្យអ្វី? មានរបៀបប្រើយ៉ាងណា? ចូរអធិប្បាយ ព្រមជាមួយដោយឧទាហរណ៍ ឲ្យបានសព្វគ្រប់!

១៤- បរិមាណវិសេសនៈ ចែកចេញជាប៉ុន្មានយ៉ាង? ក្នុងយ៉ាងមួយ ៗ មានសេចក្ដីអធិប្បាយដូចម្ដេច? មានឧទាហរណ៍យ៉ាងណា?

១៥- និយមវិសេសនៈ បានសេចក្ដីដូចម្ដេច? ចែកចេញបានជាប៉ុន្មានប្រភេទ? ក្នុងប្រភេទមួយ ៗ មានសេចក្ដីអធិប្បាយយ៉ាងណា? ចូរប្រកបឧទាហរណ៍មកផង!

១៦- អនិយមវិសេសនៈ ស្ដែងដល់អ្វី? ចែកជាប៉ុន្មានពួក? ក្នុងពួកមួយៗ មានសេចក្ដីអធិប្បាយដូចម្ដេច? មានឧទាហរណ៍យ៉ាងណា?

១៧- បុច្ឆាវិសេសនៈ ស្ដែងពីអ្វី? មានសេចក្ដីអធិប្បាយដូចម្ដេច? ចូររកឧទាហរណ៍មកប្រកបផង!

១៨- ប្ដេជ្ញាវិសេសនៈ បានដល់ពាក្យជាម៉េច? មាន

www.elibraryofcambodia.org

សេចក្ដីអធិប្បាយយ៉ាងណា? ចូរឲ្យឧទាហរណ៍សព្វគ្រប់មកមើល!

១៩ - បដិសេធវិសេសនៈ ពាក្យនេះមានរបៀបប្រើយ៉ាងណា? ប្រកបជាមួយពាក្យអ្វីបានខ្លះ? ចូរអធិប្បាយព្រមជាមួយដោយឧទាហរណ៍!

២០ - ប្រភេទវិសេសនៈ បានដល់ពាក្យអ្វី? មានប៉ុន្មានសព្ទ? ចូរនិយាយឲ្យស្ដាប់បាន ព្រមទាំងប្រកបឧទាហរណ៍ផង!

## ៣ – គុណវិសេសនៈ

កាលបើបានរៀនពាក្យវិសេសនៈទាំង១០ ប្រការ ដែលជាពាក្យសម្រាប់ទាំពាក្យនាម, ពាក្យសព្វនាម, ពាក្យកិរិយា, ពាក្យវិសេសនៈរបស់កិរិយា ឲ្យជាពាក្យមានសេចក្ដីវិសេសខ្ពង់ខ្ពស់ឡើងក្នុងដំណើរសេចក្ដីផ្សេងៗ ហើយត្រូវរៀនពាក្យគុណវិសេសនៈដែលជាពាក្យសម្រាប់ធ្វើពាក្យគុណ ឲ្យមានសេចក្ដីខ្ពង់ខ្ពស់ផ្សេងទៅទៀត ។ ពាក្យគុណវិសេសនៈនេះ មានសេចក្ដីផ្សេងគ្នាពីពាក្យវិសេសនៈ ព្រោះនាទីរបស់ពាក្យនេះ សម្រាប់តែធ្វើពាក្យគុណឲ្យមានសេចក្ដីខ្ពង់ខ្ពស់ឡើងដោយចំពោះ មិនបានធ្វើពាក្យនាម, ពាក្យសព្វនាម, ពាក្យកិរិយា, ពាក្យវិសេសនៈរបស់កិរិយា

www.elibraryofcambodia.org

ឲ្យមានសេចក្ដីខ្ទុកផ្សេងទៅទៀត ដូចពាក្យវិសេសនៈឡើយ ។

ពាក្យគុណវិសេសនៈនេះចែកបានជា ៨ យ៉ាងគឺ:

១ - ភាគគុណវិសេសនៈ;

២ - បរិមាណគុណវិសេសនៈ;

៣ - សណ្ឋានគុណវិសេសនៈ;

៤ - វណ្ណគុណវិសេសនៈ;

៥ - សទ្ទគុណវិសេសនៈ;

៦ - គន្ធគុណវិសេសនៈ;

៧ - រសគុណវិសេសនៈ;

៨ - សម្ផស្សគុណវិសេសនៈ ។

១– ភាគគុណវិសេសនៈ ពាក្យដែលសម្រាប់ធ្វើពាក្យគុណដែលជាភាគ (ចំណែក) គឺពាក្យគុណដែលស្ដែងប្រាប់នូវភាគរបស់ពាក្យនាម ឬសព្វនាម ឲ្យខ្ទុកផ្សេងពីធម្មតាទៅ ហៅថា ភាគគុណវិសេសនៈ ។ ពាក្យគុណដែលស្ដែងប្រាប់នូវភាគរបស់ពាក្យនាម ឬសព្វនាម បានដល់ពាក្យទាំងឡាយនេះគឺ ល្អ, ទន់, ចាស់, ខ្ចី, រឹង, ស្រួយ ជាដើម ។ ពាក្យភាគគុណ-

www.elibraryofcambodia.org

វិសេសៈបានដល់ពាក្យថា បំប្រែ, ឆើត, ខ្វង់, ល្ងង់, ក្ងិន,
កំព្រុក, កំព្រាត, ល្ហោក, ក្រតាំង, ថែស, ស្រឹម, ស្រែស ជាដើម ។

២-បរិមាណគុណវិសេសនៈ បានដល់ពាក្យសម្រាប់
ធ្វើពាក្យគុណដែលជាភាគប្រមាណ គឺពាក្យដែលស្តែងប្រាប់នូវ
ភាគប្រមាណរបស់ពាក្យនាម ឬសព្វនាម ទៀតក្តីផ្សេងពីធម្មតា
ទៅ ហៅថា បរិមាណគុណវិសេសនៈ ។ ពាក្យគុណដែលស្តែង
ប្រាប់នូវភាគរបស់ពាក្យនាម ឬសព្វនាមនោះ បានដល់ពាក្យ
តាំងអម្បាលនេះ គឺ ធំ, តោ, តូច, ធាត់, ស្គម, វែង, ខ្លី, ស្តើង,
ក្រាស, ធ្ងារ, ល្អិត, ថ្លោស ។ ពាក្យបរិមាណគុណវិសេសនៈ
បានដល់ពាក្យថា : កន្ទុប, ក្រញ៉ឹង, ក្រញុញ, ក្រឡុញ,
កំបុត, កំកេ, ក្រអុប, ក្រអុល, ស្រលន, ក្រលុក, ស្អូល, កំ-
ប្រេវ, កំព្រយ, កំព្រឹង, ប្រខក់, ប្រផក់, ប្រឌឹង, រំយឹង, កំពាន,
កំប៉ាំង, ក្រមឹង, ស្តឹង, ស្តើន, ជំរើរ, ក្រញឹម, ប្រមក់, ក្រ-
ញឹបៗ, ប្រមិច, ប្រឡឹង, ស្រអុក, គ្រលុប, ស្មោះ, ស្មោញ,
ផង់, ស្មោ, រលែម, ល្អែម, ឃ្មឹក, ឃ្មុក, លលៃ, លោម
ជាដើម ។

www.elibraryofcambodia.org

៣ - សណ្ឋានគុណវិសេសនៈ ពាក្យដែលសម្រាប់ធ្វើពាក្យគុណដែលជាសណ្ឋាន គឺពាក្យដែលស្តែងប្រាប់នូវសណ្ឋានរបស់ពាក្យនាម ឬសព្វនាម ឲ្យប្លែកផ្សេងពីធម្មតាទៅ ហៅថា សណ្ឋានគុណវិសេសនៈ ។ ពាក្យគុណដែលស្តែងប្រាប់នូវសណ្ឋានរបស់ពាក្យនាម ឬសព្វនាមនោះ ដូចជាពាក្យទាំងអម្បាលនេះគឺ ខ្ពស់, ទាប, ត្រង់, មូល, រាក់, ជ្រៅ, ទូលាយ, ចង្អៀត, យារ, ង, វៀច, ពោក ជាដើម ។ ពាក្យសណ្ឋានគុណវិសេសនៈភ្ជាប់ដល់ពាក្យថា ទ្រដាប, គ្រដឹង, គ្រដឹម, ត្រដែក, គ្រះដាម, ស្រោង, លៃល, ស្រាវ, ស្រយាវ, ស្រៀវ, ស្រលូន, ស្រឡេត, ស្រឡេវ, ស្រះលាប, ត្រឡៃ, កន្តាញ, កន្តិល, កន្តឹប, កន្ទុញ, កន្ទុល, កន្ទែក, ក្រញិញ, ទ្រនាប់, ទ្រមែម, ស្រវ្រឹម, ស្រអិប, ធុន, ធូ, ធុញ, ក្ញឹង, ស្មុង, ស្មើ, កុំ, ក្រមុំ, ថ្នុំ, កន្ទួល, កំប៉ុក, កំភែល, ល្ហួន, ស្រឡូន, ល្វីង, ប៉ែស, ស្អាក់, ស្តុក, ស្តោក, ស្បក, ស្មើក, ខ្ទង់, ក្បេច, ក្ងក់, ក្រោនីវ, គ្រេង, ស្រេវ, ថ្វេយាង, ទ្រដាង ជាដើម ។

៤- វណ្ណគុណវិសេសនៈ ពាក្យដែលសម្រាប់ធ្វើពាក្យ

www.elibraryofcambodia.org

គុណដែលជាវណ្ណ គឺពាក្យដែលស្ដែងប្រាប់នូវវណ្ណរបស់ពាក្យនាម ឬសព្វនាម ទៀតទុកផ្សេងពីធម្មតាទៅ ហៅថា វណ្ណគុណវិសេសនៈ ។ ពាក្យគុណដែលស្ដែងប្រាប់នូវវណ្ណរបស់ពាក្យនាម ឬសព្វនាមនោះ បានដល់ពាក្យទាំងអម្បាលនេះគឺ ខ្មៅ, ស, ក្រហម, ខៀវ, លឿង, ភ្លឺ, ពពាល, ថ្លា, ល្អក់ ជាដើម ។ ពាក្យវណ្ណគុណវិសេសនៈ បានដល់ពាក្យថា : យ៉ក, កក្រិត, គគ្រិះ, គិរិះ, គិកង, គឃ្លាក់, ក្រេះ, ងឺង, ងិល, ង្វ, ង្វង, ពព្វាក់, ព្រិល, ព្រឹត, បប៉ុច, បប៉ិះ, រលីក, រលីស, ររលីប, ររលាង, ស្រអិប, ស្រអែម, ស្រិល, កំប្លង់, ក្បុស, គ្រសុស, គ្រសួល, គ្រសោល, ចិញ្ចាច, ល្វល្វ, ថ្លាវ, ព្រាត, ស្គុស, ស្វាច, ស្វែត, ងិល, ឆៅ, ឆិន, ខ្ញុរខ្ញារ, ខ្ពៅ, តែក, ខែង, បប្រិញ, ប្រចិញ, ខ្វក, ប្រតែក, ព្រូក, ខ្មែរ, ភ្លឺះ, ឆោល, ខ្ចោល, សខ្ចៅ, ស្រងែ, ស្រងាក់, អន្ទង, ឈឹង, ឈ្ងប់, ប្រព្រេញ, សុង, ក្រឡង់, គ្រប៉ះ, គ្រចង់, ក្រលុង, ខែង, សខ្ទោ, ស្រោង, ចំពែង, យង់, ព្រៀង, ត្នង់, ហ្វង, វង់, ឈ្មោង, គ្រយង់, គឃ្លួ, ខ្វល់, វៀប, ពពើម, សំព្រុះ, ប៉ុនៗ

៨—សព្ទគុណវិសេសនៈ ពាក្យដែលសម្រាប់ធ្វើពាក្យគុណ

www.elibraryofcambodia.org

ដែលជាសណ្ឋ គឺពាក្យគុណដែលសម្ដែងប្រាប់នូវសណ្ឋរបស់ពាក្យនាម ឬសព្វនាម ឲ្យប្លែកផ្សេងពីធម្មតាទៅ ហៅថា សណ្ឋគុណវិសេសនៈ ។ ពាក្យគុណដែលសម្ដែងប្រាប់នូវសណ្ឋរបស់ពាក្យនាម ឬសព្វនាមនោះ បានដល់ពាក្យនេះគឺ ពិការ ។ ពាក្យសណ្ឋគុណវិសេសនៈ បានដល់ពាក្យថា: ត្រយែត, ពិចិត្រ, កិលឹក, លន់, លន្លាច, ស្រឡើប ។

៦–គន្ធគុណវិសេសនៈ: ពាក្យដែលសម្រាប់ធ្វើពាក្យគុណ ដែលជាគន្ធ គឺពាក្យគុណដែលសម្ដែងប្រាប់គន្ធរបស់ពាក្យនាម ឬសព្វនាម ឲ្យប្លែកផ្សេងពីធម្មតាទៅ ហៅថា គន្ធគុណវិសេសនៈ ។ ពាក្យគុណដែលសម្ដែងប្រាប់នូវគន្ធរបស់ពាក្យនាម ឬសព្វនាមនោះ បានដល់[illegible]នេះ គឺ ក្រអូប, ស្អុយ, ឆ្អេះ, ឆ្អាប, ប្រហើរ ជាដើម ។ ពាក្យគន្ធគុណវិសេសនៈ បានដល់ពាក្យថា: ឈ្ងុយ, រ៉ង់, ហួង; ឆ្អាំង, ងឹត, ងំត, ហ៊ុំ, ត្រេក, ធ្ងិត, ឡប់ ជាដើម ។

៧– រសគុណវិសេសនៈ: ពាក្យដែលសម្រាប់ធ្វើពាក្យគុណដែលជារស គឺពាក្យគុណដែលសម្ដែងប្រាប់នូវរសរបស់ពាក្យ

www.elibraryofcambodia.org

នាម ឬសព្វនាម ឲ្យប្លែកផ្សេងពីធម្មតាទៅ ហៅថា រសគុណវិសេសនៈ ។ ពាក្យគុណដែលស្តែងប្រាប់នូវរសរបស់ពាក្យនាម ឬសព្វនាមនោះ បានដល់ពាក្យតាំងអម្បាលនេះគឺ ជូរ, ផ្អែម, សាប, ឆ្ងាញ់ ជាដើម ។ ពាក្យរសគុណវិសេសនៈ បានដល់ពាក្យថាៈ ជ្រេញ, ល្ហែម, ហួញ, ហេញ, ស្លេញ, ល្វាច់, ល្ហក, ម្ចាន់, ឈឹង, ពិសា ជាដើម ។

៨– សម្ពស្សគុណវិសេសៈ ពាក្យដែលសម្រាប់ធ្វើពាក្យគុណដែលជាសម្ពស្សឬផស្សៈ គឺពាក្យគុណដែលស្តែងប្រាប់នូវសម្ពស្ស ឬផស្សរបស់ពាក្យនាមឬ សព្វនាម ឲ្យប្លែកផ្សេងពីធម្មតាទៅ ហៅថា សម្ពស្សគុណវិសេសនៈ ។ ពាក្យតាំងអម្បាលនេះគឺ ក្តៅ, ត្រជាក់, រងា, ផ្សា, ក្រហាយ, តឹង, ធូរ, ណែន, ស្ងួត, ធ្ងន់, ស្រាល, ស្រស់, ជ្រាយ, ខាប់, រាវ, ស្វិត, ស្អិត, ស្រពោន, ក្រៀម, រលីង, គគ្រើម, គគ្រាត ជាដើម ជាពាក្យគុណស្តែងប្រាប់នូវសម្ពស្សរបស់ពាក្យនាម សព្វនាម ។ ពាក្យសម្ពស្សគុណវិសេសនៈ បានដល់ពាក្យថា "បំព្រឹង, បំព្រួញ, ក្រពង់, ប៉ុស់, ញញឹម, ស្រើង, រំហួន,

www.elibraryofcambodia.org

ថែស, គគុក, ស្រេង, ស្រេច, ល្អក, ល្អឹម, ល្ហឹម, ក្រៃឈ់, ខ្សុក, ស្បុក, ស្ទុក, ង៉ាង, ចេស, ត្អឹះ, ស្ទឹក, កណ្ដុក, ស្រមុក, ស្មើក, កំបុត, ធញ, ណាល, រេង, យង់, ក្រិល, ពង្សៀថ, ល្អៀក, អំពើក, កែក, រេតត, កញ្ចាវ, កញ្ចៀវ, ក្រញង់, ក្ដង់, ប្រឹះ, បរិប្រែ, គគាក់, អន្ទុល, កណ្ដុក ជាដើម ។

ពាក្យតទៅនេះ ជាពាក្យគុណផ្សំនឹងពាក្យគុណវិសេសនៈ ។

នេះជាពាក្យគុណផ្សំនឹងពាក្យភាគគុណវិសេសនៈ :

| | | |
|---|---|---|
| ល្អប៉ប្រែ | រឹងប្រឹស | ថ្មីថែស |
| ល្អទើត | រឹងស្កុក | ផ្ទុយគេម |
| ល្អខ្ទង់ | រឹងប៉ុង | ខ្លាចសកម្ញ៉ុក |
| ខ្ចីល្ងក់ | ទន់ក្ងិច | ខ្លោចប្រុះ |
| ខ្ចីល្ហក់ | ទន់ល្មើយ | ថ្កែកនិងឆាល |
| ចាស់កំព្រុក | ទន់ល្វៃ | ឆ្កួតលលា |
| ចាស់គំព្រួក | ទន់ល្វើក | ឆ្កួតបល់ពាយ |
| ចាស់កញ្ច្រាក | ទន់ល្វុត | ទន់ល្វិក |
| ចាស់គកគាក | ទន់ល្វន់ | ទន់ល្ហាក |

www.elibraryofcambodia.org

នេះជាពាក្យគុណផ្សំនឹងពាក្យភាគគុណវិសេសនៈ

| | | |
|---|---|---|
| រឹងក្រឹស | ស្រួយស្រើង | ស្រួយខ្ទោក |
| រឹងក្រពាំង | ស្រួយស្រឹប | ស្រួយស្រោក |
| រឹងតាំង | ស្រួយស្រែស | |
| រឹងថែស | ថ្នុសន្ទាន | |

នេះជាពាក្យគុណផ្សំនឹងពាក្យរសគុណវិសេសនៈ

| | | | |
|---|---|---|---|
| ជូរជ្រេញ | ជូរហេញ | ផ្អែមល្ហក | [illegible] |
| ជូរឈ្លួម | ជូរស្ងួញ | ផ្អែមម្ល៉ាន់ | ល្វីញពិសា |
| ជូរហួញ | ផ្អែមល្ហាន់ | សាបឈឹង | |

នេះជាពាក្យគុណផ្សំនឹងពាក្យគន្ធគុណវិសេសនៈ

| | | | |
|---|---|---|---|
| ក្រអូបឈ្ងុយ | ស្អុយឆ្អើន | ស្អុយរហ៊ុ | ប្រហើរឆ្ងុត |
| ក្រអូបរ៉ី | ស្អុយធឹក | ស្អុយគគ្រុក | ឆ្អាបខ្ញប់ |
| ក្រអូបហួន | ស្អុយថែក | ឆ្អាបឆ្អើន | |

នេះជាពាក្យគុណផ្សំនឹងពាក្យសទ្ទគុណវិសេសនៈ

| | | |
|---|---|---|
| ពីរោះត្រចៀក | ពីរោះក្រលឹក | ពីរោះលង្វោច |
| ពីរោះពិចិត្រ | ពីរោះលន់ | ពីរោះស្រណោច |

www.elibraryofcambodia.org

នេះជាពាក្យគុណផ្សំនឹងពាក្យវណ្ណគុណវិសេសខ្លះ ៖

| | | | |
|---|---|---|---|
| ខ្មៅឃ្មឹក | ខ្មៅនិល | ខ្មៅរលើក | សក្បុស |
| ខ្មៅកក្រិត | ខ្មៅធូ | ខ្មៅរលើស | សក្រសុស |
| ខ្មៅគគ្រិះ | ខ្មៅធូង | ខ្មៅរលើប | សក្រសួល |
| ខ្មៅគរិះ | ខ្មៅភព្វក់ | ខ្មៅរលោង | សក្រសោល |
| ខ្មៅគំកាំង | ខ្មៅព្រិល | ខ្មៅស្រអិច | សចិញ្ចាច |
| ខ្មៅគឃ្លាក់ | ខ្មៅព្រឹក | ខ្មៅស្រអែម | សព្រលូ |
| ខ្មៅក្វេះ | ខ្មៅវិប៉ុក | ខ្មៅស្រិល | សផ្ទរ |
| ខ្មៅនឹន | ខ្មៅប៊ីប៉េះ | សកំបុង | សព្រោក |
| សស្កុស | ក្រហមប្រៃកត | ងងឹតសុង | ថ្លាយង់ |
| សស្វាច | ក្រហមព្រាក | ភ្លឺក្រឡង់ | ថ្លាធ្វង់ |
| សស្វែក | ក្រហមក្លែត | ភ្លឺចិញ្ចាច | ថ្លាហ្វង់ |
| ក្រហមងិល | ក្រហមឆ្អឹះ | ភ្លឺក្រពះ | ថ្លាវង់ |
| ក្រហមឆៅ | ក្រហមឆ្អាល | ភ្លឺក្រពង់ | ថ្លាឈ្វេង |
| ក្រហមឆ្អាំង | ក្រហមទ្រាល | ភ្លឺក្រលុង | ថ្លាក្រយ៉ង់ |
| ក្រហមព្រាល | ក្រហមសន្ទៅ | ភ្លឺវែង | ល្អក់គឃ្លូ |

www.elibraryofcambodia.org

នេះជាពាក្យគុណផ្សំនឹងពាក្យវណ្ណគុណវិសេសខ: :

| | | | |
|---|---|---|---|
| ក្រហមឆ្អៅ | ខៀវស្រងាត់ | ក្តឹព្រោត | ល្អក់ខ្វល់ |
| ក្រហមតែត | ខៀវស្រងែ | ក្តឹបេខ្លា | ល្អក់វ៉ល់ |
| ក្រហមខែង | ខៀវឥន្ធូន | ក្តឹស្រោង | ងងឹតតេម |
| ក្រហមប៉ប្រិញ | ងងឹតឈឹង | ក្តឹចំត្នង | ងងឹតស្ងុង |
| ក្រហមប្រឆិញ | ងងឹតឈ្លប់ | ក្តឹគ្រេបើង | សសំព្រុះ |
| ពពាលខ្វក | ក្រហមប្រាប្រេញ | ក្រហមព្រឿង | ក្រហមចុង |

នេះជាពាក្យគុណផ្សំនឹងពាក្យសណ្ឋានគុណវិសេសខ: :

| | | | |
|---|---|---|---|
| ខ្ពស់ត្រដាប | ខ្ពស់លលៃ | ខ្ពស់ស្រឡៅ | ទាបកន្ទុញ |
| ខ្ពស់ត្រដឹង | ខ្ពស់ស្រាវ | ខ្ពស់ស្រឡោង | ទាបកន្ទុល |
| ខ្ពស់ត្រដឹម | ខ្ពស់ស្រយាវ | ខ្ពស់ត្រៃឈ | ទាបកន្ទ្រែត |
| ខ្ពស់ត្រដែត | ខ្ពស់ស្រៀវ | ទាបកន្ទាញ | ទាបក្រញិញ |
| ខ្ពស់ត្រដោម | ខ្ពស់ស្រលូន | ទាបកន្ទិល | ទាបទ្រនាប់ |
| ខ្ពស់ស្រោង | ខ្ពស់ស្រឡេត | ទាបកន្ទឹប | ទាបទ្រមែ |
| ទាបស្រឡឹប | មូលក្លំ | ខូលាយល្វឹង | វៀចកោច |
| ទាបស្រគឹប | មូលត្រឡំ | ចង្អៀតប៉ែស | វៀចក្ងក់ |

www.elibraryofcambodia.org

ខេះជាពាក្យគុណផ្សំនឹងពាក្យបណ្ដាខគុណវិសេសខ: :

| | | | |
|---|---|---|---|
| ក្រន់ចួន | ម្សូលចុំ | យារស្គាក់ | វៀចស្រវេរ |
| ក្រន់ច្ប | កក់កន្ទួល | យារស្គក | ពោតគ្រេន |
| ក្រន់ច្បួញ | កក់កំប៉ុក | យាររស្គាក | ពោតស្រេវ |
| ក្រន់ក្ទឹន | កក់កំភែល | ឃារស្យក | ខ្ពស់ជ្រយោន |
| ក្រន់ស្ទុន | ជ្រៅល្ហួន | ង៉ស្ទុក | ខ្ពស់ប្រដោន |
| ក្រន់ស្ទេវ | ជ្រៅស្រឡូន | ងខ្ញូន់ | |

ខេះជា ពាក្យគុណផ្សំនឹងសម្ផស្សគុណវិសេសខ: :

| | | | |
|---|---|---|---|
| ស្រស់បំប្រឹម | ក្តៅងំ | តឹងបើស | លើងយង់ |
| ស្រស់ប្រិមប្រិយ | ក្តៅថែស | តឹងត្អឹះ | លើនត្រិល |
| ស្រស់បំព្រង | ត្រជាក់ត្រឈៃ | តឹងស្ទឹត | លើនស្រេប |
| ស្រស់ត្រចង | ត្រជាក់ល្ហឹម | ជូចកណ្ដុក | លើនស្រិល |
| ស្រស់ញញឹម | ត្រជាក់ល្អូក | ជូចកណ្តុក | ជ្រាយតាដ្សៀច |
| ស្រស់បស់ | ត្រជាក់ស្រេន | ជូចច្រយុក | ជ្រាយល្អៀច |
| ស្រស់បំប្រែ | ត្រជាក់ស្រេប | ស្រោលស្ទើក | រាបរំពើក |
| ស្អុតថែស | ផ្ទូរខ្សត | ស្រោលកំប៉ុក | រាប់អន្ទិល |

www.elibraryofcambodia.org

នេះជាពាក្យគុណនាមច្រើនសព្ទស្ទួនគុណវិសេសនៈ :

| | | | |
|---|---|---|---|
| ស្ងួតស្រឹង | ជូរស្ងៀត | រលីងឆិញ | ខាប់អន្ទាយ |
| ស្ងួតហែង | ជូរស្ងួត | រលីងណិល | ខាប់អន្ទិល |
| ក្តៅគគុក | តឹងតាំង | រលីងរេង | ស្អិតគាត់ |
| ស្អិតគេត | ស្អិតល្អួត | ស្អិតល្អូន | ស្អិតក្រញៅ |
| ស្អិតគែត | ស្អិតល្អួត | ស្អិតក្រញង់ | ស្អិតក្រជិវ |
| ណែនគគ្តន់ | ណែនកណ្តុក | ស្អិតក្រទាំង | ក្រៀមស្អោះ |
| ណែនច្រើះ | | ស្អិតរញាម | ក្រៀមក្រញង់ |

នេះជាពាក្យគុណនាមច្រើនពាក្យបរិមាណគុណវិសេសនៈ :

| | | | |
|---|---|---|---|
| ធំកំភាង | តូចច្រមិច | ឆាត់ស្រលះ | ខ្ចីក្រញឹង |
| ធំក្រអួន | តូចច្រពុច | ឆាត់ស្លួល | ខ្ចីក្រញុញ |
| ធំក្រអួល | តូចច្រឡឹង | ស្គមកំព្រៅ | ខ្ចីក្រឡុញ |
| ធំកំប៉ាង | តូចកំពុច | ស្គមកំព្រយ | ថ្លោសទ្រមោក |
| ធំទ្រមឹង | តូចចំរើរ | ស្គមកំព្រឹង | ថ្លោសទ្រលុក |
| ធំស្តឹង | ជាត់ក្រអាញ | ស្គមប្រខក់ | ថ្លោសស្រអ៊ិក |
| ធំស្កឹង | ជាត់ក្រអុប | ស្គមប្រជក់ | ថ្លោសស្រតុក |

www.elibraryofcambodia.org

នេះជាពាក្យគុណផ្សំនឹងពាក្យបរិមាណគុណវិសេសន:

| | | | |
|---|---|---|---|
| ធំស្តើន | ធាត់ក្រអុល | ស្គមប្រខឹង | ល្អិតផង់ |
| ធំសួល | ធាត់ក្រអាញ | ស្គមរំងឹត | ល្អិតស្មេ |
| ធំធួល | ធាត់កំកើ | ស្គមរំបឹង | ល្អិតស្មេញ |
| តូចក្រញឹប | ធាត់កន្ទាញ | ស្គមស់កម្ញឹក | ល្អិតស្មេះ |
| តូចក្រញឹបៗ | ធាត់កន្ទុល | វែងរលាម | ស្រួចឈ្លេម |
| តូចញី | ធាត់ត្រលុច | វែងលលៃ | ស្រួចលែម |
| តូចញឹប | ធាត់ទ្រលុក | ខ្ទីកន្ទុប | ក្រាស់ឃ្មឹក |
| តូចប្រម៉ក់ | ធាត់ធួល | ខ្ទីកំប៉ុត | ក្រាស់ស្មឹក |
| ឆ្ងាយល្ហិត | ឆ្ងាយរហង់ | ស្ដើងយ៉ុល | ស្ដើងហៀ |
| ឆ្ងាយរកេត | | | |

សូមឲ្យរមៀនការរមៀនិយោ ពិនិត្យមើលឲ្យមែនទែន ព្រោះមានពាក្យគុណវិសេសន:ខ្លះ អាចទៅជាពាក្យកិរិយាវិសេសន:ផងក៏បាន ដូចជាពាក្យថា: "ខែង" នេះ អាចនឹងទៅជាកិរិយាវិសេសន:ថា "ស្ទើរខែង" បាន ។ មានពាក្យមួយបែបទៀត ហៅថា "បរក់ត្រាន" នោះស្មើតែនឹងដូចពាក្យគុណវិសេសន:

www.elibraryofcambodia.org

ដែរ ព្រោះជាពាក្យសម្រាប់ថែមខាងចុងពាក្យគុណក៏មាន ពាក្យនាមក៏មាន ។ ការដែលនឹងសង្កេតមិនឲ្យច្រឡំនោះគឺ ពាក្យគុណវិសេសនៈ ជាពាក្យសម្រាប់ដាក់ភ្ជាប់តពីខាងចុងពាក្យគុណ ហើយជាពាក្យផ្ទុកផ្សេងពីពាក្យគុណ ។ ឯពាក្យបរិវារនោះ សម្រាប់ដាក់ភ្ជាប់ពីខាងចុងពាក្យគុណដែរ តែជាពាក្យមានអក្សរប្តូរដំណើរដូចគ្នានឹងពាក្យគុណ ដូចជា "តូចតាច, ស្អាតស្អំ, ស្ងិតស្ងាញ, ក្រៀមក្រោះ, តឹងតែង" នេះ; ពាក្យថា: "តូច, ស្អាត, ស្ងិត, ក្រៀម, តឹង" ជាពាក្យគុណ; ឯពាក្យថា "តាច, ស្អំ, ស្ងាញ, ក្រោះ, តែង" នេះជាពាក្យបរិវារ ព្រោះមានអក្សរប្តូរដំណើរពាក្យដូចគ្នានឹងពាក្យគុណនោះ ។ មួយវិញទៀតឲ្យរៀនាសង្កេតថា: មានពាក្យគុណខ្លះ អាចប្រកបនឹងពាក្យគុណវិសេសនៈបានច្រើនយ៉ាង ពាក្យខ្លះប្រកបបានតែមួយយ៉ាង ឬពីរយ៉ាង ហើយនឹងពាក្យគុណវិសេសនៈខ្លះ អាចប្រកបបាននឹងពាក្យគុណច្រើនយ៉ាង ខ្លះក៏បានតិចយ៉ាងដូចគ្នា ។ ត្រង់នេះត្រូវតែរៀនាសង្កេតចាំយកខ្លួនឯងទើបបាន បើមិនសង្កេតចាំទេ មុខជានឹងប្រកបខុសចំនងរបស់ភាសា ដូចយ៉ាងពាក្យគុណវិសេសនៈ ថា

www.elibraryofcambodia.org

"ព្រឹក" នេះ ប្រកបតែនឹងពាក្យគុណថា "ខ្មៅ" ជា "ខ្មៅព្រឹក" តែបើយើងយកទៅប្រកបនឹងពាក្យគុណថា "ស" ជា "សព្រឹក" ដូច្នេះវិញ នោះយ៉ាប់! គេនឹងសើចដួលតែម្តង!

ដូច្នេះ ចូរសង្កេតមើលក្នុងឧទាហរណ៍ដែលបានរៀនមក. អម្បាញ់នេះឯងឲ្យមែនទែន ។

## វគ្គសភាបធទី ៤

១- យ៉ាងម៉េចហៅថា ពាក្យវិសេសនៈ ? បានដល់អ្វី ? ចូរឆ្លើយប្រាប់មក!

២- ពាក្យវិសេសនៈ ប្រែថាម៉េច ? ពាក្យណាខ្លះដែលត្រូវប្រើពាក្យវិសេសនៈប្រកបបាន ? ចូររកមើល!

៣- ពាក្យវិសេសនៈ ដែលប្រកបនឹងនាម ឬសព្វនាម យើងហៅថាអ្វី ?

៤- ពាក្យវិសេសនៈ ដែលសម្រាប់ប្រកបនឹងពាក្យកិរិយា ហៅថាម៉េច? ហើយពាក្យដែលសម្រាប់ប្រកបនឹងពាក្យវិសេសនៈ របស់កិរិយានោះ ហៅថាអ្វី?

៥-ពាក្យវិសេសនៈ កន្តែកម្តដៈ មានប៉ុន្មានយ៉ាង? អ្វីខ្លះ?

www.elibraryofcambodia.org

៦. ពាក្យថា "គុណ" ប្រែយ៉ាងម៉េច ? និងពាក្យថា "វិសេសនៈ" ប្រែយ៉ាងណា? បើភ្ជាប់ថា "គុណវិសេសនៈ" ដូច្នេះវិញ តើប្រែយ៉ាងណាទៅ? អធិប្បាយ!

៧.- ពាក្យគុណ និង ពាក្យគុណវិសេសនៈ ណាប្រកបនឹងពាក្យដទៃបានច្រើនជាងណា? អ្វីខ្លះ? ចូររៀបរាប់ឲ្យអស់!

៨.- ពាក្យគុណនិងពាក្យគុណវិសេសនៈ ដូចគ្នាឬផ្សេងគ្នា? ពាក្យគុណគឺពាក្យយ៉ាងម៉េច ? ពាក្យថាកិរិយាគឺពាក្យយ៉ាងណា?

៩.- ពាក្យថា "ឡែក" និង "ណាស់" ២ម៉ាត់នេះរាប់ថាជាពាក្យគុណវិសេសនៈបានឬទេ? ព្រោះហេតុអ្វី?

១០.- ពាក្យគុណវិសេសនៈ ទាំងអស់ គាប់នឹងបន្ថែមពាក្យគុណទាំងអម្បាលម៉ានឲ្យមានជាន់មានថ្នាក់ តាមរបៀបលក្ខណ-គុណសព្ទបានទេ? ព្រោះហេតុអ្វី? អធិប្បាយ!

១១– ពាក្យគុណសម្រាប់ដាក់ភ្ជាប់ពីខាងណានាមនិងសព្វនាម? ពាក្យគុណវិសេសនៈ សម្រាប់ដាក់ភ្ជាប់ខាងណាពាក្យអ្វី ?

១២– ពាក្យគុណវិសេសនៈ បើយើងដាក់រៀងភ្ជាប់នឹងពាក្យនាម ឬ សព្វនាមផ្ទាល់តែម្ដងបានឬទេ ? ព្រោះអីម៉េច ?

www.elibraryofcambodia.org

១៣– ពាក្យគុណមានច្រើនរាប់មិនអស់, ប៉ុន្តែបើនិយាយតែពីដំណើរដែលស្តែងប្រាប់លក្ខណៈ របស់ពាក្យនាមនិងសព្វនាមនោះ តើមានប៉ុន្មានប្រការ? អ្វីខ្លះ? ចូររាប់ឲ្យសព្វគ្រប់!

១៤– ពាក្យគុណវិសេសន៍ មានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់!

១៥– ពាក្យភាគគុណវិសេសន៍នោះ គឺពាក្យយ៉ាងម៉េច?

១៦– ពាក្យគុណដែលស្តែងប្រាប់នូវពណ៌របស់ពាក្យនាម ឬសព្វនាមនោះ បានដល់ពាក្យថាម៉េចខ្លះ? ចូររាប់!

១៧– ពាក្យភាគគុណវិសេសន៍នោះ គឺពាក្យយ៉ាងម៉េចខ្លះ? ចូររាប់!

១៨– ពាក្យរសគុណវិសេសន៍នោះ គឺពាក្យដូចម្តេច?

១៩ ពាក្យគុណដែលស្តែងប្រាប់នូវរសរបស់ពាក្យនាម ឬសព្វនាមនោះ គឺពាក្យយ៉ាងណាខ្លះ ? ចូររាប់ !

២០– ពាក្យរសគុណវិសេសន៍នោះ គឺពាក្យយ៉ាងម៉េចខ្លះ? ចូររាប់!

២១– ពាក្យគន្ធគុណវិសេសន៍ គឺពាក្យដូចម្តេច?

២២–ពាក្យគុណដែលស្តែងប្រាប់នូវក្លិនរបស់ពាក្យនាម ឬសព្វ

www.elibraryofcambodia.org

នាមនោះ គឺពាក្យអ្វីខ្លះ? ចូរកត់!

៦៣– ពាក្យគន្ធគុណវិសេសនៈនោះ បានដល់ពាក្យយ៉ាងណាខ្លះ? ចូរកត់!

៦៤– ពាក្យសទ្ទគុណវិសេសនៈ បានដល់ពាក្យយ៉ាងណា?

៦៥– ពាក្យគុណដែលសម្ដែងប្រាប់នូវសូរសម្លេងរបស់ពាក្យនាម ឬ សព្វនាមនោះ បានដល់ពាក្យជាម៉េចខ្លះ? ចូរកត់!

៦៦– ពាក្យសទ្ទគុណវិសេសនៈ បានដល់ពាក្យដូចម្ដេចខ្លះ? ចូរកត់!

៦៧– ពាក្យយ៉ាងម៉េចដែលហៅថាវណ្ណគុណវិសេសនៈ? ចូរអធិប្បាយ!

៦៨– ពាក្យគុណដែលសម្ដែងប្រាប់នូវពណ៌សម្បុររបស់ពាក្យនាមឬសព្វនាមនោះ បានដល់ពាក្យយ៉ាងណាខ្លះ?

៦៩– ពាក្យវណ្ណគុណវិសេសនៈ គឺពាក្យយ៉ាងម៉េចខ្លះ? ចូរកត់!

៧០– សណ្ឋានគុណវិសេសនៈ គឺពាក្យយ៉ាងម៉េច?

៧១· ពាក្យគុណដែលសម្ដែងប្រាប់នូវសណ្ឋានទ្រង់ទ្រាយរបស់ពាក្យនាមឬសព្វនាមនោះ គឺពាក្យយ៉ាងម៉េចខ្លះ? ចូរកត់!

www.elibraryofcambodia.org

៣២- ពាក្យសណ្ឋានគុណវិសេសនៈ បានដល់ពាក្យយ៉ាងណាខ្លះ? ចូរទាញឱ្យអស់!

៣៣ - ពាក្យសម្ពស្សគុណវិសេសនៈ គឺពាក្យយ៉ាងណា?

៣៤-ពាក្យគុណដែលស្តែងប្រាប់នូវសម្ពស្ស ឬផ្សព្វរបស់ពាក្យនាម ឬសព្វនាមនោះ បានដល់ពាក្យបែបណាខ្លះ? ចូររក!

៣៥ - ពាក្យយ៉ាងណាខ្លះ ដែលហៅថា សម្ពស្សគុណវិសេសនៈ? ចូរទាញឱ្យអស់!

៣៦. បរិមាណគុណវិសេសនៈ គឺពាក្យម៉េច?

៣៧ - ពាក្យគុណដែលស្តែងប្រាប់នូវភាគប្រមាណរបស់ពាក្យនាម ឬសព្វនាមនោះ បានដល់ពាក្យជាម៉េចខ្លះ?

៣៨- បរិមាណគុណវិសេសនៈ បានដល់ពាក្យយ៉ាងណាខ្លះ? ចូរទាញឱ្យអស់!

៣៩ - ពាក្យ ចាស់, ទន់, ខ្មៅ, ស, ធំ, តូច ប្រកបនឹងពាក្យគុណវិសេសនៈ ជាម៉េចបានខ្លះ? ចូរប្រកបឱ្យគ្រប់ទៅមើល!

៤០ - ពាក្យ ព្អឹះ, ស្រេង, ស្រេច ប្រកបនឹងពាក្យគុណ ជាម៉េចបានខ្លះ? ប្រកបទៅមើល!

www.elibraryofcambodia.org

៤១ - ពាក្យគុណវិសេសនៈ អាចនៅជាពាក្យកិរិយាវិសេសនៈវិញបានឬទេ? បើដូច្នោះ តើយើងត្រូវសង្កេតដូចម្ដេច ទើបនឹងអាចចាំបាន? ចូរស្រាយ!

៤២ - ពាក្យគុណវិសេសនៈ ដែលប្រកបទៅនឹងពាក្យគុណហើយនោះ មិនច្រឡំនឹងពាក្យសមាសគុណទេឬ? តើយ៉ាងម៉េចទើបនឹងងាយសង្កេតបាន?

៤៣ - មានពាក្យមួយបែបទៀត ហៅថា បរិមាណ សម្រាប់ដាក់ភ្ជាប់ខាងចុងពាក្យនាមក៏មាន ខាងចុងពាក្យគុណក៏មាន ដូច្នោះ មិនច្រឡំនឹងពាក្យគុណវិសេសនៈទៅហើយឬ? ចូរពន្យល់ឲ្យអស់បែប!

៤៤- ស្អិតស្អាញ, ក្រៀមក្រោះ, ក្ដុកលលះ, ក្រហះៈនះ, នេះ ណាជាពាក្យអ្វី? ចូរញែកឲ្យអស់ទៅមើល!

៤៥ - ពាក្យគុណមួយៗ អាចប្រកបបានតែនឹងពាក្យគុណវិសេសនៈមួយៗទេឬ? ឬបានច្រើនពាក្យដែរ? មានកំណត់ប៉ុន្មាន?

៤៦- ពាក្យគុណណាដែលប្រកបទៅនឹងពាក្យគុណវិសេសនៈបានច្រើនជាងគេ? ចូរជ្រើសតាមបែបមុខមើល!

www.elibraryofcambodia.org

៤៧- ពាក្យគុណវិសេសនៈ ប្រកបនឹងពាក្យគុណបានខ្លះទៅ ទាំងអស់ថ្លៗ មានកំណត់តាមពួកវាៗ បើយើងប្រកបថាៈ "ក្រហមព្រឿល, ខ្មៅស្គុស, សស្រិល, សស្រេង ដូច្នេះបានឬទេ? ព្រោះហេតុអ្វី? អធិប្បាយ!

## ២-សព្វនាម (Le pronom)

ពាក្យដែលសម្រាប់ប្រើជួស ឬប្រើជាជំនួយពាក្យនាមដែលបានពោលបញ្ចេញឈ្មោះរួចម្ដងហើយ ឬដែលកំពុងនិយាយចំពោះមុខ ដើម្បីនឹងមិនឲ្យធួនពាក្យដញ្ញាន់ស្ដាញ ញឹកៗ ដដែលៗ ឬដើម្បីឲ្យលះស្រឡះសេចក្ដីមិនឲ្យច្រឡំក៏ក្ដី ហៅថា សព្វនាម (le pronom)។ ពាក្យនេះបើប្រសិនណាជាកាត់ឲ្យដាច់បញ្ចេញពីគ្នា ជា "សព្វ" មួយម៉ាត់, "នាម" មួយម៉ាត់នោះ; "សព្វ" ប្រែថា "ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់យ៉ាង,..."; "នាម" ប្រែថា "ឈ្មោះ, សំដៅដល់នូវឈ្មោះជាគ្រឿងកំណត់សំគាល់ឲ្យហៅបាន"; បើរួមចូលគ្នាជាពាក្យ១ ប្រែថា "ឈ្មោះទាំងពួង,..." នេះគឺសំដៅសេចក្ដីថា "ពាក្យដែលជាឈ្មោះបានគ្រប់យ៉ាង" បានដល់ពាក្យជួសឈ្មោះ ។ គុណប្រយោជន៍របស់

www.elibraryofcambodia.org

ពាក្យសព្វនាមនេះ គឺគេប្រើជួសពាក្យនាមផ្សេងៗ ឬប្រើជួស ដំណើររឿង ដំណើរសេចក្ដីផ្សេងៗ ដែលចូលចិត្តហើយស្រេច ទៅហើយ ឬដែលពោលរួចពីខាងដើម។ហើយ ដើម្បីកុំឲ្យត្រួតគ្នាច្រំៗ ដដែលៗ ជាទីនាំឲ្យអផ្សុកដល់គេទៀត នាំឲ្យទ្រាន់ដល់ អ្នកស្ដាប់ដូចតួយ៉ាងថា "ភិក្ខុសួនជួបនឹងនាយមី, ភិក្ខុសួនក៏និយាយ ទៅនឹងនាយមីថា "នាយមីទៅណាហ្នឹង? មិនដែលមកលេងនឹង ភិក្ខុសួនសោះហ្ន៎! ភិក្ខុសួននឹកនាយមីនឹងសោក"; ដូច្នេះ ក្នុង ប្រយោគនេះមានពាក្យឈ្មោះដូចៗគ្នានៅជាច្រើន ស្ដាប់ទៅឲ្យ អផ្សុកក្រៃពេក នាំឲ្យអ្នកស្ដាប់ធុញទ្រាន់ នេះព្រោះតែមិនប្រើ ពាក្យសព្វនាម ។ បើប្រសិនណាជាប្រើពាក្យសព្វនាមជួសខ្លះថា: "ភិក្ខុសួនជួបនឹងនាយមី, លោកក៏សួរទៅគេថា 'អ្នកទៅណាហ្នឹង? មិនដែលមកលេងនឹងអាត្មាសោះហ្ន៎! អាត្មានឹកដល់អ្នកនឹងសោក"; ដូច្នេះ សេចក្ដីក្នុងប្រយោគនេះ ក៏ស្រឡះស្រទន់ស្រួលចូលពីរោះ ពីសាល្អឡើង នេះព្រោះតែប្រើពាក្យសព្វនាមជួសខ្លះនេះឯង! ។

ពាក្យសព្វនាមនេះ អាចប្រើជួសឈ្មោះរបស់យើង ក្នុង កាលដែលនិយាយដល់ខ្លួនរបស់យើងក៏បាន,ដូចពាក្យថា:"ខ្ញុំមិន

www.elibraryofcambodia.org

និយាយ" ដូច្នេះជាដើម បើប្រសិនណាជាយើងមិនប្រើជំនួសទេនោះ យើងឈ្មោះអី ក៏ត្រូវបញ្ចេញឈ្មោះហ្នឹងទៅ ដូចជាយើងឈ្មោះ “ម៉ុក” យើងក៏ត្រូវបញ្ចេញចំ “ម៉ុក” តែម្ដងថា “ម៉ុកមិននិយាយ” ដូច្នេះ សម្រាប់ប្រើជំនួសឈ្មោះរបស់អ្នកដែលយើងកំពុងតែនិយាយជាមួយផងក៏បាន, ដូចជាពាក្យថា: “ម៉េចក៏អ្នកមិននិយាយ” ដូច្នេះ បើប្រសិនណា ជាយើងមិនប្រើពាក្យសព្វនាមជំនួសឈ្មោះរបស់អ្នកដែលកំពុងនិយាយជាមួយនោះ គេឈ្មោះអី យើងក៏ត្រូវបញ្ចេញចំឈ្មោះរបស់គេនោះទៅ ដូចជាគេឈ្មោះ “មឿន” យើងក៏ត្រូវបញ្ចេញចំឈ្មោះ “មឿន” តែម្ដងថា: “ម៉េចក៏មឿនមិននិយាយ” ដូច្នេះ សម្រាប់ប្រើជំនួសឈ្មោះរបស់អ្នកដែលយើងនិយាយដល់ ឬរបស់ដែលយើងពោលដល់ក៏បាន, ដូចពាក្យថា: “គេនិយាយថាម៉េច?” ដូច្នេះ, បើប្រសិនណាជាយើងមិនប្រើពាក្យសព្វនាមជំនួសទេនោះ គេឈ្មោះអី យើងក៏ត្រូវបញ្ចេញចំឈ្មោះនោះទៅ និយាយអំពីរបស់អ្វី ក៏ត្រូវបញ្ចេញចំឈ្មោះរបស់នោះទៅ ចូរសង្កេតចាំឃ្លាំនិស័យ១ថា:

ពាក្យសម្រាប់ប្រើជំនួសឈ្មោះ ហៅថា សព្វនាម

www.elibraryofcambodia.org

សព្វនាម គឺពាក្យសម្រាប់ប្រើជួស នាម ។

ពាក្យសព្វនាមនោះ ចែកចេញដោយលក្ខណៈផ្សេងគ្នាជា ១១ យ៉ាងគឺ៖

១– បុរិសសព្វនាម Le pronom personnel ;

២– អបុរិសសព្វនាម Le pronom impersonnel ;

៣– អញ្ញោញសព្វនាម;

៤– វិភាគសព្វនាម Le pronom indéfini ;

៥– និយមសព្វនាម Le pronom démonstratif;

៦–អនិយមសព្វនាម Le pronom démonstatif indéfini;

៧– បុច្ឆាសព្វនាម Le pronom interogatif ;

៨– សាមិកសព្វនាម Le pronom possessif ;

៩– បរលេក្ខសព្វនាម Le pronom réflexe ;

១០– ឯម្ពូសសព្វនាម Le pronom emphatique;

១១– ប្រកទ្ទសព្វនាម Le pronom relatif ។

កម្រងសំណួរ ២

១– ពាក្យយ៉ាងណាដែលហៅថា សព្វនាម? ចូរអធិប្បាយ។

www.elibraryofcambodia.org

២– ពាក្យថា សព្វនាម បើកាត់ផ្ដាច់ចេញពីគ្នា តើប្រែថាម្ដេចបានខ្លះ? បើរួមចូលគ្នាជាពាក្យមួយម៉ាត់ តើប្រែថាម្ដេច? សំដៅសេចក្ដីយ៉ាងណា ? បានដល់ពាក្យអ្វី ?

៣– ប្រយោជន៍របស់ពាក្យសព្វនាមនោះ មានយ៉ាងណាខ្លះ ? ចូរអធិប្បាយ!

៤– ក្នុងភាសាមួយ ៗ បើប្រសិនណាជាកុំតាំធ្លាប់មានពាក្យសព្វនាមប្រើការមិនកើតឬ? ចូរអធិប្បាយតាមយោបល់ !

៥ ពាក្យសព្វនាមដែលថាប្រើជួសនោះ តើប្រើជួសអ្វីបានខ្លះ?

៦– ពាក្យសព្វនាមដែលថាប្រើជួសឈ្មោះយើង ក្នុងកាលដែលយើងនិយាយនោះ តើជួសយើងដូចម្ដេច? ដូចពាក្យថាយ៉ាងណា? បើមិនប្រើពាក្យសព្វនាមជួសនោះ តើទៅជាយ៉ាងម្ដេចទៅវិញ ? ទាញគួយ៉ាង!

៧– ពាក្យសព្វនាមដែលថា ប្រើជួសឈ្មោះអ្នកដែលយើងកំពុងនិយាយជាមួយនោះ តើជួសដូចម្ដេច ? ដូចពាក្យយ៉ាងណាខ្លះ បើមិនប្រើជួសតើការម្ដេចទៅ? ចូរបែបយ៉ាង !

៨– ត្រង់ដែលថា ប្រើជួសឈ្មោះអ្នកដែលយើងនិយាយដល់

www.elibraryofcambodia.org

មនុស្ស ឬ សត្វទាំងឡាយដែលយើងពោលដល់នោះ តើជួសយ៉ាងណា ? បើមិនប្រើជួសតើកើតរឿងទៅ? អធិប្បាយ !

៩– ពាក្យសព្វនាមបើចាត់ប្បែយ៉ាងខ្លីជាទីបំផុត តើត្រូវចាំដូចម្ដេច? ចូរចាំម.មើល!

១០– សព្វនាមនោះ ចែកចេញដោយលក្ខណៈមានប៉ុន្មានយ៉ាង? អ្វីខ្លះ ?

## ១– បុរិសសព្វនាម (le pronom personnel)

ពាក្យសព្វនាមដែលសម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗ ដោយចំពោះរូប ប៉ុន្តែមិនចេញចំណោះនោះទេ យ.ពាក្យ ដទៃផ្សេងពីនោះម.ជួសវិញ ។ ពាក្យដែលយ.ម.ជួសនេះឯង ហៅថា បុរិសសព្វនាម (le pronom personnel) ។ ពាក្យថា "បុរិសៈ" ប្រែថា "បុរស, ប្រុស"; "បុរិសសព្វនាម" ប្រែថា "ពាក្យសម្រាប់ប្រើជួសឈ្មោះបុរសទាំងពួង" ប៉ុន្តែក្នុងទីនេះ សំដៅសេចក្ដីថា "ពាក្យដែលសម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗ គ្រប់យ៉ាង ដែលមានដំណើរជាប់ទាក់ទងក្នុងការនិយាយស្ដីគ្នា" នេះឯងហៅថា បុរិសសព្វនាម មាន៣យ៉ាងគឺ

www.elibraryofcambodia.org

បឋមបុរស បុរសទី១ (Première personne) ១, ទុតិយបុរស បុរសទី២ ( Deuxième personne) ១, តតិយបុរស បុរសទី៣ ( Toisième personne ) ១ ។

១- សព្វនាមដែលសម្រាប់ប្រើជួសខ្លួនរបស់អ្នកនិយាយ គឺអ្នកនិយាយឈ្មោះអ៊ី វេលានិយាយមិនយកឈ្មោះនោះមកនិយាយ ត្រឡប់ជាយកពាក្យដទៃផ្សេងក្រៅពីឈ្មោះ របស់ខ្លួនមកនិយាយជួសវិញ ពាក្យសម្រាប់ប្រើនិយាយជួសឈ្មោះរបស់អ្នកនិយាយនោះឯងហៅថា បឋមបុរស បុរសទី១(la première personne) នេះបានដល់ពាក្យថា: ខ្ញុំព្រះអង្គ, យើងខ្ញុំព្រះអង្គ, ទូលព្រះបង្គំជាខ្ញុំទាំងឡាយ, យើងខ្ញុំព្រះបាទម្ចាស់, យើងខ្ញុំព្រះបាទ, យើងខ្ញុំព្រះករុណា, ទូលបង្គំ, ទូលបង្គំជាខ្ញុំ, ខ្ញុំព្រះករុណា, ខ្ញុំករុណា, ករុណា, ខ្ញុំព្រះបាទ, ខ្ញុំបាទ, ខ្ញុំឯង, អញខ្ញុំ, ខ្ញុំម្ចាស់, ខ្ញុំ, អាត្មាភាព, អាត្មាអញ, យើង, យើងខ្ញុំ, យើងខ្ញុំម្ចាស់ (តាមពាក្យខ្ពស់, កណ្ដាល, ទាប) ។ តែពាក្យកណ្ដាលគួរសមដែលប្រើចំពោះកិរិយាទូទៅ ក្នុងកម្ពុជវេយ្យាករណ៍នេះ ត្រូវប្រើឯកវចនៈថា "ខ្ញុំ"; ពហុវចនៈថា "យើង" ដូច្នេះ ។

www.elibraryofcambodia.org

២-សព្វនាមដែលសម្រាប់ប្រើជួសខ្លួនរបស់អ្នកស្ដាប់ គឺអ្នកស្ដាប់នោះឈ្មោះអ្វី វេលាដែលអ្នកនិយាយនោះ ត្រូវតែហៅ. អ្នកស្ដាប់នោះ ក៏មិនចេញចំឈ្មោះរបស់អ្នកស្ដាប់នោះ ត្រូវឲ្យប់ជាយ ពាក្យដទៃផ្សេងក្រៅពីឈ្មោះខ្លួនរបស់អ្នកស្ដាប់នោះ ម.ហៅរ.ជួសទៅវិញ ពាក្យសម្រាប់ប្រើហៅ.ជួសឈ្មោះខ្លួនរបស់អ្នកស្ដាប់នោះឯង ហៅថា ទុតិយបុរស បុរសទី២ ( la deuxiéme persoune )នេះ បានដល់ពាក្យថា: ព្រះអង្គ, ព្រះករុណាវិសេស, ព្រះករុណាថ្លៃវិសេស, លោក, អ្នក, នាង, ឯង, អា, មឹង, ហង (តាមពាក្យខ្ពស់, កណ្ដាល, ទាប) តែពាក្យកណ្ដាលគួរសមដែលប្រើបំផុតកិរិយាទូទៅ ក្នុងកម្ពុជវេយ្យាករណ៍នេះ នោះត្រូវប្រើឯកវចនៈថា “អ្នក”; ពហុវចនៈថា “រក់” ឬថា “អ្នកទាំងឡាយ” ដូច្នេះ ។

៣- សព្វនាម ដែលសម្រាប់ប្រើជួសឈ្មោះរបស់មនុស្ស សត្វ ឬអ្វីៗ គឺមនុស្ស សត្វ ឬអ្វីដែលយើងនិយាយដល់នោះឈ្មោះអ្វី វេលាដែលយើងនិយាយនោះ យើងត្រូវតែចេញចំឈ្មោះរបស់ មនុស្ស, សត្វ ឬអ្វីៗនោះ យើងមិនចេញចំឈ្មោះ

www.elibraryofcambodia.org

របស់ មនុស្ស, សត្វ ឬវត្ថុនោះ យើងត្រូវប្រើជាយ.ឈ្មោះដទៃផ្សេងក្រៅពីឈ្មោះរបស់ មនុស្ស, សត្វ ឬវត្ថុ ដែលយើងត្រូវការនិយាយដល់នោះ ម.ជួសឈ្មោះរបស់ មនុស្ស, សត្វ ឬវត្ថុនោះវិញ ។ ពាក្យដែលយើងយ-ម.ប្រើជួសឈ្មោះរបស់ មនុស្ស, សត្វ ឬវត្ថុ នោះឯង ហៅថា តតិយបុរស បុរសទី ៣ (la troisième personne) នេះបានដល់ពាក្យថា :"ព្រះអង្គ, ទ្រង់, លោក, នាង, គេ, គាត់, វា,..." (តាមពាក្យខ្ពស់, កណ្ដាល, ទាប) ។ តែពាក្យកណ្ដាលគួរសមដែលប្រើចំពោះកិរិយាទូទៅក្នុងកម្ពុជវេយ្យាករណ៍នេះ ត្រូវប្រើចំពោះបុរសឯកវចនៈថា "គេ", ពហុវចនៈថា "គេ ឬ គេទាំងឡាយ"; ចំពោះស្ត្រីឯកវចនៈថា : "នី ឬ នាង" ពហុវចនៈថា "នី ឬ នាងទាំងឡាយ"; ចំពោះសត្វតិរច្ឆានទាំងរបស់វត្ថុ ឯកវចនៈថា "វា", ពហុវចនៈថា "វា ឬ វាទាំងឡាយដូច្នេះ ។

ពាក្យរបស់បុរសសព្វនាម ទាំង ៣ យ៉ាង តាមដែលបានពោលមក.ហើយនោះ មានច្រើនជាអនេក មិនអាចនឹងកត់ទាំងបាន តែទុកជាពាក្យសម្រាប់ប្រើក្នុងកំណាព្យ ។ ឯពាក្យដែលសម្រាប់

www.elibraryofcambodia.org

ប្រើក្នុងវេយ្យាករណ៍នោះ គត់យកតែត្រឹម១០ពាក្យ ជាឯកវចនៈ៥ពាក្យ, ជាពហុវចនៈ៥ពាក្យ គឺ ៖

| | ឯកវចនៈ | | ពហុវចនៈ | |
|---|---|---|---|---|
| បឋមបុរស: | ខ្ញុំ | je | យើង | Nous |
| ទុតិយបុរស: | អ្នក | Tu | ឯង | Vous |
| តតិយបុរស | គេ | Il | គេ | Ils |
| | គឺ | Elle | គឺ | Ells |
| | វា | It | ទ្បូ | Its |

ពាក្យថា "យើង" ជាបឋមបុរស ពហុវចនៈ ប្រែថា "ខ្ញុំទាំងឡាយ, ខ្ញុំព្រះអង្គទាំងឡាយ, ទូលបង្គំទាំងឡាយ, ទូលបង្គំជាខ្ញុំទាំងឡាយ, ខ្ញុំព្រះករុណាទាំងឡាយ, ខ្ញុំករុណាទាំងឡាយ, ករុណាទាំងឡាយ, ខ្ញុំព្រះបាទទាំងឡាយ, ខ្ញុំបាទទាំងឡាយ, ខ្ញុំឯងទាំងឡាយ, អញខ្ញុំទាំងឡាយ, ខ្ញុំម្ចាស់ទាំងឡាយ, អាត្មាភាពទាំងឡាយ, អាត្មាទាំងឡាយ, អញទាំងឡាយ"; ប៉ុន្តែបើអ្នកធំតែម្នាក់ និយាយទៅរកអ្នកតូចទាបជាង, អ្នកឥតបណ្ដាស័ក្តិ ដោយសេចក្ដីលើកខ្លួនថាជាធំជាង ឬចាស់ជាង ដោយឥតមាន

www.elibraryofcambodia.org

សេចក្ដីគោរពកោតក្រែងនោះ: អ្នកធំ, អ្នកមានបណ្ដាស័ក្ដិធំ ឬ អ្នកចាស់ជាងនោះ សូម្បីតែម្នាក់ឯងក៏ដោយ ក៏គង់និយាយថា "យើង" បានដែរ នេះជាពាក្យរបស់អ្នកធំនិយាយទៅរកអ្នកតូច ។

ពាក្យថា "ឯង" ជាទុតិយបុរស ពហុវចនៈ: បើអ្នកធំនិយាយទៅកាន់អ្នកតូច ឬអ្នកស្មើគ្នានិយាយទៅរកអ្នកស្មើគ្នា ប្រែថា: "អ្នកទាំងឡាយ, នាងទាំងឡាយ, ឯងទាំងឡាយ, អាទាំងឡាយ, មីងទាំងឡាយ, ពួកទាំងឡាយ" ។ បើរាស្ត្រនិយាយទៅរកព្រះរាជា ប្រែថា: "ព្រះអង្គ, ព្រះករុណាវិសេស, ព្រះករុណាថ្លៃវិសេស, ទ្រង់" ។ បើរាស្ត្រនិយាយទៅរកនាហ្មឺនមានបណ្ដាស័ក្ដិធំ ប្រែថា: "ព្រះតេជព្រះគុណម្ចាស់, ឯកឧត្ដម, ព្រះតេជព្រះគុណ"; បើនិយាយទៅរកនាហ្មឺនមានបណ្ដាស័ក្ដិតូច ឬនិយាយទៅរកនឹងសុភាពបុរសផងគ្នា ជាការគួរសម ប្រែថា "លោក" នេះជាពាក្យសុភាពបុរស ឬសុភាពស្ត្រី; តាមន័យនេះ ឃើញថាពាក្យ "អ្នក" នេះជាពាក្យប្រើបានគ្រប់ជាន់គ្រប់ថ្នាក់ ឥតមានទំនាស់ ។

ពាក្យថា "គេ" ជាតតិយបុរស ពហុវចនៈ: បើអ្នកធំនិយាយទៅរកអ្នកតូច ឬអ្នកស្មើគ្នានិយាយទៅរកអ្នកស្មើគ្នា ប្រែថា: "គេ

www.elibraryofcambodia.org

ទាំងឡាយ, គាត់ទាំងឡាយ" ។ បើយើងនិយាយសំដៅដល់ព្រះពុទ្ធ ឬព្រះរាជាអង្គណាមួយដែលកំបាំងមុខ ប្រែថា: "ព្រះអង្គ, ទ្រង់"; បើសំដៅចំពោះលោកអ្នកមានបណ្ដាស័ក្តិ ប្រែថា: "លោក" ។ គឺពាក្យថា "គេ" នេះ គឺជាពាក្យមួយយ៉ាងសំ-ខាន់ក្នុងកម្ពុជភាសា សម្រាប់ប្រើបានគ្រប់ជាន់គ្រប់ថ្នាក់ មិនមានទំនាស់ ជាពាក្យសម្រាប់សុភាពបុរស ឬសុភាពស្ត្រី ប្រើបានទូទៅ ជាការងាយនឹងប្រើក្នុងការបំបែកកិរិយាទាំងឡាយ ។ តែពាក្យថា "គេ" នេះ និយាយបានចំពោះតែនឹងពាក្យដែលជាបុល្លិង្គ ហើយជាមនុស្សប៉ុណ្ណោះ ចំពោះស្ត្រី ឬពាក្យនាមដែលជាឥត្ថីលិង្គ ហើយនឹងសត្វតិរច្ឆាន ឬអ្វីៗផ្សេងៗទៀតពុំបានឡើយ ។

ពាក្យថា "គ៏" ជាតតិយបុរសឯកវចនៈ សម្រាប់និយាយចំពោះទៅស្ត្រី ឬពាក្យនាមដែលជាឥត្ថីលិង្គកំបាំងមុខ ប្រែថា "នាង" ។

ពាក្យថា "គី" ជាតតិយបុរសពហុវចនៈ បើអ្នកតូចនិយាយទៅស្ត្រីដែលមានបណ្ដាស័ក្តិ ប្រែថា "លោកស្រី, លោកជំទាវ, អ្នកស្រី" ។ បើអ្នកធំនិយាយទៅស្ត្រី ឬអ្នកស្មើគ្នា និយាយ

www.elibraryofcambodia.org

ទៅ. ស្រី. ស្មើគ្នាក្នុងទីកំបាំងមុខ ប្រែថា: “នាងទាំងឡាយ, គឺ ទាំងឡាយ” ។

ពាក្យថា “វា” ជាតតិយបុរសឯកវចនៈ សម្រាប់និយាយទៅ. សត្វតិរច្ឆាននឹងរបស់អ្វីៗ សព្វយ៉ាង ជាពាក្យស្តែងសេចក្តីមិនគោរពកោតក្រែង ។

ពាក្យថា: “ឡា” ជាតតិយបុរសពហុវចនៈសម្រាប់និយាយទៅ. សត្វតិរច្ឆានច្រើនពួក នឹងរបស់អ្វីៗសព្វយ៉ាងច្រើនសឹង ក្នុងទីកំបាំងមុខ ជាពាក្យស្តែងសេចក្តីមិនគោរពកោតក្រែង ប្រែថា: “វាទាំងឡាយ” ។

## វគ្គសរុបទី៧

១- ពាក្យសព្វនាមដូចម្តេច ដែលហៅថា បុរសសព្វនាម? ចូរអធិប្បាយ!

២- បុរសសព្វនាមបើកាត់ឲ្យដាច់ចេញពីគ្នា: បុរស ប្រែថាម៉េច? សព្វនាម ប្រែយ៉ាងណា? សំដៅសេចក្តីដូចម្តេច? អធិប្បាយ!

៣- បុរសសព្វនាមមានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់!

www.elibraryofcambodia.org

៤- បុរិសសព្វនាមយ៉ាងណា ហៅថា បឋមបុរិស? ប្រែថាម៉េច? បានដល់ពាក្យថាយ៉ាងណាខ្លះ? ចូរថាឲ្យអស់ម.មើល!

៥- ពាក្យ បឋមបុរិស ដែលគត់ប្រើក្នុងកម្ពុជវេយ្យាករណ៍ នេះមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

៦- បុរិសសព្វនាមយ៉ាងម៉េច ហៅថា ទុតិយបុរិស? ប្រែថាម៉េច? បានដល់ពាក្យអ្វីខ្លះ? ចូរសូត្រម.មើល!

៧- ពាក្យ ទុតិយបុរិស ដែលគត់ប្រើក្នុងកម្ពុជវេយ្យាករណ៍ នេះមានប៉ុន្មានម៉ាត់? អ្វីខ្លះ?

៨- បុរិសសព្វនាមដូចម្ដេច ហៅថា តតិយបុរិស? ប្រែយ៉ាងណា? បានដល់ពាក្យអ្វីខ្លះ? ចូររាប់ម.មើល!

៩- ពាក្យតតិយបុរិសដែលគត់ប្រើក្នុងកម្ពុជវេយ្យាករណ៍ នេះមានប៉ុន្មានម៉ាត់? អ្វីខ្លះ?

១០- ពាក្យបុរិសសព្វនាមដែលចាត់ថាជាសំដីវេយ្យាករណ៍ តើគឺអ្វីខ្លះ? ជាឯកវចនៈប៉ុន្មានម៉ាត់? ពហុវចនៈប៉ុន្មានម៉ាត់? ចូររាប់!

១១- ពាក្យថា "ខ្ញុំ" ជាអ្វី? ប្រើជួសពាក្យណាបានខ្លះ? សម្រាប់មនុស្សបែបណានិយាយ? ចាត់ជាពាក្យជាន់ណា?

www.elibraryofcambodia.org

១២. ពាក្យថា "យើង" ជាអ្វី? ប្រើជួសពាក្យណាបានខ្លះ? សម្រាប់អ្នកណានិយាយទៅរ.អ្នកណា ? ចាត់ជាពាក្យជាន់ណា?

១៣- ពាក្យថា "អ្នក" ជាអ្វី? ប្រើជួសពាក្យណាបានខ្លះ? សម្រាប់មនុស្សបែបណានិយាយ ចាត់ជាពាក្យជាន់ណា?

១៤. ពាក្យថា "វា" ជាអ្វី? ប្រើសម្រាប់អ្នកណានិយាយទៅរ.អ្នកតូច ឬអ្នកស្មើគ្នា និយាយគ្នា ប្រែថាម៉េច? ... និយាយទៅរ. ព្រះរាជា ប្រែថាម៉េច? ក្សត្រនិយាយទៅរ.នាម៉ឺនមានបុណ្យសក្តិធំ ប្រែយ៉ាងណា? ក្សត្រនិយាយទៅរ.នាម៉ឺនមានបុណ្យសក្តិតូច ឬសុភាពបុរស, សុភាពស្ត្រីនិយាយទៅរ.សុភាពបុរស, សុភាពស្ត្រីផងគ្នា ប្រែថាម៉េច? កាលបើយ៉ាងនេះ ពាក្យថា "វា" ប្រើបានក្នុងជាន់ណាខ្លះ ?

១៥. ពាក្យថា "គេ" សំដៅដល់អ្វី? ប្រើជួសពាក្យអ្វីខ្លះ? ចូរអធិប្បាយ !

១៦. ពាក្យថា "គេ" ប្រែថាម៉េច? ប្រើបានតែក្នុងទីយ៉ាងណា?

១៧- ពាក្យថា "គេ" ជាអ្វី? បើអ្នកធំនិយាយទៅរ.អ្នកតូច ឬអ្នកស្មើគ្នានិយាយទៅរ.អ្នកស្មើគ្នា ប្រែថាម៉េច? បើយើងនិយាយ

www.elibraryofcambodia.org

សំដៅចំពោះទៅ ព្រះពុទ្ធ ឬព្រះរាជាអង្គណាមួយ ក្នុងទីកំបាំង ព្រះភក្ត្រ ប្រែយ៉ាងណា? បើចំពោះលោកអ្នកមានបណ្ដាសក្ដិ ប្រែថាម៉េច? សម្រាប់មនុស្សបែបណានិយាយ? ចាត់ជាពាក្យជាន់ណា?

១៨- ពាក្យថា “គ័” សំដៅដល់អ្វី? ប្រើជួសពាក្យអ្វី? អធិប្បាយ!

១៩- ពាក្យថា “ក័” ប្រែយ៉ាងណា? ប្រើបានតែក្នុងទីដូចម្ដេច?

២០- ពាក្យថា “ក់” សំដៅដល់អ្វី? ប្រើបានតែនឹងអ្វី? អធិប្បាយ!

២១- ពាក្យថា “ឡូ” សំដៅដល់អ្វី? ប្រែថាម៉េច? ប្រើបានតែក្នុងទីណា ?

## ២- អបុរិសសព្វនាម (le pronom impersonnel)

ពាក្យសព្វនាម ដែលមិនបានប្រើជួសពាក្យនាមណាមួយ ដែលបានពោលមក ហើយក៏ខានដើម ទីដ៏មិនមានសេចក្ដីសំគាល់អ្នកនិទ្ទនដ៏ ហៅថា អបុរិសសព្វនាម គឺសព្វនាមមិនមានបុរស តាមពាក្យនោះ សព្វនាមមិនមានបុរស ក៏ហាក់ដូចជាមិនមានបុរសសុទ្ធមែនៗ ប៉ុន្តែដែលពិតនោះ បុរសមាន តែមានមិនគ្រប់ គឺមានតែបុរសទី៣ ដែលហៅថា តតិយបុរស ៗ បុរសទី៣ នេះសោត

www.elibraryofcambodia.org

ទៀតក៏មិនបានផល់ពាក្យថា: គេ, គេ, គឺ, គឺ, ឡូ នោះឡើយ បានផល់តែពាក្យមួយម៉ាត់គឺ "ក៏" ជាឯកវចនៈ ប៉ុណ្ណោះឯង ប៉ុន្តែបានជាហៅថា អបុរិសសព្វនាមនោះ ក៏ព្រោះតែសព្វនាមនេះមានបុរសមិនគ្រប់ទាំង ៣ ហើយបុរសទី ៣ ដែលមិនគ្រប់គ្រាន់នោះចុះម.ទទេ ៗ មិនមានការប្រើផ្សំពាក្យនាម ឬសព្វនាមផងណាមួយ ដែលបានពោលមកហើយពីខាងដើមនោះឡើយ ហើយទីងមិនមានសេចក្តីសំគាល់អ្នកនិងខ្លួនឯងបានផង ដោយហេតុដូច្នោះបានជាហៅថា អបុរិសសព្វនាម គឺសព្វនាមដែលមិនមានបុរសគ្រប់គ្រាន់, មិនបានប្រើផ្សំពាក្យនាមណាមួយ ហើយទីងមិនមានសេចក្តីសំគាល់អ្នកនិងខ្លួនឯង ដូចឧទាហរណ៍: ក៏រៀន, ក៏ខ្លាសគេ ដើដូច្នោះ ៗ

ពាក្យថា "ក៏" នេះ ប្រើភ្ជាប់នឹងកិរិយាអ្វីមួយខាងមុខក៏បាន ៗ កិរិយាណាដែលប្រើភ្ជាប់នឹងអបុរិសសព្វនាមដូច្នេះ កិរិយានោះហៅថា អបុរិសសព្វនាម ៗ ក្រៅអំពីនេះ អបុរិសសព្វនាម នៅមានប្រើពោលអណ្តែតៗ ទទេ ៗ ក្នុងសំនួរពាក្យហារដែលជាប់ទាក់ទងនឹងផល់ៈ ដី មេឃ អាកាស ឬក្នុងសំនួរពាក្យហារដទៃខ្លះ ដូចជា:

www.elibraryofcambodia.org

“ក៏ជាថ្ងៃល្អ, ក៏អាចនឹងកើតឆាយពេជួបគ្នា, ក៏ឲ្យខ្ញុំសប្បាយចិត្ត ណាស់ដែលបានឃើញនូវអ្នក, ក៏ធ្វើឲ្យខ្ញុំស្លុតចិត្ត ដែលបាន ឮថា អ្នកមិនបានសម្រេចនូវបំណង, ក៏នាំឲ្យខ្ញុំលំបាកចិត្តជាទីបំផុតដែលបានឃើញនូវអ្នកមិនសមប្រកប” ។

## វគ្គសិក្សាបទទី ៨

១ — ពាក្យសព្វនាមយ៉ាងម៉េច ដែលហៅថា អបុរិសសព្វនាម? អធិប្បាយ!

២ — ពាក្យថាសព្វនាមមិនមានបុរសនោះ មិនមានបុរសណា មានបុរសណា? ឬមិនមានតាំងអស់?

៣- បើមិនមានតាំងអស់ក៏ហើយទៅ ប៉ុន្តែបើមានខ្លះដែរ ហេតុអ្វីក៏បានជាហៅថា សព្វនាមមិនមានបុរស? ម៉េចក៏មិនហៅថា សព្វនាមមានបុរសខ្លះដែរដូច្នេះទៅ? អធិប្បាយ!

៤- អបុរិសសព្វនាមនេះ ប្រើភ្ជាប់នឹងកិរិយាណាបានខ្លះ? មានកំណត់ឬទេ ?

៥ — កិរិយាដែលប្រើភ្ជាប់នឹងអបុរិសសព្វនាមនោះ ហៅថា

www.elibraryofcambodia.org

ក្ដី? ប្រែថាម៉េច?

៦– ក្មេងៗនោះ អបុរិសសព្វនាម នៅមានប្រើទាក់ទងនឹងអ្វីទៀត, អធិប្បាយ!

៧– ឧទាហរណ៍ថា: វាកើតទុក្ខក្ដៅក្រហាយ, នេះសៀវភៅរបស់អ្នក, ចាប់វាយទៅ! នេះ “វា” ណាជាបុរិសសព្វនាម ណាជាអបុរិសសព្វនាម?

## ៣. អញ្ញោញ្ញសព្វនាម

ពាក្យសព្វនាមដែលសម្រាប់ប្រើបញ្ជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីនានាមុខ ដើម្បីឲ្យដឹងថា: មនុស្ស,សត្វ ឬអ្វីៗគ្រប់យ៉ាង នោះមានច្រើនចំណែក ដែលធ្វើកិរិយាឲ្យជាប់ទាក់ទងនឹងគ្នា ពាក្យសព្វនាមបែបនេះឯង ហៅថា អញ្ញោញ្ញសព្វនាម ។ ពាក្យថា “អញ្ញោញ្ញ” ក៏ដូចគ្នានឹង “អញ្ញ+អញ្ញ” ប្រែថា “ដទៃនឹងដទៃ, ឯទៀតនឹងឯទៀត, គ្នានឹងគ្នា, ទៅវិញទៅមក.” ។ តែក្នុងទីនេះ សំដៅសេចក្ដីថា “គ្នានឹងគ្នា” អញ្ញោញ្ញសព្វនាម ប្រែថា: “ពាក្យដែលសម្រាប់ប្រើជួសឈ្មោះ, មនុស្ស សត្វ ឬអ្វីៗគ្រប់យ៉ាង ដើម្បីធ្វើជាមួយគ្នា ឬធ្វើទៅវិញទៅមក.”; ពាក្យសម្រាប់ប្រើក្នុង

www.elibraryofcambodia.org

អញ្ញោញ្ញសព្វនាមនេះ មានតែមួយម៉ាត់គឺ "គ្នា" ពាក្យថា "គ្នា" នេះ
បានជាហៅថា អញ្ញោញ្ញសព្វនាមនោះ ព្រោះពាក្យនេះ [illegible]
ប្រើជួសពាក្យនាមខាងមុខ ដើម្បីឲ្យដឹងថា នាមនោះ [illegible]
ណែកស្រុកសីងតែធ្វើកិរិយាឲ្យជាប់ទាក់ទងជាមួយគ្នាដូចក្នុងសេ[illegible]
គតៅនេះ: "ក្មេងវាយគ្នា, ស្រុកបាញ់គ្នា, គេស្តាញ់គ្នា" ពាក្យ
"គ្នា" ក្នុងទាំងនេះ ជួសពាក្យថា "ក្មេង, ស្រុក, គេ" ស្ដែងថា
"ក្មេងច្រើននាក់ ដែលធ្វើកិរិយាវាយទៅឲ្យដល់គ្នា, ស្រុកច្រើននាក់
ធ្វើកិរិយាបាញ់ទៅវិញទៅម., គេច្រើននាក់ធ្វើកិរិយាស្តាញ់ឲ្យដល់
គ្នាទៅវិញទៅម." ។ បើប្រសិនណាជាយើងមិនប្រើពាក្យថា
"គ្នា" ជួសពាក្យនាម ឬសព្វនាមទាំងនោះទេ យើងក្រូវ[illegible]
នាមថែមចុះម.ទៀតថា: ក្មេងពួកនេះ វាយក្មេងពួក[illegible]
វាយក្មេងពួកនេះម.វិញ, ស្រុកពួកនេះ បាញ់ស្រុកពួក[illegible]
ក៏បាញ់ស្រុកពួកនេះម.វិញ, គេនេះស្តាញ់គេឯណោះៗ ក៏ស្តាញ់
គេនេះម.វិញ" ។

ពាក្យថា "គ្នា" ជាអញ្ញោញ្ញសព្វនាមនេះ មានទីសង្កេត
ដូច្នេះ: គឺជាពាក្យប្រើជួសពាក្យនាមដែលជាអ្នកត្រូវធ្វើឬពាក្យ

www.elibraryofcambodia.org

នាមបំណែកណាមួយរបស់ប្រយោគដូចគួយ៉ាងថា: ប្ដីប្រពន្ធវាយគ្នា, ប្ដីប្រពន្ធនៅជាមួយគ្នា, គេគោរពដល់គ្នាដូច្នេះជាដើម។ ក្រៅអំពីនេះ ពាក្យថា "គ្នា" អាចប្រើជាពាក្យបំណែកដទៃបានទៀត គឺអាចប្រើជួសពាក្យបុរិសសព្វនាម បឋមបុរិសឯកវចនៈក៏បាន, ជួសបុរិសសព្វនាម តតិយបុរិសឯកវចនៈក៏បាន ដូចថា "គ្នាលាសិនហើយណា៎ស! (ប. ឯក.), ឲ្យគ្នាទៅផង! គ្រាន់បានជាគ្នា (ត.ឯក.) ។

## វិញ្ញាសាបទទី ៩

១ — យ៉ាងម៉េចបានជាហៅថា អញ្ញមញ្ញសព្វនាម? អធិប្បាយទៅមើល!

២ - "អញ្ញមញ្ញ" ដូចគ្នានឹងអ្វី? ប្រែថាម៉េចបានខ្លះ? ក្នុងនេះសំដៅយកពាក្យណា?

៣ — អញ្ញមញ្ញសព្វនាម ប្រែយ៉ាងណា?

៤ - ពាក្យសម្រាប់ប្រើក្នុងអញ្ញមញ្ញសព្វនាមមានប៉ុន្មានម៉ាត់? គឺពាក្យថាម៉េច? ព្រោះហេតុអ្វី?

៥ - ឧទាហរណ៍នៃអញ្ញមញ្ញសព្វនាម[illegible]ម្ដងខ្លះ ធ្វើ

www.elibraryofcambodia.org

ហើយមិនប្រើពាក្យអញ្ញមញ្ញសព្វនាមនោះជំនួស? ឧទាហរណ៍តាំង នោះឲ្យទៅជាយ៉ាងមួយទៅវិញ!

៦– អញ្ញមញ្ញសព្វនាមនោះ មានទីសង្កេតដូចម្ដេច? ចូរអធិប្បាយ!

៧– ពាក្យថា “គ្នា” នោះប្រើជួសពាក្យអ្វីបានខ្លះទៀត? ទាញឧទាហរណ៍ម.ប្រកបផង!

## វិភាគសព្វនាម (le pronom indéfini)

ពាក្យដែលសម្រាប់ប្រើចេញជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាងដែលនៅខាងមុខ ដើម្បីចែកញែក មនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាងនោះចេញជាចំណែកៗ ពាក្យបែបនេះឯង ហៅថា វិភាគសព្វនាម ។ ពាក្យថា “វិភាគ” នេះ ប្រែថា “ការចែកញែក, ការបែង, ការចែក, ចំណែក” ដូច្នេះបានជាពាក្យថា វិភាគសព្វនាមនេះ ត្រូវប្រែថា “ពាក្យសម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗ គ្រប់យ៉ាង ដើម្បីចែកឲ្យជាចំណែកៗ” ។ ពាក្យសម្រាប់ប្រើក្នុងវិភាគសព្វនាមនេះមាន ២ ម៉ាត់គឺ ពាក្យថា “ខ្លះ, ម្នាក់” ។ ពាក្យថា “ខ្លះ” នេះ គាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗ គ្រប់

www.elibraryofcambodia.org

យ៉ាងខាងមុខបាន ដើម្បីសំដែងឲ្យដឹងថា: មនុស្ស, សត្វ ឬវត្ថុគ្រប់យ៉ាងនោះ មានច្រើនចំណែក តែញែកធ្វើកិរិយាផ្សេងៗគ្នា មិនរួមធ្វើកិរិយាជាមួយគ្នា ដូចជាប្រយោគទាំងឡាយថា: "អ្នកស្រែទាំងឡាយខ្លះភ្ជួរ ខ្លះរាស់, កងទ័ពទាំងពីរផ្នែកដូចប្រទះគ្នា ខ្លះក៏បាញ់ ខ្លះក៏ចូលប្រយុទ្ធ កាប់ ចាក់ ដាក់ប្រាំ សម្លាប់គ្នា ពាក្យ "ខ្លះ" ក្នុងទីនេះចេញជួសអ្នកស្រែ, ជួសកងទ័ព, ហើយញែកអ្នកស្រែចេញជាពួកៗ ញែកកងទ័ពចេញជាពួកៗ ហើយនឹងសុទ្ធតែធ្វើកិរិយាផ្សេងៗ គ្នាផង គឺអ្នកស្រែខ្លះ ភ្ជួរ, អ្នកស្រែខ្លះ រាស់, កងទ័ពខ្លះបាញ់, កងទ័ពខ្លះចូលប្រយុទ្ធដាល់ដៃ ។ បើប្រសិនជាយើងមិនប្រើពាក្យ "ខ្លះ" ជួសទេ ក្នុងប្រយោគមានសេចក្តីយ៉ាងនោះ យើងក៏ត្រូវថែមពាក្យនាមចុះម្តងទៀតថា: អ្នកស្រែទាំងឡាយ, អ្នកស្រែមួយពួកភ្ជួរ អ្នកស្រែមួយពួករាស់, កងទ័ពទាំងពីរផ្នែកដូចប្រទះគ្នា, កងទ័ពមួយផ្នែកបាញ់, កងទ័ពមួយផ្នែកចូលប្រយុទ្ធ ។ ដូច្នេះពាក្យថា "ខ្លះ" ហើយរាប់ថាជា វិភាគសព្វនាម បានដោយលក្ខណៈដូចបានអធិប្បាយមកនេះឯង ។

មួយវិញទៀត ពាក្យ "ខ្លះ" នេះ បើប្រើប្រកបជាក់ខាង

www.elibraryofcambodia.org

ក្រោយពាក្យនាម ក៏ត្រូវប្រែទៅជាវិភាគគុណសព្ទទៅវិញ ដូចជា: "ក្អែកខ្លះ, តាកើខ្លះ, ប្រាក់ ១០ រៀលនោះត្រូវបានខ្ញុំខ្លះ, ត្រូវបានអ្នកខ្លះ"; បើប្រកបដាក់ខាងក្រោយពាក្យកិរិយា ក៏ត្រូវប្រែទៅជាកិរិយាវិសេសនៈទៅវិញ ដូចជា: "ឥរិយាបថទាំង ៤ នោះត្រូវលៃឲ្យស្មើគ្នា ដេកខ្លះ, ដើរខ្លះ, ឈរខ្លះ, អង្គុយខ្លះ" ។ ដូច្នេះយើងតែងត្រូវពិនិត្យឲ្យមែនទែន ទើបមិនច្រឡំ គឺថា ពាក្យ "ខ្លះ" នេះបើប្រើជួសពាក្យនាម ឬ សព្វនាមផងគ្នាក៏ដោយ ប៉ុន្តែបើដាក់ខាងមុខពាក្យឯទៀត ៗ នុ៎ះជាវិភាគសព្វនាម, បើប្រើប្រកបជាមួយនឹងពាក្យនាម ឬសព្វនាមផងគ្នានោះក៏ដោយ ប៉ុន្តែបើដាក់ខាងក្រោយពាក្យនាម ឬសព្វនាមនោះ នេះជាវិភាគគុណសព្ទ បើប្រកបជាមួយនឹងពាក្យកិរិយា ហើយដាក់ខាងក្រោយកិរិយានោះ នេះជាកិរិយាវិសេសនៈ ។

ពាក្យថា "ម្នាក់" នេះ ក៏អាចប្រើជួសឈ្មោះមនុស្ស, សត្វ ឬអ្វី ៗ គ្រប់យ៉ាង ដែលនៅខាងមុខបានដូចគ្នា ដើម្បីនឹងថ្លែងឲ្យដឹងថា មនុស្ស, សត្វ ឬអ្វីៗ គ្រប់យ៉ាងនោះ មានច្រើនចំណែក ក៏ញែកធ្វើកិរិយាផ្សេង ៗ គ្នា មិនរួមធ្វើកិរិយាជាមួយគ្នាឡើយ

www.elibraryofcambodia.org

ដូចក្នុងប្រយោគថា: "ក្នុងសាលារៀនរបស់ខ្ញុំ មានស្មៀន ជាច្រើននាក់, តែមានម្នាក់នោះឈ្មោះថាជាង, គ្នា ២ នាក់ បើម្នាក់ទៅហើយ ត្រូវម្នាក់នៅ, កុំទៅទាំងអស់គ្នា ក្នុងទីប្រជុំមាន មនុស្សច្រើន មិនត្រូវដណ្ដើមនិយាយទេ ត្រូវនិយាយម្នាក់ម្ដង, បើម្នាក់ចាប់និយាយ ត្រូវអ្នកឯទៀតប្រុងចាំស្ដាប់" ។

មួយវិញទៀត ពាក្យថា "ម្នាក់" នេះ បើប្រើប្រកបដាក់ខាង ក្រោយពាក្យនាម ក៏ត្រឡប់ទៅជា វិភាគគុណសព្ទទៅវិញ ដូចជា: "ក្មេងម្នាក់ថាយ៉ាងនេះ, ក្មេងម្នាក់ថាយ៉ាងនោះ, អ្នកម្នាក់ថាឲ្យ, អ្នកម្នាក់ថាមិនឲ្យ, កើតមកជាមនុស្សម្នាក់ ៗ ត្រូវតែរៀនឲ្យបានចេះដឹង ទើបហៅថា មនុស្សពេញទីបាន" ប៉ុន្តែបើប្រើសិនជាសរសេរ ពាក្យគូជា "១នាក់" ដូច្នេះវិញនោះ, "១" ក៏ជាបុព្វបទកតិសង្ខ្យា "នាក់" ក៏ត្រឡប់ទៅជាលក្ខណនាមទៅវិញ ។

## វិក្ខសាបទទី១០

១– វិភាគសព្ទនាមអធិប្បាយដូចម្ដេច? អធិប្បាយទៅមើល!

២– "វិភាគ" ប្រែយ៉ាងម៉េច? វិភាគសព្ទនាម ប្រែយ៉ាងណា?

www.elibraryofcambodia.org

៣ - ពាក្យសម្រាប់ប្រើក្នុងវិភាគសព្វនាម មានប៉ុន្មានមាត់? គឺអ្វីខ្លះ?

៤–ពាក្យថា "ខ្លះ" សម្រាប់ប្រកបខាងណានាម ឬសព្វនាម? ដូចឧទាហរណ៍ថាម្ដេចខ្លះ? ចូរទាញមើល!

៥–ឧទាហរណ៍ខាងនោះ បើប្រសិនណាជាយើងមិនប្រើពាក្យ "ខ្លះ" នោះដូច្នេះ នឹងទៅជាយ៉ាងម្ដេចទៅវិញ? ចាំមើល!

៦–ពាក្យ "ខ្លះ" នោះបើយើងប្រកបដាក់ខាងក្រោយពាក្យនាម ឬសព្វនាមនឹងទៅជាឈ្មោះអ្វីទៅវិញ? ឧទាហរណ៍ដូចម្ដេច?

៧–ពាក្យ "ខ្លះ" នោះ បើដាក់ប្រកបខាងក្រោយកិរិយានឹងទៅជាឈ្មោះអ្វីទៅវិញ? ឧទាហរណ៍យ៉ាងណា?

៨–យើងគប្បីនឹងសង្កេតដូចម្ដេច ទើបដឹងថាពាក្យ "ខ្លះ" នេះជាគុណសព្ទ? នេះជាសព្វនាម? នេះជាកិរិយាវិសេសនៈ ចូរប្រាប់វិធីសង្កេត !

៩–ពាក្យថា "ម្នាក់" សម្រាប់ប្រកបខាងណាពាក្យនាម ឬសព្វនាម ឬក៏ដាក់ត្រង់ណា? ដូចឧទាហរណ៍ថាម្ដេចខ្លះ ? ចូរទាញមើល!

www.elibraryofcambodia.org

១០—ឧទាហរណ៍ខាងលើនោះ បើប្រសិនជាយើងមិនប្រើពាក្យ "ម្នាក់" នោះខុសទេ នឹងទៅជាយ៉ាងម៉េចទៅវិញ? ចាំមើល!

១១—ពាក្យ "ម្នាក់" បើយើងប្រកបខាងក្រោយពាក្យនាម ឬសព្វនាមនោះ នឹងទៅជាឈ្មោះអ្វីទៅវិញ? ឧទាហរណ៍ដូចម្តេចខ្លះ? -

១២—ប្រសិនបើយើងសរសេរពាក្យថា "១ នាក់" ដូច្នេះ តើនឹងទៅជា "វិភាគសព្វនាម" ដូចដើមបានឬទេ? ព្រោះហេតុអ្វី? ចូរអធិប្បាយ!

៥. និយមសព្វនាម (le pronom démonstratif)

ពាក្យដែលសម្រាប់ប្រើចេញជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាង ដើម្បីស្តែងឲ្យដឹងកំណត់ទៀងទាត់ ជាប់ស្រេច ហៅថា និយមសព្វនាម (le pronom démonstratif) ពាក្យថា "និយម" ប្រែថា "ការកត់, កំណត់, សេចក្តីទៀងទាត់, សេចក្តីជាប់ស្រេច"; និយមសព្វនាម ប្រែថា "ពាក្យសម្រាប់ប្រើជួសឈ្មោះមនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាងដែលទៀងទាត់ជាប់ស្រេច" ។ ពាក្យសម្រាប់ប្រើក្នុងនិយមសព្វនាមនេះ មាន ៤ ម៉ាត់គឺ "នេះ,

www.elibraryofcambodia.org

នុ៎ះ, នោះ, ហ្នឹង" ។ បណ្ដាពាក្យទាំង ៤ មាត់នេះ ពាក្យថា:

"នេះ" ជាពាក្យនិយមសព្វនាមសម្រាប់បង្ហាញ, សម្រាប់ចង្អុលអ្វីៗ ដែលនៅក្បែរខាងខ្លួនឲ្យឃើញជាក់ស្ដែង ដូចជា: "នេះរបស់អ្វី? នេះរបស់អ្នកណា? នេះផ្ទះរបស់ខ្ញុំ" -ៗ

"នុ៎ះ" ជាពាក្យនិយមសព្វនាម គឺជាពាក្យសម្រាប់និយាយចង្អុលពាក្យនាម ឬពាក្យសព្វនាម ដែលនៅឃ្លាតចេញពីខ្លួន តែមើលទៅឃើញ, ជាពាក្យមានសូរសម្លេងខ្ពស់ស្រួចជាងពាក្យថា "នេះ" ដូចពាក្យថា: "នុ៎ះហើយ! នុ៎ះឯង! នុ៎ះផ្ទះរបស់ខ្ញុំ!" ។

"នោះ". ជាពាក្យនិយមសព្វនាម គឺជាពាក្យសម្រាប់បង្ហាញ សម្រាប់ចង្អុលអ្វីៗ ដែលនៅឆ្ងាយចេញទៅតែប្រាកដ; ជាពាក្យមានសូរសម្លេងទាបបន្តិចជាងពាក្យថា: "នុ៎ះ"! ដូចជា: "នោះរបស់អ្នកណា? នោះផ្ទះរបស់បងស្រីផងខ្ញុំ! នោះឆត្ររបស់អ្នកឯង! នោះគឺបឹងផង់ះឃើញប្រាកដហើយ!" ។

"ហ្នឹង" ក៏ជាពាក្យនិយមសព្វនាមដែរ ព្រោះអាចប្រើជួសពាក្យនាម ឬពាក្យសព្វនាមបានដូចគ្នា, ដូចជា: "ហ្នឹងហើយ!

www.elibraryofcambodia.org

ហ្នឹងឯង! ហ្នឹងរបស់ខ្ញុំ! ហ្នឹងប្រាកដជារបស់ខ្ញុំហើយ! មិនមែនរបស់អ្នកទេ!" ។ កាលណាបើទៅជាពហុវចនៈត្រូវថែម "ទាំង" ដាក់ខាងដើមថា "ទាំងនេះ, ទាំងនុ៎ះ, ទាំងនោះ, ទាំងហ្នឹង" ពាក្យសម្រាប់ប្រើក្នុងនិយមសព្ទនាមនេះ ក៏ដូចគ្នានឹងពាក្យសម្រាប់ប្រើក្នុងនិយមគុណសព្ទដែរ តែក្នុងនិយមគុណសព្ទត្រូវដាក់ពាក្យទាំងនេះខាងក្រោយពាក្យនាម ឬសព្ទនាម ។ ឯនិយមសព្ទនាម ត្រូវដាក់ពាក្យអម្បាលនេះនៅខាងមុខពាក្យនាម ឬសព្ទនាមប៉ុណ្ណោះ ដូចពាក្យនិយមគុណសព្ទថា "ផ្ទះនេះមានដំឡៃប៉ុន្មាន? ក្មេងនុ៎ះទៅណា? គោនោះរបស់អ្នកណា? មានរោគអ្វីហ្នឹង?" ។ ពាក្យនិយមសព្ទនាមថា: "នេះហៅអ្វី? នេះសំពត់របស់អ្នក! នុ៎ះអ្នកណាដែរ? នោះក្របីរបស់អ្នក ឬមិនមែន? ហ្នឹងប្រពន្ធរបស់អ្នកឬមិនមែន ?" ។

## ឥក្ខសាកបទី ១១

---

១—និយមសព្ទនាមអធិប្បាយថាម៉េច? គិតទៅ!

២—"និយម" ប្រែថាម៉េច? និយមសព្ទនាមប្រែយ៉ាងណា?

៣—ពាក្យសម្រាប់ប្រើក្នុងនិយមសព្ទនាម មានប៉ុន្មានពាក្យ?

www.elibraryofcambodia.org

អ្វីខ្លះ? កប់!

៤—ពាក្យថា "នេះ" សម្រាប់ប្រើក្នុងទីដូចម្ដេច? ឧទាហរណ៍យ៉ាងណា?

៥—ពាក្យ "នុះ" សម្រាប់ប្រើយ៉ាងណា? ឧទាហរណ៍ដូចម្ដេចខ្លះ?

៦—ពាក្យថា "នោះ" ជាអ្វី? សម្រាប់ប្រើយ៉ាងម៉េច? ឧទាហរណ៍យ៉ាងណា?

៧—ពាក្យថា "ហ្នឹង" ជាអ្វីដែរ? ឧទាហរណ៍យ៉ាងម៉េចខ្លះ?

៨—នេះ, នុះ, នោះ, ហ្នឹង បើជាពហុវចនៈ តើសម្រេចរូបយ៉ាងណា?

៩—ពាក្យថា: និយមគុណសព្ទនឹងពាក្យថា និយមសព្ទនាម ផ្សេងគ្នាយ៉ាងណា? ចូរអធិប្បាយ!

១០—ពាក្យសម្រាប់ប្រើក្នុងនិយមគុណសព្ទ នឹងនិយមសព្ទនាម ផ្សេងគ្នា ឬដូចគ្នា? មានវិធីប្រើខុសគ្នាដូចម្ដេច? ចូរអធិប្បាយ!

១១—ពាក្យថា នេះ, នុះ, នោះ, ហ្នឹង" តើជាសព្ទអ្វីបានខ្លះ? បើប្រើជានិយមគុណសព្ទ តើត្រូវប្រើយ៉ាងណា? ឧទាហរណ៍ដូច

www.elibraryofcambodia.org

ម្ដេច ? បើប្រើជានិយមសព្វនាម តើត្រូវប្រើដូចម្ដេច? ឧទាហរណា យ៉ាងណា ?

## ៦– អនិយមសព្វនាម

(le pronom démonstratif indéfini)

---

ពាក្យដែលសម្រាប់ប្រើជំនួសឈ្មោះរបស់ មនុស្ស, សត្វ ឬអ្វីៗ គ្រប់យ៉ាង ដើម្បីស្ដែងបញ្ជាក់ឲ្យដឹងថា “មនុស្ស, សត្វ ឬអ្វីៗ គ្រប់យ៉ាងនោះ មិនមានកំណត់ មិនមានទៀងទាត់ មិនមានសេចក្ដីដាច់ស្រេច ហៅថា អនិយមសព្វនាម (le pronom démonstratif indéfini )។ ពាក្យថា “អនិយម” ប្រែថា “មិនមានកំណត់, មិនមានសេចក្ដីទៀងទាត់, មិនមានសេចក្ដីដាច់ស្រេច” បើភ្ជាប់ជា “អនិយមសព្វនាម” ប្រែថា “ពាក្យសម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាងដែលមិនប្រាកដ, មិនទៀងទាត់, មិនដាច់ស្រេច” ពាក្យសម្រាប់ប្រើក្នុងអនិយមសព្វនាមនេះមាន ៤ ម៉ាត់គឺ “ណា, ណា, អ្វី, ម៉េច” បណ្ដាពាក្យទាំង ៤ ម៉ាត់នេះ ពាក្យថា:

“ណា” នេះជាអនិយមសព្វនាម, ជាពាក្យស្ដែងសេចក្ដី

www.elibraryofcambodia.org

របស់នាម មិនមានកំណត់ទៅលើពាក្យនាម ឬសព្វនាមណាមួយ តែមិនស្តែងអាការៈ ជាសេចក្តីសង្ស័យ នាំឲ្យងឿងឆ្ងល់ ហើយសាកសួរនោះទេ និយាយសេចក្តីគ្រាន់ៗ តែម្តង ដូចជា: ណាក៏យ ខ្ញុំមិនរើសទេ! ណាក៏បានៗ គេមិនថាអីទេ! ណាក៏ដូចណាមិនប្រាប់រើសទេ!ៗ ពាក្យ "ណា" ប្រើបានទូទៅទាំង មនុស្ស, សត្វ ព្រមទាំងអ្វីៗគ្រប់យ៉ាងមិនមានកំណត់ ។

"ណា" នេះ ជាអនិយមសព្វនាមដែរ, ជាពាក្យស្តែងសេចក្តីរបស់នាមមិនមានកំណត់ទៅលើពាក្យនាម ឬសព្វនាមណាមួយ តែក៏មិនស្តែងអាការៈជាសេចក្តីមន្ទិលសង្ស័យនាំឲ្យសន្ទិះងឿងឆ្ងល់ហើយសាកសួរនោះទេ និយាយសេចក្តីគ្រាន់ៗតែម្តង ដូចជា: "ណាកាក់ន, ណារុកផែនដីយើង, យើងច្បាំងទាល់តែលើងរលាយ... ពួកយើងប្រុសប្រាណ យើងមានផងជាតិសាមាថពួជអ្នកច្បាំងគ្នា ស្លាប់, ណាស្លាប់ទៅមិនត្រូវតែតរក... (បាកអភិនតែត) ប៉ុន្តែពាក្យ "ណា" នេះប្រើដូចបានចំពោះតែមនុស្ស មិនប្រើដូចសត្វ ឬអ្វីៗគ្រប់យ៉ាងទូទៅពុំបានឡើយ ។

"អ្វី" នេះក៏ជាពាក្យអនិយមសព្វនាមមួយដែរ ព្រោះជាពាក្យ

www.elibraryofcambodia.org

សម្រាប់ប្រើ ជួសពាក្យនាម ឬសព្វនាម ដែលស្តែងសេចក្តីរបស់នាម មិនទៀង[illegible]លើនាម ឬសព្វនាមណាមួយឲ្យប្រាកដ តែប្រើជួស[illegible]ដែមួន មិនស្តែងអាការៈ ឲ្យមានទំនង ជាពាក្យសួរទេ ដូច ពាក្យថា: អ្វីក៏ដោយខ្ញុំមិនរវល់ទេ តាមតែគេចុះ! អ្វីក៏មិនថា ស្រាប់តែដើរព្រងើយទៅ! អ្វីៗគេក៏ឥតប្រាប់ដល់ខ្ញុំ! តាមតែអ្វីក៏ដោយចុះ ខ្ញុំទៅតែមិនញាក! ។ ពាក្យ "អ្វី" នេះ ប្រើបានទូទៅចំពោះមនុស្ស, សត្វនិងរបស់គ្រប់យ៉ាង ។

"មេច" នេះ ក៏ជាពាក្យអនិយមសព្វនាមដែរ ព្រោះជាពាក្យសម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗចំពោះតួន តែមិនបានស្តែងសេចក្តីឲ្យជាក់ស្រេចទៅលើ មនុស្ស, សត្វ ឬអ្វីៗចំពោះតួនោះឲ្យប្រាកដប្រជាឡើយ ហើយនិយាយសេចក្តីត្រង់ៗ មិនស្តែងអាការៈនាំឲ្យងឿងឆ្ងល់ ហើយត្រូវសាកសួរនោះទេ ដូចជា: "មេចក៏មេចចុះ ខ្ញុំមិនព្រ[illegible]ណោះ, មេច ៗ កុំព្រមឲ្យដល់គេណាស! មេច ៗ ប្រាប់ឲ្យរបស់អ្នកម្តង.កុំខាន!_ ដ្បិតចាំមើលឯណោះ! ។ ពាក្យអនិយម-សព្វនាមនេះ ក៏ដូចគ្នានឹងពាក្យបុច្ឆាសព្វនាមដែរ ប្លែកតែក្នុងបុច្ឆាសព្វនាម ចុះក្នុងប្រយោគជាពាក្យ

www.elibraryofcambodia.org

សួរ ៗ ឯក្តីអនិយមសព្វនាមនេះ ចុះក្តីសេចក្តីត្រង់ៗ មិនមែនជាពាក្យសួរប៉ុណ្ណោះ ៗ មួយវិញទៀត ពាក្យអនិយមសព្វនាមនេះគឺដូចគ្នានឹងពាក្យអនិយមគុណសព្ទដែរ ប្លែកតែក្តីអនិយមគុណសព្ទ ត្រូវរៀងដាក់ខាងក្រោយពាក្យនាម ឬពាក្យសព្វនាម ៗ ឯក្តីអនិយមសព្វនាមនេះ ត្រូវរៀងដាក់ខាងមុខពាក្យនាម ឬពាក្យសព្វនាមវិញប៉ុណ្ណោះ ៗ

## ឥក្កូសាកល្បងទី ១២

១- អនិយមសព្វនាមដូចម្តេច? អធិប្បាយទៅមើល!

២- "អនិយម" ប្រែថាម៉េច? អនិយមសព្វនាមប្រែយ៉ាងណា?

៣- ពាក្យសម្រាប់ប្រើក្តីអនិយមសព្វនាមមានប៉ុន្មានម៉ាត់ ? អ្វីខ្លះ ?

៤- ពាក្យថា "ណា" សម្រាប់ប្រើក្តីដូចម្តេច? ឧទាហរណ៍យ៉ាងណា? ប្រើចំពោះអ្វីបានខ្លះ ?

៥- ពាក្យថា "ណា" សម្រាប់ប្រើដូចអ្វី? ឧទាហរណ៍យ៉ាងណាខ្លះ? មានកំណត់ប្រើដូចម្តេច ?

www.elibraryofcambodia.org

៦. ពាក្យថា "អ្វី" ជាពាក្យដូចម្ដេច? ប្រើក្នុងទីណា? ចូរទាញតួយ៉ាង!

៧. ពាក្យថា "ម៉េច" ប្រើក្នុងទីដូចម្ដេច? ឧទាហរណ៍យ៉ាងណាខ្លះ?

៨. ពាក្យសម្រាប់ប្រើក្នុងអនិយមសព្វនាម ប្លែកពីពាក្យសម្រាប់ប្រើក្នុងបុច្ឆាសព្វនាមត្រង់ណាខ្លះ? ចូរបញ្ជាក់ប្រាប់!

៩. ពាក្យសម្រាប់ប្រើក្នុងអនិយមគុណសព្ទ ផ្សេងពីអនិយមសព្វនាម ឬដូចគ្នា? បើដូច្នេះតើធ្វើម៉េចទើបនឹងអាចសង្កេតបាន? ចូរអធិប្បាយវិធីសង្កេត!

១០—ពាក្យថា "ណា, អ្វី, ម៉េច" នេះប្រើបានក្នុងទីណាខ្លះ? ប្រើផ្សេងគ្នាយ៉ាងណា? ចូរអធិប្បាយឲ្យសព្វគ្រប់ ។

## ៧—បុច្ឆាសព្វនាម (le pronom intérrogatif)

ពាក្យដែលសម្រាប់ប្រើបញ្ជួសឈ្មោះ មនុស្ស, សត្វ អ្វីៗគ្រប់យ៉ាងដែលប្រព្រឹត្តទៅក្នុងដំណើរសេចក្ដីដែលជាពាក្យសួរ ហៅថា បុច្ឆាសព្វនាម (Le pronom intérroqatif) ពាក្យថា "បុច្ឆា" នេះប្រែថា "ពាក្យសួរ, ពាក្យដណ្ដឹង, ពាក្យទាម,

www.elibraryofcambodia.org

សំនួរ" បើភ្ជាប់គ្នានឹងពាក្យសព្វនាមថា "បុច្ឆាសព្វនាម" នោះប្រែថា "ពាក្យដែលសម្រាប់ប្រើជួស មនុស្ស សត្វ ឬអ្វីៗទាំងពួងដែលជាពាក្យសួរ" ។ បុច្ឆាសព្វនាមក្នុងទីនេះសំដៅសេចក្តីដល់ពាក្យដែលប្រើជួសឈ្មោះ មនុស្ស, សត្វ ឬរបស់អ្វីៗដែលជារបស់គេមន្ទិលសង្ស័យ ហើយគេត្រូវសួរ ។ ពាក្យសម្រាប់ប្រើក្នុងបុច្ឆាសព្វនាមនេះ មាន ៧ ម៉ាត់គឺ "ណា? អ្វី? អី? [illegible] ថ្វី? ម្តេច? ម៉េច?" ។ បណ្តាពាក្យទាំង ៧ ម៉ាត់នុ៎ះ ពាក្យថា:

"ណា" នេះ ជាពាក្យបុច្ឆាសព្វនាមព្រោះជាពាក្យសម្រាប់ប្រើជួស ឬប្រើគាំង មនុស្ស, សត្វ ឬអ្វីៗ គ្រប់យ៉ាងបាន ហើយជាពាក្យមានអាការៈជាសេចក្តីសង្ស័យនាំឲ្យសាកសួរដូចពាក្យថា: "ណាប្រពន្ធរបស់អ្នក? ណាប្តីរបស់នាង?" ពាក្យថា "ណា" ក្នុងប្រយោគខាងដើមនុ៎ះ ប្រើជួសស្ត្រី, ខាងចុងប្រើជួសប្រុស ។ បើប្រសិនជាមិនប្រើ "ណា" ទេ នោះក៏ត្រូវដាក់ពាក្យឲ្យពេញថា: "ស្ត្រីនេះឬជាប្រពន្ធរបស់អ្នក? បុរសនេះឬជាប្តីរបស់នាង? ។

"អ្វី" នេះក៏ជាពាក្យបុច្ឆាសព្វនាម ព្រោះជាពាក្យសម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗ គ្រប់យ៉ាង ហើយមានអាការៈ

www.elibraryofcambodia.org

ជាសេចក្ដីងឿងឆ្ងល់ឲ្យដេញដោលសួរ, ដូចពាក្យថា: អ្វីម្នាក់? អ្វីកន្ទាំង? អ្វីស្រែកៗ ក្នុងប្រយោគទាំង ៣ នេះ ប្រសិនបើយើង មិនប្រើពាក្យ "អ្វី" នេះទេ ក៏ត្រូវដាក់ពាក្យឲ្យពេញម.ថា: មនុស្សម្នាក់ឬ? ឬសត្វម្នាក់? សួរមនុស្ស ឬសួរសត្វកន្ទាំង ? មនុស្ស ឬសត្វស្រែក ? ៗ

"អី" នេះក៏ជាពាក្យបុច្ឆាសព្វនាមដែរ ព្រោះជាពាក្យ សម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាង ហើយ មានអាការជាសេចក្ដីមន្ទិលសង្ស័យនាំឲ្យសាកសួរ ដូចពាក្យថា: "អីនេះ? អីហ្នឹង? អី?" ៗ ក្នុងប្រយោគទាំងនោះ បើយើងមិនប្រើ ពាក្យ "អី" នេះទេ នោះក៏យើងត្រូវដាក់ពាក្យឲ្យពេញម.ថា: "មនុស្ស ឬសត្វនេះ? មនុស្ស ឬសត្វហ្នឹង? មនុស្សឬៗសត្វ?" ៗ

"ថី" នេះក៏ជាពាក្យបុច្ឆាសព្វនាមមួយដែរ ព្រោះជាពាក្យ សម្រាប់ប្រើជួសឈ្មោះ មនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាងបាន ហើយ មានអាការៈ ជាសេចក្ដីមន្ទិលសង្ស័យនាំឲ្យសួរដេញដោល ដូច ពាក្យថា: ថី? ថីហ្នឹង? ថីគឺដូល? ថីគឺយំ?" ៗ

"ថ្វី" នេះក៏ជាពាក្យបុច្ឆាសព្វនាមមួយដែរ ព្រោះជាពាក្យ

www.elibraryofcambodia.org

សម្រាប់ប្រើជួស មនុស្ស, សត្វ ឬអ្វីៗគ្រប់យ៉ាងបាន ហើយមានអាការៈជាសេចក្ដីមន្ទិលសង្ស័យនាំឲ្យសាកសួរ ដូចពាក្យថា: ថ្វី? ថ្វីក៏យំ? ថ្វីក៏សើច? ក្នុងប្រយោគទាំង ៣ នេះ ប្រសិនបើយើងមិនប្រើពាក្យ "ថ្វី" នេះទេ នោះក៏ត្រូវដាក់ឲ្យពេញពាក្យម.ថា: មានរឿងអ្វី? មានហេតុដូចម្ដេចបានជាយំ? មានហេតុយ៉ាងណាបានជាសើច? ។

"ម៉េច" នេះក៏ជាពាក្យបុច្ឆាសព្វនាមមួយទៀតដែរ ព្រោះជាពាក្យសម្រាប់ប្រើជួស មនុស្ស, សត្វ ឬអ្វីៗទាំងពួងបាន ហើយមានអាការៈជាសេចក្ដីមន្ទិលសង្ស័យនាំឲ្យដេញដោលសួរ ដូចពាក្យថា: ម៉េច? ម៉េចទៅ? ម៉េចហ្នឹង? ។ ក្នុងប្រយោគទាំង ៣ នេះ ប្រសិនបើយើងមិនប្រើពាក្យ "ម៉េច" នេះជួសទេ នោះក៏ត្រូវ. ពាក្យផ្សេងដាក់ឲ្យពេញម.ថា: រឿងនោះយ៉ាងណា? រឿងនោះយ៉ាងណាទៅហើយ? រឿងនោះដូចម្ដេចបានជាយ៉ាងនេះ? ។

"ម្ដេច" នេះក៏ទុកជាពាក្យបុច្ឆាសព្វនាមមួយដែរ ព្រោះជាពាក្យសម្រាប់ប្រើជួស មនុស្ស, សត្វឬ អ្វីៗទាំងពួងគ្រប់យ៉ាងបាន ហើយជាពាក្យមានអាការៈជាសេចក្ដីងឿងឆ្ងល់នាំឲ្យសួរពិតត្បិតដូច

www.elibraryofcambodia.org

ពាក្យថា៖ ម្តេច? ម្តេចទៅ? ម្តេចទៅអេះ? ម្តេចទៅហ្ន៎? ។ គួរ ប្រយោគទាំង ៤ នេះ ប្រសិនបើយើងមិនប្រើពាក្យ "ម្តេច" នេះទេ នោះគឺត្រូវ.ពាក្យដទៃផ្សេងក្រៅពីនេះយ.ម.ដាក់ឱ្យពេញ ថា៖ រឿងហ្នឹងយ៉ាងណា? រឿងនោះយ៉ាងណាទៅ? រឿងនោះយ៉ាងណាទៅអេះ? រឿងនោះយ៉ាងណាទៅហ្ន៎? ។ ចាហរណាខែ ពាក្យទាំង៣ម៉ាត់នេះ សុទ្ធតែជាពាក្យបុច្ឆាសព្វនាមទាំងអស់ ព្រោះនៅខាងដើមពាក្យឯទៀតៗ ហើយជាពាក្យសួរទៀតផងៗ ពាក្យបុច្ឆាសព្វនាមនឹងបុច្ឆាគុណសព្ទ ដែលបានរៀនម.ហើយនោះ ដូចគ្នាសុទ្ធសាធតែម្តង បើមិនពិនិត្យឱ្យមែនទែនទេ ក៏អាចនឹងច្រឡំគ្នាទៅបាន ដូច្នេះ រមៀនទាំងឡាយ! ត្រូវសង្កេតថា៖ ពាក្យបុច្ឆាគុណសព្ទត្រូវមានពាក្យអ្វីដទៃនៅខាងដើម ដូចពាក្យ "ណា" នេះ ត្រូវមានពាក្យអ្វីដទៃ[illegible] ដូចជា៖ ស្រីណា? ប្រុសណា? អ្នកណា? [illegible]? ជាដើម ។ ឯពាក្យបុច្ឆាសព្វនាមនេះ[illegible]នោះ ។ ដូស ច្រើនៗ តែម្តងដូចជា៖ [illegible]នរបស់អ្នក? ណាគេត្រូវបស់ខាង? [illegible]? ម៉េចទៅ

www.elibraryofcambodia.org

[illegible]

## សំណួរ[illegible]ទី ១៣

១–[illegible]ថា បុព្វសព្វនាម? អធិប្បាយទៅមើល!

២–ពាក្យថា "បុព្វ" ប្រែថាម៉េច? បុព្វសព្វនាមប្រែយ៉ាងណា? ក្នុងទីនេះ សំដៅសេចក្ដីដូចម្ដេច?

៣– ពាក្យសម្រាប់ប្រើក្នុងបុព្វសព្វនាមមានប៉ុន្មានម៉ាត់? អ្វីខ្លះ? ចូររាប់?

៤–"ណា" ជាពាក្យអ្វី? សម្រាប់ប្រើដូចអ្វី? ឧទាហរណ៍ដូចម្ដេចខ្លះ?

៥-"ណា" ដូចម្ដេចជាបុព្វសព្វនាម? ដូចម្ដេចជាបុព្វគុណសព្ទ?

៦–ពាក្យថា "អ្វី" នេះសម្រាប់ប្រើដូចអ្វី? ដូចឧទាហរណ៍យ៉ាងណា?

៧–"អ្វី" យ៉ាងណាជាបុព្វសព្វនាម? យ៉ាងណាជាបុព្វគុណសព្ទ?

៧–ពាក្យថា "អី" នេះសម្រាប់ប្រើដូចអ្វី? ដូចឧទាហរណ៍

www.elibraryofcambodia.org

រណា យ៉ាងណា ?

៩—"អី" យ៉ាងណាជាបុព្វសព្ទនាម ? យ៉ាងណាជាបុព្វ-គុណសព្ទ ?

១០—ពាក្យថា "ថី" នេះប្រើក្នុងទីដូចម្ដេច ? ឧទាហរណ៍យ៉ាងណាខ្លះ ?

១១—"ថី" យ៉ាងម៉េចជាបុព្វសព្ទនាម ? យ៉ាងម៉េចជាបុព្វ-គុណសព្ទ?

១២ ពាក្យថា "ថ្វី" នេះជាពាក្យដូចម្ដេច? ប្រើក្នុងទីណា? ឧទាហរណ៍យ៉ាងណា?

១៣—"ថ្វី" ដូចម្ដេចជាបុព្វសព្ទនាម ? ដូចម្ដេចជាបុព្វ-គុណសព្ទ ?

១៤—ពាក្យថា "ម៉េច" នេះ ជាពាក្យប្រើដូចអ្វីបានខ្លះ ? ឧទាហរណ៍យ៉ាងណាខ្លះ ?

១៥—"ម៉េច" ម៉េចជាបុព្វសព្ទនាម ? ម៉េចជាគុណសព្ទ?

១៦—ពាក្យថា "ម្ដេច" នេះជាពាក្យអ្វី? ប្រើក្នុងទីណា? ឧទាហរណ៍យ៉ាងណាខ្លះ ?

www.elibraryofcambodia.org

១៧– "ម្ដេច" នេះមើលជាបុច្ឆាសព្វនាម? មើលជាបុច្ឆាគុណសព្ទ ?

១៨-ពាក្យបុច្ឆាសព្វនាម និងពាក្យបុច្ឆាគុណសព្ទ ផ្សេងគ្នាប្តូចម្ដេចគ្នា?

១៩–តើមើល ទើបដឹងបានបស្លាក់បានថា ពាក្យនេះជាពាក្យបុច្ឆាសព្វនាម? ពាក្យនេះជាពាក្យបុច្ឆាគុណសព្ទ ?

២០– ឧទាហរណ៍ថា: អ្នកណាដើរនុ៎ះ? ឯណាផ្ទះរបស់លោក? ណាល្អ? ណាស្រុកជាងណា? នេះពាក្យណាជាបុច្ឆាសព្វនាម? ណាជាពាក្យបុច្ឆាគុណសព្ទ? ព្រោះហេតុអ្វី ?

## ៨–សាមីកសព្វនាម (Le pronom possessif)

ពាក្យដែលសម្រាប់ប្រើចេញជំនួសឈ្មោះរបស់នាម ដែលជារបស់អ្នកនិយាយ របស់អ្នកដែលយើងនិយាយជាមួយផង និងរបស់អ្នកដែលយើងនិយាយដល់ ពាក្យបែបនេះឯង ហៅថា សាមីកសព្វនាម គឺសព្វនាមដែលតាក់តែងជាម្ចាស់របស់(Le pronom po-

www.elibraryofcambodia.org

ssessif) ។ កាលបើយើងញែកចេញឲ្យដាច់ពីគ្នាក៏បានជា ២ ពាក្យគឺ សាមិក ១ ពាក្យ, សព្វនាម ១ ពាក្យ ។ "សាមិក" ប្រែថា: "ម្ចាស់របស់ខ្ញុំ, អ្នកជាម្ចាស់របស់, ជនជាម្ចាស់របស់" បើរួមជាសាមិក-សព្វនាមហើយ ក៏ប្រែបានសេចក្ដីថា: "ពាក្យសម្រាប់ប្រើជួសឈ្មោះរបស់ជនជាម្ចាស់របស់" ។ ពាក្យសម្រាប់ប្រើក្នុងសាមិក-សព្វនាមនេះ មាន ១០ ពាក្យគឺ ជាឯកវចនៈ ៥ ពាក្យ, ជាពហុ-វចនៈ ៥ ពាក្យ ពាក់ជាគូ ៗ គ្នាដូច្នេះ:

| | |
|---|---|
| ផងខ្ញុំ | ផងយើង |
| ផងអ្នក | ផងឯង |
| ផងគេ | ផងគេ ឬ ផងគេទាំងឡាយ |
| ផងគី | ផងគី ឬ ផងគាត់ទាំងឡាយ |
| ផងវា | ផងឡា ឬ ផងវាទាំងឡាយ |

បណ្ដាពាក្យសាមិកសព្វនាមទាំង ៨ យ៉ាងនេះ, ពាក្យថា: "ផងខ្ញុំ" នេះ ជាពាក្យសាមិកសព្វនាម ទី ១ ជាឯកវចនៈ ប្រែថា: "ជារបស់ខ្ញុំ" ។ បានជាហៅថា សាមិកសព្វនាមនោះ ក៏ព្រោះពាក្យនេះគាប់ប្រើជួសឈ្មោះរបស់នាម ដែលជារបស់អ្នក

www.elibraryofcambodia.org

និយាយខ្លួនឯង ដូចពាក្យថា: "នេះផងខ្ញុំ, នេះស្រែផងខ្ញុំ, នេះមួកផងខ្ញុំ" ។ ក្នុងប្រយោគតាំង ៣ នេះ ប្រសិនបើយើង មិនប្រើពាក្យ "ផងខ្ញុំ" នេះដូសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថា: "ផ្ទះនេះជារបស់ខ្ញុំ! ស្រែនេះជារបស់ខ្ញុំ! មួកនេះជារបស់ខ្ញុំ!" ។

"ផងយើង" នេះជាពាក្យសាមិកសព្វនាមទី ១ ជាពហុវចនៈ ប្រែថា: "ជារបស់យើង" បានជាហៅថា សាមិកសព្វនាមនោះ ក៏ព្រោះពាក្យនេះអាចប្រើជួសឈ្មោះរបស់ទាំងដែលជារបស់អ្នកនិយាយខ្លួនឯង តែអ្នកនិយាយក្នុងទីនេះ ច្រើននាក់ ឬជាអ្នកមានបុណ្យ មានបណ្ដាស័ក្តិជាងអ្នកស្ដាប់ ឬអ្នកដែលនិយាយជាមួយផង និងអ្នកដែលនិយាយដល់ ដូច្នេះ បានជាថា "ផងយើង" ។ បើប្រែចេញទៅទៀតក៏ប្រែថា: "ផងខ្ញុំទាំងឡាយ" ដូចពាក្យថា: "ផ្ទះយើងឬ? សំពត់ផងយើងឬ? គោផងយើងឬ?" ។ ក្នុងប្រយោគតាំង ៣ នេះ ប្រសិនបើយើងមិនប្រើពាក្យ "ផងយើង" នេះដូសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថា: "ផ្ទះអម្បាលនេះជារបស់យើងឬមិនមែន? សំពត់នេះជារបស់យើងឬមិនមែន? គោនេះជារបស់យើងឬមិនមែន?" ។

www.elibraryofcambodia.org

"ផងអ្នក" នេះជាពាក្យសាមិកសព្វនាមទី ២ជាឯកវចនៈប្រែថា "ជារបស់អ្នក" បានជាហៅថាសាមិកសព្វនាមនោះ ក៏ព្រោះពាក្យនេះ អាចប្រើជួសឈ្មោះរបស់នាមដែលជារបស់អ្នកដែលយើងនិយាយជាមួយផង តែក្នុងទីនេះ អ្នកនិយាយជាមួយនឹងយើងតែម្នាក់ ដូច្នេះបានជាថា "ផងអ្នក" ដូចពាក្យថា: "នេះផងអ្នកហើយ! នេះសៀវភៅផងអ្នក! នេះកៅអីផងអ្នកឬ?"ៗ ក្នុងប្រយោគទាំង ៣ នេះ ប្រសិនបើយើងមិនប្រើពាក្យ "ផងអ្នក" នេះជួសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថា: "តុនេះជារបស់អ្នកហើយ! សៀវភៅនេះជារបស់អ្នក! កៅអីនេះជារបស់អ្នកឬ?"ៗ

"ផងគេ" នេះក៏ជាពាក្យសាមិកសព្វនាមទី ២ ដែរ ប៉ុន្តែជាពហុវចនៈ ប្រែថា: "ជារបស់គេ" បានជាហៅថា សាមិកសព្វនាម នោះ ក៏ព្រោះពាក្យនេះអាចប្រើជួសឈ្មោះរបស់នាមដែលជារបស់អ្នកដែលយើងនិយាយជាមួយផង តែក្នុងទីនេះអ្នកនិយាយជាមួយនឹងយើងច្រើននាក់ ដូច្នេះបានជាថា "ផងគេ" បើប្រែពេញពេលទៀត ក៏ប្រែថា "ជារបស់អ្នកទាំងឡាយ" ដូចពាក្យថា:

ផ្ទះ? មនោទ? នេះមិនមែនខ្ពុលផងគេឬ? ផងគេល្អឬទេ?"ៗ

www.elibraryofcambodia.org

ក្នុងប្រយោគទាំង ៣ នេះ ប្រសិនបើយើងមិនប្រើពាក្យ "ផងគេ" នេះជួសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថា: "វត្ថុនេះជារបស់ដទៃមែនទេ? នេះមិនមែនផ្ដលជារបស់គេឬ? វត្ថុជារបស់គេល្អឬទេ? ។

"ផងគេ" នេះជាពាក្យសាមិកសព្វនាមទី ៣ ជាឯកវចនៈ ប្រែថា "ជារបស់គេ" បានជាហៅថា សាមិកសព្វនាម នោះក៏ព្រោះពាក្យនេះ អាចប្រើជួសឈ្មោះរបស់នាមដែលជារបស់អ្នកដែលយើងនិយាយដល់ តែក្នុងទីនេះអ្នកដែលយើងនិយាយដល់តែម្នាក់ ហើយជាបុរសផង ដូច្នេះបានជាថា "ផងគេ" ពាក្យនេះប្រើបានចំពោះតែនឹងមនុស្ស ហើយជាបុរស មិនប្រើទៅដល់ស្ត្រី ឬសត្វតិរច្ឆាននោះពុំបានឡើយ ដូចពាក្យថា: "នេះស្រែផងគេ! នេះគោផងគេ! នេះក៏គោផងគេដែរ ។ ក្នុងប្រយោគទាំង៣នេះ ប្រសិនបើយើងមិនប្រើ "ផងគេ" នេះជួសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញ: "នេះស្រែជារបស់គេ! នេះគោជារបស់គេ! នេះក៏គោជារបស់គេដែរ" ។

"ផងគេ" នេះក៏ជាពាក្យសាមិកសព្វនាម ទី៣ដែរ ប៉ុន្តែជា

www.elibraryofcambodia.org

ពហុវចនៈ ប្រែថា: "ជារបស់គេ" បានជាហៅថា សាមីកសព្វ-នាមនោះ ក៏ព្រោះពាក្យនេះ គាប់ប្រើជួសឈ្មោះរបស់នាមដែលជារបស់អ្នកដែលយើងនិយាយដល់ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់មានច្រើននាក់ ហើយជាបុរសផង ដូច្នេះបានជាថា "ផងគេ" នេះ បើប្រែចេញ ១ ជាន់ទៅទៀត ក៏ប្រែថា: "ផងគេទាំងឡាយ" ពាក្យនេះ ប្រើបានចំពោះតែនឹងមនុស្ស ហើយជាបុរសផង នឹងប្រើឲ្យទៅដល់ស្ត្រី ឬសត្វតិរច្ឆាននោះពុំបានឡើយ ដូចពាក្យថា: "នេះផងគេហើយមែនទេ? នេះផងគេ ឬមិនមែន? ផងគេនៅឯណា?" ។ ក្នុងប្រយោគទាំង៣នេះ ប្រសិនបើយើងមិនប្រើពាក្យ "ផងគេ" នេះជួសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថា: "វត្ថុនេះជារបស់គេហើយ មែនទេ? វត្ថុនេះជារបស់គេ ឬមិនមែន? វត្ថុជារបស់គេនៅឯណា?" ។

"ផងគី" នេះជាពាក្យសាមីកសព្វនាមទី ៣ ជាឯកវចនៈដែរ ប៉ុន្តែប្រើបានចំពោះតែនឹងមនុស្សស្ត្រី ប្រែថា "ជារបស់ស្ត្រី" បានជាហៅថា សាមីកសព្វនាម នោះក៏ព្រោះពាក្យនេះ គាប់ប្រើជួសឈ្មោះរបស់នាមដែលជារបស់អ្នកដែលយើងនិយាយដល់

www.elibraryofcambodia.org

តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់តែម្នាក់ ហើយជាស្ត្រីផង ដូច្នេះបានជាថា: "ផងគី" ពាក្យនេះប្រើបានចំពោះតែទីងមនុស្ស ហើយជាស្ត្រី ទីងប្រើទូទៅដល់ប្រុស ឬសត្វតិរច្ឆាននោះពុំបានឡើយ ដូចពាក្យថា: "នេះផងគីឬ? ហ្នឹងផងគីហើយ! អ្នកណាយក ផងគីទៅ?" ។ ក្នុងប្រយោគទាំង៣ នេះ ប្រសិនបើយើងមិនប្រើពាក្យ "ផងគី" នេះដូសទេ នោះយើងគឺត្រូវផ្លាស់ប្រយោគជាថ្មីវិញថា: "វត្ថុនេះជារបស់គីឬ? ហ្នឹងរបស់គីហើយ! អ្នកណាយកវត្ថុ របស់គីទៅ" ។

"ផងគី" នេះជាពាក្យសាមិកសព្វនាមទី ៣ ជាពហុវចនៈដែរ ប៉ុន្តែប្រើបានចំពោះតែទីងមនុស្សស្ត្រី ប្រែថា "ជារបស់គី" បានជាហៅថា សាមិសកសព្វនាមនោះ ក៏ព្រោះពាក្យនេះ គាប់ប្រើជួសឈ្មោះរបស់នាម ដែលជារបស់អ្នកដែលយើងនិយាយដល់ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់មានច្រើននាក់ ហើយជាស្ត្រីផង ដូច្នេះបានជាថា "ផងគី" នេះបើប្រែចេញឲ្យជាប់ទៅទៀត គឺប្រែបានថា: "ផងគីទាំងឡាយ" ពាក្យនេះ ប្រើបានចំពោះតែទីងមនុស្ស ហើយជាស្ត្រីផង ទីងប្រើទូទៅដល់ប្រុស ឬសត្វតិ-

www.elibraryofcambodia.org

វេញ្ញាននោះពុំបានទៀង ដូចពាក្យថា៖ “ផងគីប្អូនឯង? ផងគីនៅឯណា? ផងគីអ្នកណាឃ.ទៅ?” ។ ក្នុងប្រយោគទាំងពីរនេះ ប្រសិនបើយើងមិនប្រើពាក្យ “ផងគី” នេះជួសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថា៖ “ជារបស់គីប្អូនឯង? តែជារបស់គីនៅឯណា? តែជារបស់គីអ្នកណាឃ.ទៅ?” ។

“ផងក់” នេះក៏ជាពាក្យសាមីកសព្វនាមទីពីជាឯកវចនៈដែរ ប៉ុន្តែប្រើបានចំពោះតែទីងសក្តិវេញ្ញាន ប្រែថា “ជារបស់ក់” បានជាហៅថា សាមីកសព្វនាមៈនោះ ក៏ព្រោះពាក្យនេះអាចប្រើជួសឈ្មោះរបស់នាម ដែលជារបស់អ្នកដែលយើងនិយាយដល់ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់តែម្នាក់ ហើយជាសក្តិវេញ្ញានផង ដូច្នេះបានជាថា៖ “ផងក់” ពាក្យនេះប្រើបានចំពោះតែទីងសក្តិវេញ្ញាន ហើយទីងរបស់ផ្សេងៗ មិនបានប្រើខ្ពស់ទៅដល់បុរស ឬស្ត្រីផងទេ ដូចពាក្យថា៖ “នេះផងក់? ហ្នឹងផងក់ហើយ! អ្នកណាឃ.ផងក់ទ្វាត់” ។ ក្នុងប្រយោគទាំងពីរនេះ ប្រសិនបើយើងមិនប្រើពាក្យ “ផងក់” នេះជួសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថា៖ “តែនេះជារបស់ក់ឬ?, តែហ្នឹងជារបស់

www.elibraryofcambodia.org

ក៏ហើយ! អ្នកណាយកវត្ថុជារបស់កំបុត?" ។

"ផងឡា" នេះក៏ជាពាក្យសាមីកសព្វនាមទី៣ជាពហុវចនៈដែរ ប៉ុន្តែប្រើបានចំពោះតែនឹងសត្វតិរច្ឆាន ប្រែថា "ជារបស់ឡា" បានជាហៅថា សាមីកសព្វនាមនោះ ក៏ព្រោះពាក្យនេះអាចប្រើជួសឈ្មោះរបស់នាមដែលជារបស់អ្នកដែលយើងនិយាយដល់ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់ មានច្រើននាក់ ហើយជាសត្វតិរច្ឆានផង ដូច្នេះបានជាថា "ផងឡា" នេះបើប្រែបញ្ច១ជាន់ទៅទៀត ក៏ប្រែបានថា "ជនកាំទាំងឡាយ" ពាក្យនេះប្រើបានចំពោះតែនឹងសត្វតិរច្ឆាន ហើយនឹងរបស់ផ្សេងៗប៉ុណ្ណោះ មិនបានប្រើឲ្យទៅដល់បុរស ឬស្ត្រីផងទេ ដូចពាក្យថាៈ "នេះកន្ទុយផងឡា! ជើងផងឡានៅឯណា ? ស្លាបផងឡាឬ?" ។ ក្នុងប្រយោគទាំង៣នេះ ប្រសិនបើយើងមិនប្រើពាក្យ "ផងឡា" នេះដូសទេ នោះយើងក៏ត្រូវផ្លាស់ប្រយោគជាថ្មីវិញថាៈ "នេះកន្ទុយជារបស់ឡា! ជើងជារបស់ឡានៅឯណា ? ស្លាបជារបស់ឡានៅឯណា ?" ។

## វិញ្ញាសាបទទី ១៤

---

១—ពាក្យយ៉ាងម៉េចដែលបានឈ្មោះថា សាមីកសព្វនាម ?

www.elibraryofcambodia.org

អធិប្បាយ ។

២– សាមិកសព្វនាម គឺសព្វនាមយ៉ាងម៉េច ?

៣– "សាមិក" ប្រែដូចម្ដេច ? "សាមិកសព្វនាម" ប្រែយ៉ាងណា ?

៤– ពាក្យសម្រាប់ប្រើក្នុងសាមិកសព្វនាម មានប៉ុន្មានម៉ាត់ ? ជាអ្វីប៉ុន្មាន ? អ្វីប៉ុន្មាន ? ពាក់ជាអ្វីដូចម្ដេច ?

៥– ពាក្យថា "ផងខ្ញុំ" ជាអ្វី ? ប្រែថាម៉េច ? ហេតុអ្វីបានជាហៅថាសាមិកសព្វនាម ? ដូចឧទាហរណ៍យ៉ាងណា ?

៦– បើយើងមិនប្រើពាក្យ "ផងខ្ញុំ" នេះដូសទេ ឧទាហរណ៍ទាំងនោះ ត្រូវផ្លាស់យ៉ាងម៉េចទៅវិញ ?

៧– ពាក្យថា "ផងយើង" ជាអ្វី ? ប្រែថាម៉េច ? ដូចម្ដេចបានជាហៅថាសាមិកសព្វនាម ? ដូចឧទាហរណ៍យ៉ាងណាខ្លះ ?

៨– បើយើងមិនប្រើពាក្យ "ផងយើង" នេះដូសទេ ឧទាហរណ៍ទាំងនោះត្រូវផ្លាស់ទៅជាយ៉ាងម៉េចទៅវិញ ?

៩– ពាក្យថា "ផងអ្នក" ជាអ្វី ? ប្រែថាម៉េច ? បានជាហៅថាសាមិកសព្វនាមនោះ ព្រោះហេតុអ្វី ? ដូចឧទាហរណ៍យ៉ាងណាខ្លះ ?

www.elibraryofcambodia.org

១០—បើយើងមិនប្រើពាក្យ "ផងអ្នក" នេះជួសទេ ឧទាហរ-ណ៍ទាំងនោះ ត្រូវផ្លាស់ទៅជាយ៉ាងណាទៅវិញ?

១១—ពាក្យថា: "ផងគេ" ជាអ្វី? ប្រែថាម៉េច? បានជាហៅថា សាមិកសព្វនាមនោះព្រោះហេតុអ្វី? ដូចឧទាហរណ៍ យ៉ាងណាខ្លះ?

១២—បើយើងមិនប្រើពាក្យ "ផងរក់" នេះជួសទេ ឧទាហរ-ណ៍ទាំងនោះ ត្រូវផ្លាស់ទៅជាយ៉ាងណាទៅវិញ?

១៣—ពាក្យថា "ផង៖គេ" ជាអ្វី? ប្រែថាម៉េច? ដូចម្តេចបាន ជាហៅថាសាមិកសព្វនាម? ពាក្យនេះមានវិធីកំណត់ប្រើដូចម្តេច? ដូចឧទាហរណ៍យ៉ាងណា?

១៤—បើយើងមិនប្រើពាក្យ "ផងគេ" នេះជួសទេ ឧទា-ហរណ៍ទាំងនោះ ត្រូវផ្លាស់ជាយ៉ាងណាទៅវិញ?

១៥—ពាក្យថា "ផងគេ" ជាអ្វី? ប្រែថាម៉េច? ដូចម្តេចបាន ជាហៅថា សាមិកសព្វនាម? ពាក្យនេះមានវិធីកំណត់ប្រើដូច ម្តេច? ឧទាហរណ៍យ៉ាងណាខ្លះ?

១៦—បើយើងមិនប្រើពាក្យ "ផងគេ" នេះជួសទេ ឧទាហរ-ណ៍ទាំងនោះ ត្រូវផ្លាស់ទៅជាយ៉ាងណាទៅវិញ?

www.elibraryofcambodia.org

១៧–ពាក្យថា "ផងគី" ជាអ្វី? ប្រែថាម៉េច? ដូចម្ដេចបានជាហៅថា សាមិកសព្ទនាម? ពាក្យនេះមានវិធីកំណត់ប្រើដូចម្ដេច? ឧទាហរណយ៉ាងណាខ្លះ?

១៨–បើយើងមិនប្រើពាក្យ "ផងគី" នេះដូសទេ ឧទាហរណតាំងនោះ ត្រូវផ្លាស់ទៅជាយ៉ាងណាទៅវិញ?

១៩–ពាក្យថា "ផងគី" ជាអ្វី? ហេតុអ្វីបានជាហៅថា សាមិកសព្ទនាម? ពាក្យនេះមានវិធីកំណត់ប្រើដូចម្ដេច? ឧទាហរណយ៉ាងណាខ្លះ?

២០–បើយើងមិនប្រើពាក្យ "ផងគី" នេះដូសទេ ឧទាហរណតាំងនោះ ត្រូវផ្លាស់ទៅជាយ៉ាងណាទៅវិញ?

២១–ពាក្យថា "ផងក់" ជាអ្វី? ប្រែថាម៉េច? ដូចម្ដេចបានជាហៅថា សាមិកសព្ទនាម? ពាក្យនេះមានវិធីកំណត់ប្រើដូចម្ដេចខ្លះ? ឧទាហរណយ៉ាងណា?

២២–បើយើងមិនប្រើពាក្យ "ផងក់" នេះដូសទេ ឧទាហរណតាំងនោះ ត្រូវផ្លាស់ទៅជាយ៉ាងណាទៅវិញ?

២៣ ពាក្យថា "ផងឡា" ជាអ្វី? ប្រែថាម៉េច? ហេតុអ្វីបាន

www.elibraryofcambodia.org

ជាហៅថា សាមីកសព្វនាម? ពាក្យនេះមានដែនកំណត់ប្រើដូចម្ដេច? ឧទាហរណ៍យ៉ាងណាខ្លះ?

៦៤–បើយើងមិនប្រើពាក្យ "ផងឲ្យ" នេះជួសទេ ឧទាហរណ៍ទាំងនោះ ត្រូវផ្លាស់ទៅជាយ៉ាងណាទៅវិញ?

## ៤– បរិវត្តសព្វនាម (Le pronom réflexe)

ពាក្យដែលសម្រាប់ប្រើប្រាប់បញ្ជាក់ ម.រ.ឈ្មោះរបស់នាម ដែលជាអ្នកនិយាយ, របស់អ្នកដែលយើងនិយាយជាមួយផង និង របស់អ្នកដែលយើងនិយាយដល់ ដើម្បីឲ្យដឹងប្រាកដថា: អ្នកដែលនិយាយនោះធ្វើអ្វីធ្វើខ្លួនឯង មិនបានប្រើអ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួស; អ្នកដែលយើងនិយាយជាមួយផងនោះ ធ្វើអ្វីធ្វើខ្លួនឯង មិនបានប្រើអ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួស; អ្នកដែលយើងនិយាយដល់នោះ ធ្វើអ្វីធ្វើខ្លួនឯង មិនបានប្រើអ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួស ពាក្យយ៉ាងនេះឯង ហៅថា បរិវត្តសព្វនាម (Le pronom réflexe) គឺសព្វនាមដែលប្រើជាកម្មរបស់ប្រធានក្នុងប្រយោគ ពាក្យសម្រាប់ប្រើក្នុងបរិវត្តសព្វនាមនេះមាន ១០ ពាក្យ ជាឯកវចនៈ: ៥ ពាក្យ, ជាពហុវចនៈ: ៥ ពាក្យ

www.elibraryofcambodia.org

ចាត់ជាគូ ៗ ដូច្នេះ :

| | |
|---|---|
| ខ្លួនខ្ញុំ | ខ្លួនយើង |
| ខ្លួនអ្នក | ខ្លួនឯង ឬ ខ្លួនអ្នកទាំងឡាយ |
| ខ្លួនគេ | ខ្លួនគេ ឬ ខ្លួនគេទាំងឡាយ |
| ខ្លួនគាត់ | ខ្លួនគាត់ ឬ ខ្លួនគាត់ទាំងឡាយ |
| ខ្លួនវា | ខ្លួនវា ឬ ខ្លួនវាទាំងឡាយ |

បណ្ដាពាក្យបរលក្ខសព្វនាមទាំង ១០ ម៉ាត់នេះ ពាក្យថា:

"ខ្លួនខ្ញុំ" នេះជាពាក្យបរលក្ខសព្វនាមទី ១ ជាឯកវចនៈ បានជាហៅថា បរលក្ខសព្វនាម ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ឈ្មោះរបស់អ្នកដែលនិយាយ ដើម្បីប្រើប្រាប់ឱ្យដឹងថា: អ្នកដែលនិយាយនោះឯង ធ្វើអ្វីៗខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួសឡើយ តែក្នុងទីនេះ អ្នកដែលនិយាយតែម្នាក់ ដោយហេតុដូច្នេះបានជាថា "ខ្លួនខ្ញុំ" គឺប្រើជាកម្មរបស់ប្រធាន "ខ្ញុំ" ក្នុងប្រយោគ ដូចពាក្យថា: "ខ្ញុំសម្លាប់ខ្លួនខ្ញុំ, ខ្ញុំភ្នកក្នុងវ័នងឹកខ្លួនខ្ញុំ, ខ្ញុំឃើញខ្លួនខ្ញុំ" ។

"ខ្លួនយើង" នេះជាពាក្យបរលក្ខសព្វនាម ទី១ ជាពហុ-

www.elibraryofcambodia.org

វចនៈ បានជាហៅថា បុរសសព្វនាមនោះ ក៏ព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់ ទៅឈ្មោះរបស់អ្នកដែលនិយាយ ដើម្បីឲ្យដឹងថា អ្នកដែលនិយាយនោះឯង ធ្វើអំពើខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួសឡើយ តែក្នុងទីនេះ អ្នកដែលនិយាយមានច្រើននាក់ ដោយហេតុដូច្នេះបានជាថា "ខ្លួនយើង" គឺប្រើជាកម្មរបស់ប្រធាន "យើង" ក្នុងប្រយោគដូចពាក្យថា: "យើងឲ្យខ្លួនយើង, យើងទៅខ្លួនយើង, យើងធ្វើខ្លួនយើង យើងប្រកែកថា មិនដឹង ធ្វើម៉េចនឹងកើត!" ។

"ខ្លួនអ្នក" នេះជាពាក្យ បុរសសព្វនាមទី ២ ជាឯកវចនៈ: បានជាហៅថា បុរសសព្វនាមនោះ ក៏ព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់ ទៅឈ្មោះរបស់អ្នកដែលនិយាយជាមួយនឹងយើង ដើម្បីឲ្យដឹងជាក់ថា អ្នកដែលនិយាយជាមួយនឹងយើងនោះ ធ្វើអំពើខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួសឡើយ តែក្នុងទីនេះ អ្នកដែលនិយាយជាមួយនឹងយើងមានតែម្នាក់ ដូច្នេះបានជាថា: "ខ្លួនអ្នក" គឺប្រើជាកម្មរបស់ប្រធាន "អ្នក" ក្នុងប្រយោគដូចពាក្យថា: "អ្នកនិយាយខ្លួនអ្នក, អ្នកដេរ

www.elibraryofcambodia.org

ខ្លួនអ្នក, អ្នកស្ដីខ្លួនអ្នក ម៉េចមិនដឹង ?" ។

"ខ្លួនឯង" នេះជាពាក្យប្រើលេខសព្វនាមទី ២ ជាឯកវចនៈ បានជាហៅថា បុរិសសព្វនាមនោះ ក៏ព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់ ទៅលើឈ្មោះរបស់អ្នកដែលនិយាយជាមួយនឹងយើងនោះ ដើម្បីឲ្យដឹងជាក់ប្រាកដថា អ្នកដែលនិយាយជាមួយនឹងយើងនោះ ពើអើយខ្លួនឯងនឹង មិនបានប្រើ ឬបន្ថែមអ្នកឯទៀតក្រៅពីខ្លួនឡើយ វីតែក្នុងវិធីនេះ អ្នកដែលនិយាយជាមួយនឹងយើងមានច្រើននាក់ [illegible] "ខ្លួនឯង" គឺប្រើជាកម្មរបស់ប្រធាន [illegible] ពាក្យថា: "ឯងដើរខ្លួនឯង, ឯងនិយាយខ្លួន [illegible] ណាហ៎!" ។

"ខ្លួនគេ" នេះជា [illegible] ជាឯកវចនៈ បានជាហៅថា បុរិសសព្វនាមនោះ ក៏ព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់ ទៅលើឈ្មោះរបស់អ្នកដែលយើងនិយាយដល់ ដើម្បីឲ្យដឹងជាក់ប្រាកដថា: អ្នកដែលយើងនិយាយដល់នោះ ពើអើយខ្លួនឯង មិនបានប្រើ ឬបន្ថែមអ្នកឯទៀតក្រៅពីខ្លួនឲ្យពើជួសឡើយ វីតែក្នុងវិធីនេះ អ្នកដែលយើងនិយាយដល់មានតែម្នាក់

www.elibraryofcambodia.org

ដូច្នេះបានជាថា "ខ្លួនគេ" គឺប្រើជាកម្មរបស់ប្រធាន "គេ" ក្នុងប្រយោគ ហើយពាក្យនេះ ប្រើបានចំពោះតែនឹងមនុស្សប្រុសប៉ុណ្ណោះ មិនបានប្រើខ្លួនទៅដល់មនុស្សស្រី ឬសត្វតិរច្ឆាន ឬក៏ទ្រព្យរបស់អ្វី ៗ សព្វយ៉ាងនោះឡើយ ដូចពាក្យថា: "គេសរសេរខ្លួនគេ, គេប្រាប់ខ្លួនគេ, គេប្រព្រឹត្តអាក្រក់ខ្លួនគេខ្ញុំមិនបានដឹងផង" ។

"ខ្លួនគេ" នេះជាពាក្យវេវលេក្ខសព្វនាមទី ៣ ជាពហុវចនៈ បានជាហៅថា វេវលេក្ខសព្វនាមនោះ ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ ទៅលើឈ្មោះរបស់អ្នកដែលយើងនិយាយដល់ ដើម្បីឲ្យដឹងជាក់ប្រាកដថា អ្នកដែលយើងនិយាយដល់នោះ ធ្វើអំពើខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួសឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់មានច្រើននាក់ ដូច្នេះបានជាថា "ខ្លួនគេ" គឺប្រើជាកម្មរបស់ប្រធាន "គេ" ក្នុងប្រយោគ ហើយពាក្យនេះ ប្រើបានចំពោះតែនឹងមនុស្សប្រុសប៉ុណ្ណោះ មិនបានប្រើខ្លួនទៅដល់មនុស្សស្រី ឬសត្វតិរច្ឆាន ឬក៏ទ្រព្យរបស់អ្វីៗ សព្វយ៉ាងនោះឡើយ ដូចពាក្យថា: "គេស្អប់ខ្លួនគេ, គេជេញខ្លួនគេ, គេមើលខ្លួនគេ" ។

www.elibraryofcambodia.org

"ខ្លួនគី" នេះជាពាក្យរេវលក្ខសព្វនាមទី ៣ ជាឯកវចនៈផង បានជាហៅថា រេវលក្ខសព្វនាមនោះ ក៏ព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់នៅ ឈ្មោះរបស់អ្នកដែលយើងនិយាយដល់ ដើម្បីឲ្យដឹងជាក់ប្រាកដថា អ្នកដែលយើងនិយាយដល់នោះ ធ្វើអ្វីធ្វើខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីនេះឲ្យធ្វើជួសឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់មានតែម្នាក់ ដូច្នេះបានជាថា "ខ្លួនគី" ប្រើជាកម្មរបស់ប្រធាន "គេ" ក្នុងប្រយោគ ហើយពាក្យនេះប្រើបានចំពោះតែនឹងមនុស្សប៉ុណ្ណោះ មិនបានទូទៅដល់មនុស្សប្រុស ឬបក្សីតិរច្ឆាន ឬក៏ទ្រព្យរបស់អ្វីៗសព្វយ៉ាងនោះឡើយ ដូចពាក្យថា: "គេ. ខ្លួនគី មានអ្នកណាទេ., គេជេរគេ ខ្លួនគី, គេស្រែកខ្លួនគី" ។

"ខ្លួនគី" នេះជាពាក្យរេវលក្ខសព្វនាមទី ៣ ជាពហុវចនៈផង បានជាហៅថា រេវលក្ខសព្វនាមនោះ ក៏ព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់នៅ ឈ្មោះរបស់អ្នកដែលយើងនិយាយដល់ ដើម្បីឲ្យដឹងជាក់ប្រាកដថា អ្នកដែលយើងនិយាយដល់នោះ ធ្វើអ្វីធ្វើខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួស

www.elibraryofcambodia.org

ឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់មានច្រើននាក់ ដូច្នេះបានជាថា "ខ្លួនគេ" គឺប្រើជាកម្មរបស់ប្រធាន "គេ" ក្នុងប្រយោគ ហើយពាក្យនេះប្រើបានចំពោះតែនឹងមនុស្សស្រីប៉ុណ្ណោះ មិនបានប្រើចំពោះដល់មនុស្សប្រុស ឬសត្វតិរច្ឆាន ឬក៏ទ្រព្យរបស់អ្វីៗសព្វយ៉ាងនោះឡើយ ដូចពាក្យថាៈ "គេហៅខ្លួនគេ បានជាគេមក.,គេយំខ្លួនគេ មានអ្នកណាយំ, គេសោកខ្លួនគេ បានជាគេដឹង។

"ខ្លួន[illegible]នេះជាពាក្យវេវចនសព្ទនាមទី ៣ ជាឯកវចនៈដែរ បានជាហៅថា វេវចនសព្ទនាមនោះ ក៏ព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់ទៅ.ឈ្មោះរបស់អ្នកដែលយើងនិយាយដល់ ដើម្បីឲ្យដឹងជាក់ច្បាស់ថា អ្ន[illegible]យើងនិយាយដល់នោះ ធ្វើអំពើខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួសឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់មានតែម្នាក់ ដូច្នេះបានជាថា "ខ្លួនវា" គឺប្រើជាកម្មរបស់ប្រធាន "វា" ក្នុងប្រយោគ ហើយពាក្យនេះប្រើបានចំពោះតែនឹងសត្វតិរច្ឆាន ឬទ្រព្យរបស់អ្វីៗ ផ្សេងៗ ប៉ុណ្ណោះ មិនយកទៅប្រើចំពោះមនុស្សប្រុស ឬស្រីនោះពុំសមគួរឡើយ ព្រោះចាត់ថាជាពាក្យមើល

www.elibraryofcambodia.org

ឆ្ងាយ ដូចពាក្យថា: "គាត់ទៅខ្លួនគាត់ មិនមានអ្នកណាយកគាត់ទេ, គាត់រត់ខ្លួនគាត់ មិនមានអ្នកណាដេញគាត់ទេ, គាត់ក្រោកខ្លួនគាត់ ឥតអ្នកណាលើកទេ ។

"ខ្លួនវា" នេះ គឺជាពាក្យបរៈលក្ខសព្វនាមទី៣ ជាពហុវចនៈដែរ បានជាហៅថា បរៈលក្ខសព្វនាមនោះ គឺព្រោះពាក្យនេះសម្រាប់ប្រើប្រាប់បញ្ជាក់ ទៅលើឈ្មោះរបស់អ្នកដែលយើងនិយាយដល់ ដើម្បីឲ្យដឹងជាក់ច្បាស់ថា អ្នកដែលយើងនិយាយដល់នោះ ធ្វើអីធ្វើខ្លួនឯង មិនបានប្រើ ឬបង្គាប់អ្នកឯទៀតក្រៅពីខ្លួនឲ្យធ្វើជួសឡើយ តែក្នុងវិធីនេះ អ្នកដែលយើងនិយាយដល់មានច្រើននាក់ ដូច្នេះបានជាថា "ខ្លួនវា" គឺប្រើជាកម្មរបស់ប្រធាន "វា" ក្នុងប្រយោគ ហើយពាក្យនេះប្រើបានចំពោះតែនឹងសត្វតិរច្ឆាន ឬក្រុមរបស់គ្នាៗ ផ្សេងៗ ប៉ុណ្ណោះ បើយកទៅប្រើចំពោះមនុស្សប្រុស ឬស្រីនោះ ពុំសមគួរឡើយ ព្រោះចាត់ថាជាពាក្យមើលងាយ ដូចប្រយោគថា: "វាស្លាប់ខ្លួនវា ឥតអ្នកណាសម្លាប់ទេ, វាដួលខ្លួនវា ឥតអ្នកណាផ្ដួលទេ, វាដេកខ្លួនវា ឥតអ្នកណាវាយដំទេ" ។

www.elibraryofcambodia.org

តាមក្បួនផ្សេងៗ ដែលបានអធិប្បាយរួចមក. ហើយនេះ យើងនឹងឃើញបានថា វេវលេក្ខសព្វនាម មានលិង្គ វចនៈ និងបុរស ដូចគ្នានឹងក្បួនប្រធាន ទំហើររបស់ប្រធានធ្វើដល់ខ្លួនឯងមិនមែនធ្វើឲ្យដល់អ្នកដទៃទេ, កិរិយាដែលប្រើជាមួយនឹងវេវលេក្ខសព្វនាម ដូច្នេះហៅថា វេវលេក្ខកិរិយា ។

## ឥក្ខាសភាពទី ១៨

១-ពាក្យយ៉ាងណាដែលបានឈ្មោះថា វេវលេក្ខសព្វនាម? អធិប្បាយ!

២. វេវលេក្ខសព្វនាម គឺសព្វនាមយ៉ាងម៉េច?

៣-ពាក្យសម្រាប់ប្រើក្នុងវេវលេក្ខសព្វនាមមានប៉ុន្មានម៉ាត់? ជាអ្វីប៉ុន្មាន? អ្វីប៉ុន្មាន? ចាត់ជាអ្វីដូចម្ដេច?

៤-ពាក្យថា "ខ្លួនខ្ញុំ" ជាអ្វី? ហេតុអ្វីបានជាហៅថា វេវលេក្ខសព្វនាម? ប្រើជាអ្វីក្នុងប្រយោគ? ដូចឧទាហរណ៍យ៉ាងម្ដេចខ្លះ?

៥-ពាក្យថា "ខ្លួនយើង" ជាអ្វី? ហេតុអ្វីបានជាហៅថា វេវលេក្ខសព្វនាម? ប្រើជាអ្វីក្នុងប្រយោគ? ដូចឧទាហរណ៍

www.elibraryofcambodia.org

ដូចម្ដេចខ្លះ ?

៦-ពាក្យថា "ខ្លួនអ្នក" ជាអ្វី? ហេតុអ្វីបានជាហៅថា វេវចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ដូចឧទាហរណ៍យ៉ាងណាខ្លះ ?

៧-ពាក្យថា "ខ្លួនឯង" ជាអ្វី? ហេតុអ្វីបានជាហៅថា វេវចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ឧទាហរណ៍ដូចម្ដេចខ្លះ?

៨-ពាក្យថា "ខ្លួនគេ" ជាអ្វី? ហេតុអ្វីបានជាហៅថា វេវចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ឧទាហរណ៍យ៉ាងណាខ្លះ ?

៩-ពាក្យថា "ខ្លួនគេ" ជាអ្វី? ហេតុម៉េចបានជាហៅថា វេវចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ឧទាហរណ៍ម៉េចខ្លះ? ប្រើបានចំពោះតែនឹងអ្វី?

១០-ពាក្យថា "ខ្លួនគី" ជាអ្វី? ហេតុៈម៉េចបានជាហៅថា វេវចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ឧទាហរណ៍ម៉េចខ្លះ? ប្រើបានចំពោះតែនឹងអ្វី?

១១-ពាក្យថា "ខ្លួនគី" ជាអ្វី?៕ ម៉េចបានជាហៅថា

www.elibraryofcambodia.org

វេវចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ឧទាហរណ៍ម្ដេចខ្លះ? ប្រើបានតែនឹងអ្វី? អ្វីទៀតប្រើមិនបាន?

១៦-ពាក្យថា "ខ្លួន" ជាអ្វី? ហេតុបានជាហៅថា វេវ-ចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ឧទាហរណ៍ដូចម្ដេចខ្លះ? ប្រើបានចំពោះតែនឹងអ្វី? ជាមួយនឹងអ្វីទៀតប្រើមិនបាន?

១៧-ពាក្យថា "ខ្លួនឯង" ជាអ្វី? ហេតុបានជាហៅថា វេវចនសព្ទនាម? ប្រើជាអ្វីក្នុងប្រយោគ? ឧទាហរណ៍ម្ដេចខ្លះ? ប្រើបានតែនឹងអ្វី? នឹងអ្វីទៀតប្រើមិនបាន?

១៨. លិង្គ, វចនៈ និងបុរស របស់វេវចនសព្ទនាម នោះ ដូចគ្នានឹងអ្វី?

១៩-កិរិយាដែលប្រើជាមួយនឹងវេវចនសព្ទនាមនេះ មានឈ្មោះដូចម្ដេច?

## ១០. ឯម្ពសសព្ទនាម (le pronom emphatique)

ពាក្យដែលសម្រាប់ប្រើភ្ជាប់បញ្ជាក់ប្រធាន ឬកម្មរបស់ប្រយោគ ដើម្បីឲ្យធ្ងន់សេចក្ដីរបស់វាក្រៃលែងឡើង ហៅថា ឯម្ពសសព្ទនាម (le pronom emphatique) នេះបានដល់ពាក្យ

www.elibraryofcambodia.org

ដែលសម្រាប់ប្រើប្រាប់បញ្ជាក់ ដល់អ្នកដែលនិយាយខ្លួនឯង, ដល់អ្នកដែលយើងនិយាយជាមួយនឹងអ្នកដែលយើងនិយាយដល់ គឺអ្នកដែលនិយាយនោះ ធ្វើ ក៏ប្រាប់បញ្ជាក់ថា ប្រាកដជាខ្លួនបានធ្វើ មិនមែនអ្នកដទៃក្រៅពីខ្លួនធ្វើឡើយ ។ អ្នកដែលយើងនិយាយជាមួយធ្វើ ក៏ប្រាប់បញ្ជាក់ថាប្រាកដជាខ្លួនបានធ្វើ មិនមែនអ្នកឯទៀតក្រៅពីខ្លួនធ្វើឡើយ, អ្នកដែលយើងនិយាយដល់នោះ ធ្វើ ក៏ប្រាប់បញ្ជាក់ថាប្រាកដជាខ្លួនបានធ្វើ មិនមែនអ្នកឯទៀតក្រៅពីខ្លួនធ្វើឡើយ ។ ពាក្យដែលសម្រាប់ប្រាប់បញ្ជាក់នេះឯងហៅថា ឯមួសសព្វនាម ។ ពាក្យដែលសម្រាប់ប្រើក្នុងឯមួស-សព្វនាមនេះ មាន១០ពាក្យគឺ ជាឯកវចនៈ ៥ ពាក្យ, ជាពហុ-វចនៈ៥ ពាក្យ ចាត់ជាគូៗ គ្នាដូច្នេះ :

ខ្ញុំឯង — យើងឯង

អ្នកឯង — ពេឯង

គេឯង — គេឯង

គ៏ឯង — គ៏ឯង

ពឯង — ឡាឯង

www.elibraryofcambodia.org

បណ្ដាពាក្យឯមួសសព្វនាមទាំង ១០ ម៉ាត់នេះ, ពាក្យថា:

"ខ្ញុំឯង" នេះជាពាក្យ ឯមួសសព្វនាមទី ១ ជាឯកវចនៈ ប្រែថា "ខ្ញុំប្រាកដ" ឬ "ប្រាកដជាខ្ញុំ" បានជាហៅថា ឯមួស-សព្វនាម ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលនិយាយនោះឯងពេញ មិនមែនអ្នកឯទៀតក្រៅពីនេះឡើយ តែក្នុងទីនេះ អ្នកដែលនិយាយនោះ តែម្នាក់ ដោយហេតុដូច្នេះ បានជាត្រូវប្រើ ពាក្យទី១ក្នុងគូទី ១ ថា "ខ្ញុំឯង" ដូចប្រយោគថា: "ខ្ញុំឯងបានឃើញគេដើរ, ខ្ញុំឯង ក៏ធ្លាប់និយាយដូច្នោះ, ខ្ញុំឯងបានប្រាប់ជាច្រើនលើកហើយ ។" ។

"យើងឯង" នេះជាពាក្យ ឯមួសសព្វនាមទី ១ ជាពហុវចនៈ ប្រែថា "យើងប្រាកដ" ឬ "ប្រាកដជាយើង" បានជាហៅថា ឯមួស-សព្វនាមនោះ ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលនិយាយនោះឯងពេញ មិនមែនអ្នកឯទៀតក្រៅពីនេះពេញឡើយ តែក្នុងទីនេះ អ្នកដែលនិយាយនោះមានច្រើននាក់ ដូច្នេះបានជាត្រូវប្រើពាក្យទី ២ ក្នុងគូទី ១ ថា "យើងឯង" ដូចប្រ-យោគថា: "យើងឯងក៏ល្មមតែធ្វើបានដែរ, យើងឯងក៏ធ្លាប់បាន

www.elibraryofcambodia.org

រៀនដែរ, យើងឯងមិនត្រូវការឡើយ" ។

"អ្នកឯង" នេះជាពាក្យឯមួសសព្វនាមទី ២ ជាឯកវចនៈ ប្រែថា "អ្នកប្រាកដ" ឬ "ប្រាកដជាអ្នក" បានជាហៅថា ឯមួសសព្វនាមនោះ គឺព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលនិយាយជាមួយនឹងយើងនោះឯងតែ មិនមែនអ្នកឯទៀតក្រៅពីនេះទេឡើយ តែក្នុងទីនេះ អ្នកដែលនិយាយជាមួយនឹងយើងនោះ មានតែម្នាក់ ដោយហេតុដូច្នេះ បានជាត្រូវប្រើពាក្យទី ១ ក្នុងគូទី ២ ថា "អ្នកឯង" ដូចប្រយោគថា: "អ្នកឯងនិយាយរឿងនេះ, អ្នកឯងមិនដែលមកទីនេះទេ, អ្នកឯងឲ្យរបស់នេះ" ។

"គេឯង" នេះជាពាក្យឯមួសសព្វនាមទី ២ ជាពហុវចនៈ ប្រែថា "គេប្រាកដ"ឬ"ប្រាកដជាគេ" បានជាហៅថា ឯមួស-សព្វនាមនោះ គឺព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលនិយាយជាមួយនឹងយើងនោះឯងតែ មិនមែនអ្នកឯទៀតក្រៅពីនេះទេឡើយ តែក្នុងទីនេះ អ្នកដែលនិយាយជាមួយនឹងយើងនោះ មានច្រើននាក់ ដោយហេតុដូច្នេះ បានជាប្រើពាក្យទី ២ ក្នុងគូទី ២

www.elibraryofcambodia.org

ថា "អាឯង" ដូចប្រយោគថាៈ "អាឯងទាំងនើបានទេឬ? អាឯងក៏ចាប់រៀនដែរ៕ អាឯងទាំងត្រឡប់ទៅណា" ។

"គេឯង" នេះជាពាក្យឯម្ចាស់សព្វនាមទី ៣ ជាឯកវចនៈ ប្រែថា "គេប្រាកដ" ឬ "ប្រាកដជាគេ" បានជាហៅថា ឯម្ចាស់សព្វនាមនោះ ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលយើងនិយាយដល់នោះឯងផង មិនមែនអ្នកឯទៀតក្រៅពីនេះទេឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់នោះ មានតែម្នាក់ ដោយហេតុដូច្នេះ បានជាត្រូវប្រើពាក្យទី ១ ក្នុងទី ៣ ថា "គេឯង" ដូចប្រយោគថាៈ "គេឯងបាននិយាយមិនខុស, គេឯងបញ្ចានរឿងនេះម្ដេច? ថ្ងៃណា គេឯងទំនេរ?" ។

"គេឯង" នេះជាពាក្យ ឯម្ចាស់សព្វនាមទី ៣ ជាពហុវចនៈ ប្រែថាៈ "គេប្រាកដ" ឬ "ប្រាកដជាគេ" បានជាហៅថា ឯម្ចាស់សព្វនាមនោះ ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលយើងនិយាយដល់នោះឯងផង មិនមែនអ្នកឯទៀតក្រៅពីនេះទេឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់នោះមានច្រើននាក់ ដោយហេតុដូច្នេះ បានជាត្រូវប្រើពាក្យទី ២

www.elibraryofcambodia.org

ក្នុងទី៣, ជា: "គេឯង" ដូចប្រយោគថា: "ម្សិលមិញ គេឯងនិយាយថាម៉េចខ្លះ?, ប៉ុន្មានថ្ងៃទៀត គេឯងនឹងត្រឡប់? គេឯងកែនរឿងនេះ" ។

"គឹឯង" នេះជាពាក្យឯម្ពួសសព្វនាមទី៣ ជាឯកវចនៈដែរ ប្រែថា "គឺប្រាកដ" ឬ "ប្រាកដជាគឺ" បានជាហៅថា ឯម្ពួសសព្វនាមនោះ ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលយើងនិយាយដល់នោះឯងហ្ន៎ មិនមែនអ្នកឯទៀតក្រៅពីនេះទេហើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់នោះ ជាស្ត្រី ហើយមានតែម្នាក់ ដោយហេតុដូច្នេះ បានជាត្រូវប្រើពាក្យទី១ ក្នុងទី២ ជា "គឹឯង" ដូចប្រយោគថា: "គឹឯងបាននិយាយនឹងខ្ញុំលាំង ១ ណាស់! គឹឯងបានធ្វើបម្យម.ដល់ខ្ញុំពីម្សិលមិញ, គឹឯងមានជម្ងឺជាទម្ងន់" ។

"គឹឯង" នេះជាពាក្យឯម្ពួសសព្វនាមទី ៣ ជាពហុវចនៈដែរ ប្រែថា: "គឺប្រាកដ" ឬ "ប្រាកដជាគឺ" បានជាហៅថា ឯម្ពួសសព្វនាមនោះ ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលយើងនិយាយដល់នោះឯងហ្ន៎ មិនមែនអ្នកឯទៀតក្រៅពី

www.elibraryofcambodia.org

នេះទៀតឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់នោះជាស្ត្រី ហើយមានច្រើននាក់ ដោយហេតុដូច្នេះ បានជាត្រូវប្រើពាក្យទី២ ក្នុងតួទី៤ ថា: "គីឯង" ដូចប្រយោគថា: "សព្វថ្ងៃ គីឯងកំពុងរៀននៅសាលារៀននៅឡើយ, គីឯងកំពុងធ្វើអ្វី ? គីឯងប្រាប់គេឲ្យគេទៅឬ ? បានជាគេទៅ!" ។

"វាឯង" នេះជាពាក្យ បុរសសព្វនាម ទី៣ ជាឯកវចនៈដែរ ប្រែថា "វាប្រាកដ" ឬ "ប្រាកដជាវា" បានជាហៅថា បុរសសព្វនាមនោះ ក៏ព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលយើងនិយាយដល់នោះឯងពិត មិនមែនអ្នកឯទៀតក្រៅពីនេះទៀតឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់នោះជាសត្វតិរច្ឆាន ហើយមានតែ១តួ ដោយហេតុដូច្នេះ បានជាត្រូវប្រើពាក្យទី១ ក្នុងតួទី៨ ថា: "វាឯង" ដូចប្រយោគទាំងឡាយថា: វាឯងស៊ី មិនមែនសត្វឯទៀតម.ស៊ីទេ, វាឯងកេតកេតអ្វី បានជាកើតខ្លាំងម្ល៉េះ? វាឯងកើត មិនមែនគោឯទៀតទេ" ។

---

(១) ជម្ងឺ ត្រូវជាងជំងឺ មកពីកិរិយាសព្ទថា ឈឺ ប្រើជាជំងឺតាមទម្លាប់ក៏បាន ប៉ុន្តែប្រើដូចនេះ វេយ្យាករណ៍ត្រូវឲ្យយើងខុស ។

www.elibraryofcambodia.org

"ខ្លួនឯង"នេះ គឺជាពាក្យឯម្លួសសព្វនាមទី ៣ ជាពហុវចនៈផង ប្រែថា: "ខ្លួនប្រាកដ" ឬ "ប្រាកដជាខ្លួន" បានជាហៅថា ឯម្លួសសព្វនាមនោះ គឺព្រោះពាក្យនេះ សម្រាប់ប្រើប្រាប់បញ្ជាក់ដល់អ្នកដែលយើងនិយាយដល់នោះឯងចើ មិនមែនអ្នកឯទៀតក្រៅពីនេះទេឡើយ តែក្នុងទីនេះ អ្នកដែលយើងនិយាយដល់នោះជាសត្វតិរច្ឆាន ហើយមានច្រើនតួ ដោយហេតុដូច្នេះ បានជាត្រូវប្រើពាក្យទី ២ ក្នុងតួទី ៤ ថា: "ខ្លួនឯង" ដូចប្រយោគវ៉ាំងខ្លួនថា: "មៀលមិញ ខ្លួនឯងតែពៅឯណាអស់, ខ្លួនឯងម.ដល់អស់ហើយ! ខ្លួនឯងស៊ី មិនមែនសត្វឯទៀតស៊ីទេ" ។

## វគ្គសាកបធធី ១៦

១-ពាក្យយ៉ាងម៉េចដែលហៅថា ឯម្លួសសព្វនាម? អធិប្បាយ!

២-ឯម្លួសសព្វនាម បានដល់ពាក្យយ៉ាងម៉េច?

៣-ពាក្យដែលសម្រាប់ប្រើក្នុងឯម្លួសសព្វនាមនោះ មានប៉ុន្មានពាក្យ? ជាឯកវចនៈប៉ុន្មានពាក្យ? ជាពហុវចនៈប៉ុន្មានពាក្យ? ចាត់ជាអ្វីដូចម្តេច?

៤-ពាក្យថា "ខ្ញុំឯង" ជាអ្វី? ប្រែថាម៉េច? ហេតុដូចម្តេច

www.elibraryofcambodia.org

បានជាហៅថា ឯម្ចាស់សព្វនាម? ឧទាហរណ៍យ៉ាងណាខ្លះ?

៥-ម៉េចបានជាប្រើពាក្យថា "ខ្ញុំឯង"? អធិប្បាយ!

៦-ពាក្យថា "យើងឯង" ជាអ្វី? ប្រែថាម៉េច? ហេតុដូចម្ដេចបានជាហៅថា ឯម្ចាស់សព្វនាម? ឧទាហរណ៍ដូចម្ដេចខ្លះ?

៧- ហេតុដូចម្ដេចបានជាប្រើពាក្យថា "យើងឯង"? អធិប្បាយ!

៨-ពាក្យថា "អ្នកឯង" ជាអ្វី? ប្រែថាម៉េច? ហេតុដូចម្ដេចបានជាហៅថា ឯម្ចាស់សព្វនាម? ឧទាហរណ៍ដូចម្ដេចខ្លះ?

៩-ហេតុម៉េច បានជាប្រើពាក្យថា "អ្នកឯង"? អធិប្បាយ!

១០-ពាក្យថា "វាឯង" ជាអ្វី? ប្រែថាម៉េច? ហេតុដូចម្ដេចបានជាហៅថា ឯម្ចាស់សព្វនាម? ឧទាហរណ៍យ៉ាងម៉េចខ្លះ?

១១-ហេតុម៉េចបានជាប្រើពាក្យថា "វាឯង"? អធិប្បាយ!

១២-ពាក្យថា "គេឯង" ជាអ្វី? ប្រែថាម៉េច? ហេតុដូចម្ដេចបានជាហៅថា ឯម្ចាស់សព្វនាម? ឧទាហរណ៍យ៉ាងណាខ្លះ?

១៣-ហេតុយ៉ាងម៉េចបានជាប្រើពាក្យថា "គេឯង"? អធិប្បាយ!

www.elibraryofcambodia.org

១៤-ពាក្យថា "គេឯង" ជាអ្វី? ប្រែថាម៉េច? ហេតុយ៉ាងណាបានជាហៅថា បុរសសព្វនាម? ឧទាហរណ៍ដូចម្ដេចខ្លះ? ហេតុដូចម្ដេចបានជាប្រើពាក្យ "គេឯង"? អធិប្បាយ!

១៥- ពាក្យ "គ៏ឯង" ជាអ្វី? ប្រែថាម៉េច? ហេតុយ៉ាងម៉េចបានជាហៅថា បុរសសព្វនាម? ឧទាហរណ៍យ៉ាងម៉េចខ្លះ?

១៦-ហេតុយ៉ាងណាបានជាប្រើពាក្យថា "គ៏ឯង"? ចូរអធិប្បាយ!

១៧- ពាក្យថា "គ៏ឯង" ជាអ្វី? ប្រែថាម៉េច? ហេតុយ៉ាងម៉េចបានជាហៅថា បុរសសព្វនាម? ឧទាហរណ៍យ៉ាងម៉េច?

១៨- ហេតុម៉េចបានជាប្រើពាក្យថា "គ៏ឯង"? អធិប្បាយ!

១៩- ពាក្យថា "វាឯង" ជាអ្វី? ប្រែថាម៉េច? ហេតុដូចម្ដេចបានហៅថា បុរសសព្វនាម? បានដល់ឧទាហរណ៍ដូចម្ដេចខ្លះ?

២០-ហេតុដូចម៉េចបានជាប្រើពាក្យថា "វាឯង"? អធិប្បាយ!

២១- ពាក្យថា "ឡាឯង" ជាអ្វី? ប្រែថាម៉េច? ហេតុម៉េចបានជាហៅថា បុរសសព្វនាម? ឧទាហរណ៍យ៉ាងម៉េចខ្លះ?

២២-ហេតុដូចម្ដេចបានជាប្រើពាក្យថា "ឡាឯង"? អធិប្បាយ!

www.elibraryofcambodia.org

## ១១- ប្រពន្ធសព្វនាម (le pronom relatif)

ពាក្យដែលសម្រាប់ប្រើបញ្ចូលឈ្មោះរបស់ មនុស្ស,សត្វ ឬគ្រឿង គ្រប់យ៉ាងដែលជាប់ទាក់ទងគ្នានឹងពាក្យដទៃ ពាក្យបែបនេះ ហៅថា ប្រពន្ធសព្វនាម។ ពាក្យថា "ប្រពន្ធ" ប្រែថា "ចងភ្ជាប់, ចងក្រង" តែក្នុងទីនេះ សំដៅសេចក្ដីថា "ជាប់គ្នា" គឺពាក្យនាមដែលនៅជាប់គ្នា ។ បើគ្រាប់ជាប្រពន្ធសព្វនាម ប្រែថា: "ពាក្យដែលសម្រាប់ប្រើជួសឈ្មោះរបស់ មនុស្ស, សត្វ ឬគ្រឿង ដែលជាប់ទាក់ទងគ្នា" ចូរមើលប្រយោគនេះ "នេះគឺជាកុមារ,កុមារមានសេះមួយគួរល្អ" ។ បើយើងពោលតាមកុមារនូវគ្នា២ ដងដូច្នេះ នឹងជឿស្ដាប់ទាស់ត្រចៀក ដោយហេតុដូច្នោះ យើងត្រូវ.ពាក្យសព្វនាម.ជួសកុមារក្នុងប្រយោគក្រោយ និងភ្ជាប់សេចក្ដីឲ្យជាប្រយោគជាមួយគ្នាតែម្ដងទៅ ដំណើរសេចក្ដី ក៏នឹងស្រឡះស្រឡូនឡើង យើងបានប្រយោគនេះគឺ "ជាកុមារដែលមានសេះ១គួរល្អ" ។ ពាក្យ "ដែល" ជាសព្វនាមមួយបែបទៀត ហៅថា ប្រពន្ធសព្វនាម ព្រោះប្រើជួសនាម និងភ្ជាប់ប្រយោគក្នុងនេះជាមួយគ្នា ។ ចំណែកពាក្យកុមារដែលនៅខាងមុខពាក្យប្រពន្ធសព្វនាម ហៅថា

www.elibraryofcambodia.org

អត្តសិទ្ធក(Antécedent) (ដែលនាំមុខ) ។

ពាក្យដែលសម្រាប់ប្រើក្នុងប្រពន្ធសព្ទនាមនេះ មានតែមួយគត់ គឺ "ដែល" នេះឯង ។ ពាក្យប្រពន្ធសព្ទនាមនេះ មានប្រើតែក្នុងសេចក្តីដែលមានពាក្យនាម ឬសព្ទនាមជាមួយគ្នារៀងនៅជាប់ៗ គ្នាដោយច្រើន តែជាសេចក្តីដែលមានប្រយោគកម្រគ្នាបួលម. ដូចប្រយោគតាំងឡាយនេះ : "ខ្ញុំគាប់ចិត្តមនុស្សដែលខ្សោយ, មនុស្សដែលខ្ជិលច្រអូស ត្រូវតែលំបាកជាដរាប, ខ្ញុំស្តាយសេះដែលលក់" ។ សេចក្តីដែលគូសសញ្ញាប្រកាសនោះ ជាប្រយោគតូចដែលជ្រែកចូលម.នេះ បើមិនប្រើប្រពន្ធសព្ទនាមទេ ក៏មុខជាមិនមាននាមត្រួតគ្នាច្រើននៅជាប់ៗគ្នាថា: "ខ្ញុំគាប់ចិត្តមនុស្ស មនុស្សខ្សោយ, មនុស្ស មនុស្សខ្ជិលច្រអូស ត្រូវតែលំបាកជាដរាប, ខ្ញុំស្តាយសេះ សេះលក់" ដូច្នេះជាដើម ព្រោះដើម្បីមិនឲ្យពាក្យនាម ឬសព្ទនាមត្រួតគ្នាជាប់ដែក ដូច្នេះហើយបានជាត្រូវប្រើប្រពន្ធសព្ទនាម ។

## វិក្កាសាបទទី ១៧

១- ពាក្យយ៉ាងម៉េចហៅថា ប្រពន្ធសព្ទនាម? អធិប្បាយ!

www.elibraryofcambodia.org

២- ពាក្យថា “ប្រពន្ធ” ប្រែយ៉ាងម៉េច? សំដៅសេចក្ដីយ៉ាងណា? ប្រពន្ធសព្វនាម ប្រែដូចម្ដេចទៅវិញ?

៣- ប្រយោគយ៉ាងណា? ហើយយើងត្រូវធ្វើដូចម្ដេច ទើបហៅថា ប្រពន្ធសព្វនាម?

៤. ចូរកែប្រយោគនេះ ឲ្យទៅជាប្រយោគមានប្រពន្ធសព្វនាមចូលមកនៅផង: “នេះគឺសំពត់ស, សំពត់មានសាច់ក្រាស់”

៥-ពាក្យសម្រាប់ប្រើក្នុងប្រពន្ធសព្វនាមនេះមានប៉ុន្មានម៉ាត់? សម្រាប់ប្រើក្នុងទីណា? ឧទាហរណ៍ដូចម្ដេចខ្លះ? ពន្យល់

៦-ពាក្យនាមដែលនៅខាងមុខពាក្យប្រពន្ធសព្វនាម ហៅថាអ្វី? ប្រែយ៉ាងម៉េច?

៧- ប្រយោគទាំងនោះ បើយើងមិនប្រើពាក្យប្រពន្ធសព្វនាមទេ នឹងទៅជាយ៉ាងម៉េចទៅវិញ?

៨-“ខ្ញុំរៀនក្នុងសាលារៀន ដែលរដ្ឋាភិបាលចាយប្រាក់ឲ្យសង់” នេះ បើយើងមិនប្រើប្រពន្ធសព្វនាមទេ នឹងទៅជាយ៉ាងម៉េចទៅវិញ?

៩- ប្រយោគថា: “គេចង់បានប្រពន្ធ ប្រពន្ធមានមារយាទ-

www.elibraryofcambodia.org

ល្អ" [illegible] បើប្រើប្រពន្ធសព្ទនាម ត្រូវដាក់ត្រង់ណា?

១០- ក្នុងប្រពន្ធគុណសព្ទ និងប្រពន្ធសព្ទនាមមានពាក្យថា "ដែល"ដូចគ្នា, ដូច្នេះតើយើងអាចដឹងបានថា ណាជាប្រពន្ធ-គុណសព្ទ? ណាជាប្រពន្ធសព្ទនាម? ចូរអធិប្បាយ!

១១- ប្រយោគទៅនេះថា "ខ្ញុំបាត់ប្រាក់ដែលខ្ញុំរើសបាន, ខ្ញុំស្តាយគោដែលខ្ញុំលក់, ខ្ញុំនឹកប្រពន្ធដែលស្លាប់, ខ្ញុំឃើញដើមដែលជំពប់" នេះ ណាជាប្រយោគប្រពន្ធគុណសព្ទ? ណាជាប្រយោគប្រពន្ធសព្ទនាម?

## ៥– ពាក្យកិរិយា (le Verbe)

ពាក្យក្នុងកម្ពុជភាសាយើង លោកចែកដោយលក្ខណៈដែលផ្សេងគ្នានោះ មាន ១០ យ៉ាង, តែដែលយើងបានរៀនមកហើយនោះ ៤ ពាក្យគឺ ពាក្យនាម, ពាក្យគុណ, ពាក្យគុណវិសេសនៈ និងពាក្យសព្វនាម ។

នាម គឺយើងរៀនឲ្យដឹងថា វត្ថុទាំងពួងក្នុងលោក ទោះបីមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី ដែលមានឈ្មោះសម្រាប់ហៅបាន ដូចពាក្យថា: មនុស្ស, សត្វ, ដី, ទឹក, ភ្លើង, ខ្យល់, អាកាសជា

www.elibraryofcambodia.org

ដើម ហៅថា នាម ។ ពាក្យថា "មនុស្ស ឬសត្វ" ជាដើមនេះ, មនុស្សមានច្រើនក្នុងលោក មិនដឹងថាមនុស្សណាជាមនុស្សណា ។ សំគាល់ ឬចាំក៏មិនបាន ព្រោះរាងដូច ៗ គ្នា, ដោយហេតុដូច្នេះបានជាយើងត្រូវរៀនឲ្យស្គាល់គ្រឿងចាំរបស់មនុស្ស ជាដើមនោះទៀត គ្រឿងចាំនោះក៏គឺពាក្យដែលគេហៅថា "គុណ" ។

គុណ គឺពាក្យដែលស្ដែងលក្ខណៈរបស់នាមណាមួយ សម្រាប់សំគាល់ឲ្យដឹងថា: នាមនោះល្អ ឬ អាក្រក់, ធំ ឬ តូច, ឬក៏ ខ្មៅ, ស, វែង, ខ្លី, ខ្ពស់, ស្ដើង, [illegible] ស្លូត, កាច ជាដើមនេះហៅថា គុណ ។ ពាក្យថា "ល្អ" ឬ "អាក្រក់" ជាដើមនេះ នៅតែមិនល្មមគ្រប់គ្រាន់ [illegible] ទាំងអស់ សុទ្ធតែមានពណ៌សម្បុរ [illegible] ត្រូវតែមានពាក្យនាម បានជាពាក្យគ្រាន់តែថា [illegible] ទាន់ស្រេច ដូច្នេះ ទើបយើងត្រូវរៀនពាក្យសម្រាប់ធ្វើ ស ឬខ្មៅ ជាដើមនេះ ឲ្យខុសៗគ្នាតទៅទៀត ពាក្យសម្រាប់ធ្វើ ស ឬខ្មៅ ជាដើមនេះឲ្យខុសពីគ្នានោះក៏គឺពាក្យដែលយើងហៅថា "គុណវិសេសនៈ" ។

គុណវិសេសនៈ ក៏គឺពាក្យដែលសម្រាប់ធ្វើពាក្យគុណ

www.elibraryofcambodia.org

ឲ្យខ្ទាៗផ្សេងពីគ្នា ដើម្បីឲ្យគេដឹងស្គាល់នាមនោះជាក់ប្រាកដ
ទៀត មិនឲ្យច្រឡំគ្នា ដូចពាក្យថា: "ខ្មៅព្រឹក, សស្គុស, ខ្ទី-
ក្រញូញ, វែងអន្លាយ, ទាបកន្ទុប, ខ្ពស់ច្រហោង" ជាដើមនេះ
ហៅថា គុណវិសេសនៈ ។ រៀនត្រឹមពាក្យប៉ុណ្ណេះ ឈ្មោះថាយើង
បានស្គាល់ពាក្យនាមនោះ ប្រាកដមែនទែនហើយ មិនច្រឡំគ្នា
ទៀតទេ, ប៉ុន្តែបើយើងស្គាល់តែពាក្យនាមនោះប្រាកដ ដោយអំ-
ណាចពាក្យគុណនិងពាក្យគុណវិសេសនៈ ប្រាប់បញ្ជាក់យើង
ហើយ វេលាណាដែលយើងនិយាយ យើងក៏យកតែពាក្យនាមនោះ
ទៅនិយាយញឹកញាប់ពេកទៅ នោះក៏ជាហេតុនាំឲ្យអ្នកស្ដាប់ៗ
ពាក្យដែលយើងនិយាយនោះ ធុញទ្រាន់នឹងស្ដាប់ពាក្យយើង
ព្រោះតែដដែល ម.ដដែលមិនមានប្លែកគ្នាសោះ ដោយហេតុ
ដូច្នេះ បានជាយើងត្រូវតែរៀនពាក្យសម្រាប់ប្រើជួសឈ្មោះនាម
នោះទៀត ដើម្បីកុំឲ្យពេញចំពាក្យនាមនោះដដែល ៗ ពេក
ពាក្យដែលសម្រាប់ប្រើជួសពាក្យនាមទាំងពួងនោះឯង ក៏គឺពាក្យ
ដែលយើងហៅថា "សព្វនាម" ។

សព្វនាម ក៏គឺពាក្យសម្រាប់ប្រើជួសពាក្យនាមទាំងពួង

www.elibraryofcambodia.org

នោះឯង ។ តែទាំង៤ពាក្យ ដែលយើងបានរៀនម. ហើយនេះ ទើបតែទឹងបានមួយភាគទេ! ព្រោះពាក្យទាំង៤នេះ រួមចូលគ្នាទៅ ក៏ដូចជាតែ១ពាក្យ គឺយើងគ្រាន់តែស្គាល់ឈ្មោះ, ស្គាល់គ្រឿងពាក់របស់ឈ្មោះ, ស្គាល់គ្រឿងប្លន់ គ្រឿងពាក់របស់ឈ្មោះ, ស្គាល់គ្រឿងជួសរបស់ឈ្មោះ តែត្រង់ឈ្មោះទៅណា ក៏យើងមិនដឹង ឈ្មោះម.ពីណា ក៏យើងមិនដឹង ឈ្មោះធ្វើអីក៏យើងមិនដឹង ឈ្មោះមានអាការប្រែប្រួលយ៉ាងណាក៏យើងមិនដឹង, ដោយហេតុដូច្នេះ បានជាយើងត្រូវរៀនឲ្យដឹងការប្រែប្រួលរបស់ឈ្មោះផងទើបបាន ។ ដើម្បីឲ្យដឹងថាឈ្មោះនោះធ្វើអី ព្រោះថាបើយើងមិនស្គាល់អាការៈរបស់ឈ្មោះទេ នោះយើងក៏បាននាមជាប្រើការមិនកើត ក៏អាការប្រែប្រួលរបស់ឈ្មោះនោះ គឺគឺពាក្យថា "កិរិយា" នោះឯង ។

កិរិយានោះ គឺសំដីដែលស្ដែងប្រាប់នូវដំណើរនៃទំហើ ឬអាការរបស់នាម ឬសព្វនាម ដើម្បីឲ្យដឹងថា នាម ឬសព្វនាមនោះៗ ធ្វើអ្វី ឬកំថាយ៉ាងណា? ។ ពាក្យថា "ដេក, ដើរ; ឈរ, អង្គុយ, ស៊ី, ផឹក, និយាយ, ស្ដាប់, គិត, ហៅ, លេង"

www.elibraryofcambodia.org

ជាដើមនេះហៅថា "កិរិយា" ព្រោះសំដែងអាការរបស់នាម ឬសព្វនាម បានផ្សេងៗគ្នា ឲ្យដឹងថា នាមឬសព្វនាមនោះប្រែប្រួលយ៉ាងណា? ធ្វើអ្វី? សម្រេចកិរិយាបថណា? ដូចពាក្យថា "មនុស្សដេក" ដេក ជាកិរិយា ព្រោះសំដែងអាការៈរបស់មនុស្សថា មិនដើរ, មិនអង្គុយទេ គឺ "ដេក"; "សត្វហើរ" ហើរក៏ជាកិរិយា ព្រោះសំដែងអាការៈរបស់សត្វថា: មិនទៅស្ងៀម គឺហើរចេញទៅពីទីនេះ; "ភ្លើងរលត់" រលត់ ក៏ជាកិរិយា ព្រោះសំដែងអាការៈប្រាកដរបស់ភ្លើងថា មិនទៅជាប្រក្រតីទេ គឺបាត់សូន្យលែងឆេះ តទៅ ជាដើមៗ ចូរសង្កេតយ៉ាងងាយៗ ថា:

ពាក្យដែលសំដែងអាការៈរបស់នាម ឬសព្វនាមហៅថា "កិរិយា"

"កិរិយា" គឺពាក្យដែលសំដែងអាការៈរបស់នាម ឬសព្វនាម ។

ពាក្យកិរិយានោះ កាលបើនិយាយតាមដំណើរដែលប្រាប់មូលចំហើយផ្សេងៗគ្នាទៅ, ក្នុងកម្ពុជភាសាយើង លោកចែកចេញជា១៣យ៉ាងគឺ

១- សកម្មកិរិយា (Verbe transitif)

២- អកម្មកិរិយា (Verbe intransitif)

៣- សកម្មាកម្មកិរិយា (Verbe transitif et intransitif)

៤- វិកត្តកិរិយា

៥- កិរិយានុគ្រោះ (Verbe auxiliaire)

៦- សុទ្ធនាមកិរិយា

៧- នាមកិរិយា

៨- សុទ្ធគុណកិរិយា

៩- គុណកិរិយា

១០- នាមគុណកិរិយា

១១- សមាសកិរិយា

១២- កត្តុកិរិយា

១៣- ហេតុកត្តុកិរិយា

ក្នុងកិរិយាទាំង១៣នេះនឹងនិយាយចំពោះតែកិរិយាដែលមានការចាំបាច់ ត្រូវប្រើក្នុងប្រយោគភាសា ហើយដែលមានសេចក្តីល្អិតល្អន់លំបាកយល់គេ ។ ឯកិរិយាដែលមានសេចក្តីងាយយល់នឹងមិនបាននិយាយក្នុងទីនេះទេ ព្រោះរៀនបានចាប់ផ្តើមស្រាប់ហើយ ។

www.elibraryofcambodia.org

## វិញ្ញាសាបទទី ១៨

១- នាមយើងរៀនឲ្យដឹងអ្វីខ្លះ ? មានដំណើរពាក់ព័ន្ធនឹងអ្វី?

២. គុណ យើងរៀនឲ្យដឹងលក្ខណៈរបស់អ្វី? មានប្រយោជន៍ដូចម្ដេចដល់អ្វីនោះ?

៣- គុណវិសេសនៈ យើងរៀនឲ្យដឹងលក្ខណៈរបស់អ្វីទៀត? បើមិនមានគុណវិសេសនៈទេ តើនឹងប្រើបានឬទេ ?

៤- សព្វនាម សម្រាប់ប្រើជំនួសអ្វី? បើមិនមានសព្វនាមទេនោះ នឹងដូចម្ដេចទៅ? ចូរអធិប្បាយ!

៥- បើយើងរៀនតែត្រឹមនាម, គុណ, គុណវិសេសនៈ នឹងសព្វនាមប៉ុណ្ណោះបាន ឬទេ? ព្រោះហេតុអ្វី?

៦- អាការៈ ប្រែប្រួលរបស់នាម ឬសព្វនាមនោះ យើងហៅថាអ្វី?

៧- ពាក្យថា កិរិយាបានសេចក្ដីដូចម្ដេច? ដូចពាក្យថាយ៉ាងណា?

៨- ពាក្យថា ដេក, ហើរ, លោតនេះ ហេតុអ្វីបានជាហៅថាកិរិយា ? ចូរអធិប្បាយ!

www.elibraryofcambodia.org

៩. ពាក្យកិរិយាក្នុងកម្ពុជភាសា បរទេស លោកចែកចេញជា ប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូររាប់!

១—សកម្មកិរិយា (Verbe transitif)

កិរិយាប្រកបដោយកម្ម ឬកិរិយាមានកម្ម ហៅថា សកម្មកិរិយា (Verbe transitif) នេះបានដល់កិរិយាដែលកាលណានិយាយដល់ហើយ ត្រូវស្រែកហៅទំហំដែលត្រូវធ្វើ.ផង ។

អធិប្បាយថា: ពាក្យកិរិយាឯណា ដែលមានសេចក្ដីមិនគ្រប់គ្រាន់បរិបូណ៌ក្នុងខ្លួន ត្រូវមានពាក្យដែលជាកម្ម ដ៏អ្នកត្រូវធ្វើចូលម.ទទួលខាងចុងទៀត ទើបមានសេចក្ដីពេញលេញគ្រប់គ្រាន់បាន ទើបស្ដាប់ចូលចិត្តបាន បើតែទំនើងខ្លួនឯងទេ ស្ដាប់មិនបាន មិនចូលចិត្ត កិរិយានោះ ហៅថា សកម្មកិរិយា ដូចគួរយ៉ាងថា: “ធ្វើ, ស៊ី, ទទួល, វាយ, បិទ” ជាដើមដូច្នេះ ពាក្យថា: “ធ្វើ, ស៊ី, ទទួល, វាយ, បិទ” ក្នុងទីនេះ នៅមិនទាន់គ្រប់គ្រាន់បរិបូណ៌ គឺមិនដឹងថា “ធ្វើអ្វី? ស៊ីអ្វី? ទទួលអ្វី, វាយអ្វី? បិទអ្វី?” លុះណាតែមានបទកម្មចូលម.ទទួលខាងចុងថា: “ធ្វើការ, ស៊ីបាយ ទទួលសម្បុត្រ, វាយស្គរ, បិទទ្វារ, ដូច្នេះ ទើបស្ដាប់សេចក្ដី

www.elibraryofcambodia.org

បានពេញលេញ ។ ពាក្យថា: "ការ, បាយ, សម្បុត្រ, ស្គរ, ទ្វារ" នេះឯងហៅថា បទកម្ម (Complément) គឺជាចំហើរបស់ ធ្វើ, ស៊ី, ទទួល, វាយ, បិទ បានជាហៅកិរិយានេះថា សកម្ម-កិរិយានោះ ព្រោះប្រែថា "កិរិយាប្រព្រឹត្តទៅមួយអន្លើដោយកម្ម" ឬ "កិរិយាប្រកបដោយកម្ម" ឬក៏ "កិរិយាត្រូវមានបទកម្ម" ព្រោះជាកិរិយាត្រូវការដោយពាក្យបុព្វបទថា "ឧប–"

## វិញ្ញាសាបទទី១៩

១- កិរិយាយ៉ាងម៉េចដែលហៅថា សកម្មកិរិយា ?

២- សកម្មកិរិយាបានដល់ពាក្យកិរិយាយ៉ាងម៉េចខ្លះ ?

៣- ធ្វើ, ស៊ី, ទទួល, វាយ, បិទ នេះហេតុអ្វីបានជាហៅថា សកម្មកិរិយា? ចូរអធិប្បាយ។

៤- ដែលហៅថា បទកម្ម [illegible] មានដំណើរទាក់ទងនឹងអ្វី?

៥- សកម្មកិរិយា [illegible] បានសេចក្តីថា ម៉េចខ្លះ?

www.elibraryofcambodia.org

## ២- អកម្មកិរិយា (Verbe Intransitif)

កិរិយាណាដែលមិនប្រកបដោយកម្ម ឬកិរិយាដែលមិនមានកម្ម គឺកិរិយាដែលកាលណានិយាយមិនបាច់ដាក់ចំហៅដែលត្រូវធ្វើ ម.ផឹងវេ កិរិយានោះហៅថាអកម្មកិរិយា (Verbe Intransitif) គឺ បានដល់ពាក្យកិរិយា១ពួកដែលមានសេចក្តីពេញលេញគ្រប់គ្រាន់ បរិបូណ៌ក្នុងខ្លួនឯង គឺកិរិយាដែលអាចធ្វើឲ្យពេញសេចក្តីបានចំ-ពោះខ្លួនឯង មិនបាច់ចាំមានពាក្យដែលជាកម្ម គឺអ្នកត្រូវធ្វើឬ ទទួលខាងចុង ក៏ស្តាប់សេចក្តីបានពេញទី កិរិយានោះ ហៅថា អកម្មកិរិយា ដូចជា: "ដេក, ដួល, ឈរ, អង្គុយ, ទៅ, ម.ជាដើម ក្នុងទីនេះ មានសេចក្តីពេញលេញគ្រប់គ្រាន់បរិបូណ៌ស្រេចតែម្តង គឺគ្រាន់តែមានពាក្យនាម ឬពាក្យសព្វនាម១ មកដាក់ជាតួប្រធាន នឹង ពាក្យកិរិយា១មកប៉ុណ្ណោះ គឺអាចស្តាប់បួលចិត្តបាន ដូចជា: "មនុស្សដេក, គោដួល, ខ្លាឈរ, ស្វាអង្គុយ ប៉ុណ្ណោះ ក៏ស្តាប់បានស្រេច មិនចាំបាច់មានបទកម្ម ឬអ្វីៗ ទៀតឡើយ ដោយហេតុដូច្នេះ បានជាហៅកិរិយា បែបនោះថា អកម្មកិរិយា ដែលប្រែថា "កិរិយាមិនប្រកបដោយកម្ម" ឬ "កិរិយាមិនមានកម្ម" ។

www.elibraryofcambodia.org

## វគ្គសាភបធជ ២០ ។

១- យ៉ាងម៉េចបានជាហៅថា អកម្មកិរិយា ?

២- អកម្មកិរិយា គឺកិរិយាយ៉ាងម៉េច ?

៣- ពាក្យថា: "ដេក, ដួល, ឈរ, អង្គុយ" នេះហេតុដូចម្តេចបានជា ហៅថា អកម្មកិរិយា? អធិប្បាយ !

៤- ពាក្យកិរិយាថា: យំ, សើច, ចាក់, ដោត នេះជាកិរិយាអ្វី ? ព្រោះហេតុអ្វី ? អធិប្បាយ !

៥- ពាក្យកិរិយាថា: ដាល់, គប់, ស្រែក, ផឹក, គិត, និយាយ, ទាញ, កាប់, សម្លាប់, ដាក់, ព្រាន, បើក, បរ, ឲ្យ, រៀន, ស្លូត នេះណាជាសកម្មកិរិយា ណាជាអកម្មកិរិយា ? ចូរញែកដាក់ដោយខ្លួនពីគ្នា !

### ៣-សកម្មាកម្មកិរិយា

(Verbe transitif et intransitif)

កិរិយាណាដែលប្រព្រឹត្តទៅបានទាំងជាសកម្មកិរិយា ទាំងជាអកម្មកិរិយា កិរិយានោះហៅថា សកម្មាកម្មកិរិយា (Verbe transitif et intransitif) នេះបានដល់កិរិយាពួកខ្លះ ដែលអាចប្រព្រឹត្ត

www.elibraryofcambodia.org

ទៅបានជាង ២ ផ្នែក គឺជាសកម្មកិរិយាក៏បាន ជាអកម្មកិរិយាក៏បាន ស្រេចហើយតែនឹងការប្រើ ដូចគួយ៉ាងថា: "មនុស្សបើកបង្អួច" ដូច្នេះ ពាក្យថា "បើក" កន្លែងនេះ មិនបានសេចក្ដីពេញគ្រប់គ្រាន់ គឺមិនដឹងថា "បើកអ្វី?" ត្រូវមានពាក្យ "បង្អួច" ចូលមកភ្ជួលផង ទើបបានសេចក្ដីពេញ ៗ ដូច្នេះ ពាក្យកិរិយា "បើក" កន្លែងនេះត្រូវរាប់ថា ជាសកម្មកិរិយា តែបើនិយាយថា "បង្អួចបើក" ដូច្នេះវិញ នោះពាក្យ "បើក" កន្លែងនេះ មានសេចក្ដីពេញគ្រប់គ្រាន់ សំដៅសេចក្ដីបើកចំហ ៗ ដូច្នេះ ពាក្យកិរិយា "បើក" កន្លែងនេះត្រូវរាប់ថា: អកម្មកិរិយាទៅវិញ យ៉ាងនេះជាដើម ។

ហេតុនោះ: មុនដែលនឹងប្រាប់ថា កិរិយាពាក្យណា ជាកិរិយាចំណែកណានោះ គួរពិចារណាសេចក្ដីដែលផ្សេងកន្លែងការប្រើជាមុនសិន ដូចគួយ៉ាងតទៅនេះ :

## សកម្មកិរិយា ប្រែជា អកម្មកិរិយា

| សកម្មកិរិយា | | អកម្មកិរិយា |
|---|---|---|
| ១. គេមិនដែលស៊ីសាច់ស្រស់ | = | មនុស្សស៊ីដើម្បីរក្សាជីវិត |
| ២. គីសរសេរសំបុត្រ | = | គីសរសេររៀបរយ |

www.elibraryofcambodia.org

៣- គេបើក នូវទ្វារ = ទ្វារបើក

៤- គោអូស នូវរទេះ = គោអូសជិតខ្ញុំ

៥- គេចាត់សាលាជារបៀប = គេចាត់រៀបរយតាំងពីព្រឹក

"អកម្មកិរិយា" ប្រើជា "សកម្មកិរិយា" បាន ប៉ុន្តែត្រូវផ្លាស់ឲ្យទៅជា "សកម្មកិរិយាហេតុកត្តុកិរិយា" សិន:

| អកម្មកិរិយាកត្តុកិរិយា: | | សកម្មកិរិយាហេតុកត្តុកិរិយា |
|---|---|---|
| ១- បក្សីហើរ | = | គេបង្ហើរខ្លែង |
| ២- ស្រូវសាលីដុះក្នុងស្រែ | = | គេបណ្ដុះស្រូវសាលីក្នុងស្រែ |
| ៣- សេះបោលចេញពីក្រោល | = | គេបំបោលសេះចេញពីក្រោល |
| ៤- មនុស្សដើរ | = | គេបណ្ដើរអ្នកទោស |
| ៥- គេងូត ក្នុងស្រះ | = | គេផ្ងូតកូនក្នុងស្រះ |
| ៦- ទូកលិចក្នុងទន្លេ | = | គេពន្លិចទូកក្នុងទន្លេ |

តែបើមិនផ្លាស់ទៅជាហេតុកត្តុកិរិយានោះ ក៏នៅជាអកម្មកិរិយាតាមធម្មតា មិនទៅជាសកម្មកិរិយាបានឡើយ ដោយហេតុដូច្នេះ កិរិយាក្នុងឧទាហរណ៍ទាំង ៦ យ៉ាងនេះ មិនបានហៅថា សកម្មាកម្មកិរិយាឡើយ គឺថា បើទៅជាកត្តុកិរិយា ក៏ហៅថា

www.elibraryofcambodia.org

អកម្មកិរិយាតាមធម្មតា បើកាលណាផ្លាស់ទៅជាហេតុកត្តុកិរិយា ទើបហៅថា សកម្មកិរិយា ដែលជាសកម្មាកម្មកិរិយាបាននោះ ព្រោះតែកិរិយាដែលជាគួយ៉ាង ក្នុងឧទាហរណ៍ទាំង៥យ៉ាងខាងដើមនោះប៉ុណ្ណោះ ។

## នក្ខសភបធទី២១

១. សកម្មាកម្មកិរិយា គឺ កិរិយាយ៉ាងម៉េច? អធិប្បាយ!

២. កិរិយាពួកណាខ្លះ ដែលជាសកម្មាកម្មកិរិយា?

៣. ពាក្យកិរិយា "បើក" នេះជាសកម្មកិរិយា ឬអកម្មកិរិយា? ចូរអធិប្បាយពញ្ញគួយ៉ាង!

៤. ពាក្យកិរិយាមួយៗអាចប្រើជាសកម្មកិរិយាផង ជាអកម្មកិរិយាផងដូច្នេះឬ? បើដូច្នោះ តើធ្វើម៉េចយើងទើបនឹងអាចងាយស្រួលកត់បានថា កិរិយានេះ ជាអ្វីៗ បាន?

៥. ចូរនាំឧទាហរណ៍សកម្មាកម្មកិរិយា ដែលនៅជាកត្តុកិរិយាធម្មតា ឲ្យបាន ៥ ឧទាហរណ៍មើល!

៦. ចូរយកពាក្យសកម្មាកម្មកិរិយាទាំងនេះទៅប្រកបឲ្យបានជាប្រយោគទាំងជាសកម្មកិរិយា និងជាអកម្មកិរិយា? ប្រយោគ

www.elibraryofcambodia.org

ខុសគ្នាក៏បាន ឲ្យតែមានន័យសកម្មកិរិយា : ឧទា: ចូលក្នុងរោង ឃើញ, និយាយស្តី, ដក, កាត់, កាប់, បាញ់, វាំ, ឲ្យ ។

៧ — ចូរពាញអកម្មកិរិយាកត្តុកិរិយា ដែលផ្លាស់ទៅជាសកម្មកិរិយាហេតុកត្តុកិរិយាឲ្យបាន ៤ ឧទាហរណ៍មើល!

៨ — ចូរនាំយកពាក្យអកម្មកិរិយាខាងនេះ ទៅប្រកបឲ្យបានជាសកម្មកិរិយា ដោយផ្លាស់ឲ្យទៅជាហេតុកត្តុកិរិយា: ដាច់, ចូល, ចេញ, ទៅ, នៅ, ឆេះ, ក្រុប, គេ, . . . ។

៩ — អកម្មកិរិយាដែលប្រើជាសកម្មកិរិយាបានកើត បើមិនផ្លាស់ទៅជាហេតុកត្តុកិរិយាទេ ដូច: ហើរ, ដុះ, ពោល, ដើរ, លិច ជាដើមនេះហៅថា សកម្មកម្មកិរិយាបានឬទេ? បើហៅបានក៏ហើយទៅ, តែបើហៅមិនបានទេ នោះនឹងហៅដូចម្តេចទៅវិញ?

## កម្ម ( Complément )

“កម្ម” បើប្រែតាមសព្ទក៏បានសេចក្តីថា “អំពើដែលគេធ្វើ” តែក្នុងទីនេះ សំដៅសេចក្តីថា បទដែលធ្លាក់ទៅជាអ្នកត្រូវរបស់សកម្មកិរិយា ។ បទកម្មនេះមានលក្ខណៈដំណើរទំនងប្រហែលគ្នា

www.elibraryofcambodia.org

នឹងបទប្រធានគ្រប់យ៉ាង ដែលផ្សេងគ្នានោះក៏តែត្រង់ដែលធ្វើភ្នាក់ងារជាអ្នកត្រូវរបស់សកម្មកិរិយាប៉ុណ្ណោះ ។ បទណាដែលជាបទប្រធានបាន បទនោះក៏ត្រូវជាបទកម្មបានទាំងអស់ ។ បទកម្មនេះ បើនិយាយឲ្យអស់ទៅ ក៏មាន៦យ៉ាងគឺ ឧជុកម្ម (complément direct) ១, អនុជុកម្ម (Complément Indirect) ១, អាវេលក្ខកម្ម (Complément Réflexe) ១, ញាតកម្ម (Complément Cognat) ១, រេតនកម្ម (Complément Rétention) ១, កិរិយាវិសេសនកម្ម (Complément Adverbe) ១ ។

១- ឧជុកម្ម (Complément Direct) ប្រែថា "បទកម្មត្រង់" បានដល់បទកម្មទី១ គឺប្រយោគ ។ តាមធម្មតាប្រយោគដែលមានសកម្មកិរិយា [illegible] នោះ សុទ្ធតែត្រូវមានបទកម្មជាដរាប បើមិនប្រើ [illegible] ។ បទកម្មទី១ ខាងដើមក្នុងប្រយោគ ហៅថា ឧជុកម្ម ។ ចូរមើលប្រយោគតទៅនេះ "គេឲ្យសៀវភៅខ្ញុំ១ក្បាល" ។ កិរិយា "ឲ្យ" ដែលជាសកម្មកិរិយាមានបទកម្ម២ បទគឺ "សៀវភៅ" នឹង "ខ្ញុំ" ។ ពាក្យថា "សៀវភៅ" ជាឧជុកម្ម (Complément Direct) ព្រោះជា

www.elibraryofcambodia.org

បទកម្មត្រង់របស់កិរិយា "ឲ្យ" ។ ចំណែកពាក្យថា "ខ្ញុំ" នោះ ជាអនុផុកម្ម (Complément Indirect) គឺជាកម្មរេង, កម្មបន្ទាប់ ឬកម្មមិនត្រង់, កម្មរបស់បុព្វបទ "ដល់" ដែលលះទុកក្នុងចិត្តបាន ។ យើងអាចសរសេរប្រយោគនេះជាថ្មីបានថា: "គេឲ្យនូវសៀវភៅមួយក្បាលដល់ខ្ញុំ" ។

២–អនុផុកម្ម (Complément Indirect) ប្រែថា "បទកម្មមិនត្រង់" នេះបានដល់បទកម្មរេង ឬបទកម្មបន្ទាប់ ឬក៏បទកម្មទី២ ក្នុងប្រយោគ ។ តាមធម្មតាក្នុងប្រយោគដែលមានសកម្មកិរិយានោះ សុទ្ធតែត្រូវមានបទកម្មជាដរាប បើមិនច្រើនក៏តិច ។ ដូច្នោះ បទកម្មទី ២ ឬបទកម្មរេង ឬក៏បទកម្មបន្ទាប់នោះ ហៅថា អនុផុកម្ម (Complément Indirect) ចូរមើលប្រយោគតទៅនេះ: "ខ្ញុំទិញរថគេមួយ" ។ ក្នុងប្រយោគនេះ "គេ" ជាអនុផុកម្មរបស់បុព្វបទ "អំពី" ដែលលះទុកក្នុងចិត្តបាន ។ យើងអាចសរសេរប្រយោគជាថ្មីបានថា: "ខ្ញុំទិញនូវរថមួយអំពីគេ" ។

រឿងគួរចាំ: ប្រយោគដែលមានបទកម្ម ២ បទនោះ, បទកម្មដំបូង ត្រូវជាចផុកម្ម ហើយបទកម្មខាងក្រោយ ត្រូវជាអនុផុកម្ម

www.elibraryofcambodia.org

ជាដរាប ។

៣ វេវលេក្ខកម្ម (Complément Réflexe) បទកម្ម ដែលមានរូបមួយជាមួយបទនឹងប្រធាន នេះបានដល់បទកម្មដែលមានដំណើរដូចគ្នានឹងប្រធាន គឺបើប្រធានជានាម ឬសព្វនាម ជាលិង្គណា, វចនៈណា, ជាបុរសអ្វី បទកម្មនេះក៏ជានាមនោះ ឬសព្វនាមនោះ ជាលិង្គនោះ, វចនៈនោះ, ជាបុរសនោះ តាមដូចគ្នា ចូរមើលប្រយោគតទៅនេះ :

គេសម្លាប់ខ្លួនគេ, គាត់ពួនកន្ទុំនឹងខ្លួនគាត់, គាត់តែងខ្លួន ខ្លួនគាត់, គេប្រុងស្តុខ្លួនគេ, យើងឃើញខ្លួនយើង ។

៤ – គោញ្ញកម្ម (Complément Cognat) បទកម្ម ដែលមានសេចក្តីសំគាល់តាក់តង ឬ ប្រហែលគ្នា គឺបើកិរិយា មានដំណើរសេចក្តីដូចម្តេច បទកម្មនោះក៏មានដំណើរសេចក្តីដូច្នោះ ចូរមើលប្រយោគតទៅនេះ :

សេះរត់មួយរបត់, គេគិតដោយសប្បាយយ៉ាងល្អ, គេស្លាប់ដោយសេចក្តីស្លាប់យ៉ាងទារុណ, នាឡិកាកាប់មួយឆ្នាំ, គេរស់មួយឆ្នាំស, គេរស់លូ១០០ឆ្នាំ ។

www.elibraryofcambodia.org

៥ – វេតនកម្ម (Complément Rétention) គឺបទកម្មណាមួយក្នុងប្រយោគដែលមានបទកម្ម ២ បទ ក្នុងប្រយោគកត្តុវាចក:, លុះដល់ផ្លាស់ទៅជាប្រយោគកម្មវាចក: បទកម្មនោះត្រូវនៅសល់ជាបទកម្មតាមដើម១បទ ៗ បទកម្មដែលនៅសល់នោះឯងហៅថា វេតនកម្ម (Complément Rétention) ដូចតទៅនេះ :

កត្តុវាចក: គ្រូឲ្យសៀវភៅគេ ១ ក្បាល ។

កម្មវាចក: { សៀវភៅ១ក្បាល ដែលគេមាននោះគឺគ្រូឲ្យ ។ / គេមានសៀវភៅ ១ ក្បាល ដែលគ្រូឲ្យ ។ }

ក្នុងប្រយោគកម្មវាចក:ដំបូងនោះ ពាក្យថា "គេ" ជាវេតនកម្ម ។

ក្នុងប្រយោគកម្មវាចក:ខាងក្រោយនោះ ពាក្យថា "សៀវភៅ" ជាវេតនកម្ម ។

៦– កិរិយាវិសេសនកម្ម (Complément Adverbe)

គឺបទកម្មដែលធ្វើជាគ្រឿងពង្រីកកិរិយាវិសេសន: គឺធ្វើជាគ្រឿងពង្រីកកិរិយា វែងវេលា ឬរយៈ ដូចប្រយោគតទៅនេះ :

គេដើរការ១ម៉ោង, គេការស្រ័យ១ឆ្នាំ, គេលោក៤ ខែក្រ ។

www.elibraryofcambodia.org

# វិញ្ញាសាកបទី ២៦

១ កម្មបើប្រែតាមសព្ទតាមសេចក្ដីជាម៉េច? កន្ទុំនេះសំដៅសេចក្ដីយ៉ាងណា?

២- បទកម្មនឹងបទប្រធាននោះ ដូចគ្នា ឬផ្សេងគ្នា?

៣- បទកម្មនឹងបទប្រធាននោះ ត្រង់ដែលដូចគ្នា តើដូចត្រង់ណា? ត្រង់ដែលផ្សេងគ្នានោះ តើផ្សេងត្រង់ណាខ្លះ?

៤. បទកម្មនោះ បើនិយាយឲ្យអស់ តើមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

៥- ឧជុកម្មនោះ គឺបទកម្មយ៉ាងម៉េច? ឧទាហរណ៍យ៉ាងណា?

៦- ឧទាហរណ៍ថា: គេឲ្យសៀវភៅខ្ញុំ១ក្បាល នេះបើយើងត្រូវការផ្លាស់ តើអាចផ្លាស់ទៅជាយ៉ាងម៉េចបាន?

៧- ឧទាហរណ៍ថា : គេលក់ចិញ្ចៀនខ្ញុំ១វង់ នេះណាជាឧជុកម្ម? ណាជាអ្វី? ញែកមើល!

៨- អនុជុកម្ម គឺបទកម្មយ៉ាងណា? ឧទាហរណ៍ដូចម្ដេច?

៩- ឧទាហរណ៍ថា: ខ្ញុំទិញរថគេមួយ នេះយើងអាចផ្លាស់ទៅជាយ៉ាងម៉េច?

www.elibraryofcambodia.org

១០. ឧទាហរណ៍ថា : ខ្ញុំជួលក្របីគេមួយនឹម នេះណាជាអនុជុកម្ម? ណាជាអ្វី? ចូរញែកឲ្យស្រឡះ!

១១- វេលេក្ខកម្ម គឺបទកម្មយ៉ាងម៉េចខ្លះ? ឧទាហរណ៍យ៉ាងណា?

១២- គោណកម្ម គឺបទកម្មយ៉ាងម៉េច? ដូចឧទាហរណ៍យ៉ាងម៉េចខ្លះ?

១៣- វេគនកម្ម គឺបទកម្មយ៉ាងណា? បានដល់ឧទាហរណដូចម៉េចខ្លះ?

១៤- ប្រយោគកត្តុវាចកៈ ថា ខ្ញុំទិញគោគេមួយ នេះចូរក្រឡប់ទៅជាប្រយោគកម្មវាចកៈវិញ តើបានជាយ៉ាងណាខ្លះ? បទត្រង់ណាខ្លះ ជាវេគនកម្ម? ចូរញែកឲ្យស្រួលបួល!

១៥- កិរិយាវិសេសនកម្ម គឺបទកម្មយ៉ាងម៉េច? ចូរទាញឧទាហរណម.មើល!

## ៤- វិកត្តកិរិយា (១)

ពាក្យកិរិយាដែលមិនមានសេចក្ដីស្រេចក្នុងខ្លួនឯង សម្រាប

(១) អាន វិក កត្តកិរិយា

www.elibraryofcambodia.org

តែជាកភ្ជាប់នឹងពាក្យនាមនិងនាម ឬនាមនិងពាក្យគុណ ទើបបានជាប្រយោគសេចក្ដីឡើង ហៅថា វិកត្តកិរិយា; ពាក្យថា "វិក:" ប្រែថា "ទេ" ឬ "ចេញ"; "គត្ត" ប្រែថា "សេចក្ដី" ; កាលបើភ្ជាប់ជា "វិកត្ត" ប្រែថា "មានសេចក្ដីទទេ" ហើយបើភ្ជាប់ជាវិកត្តកិរិយា ក៏ប្រែថា "កិរិយាដែលមិនមានសេចក្ដីក្នុងខ្លួន" គឺកិរិយាដែលមិនមានសេចក្ដីស្រេចនៅក្នុងខ្លួនឯង ត្រូវអាស្រ័យសេចក្ដីរបស់សព្ទដែលនៅខាងចុងខ្លួនជាគោល នេះបានដល់ពាក្យទាំងឡាយថា: "ជា, ដូច, ប្រហែល, ស្រដៀង, ប៉ុន ជាដើម ដូចឃើញតទៅនេះ:

"ជា" ដូចប្រយោគថា: គេជាពេទ្យ, គេជាធំ, គេជាចៅហ្វាយស្រុក ។

"ដូច" ប្រយោគថា: គេដូចក្មេង, ក្មេងដូចឆ្កួត, គេដូចក, គេដូចស្រី, គឺដូចកុកទី ។

"ប្រហែល" ប្រយោគថា: គេប្រហែលខ្ញុំ, គោប្រហែលក្របី ។

"ស្រដៀង" ប្រយោគថា: អ្នកស្រដៀងកូនរបស់ខ្ញុំ, គេស្រដៀងអ្នក, ខ្ញុំស្រដៀងគេ ។

www.elibraryofcambodia.org

"ប៉ុន" ប្រយោគថា: គេប៉ុនមារបស់ខ្ញុំ, គីប៉ុនមាតាខ្ញុំ ។ សេចក្ដីសំខាន់នោះ នៅត្រង់ពាក្យសង្កាត់ខាងចុងឯណោះទេ គឺនៅត្រង់ពាក្យ "វែង, ធំ, ចៅហ្វាយស្រុក, ក្មេង, ស្រី, កិត្តិ, ខ្ញុំ, ក្របី, គេ, មា, មាតា" ។ ឯពាក្យកិរិយាដែលនៅខាងដើមនោះ គ្រាន់តែជួយជាទំនង សម្រាប់ឲ្យពាក្យសង្កាត់ខាងចុងទាំងនៅលម្អតែឲ្យសម្រេចរូបជាប្រយោគប៉ុណ្ណោះ ។

## វិញ្ញាសាបទទី ២២

១- ពាក្យកិរិយាយ៉ាងម៉េច ហៅថា វិក្កតកិរិយា? អធិប្បាយ!

២- វិក្កតកិរិយា សព្វដើមជាម៉េចខ្លះ? ញែកប្រែទៅមើល!

៣- វិក្កតកិរិយា សំដៅសេចក្ដីដូចម្ដេច? ចូរថាម.មើល!

៤- វិក្កតកិរិយា បានជាក់ពាក្យជាម៉េចខ្លះ? រាប់!

៥- "ជា" ជួយប្រយោគជាម៉េចខ្លះ? ចូរទាញ!

៦- "ដូច" ជាអ្វី? ជួយប្រយោគយ៉ាងណាខ្លះ ?

៧- "ប្រហែល" នេះជាអ្វីដែរ? ជួយប្រយោគឲ្យយ៉ាងៗណា?

៨- "ស្រដៀង" នេះដូចម្ដេច? ប្រយោគឲ្យយ៉ាងៗម៉េច?

៩- "[illegible]" នេះទុកជាអ្វី? ជួយប្រយោគយ៉ាងទៅណា ?

www.elibraryofcambodia.org

## ៥– កិរិយានុគ្រោះ (Verbe Auxiliaire)

ពាក្យកិរិយាមួយផ្នែក ដែលសម្រាប់តែជួយកិរិយាដទៃឲ្យមានសេចក្ដីគ្រប់គ្រាន់តាមរបៀបរបស់កិរិយា ហៅថា កិរិយានុគ្រោះ (Verbe Auxiliaire) ពាក្យថា "អនុគ្រោះ" ប្រែថា "ការជួយទំនុកបំរុង" បើភ្ជាប់នឹងកិរិយាផ្សំជា "កិរិយានុគ្រោះ" ប្រែថា "ការជួយទំនុកបំរុងកិរិយា" សំដៅសេចក្ដីដល់កិរិយាដែលប្រើជួយកិរិយាដទៃ ឲ្យបានសេចក្ដីគ្រប់គ្រាន់ តាមរបៀបរបស់កិរិយា គឺគ្រប់តាម មាលា, កាល, វាចក: ដូចនឹងស្ដែងក្នុងខាងមុខនេះបានដល់ពាក្យថា "គង់, នឹង, ត្រូវ, កុំ" ជាដើម ដូចក្នុងពាក្យនិយាយថា "គេគង់វាយខ្ញុំ, គេនឹងវាយខ្ញុំ, ខ្ញុំត្រូវគេវាយ, កុំធ្វើគេ" ដូច្នេះជាដើម ។ ពាក្យអម្បាលនេះ ច្រើនតែប្រកបនៅខាងមុខកិរិយា តែមានពាក្យពួកខ្លះ ក៏ប្រើប្រកបនៅខាងក្រោយកិរិយាដែរ ដូចពាក្យថា: "-ចុះ, -ហើយ" ជាដើម ។ ក្នុងពាក្យដូចជា: "អញ្ជើញចុះ! ទៅហើយ" ដូច្នេះជាដើម ហើយកិរិយានុគ្រោះនេះ ចែកចេញទៅតាមលក្ខណៈជា ២ ចំពូកទៀតគឺ

១ -ពួកដែលប្រើជាកិរិយានុគ្រោះតែមួយយ៉ាង មានដល់

ពាក្យថា: "គប្បី, ចូរ, កំពុង, រមែង, កុំ, កុំអាល ចឹង អម្បាលនេះ ជាដើម ។

២– ពួកកិរិយាដទៃដែលនិយមប្រើជាកិរិយានុគ្រោះ ដូចក្នុងសេចក្តីតទៅនេះជាដើម :

| កិរិយា | ប្រើជាកិរិយាដទៃ | ប្រើជាកិរិយានុគ្រោះ |
|---|---|---|
| គង់ | ព្រះរាជាគង់ក្នុងវាំង | គេគង់ធ្វើ |
| ត្រូវ | របស់នេះត្រូវភ្នែកខ្ញុំ | គេត្រូវដេក |
| បាន | គេបានប្រាក់ច្រើន | គេបានទៅហើយ |
| ឲ្យ | គេឲ្យប្រាក់ខ្ញុំ | គេឲ្យខ្ញុំដេក |
| នៅ | គេនៅក្នុងបន្ទប់ | គេនៅមិនទាន់ទៅ |
| ធ្លាប់ | គេធ្លាប់ហើយ | គេធ្លាប់មកជាប្រកប |
| ដែល | ខ្ញុំដែលហើយ | គេដែលទៅដែរ |
| ហើយ | ការធ្វើហើយពីព្រឹក | គេធើហើយ |

វិធីសង្កេត ៖ ពាក្យកិរិយានុគ្រោះ ត្រូវជាពាក្យកិរិយា ២ ពីពួកដូចខាងលើនេះ ដែលនាំមកប្រើជួយកិរិយាដទៃ ឲ្យមានសេចក្តីពេញលេញ តាមភ្នាក់ងាររបស់កិរិយាគឺ មាលា, កាល,

www.elibraryofcambodia.org

កំបក: ដូចពោលម.ហើយ មិនមែនពាក្យកិរិយា ឬពាក្យដទៃដែលនាំម. ប្រើជាពាក្យកិរិយាវិសេសនៈ ប្រកបកិរិយាឲ្យមានសេចក្ដីផ្ទុកចេញទៅដូច: "គាត់ស៊ីទ្លាយអស់, យាយសកយកយធ្លាស្លាប់, តាទៅមិនម." ជាដើមដូច្នេះៈនោះទេ ៗ ពាក្យថា "អស់, ស្លាប់, មិន" ក្ដីទាំងនេះ មិនមែនជាកិរិយានុគ្រោះឡើយ ៗ

## វិញ្ញាសាបទទី ២៣

១- កិរិយាយ៉ាងម៉េចដែលហៅថា កិរិយានុគ្រោះ?

២- អនុគ្រោះ ប្រែថាម៉េច? កិរិយានុគ្រោះបានសេចក្ដីយ៉ាងណា?

៣- កិរិយានុគ្រោះ សំដៅដល់កិរិយាយ៉ាងម៉េច? បានដល់ពាក្យយ៉ាងណា?

៤- ពាក្យកិរិយានុគ្រោះទាំងនេះ ត្រូវរៀងនៅខាងណាកិរិយាដែលត្រូវជួយនោះ?

៥- កិរិយានុគ្រោះចែកចេញជាប៉ុន្មានពួក ? អ្វីខ្លះ ? ហើយពួកណាជាយ៉ាងណា? រ.តួយ៉ាងចងជាសេចក្ដីម.ក្នុងមួយពួក ១ ឲ្យបានបីយ៉ាង!

www.elibraryofcambodia.org

៦- កិរិយានុគ្រោះ ខុសពីពាក្យដែលប្រកបកិរិយាដទៃយ៉ាងណា? អធិប្បាយ !

៧- ពាក្យក្នុងសេចក្តីតទៅនេះ ណាជាពាក្យកិរិយាពួកណា? សង្កេតបានយ៉ាងម៉េច?

ក) គេមិនរកក្រសម្អាត ទើបកើតកេរ្តិ៍ឈ្មោះ ។

ខ) គេខ្លាចខ្ញុំគ្រាន់បើជាងគេ បានជាគេមិនប្រាប់វិជ្ជាដល់ខ្ញុំ ។

## ៦- កត្តុកិរិយា (Verbe Actif)

ពាក្យកិរិយាឯណាដែលស្តែងប្រាប់សេចក្តីថា ប្រធានរបស់ខ្លួនជាអ្នកសម្រេចនូវទំហើ ដោយខ្លួនឯង មិនបានប្រើបុគ្គលដទៃ ឲ្យសម្រេចជួសខ្លួនទេ កិរិយានោះ ហៅថា កត្តុកិរិយា (Verbe Actif) នេះបានដល់ពាក្យកិរិយារបស់អ្នកធើ ដែលធើ ត្រូវធើខ្លួនឯង មិនបានប្រើអ្នកឯទៀតឲ្យធើជួសខ្លួនទេ ដូចជា: "ដេក, ដើរ, ឈរ, ស៊ី, ផឹក" ជាដើមនេះ តួប្រធានរបស់កិរិយាទាំងនុះ "ដេក" ខ្លួនឯង មិនបានប្រើឲ្យអ្នកណា "ដេក" ជួស; "ដើរ" ខ្លួនឯង មិនបានបង្គាប់ឲ្យគេ "ដើរ" ជួស; "ឈរ" ខ្លួនឯង មិនបានញ៉ាំងអ្នកណាឲ្យ "ឈរ" ជួស; "ស៊ី"

www.elibraryofcambodia.org

ខ្លួនឯង មិនបានប្រើអ្នកដទៃឲ្យ "ស៊ី" ជួស; "ផឹក" ខ្លួនឯងមិនបាន បង្គាប់អ្នកឯទៀតឲ្យគេ "ផឹក" ជួស ។ កិរិយាបែបនេះឯងហៅថា កត្តុកិរិយា ព្រោះវាស្តែង(១)ប្រាប់គេឲ្យដឹងសេចក្តីថា: បទប្រធានរបស់ ខ្លួននោះ ជាអ្នកសម្រេចនូវទំហើដោយខ្លួនឯង មិនមែនប្រើ ឬបង្គាប់អ្នកដទៃ ឲ្យសម្រេចនូវទំហើខ្លួនឯងឡើយ ។ បទប្រធាន ឯណា ទោះបីជាពាក្យនាមក្តី ជាពាក្យសព្វនាមក្តី បើប្រកបចូល នឹងបទកត្តុកិរិយាដូច្នេះ បទប្រធាននោះ ហៅថា សយកត្តា ឬសយកត្តុបមា ។

## វគ្គសភាបធធី ២៤

១. ពាក្យកត្តុកិរិយា បានសេចក្តីដូចម្តេច? អធិប្បាយ!

២- កត្តុកិរិយាបានដល់ពាក្យកិរិយាយ៉ាងម៉េចខ្លះ?

៣- ដេក, ដើរ, ឈរ, ស៊ី, ផឹក អម្បាលនេះ ហេតុដូចម្តេចបានជាហៅថា កត្តុកិរិយា? អធិប្បាយមួយបទម្តងៗ!

៤- កត្តុកិរិយានេះសំដៅទៅតែសកម្មកិរិយា ឬអកម្មកិរិយា?

៥- បទប្រធានរបស់កត្តុកិរិយានោះ ហៅថា អ្វី ? ព្រោះអ្វី?

(១) ស្តែង កិរិយា, សំដែង តាម ដូច ស្ដី សំដី

www.elibraryofcambodia.org

## ៧- ហេតុកត្តុកិរិយា

ពាក្យកិរិយាដែលសំដែងប្រាប់សេចក្ដីថា បទប្រធានរបស់ខ្លួនជាអ្នកគ្រាន់តែប្រើគេឲ្យសម្រេចនូវទង្វើ គឺថាមិនធ្វើអ្វីៗ គ្រប់យ៉ាងដោយខ្លួនឯងឡើយ គ្រាន់តែប្រើ [illegible] អ្នកដទៃ ឲ្យសម្រេចនូវទង្វើអ្វីៗ គ្រប់យ៉ាង [illegible] ពាក្យកិរិយានោះហៅថា ហេតុកត្តុកិរិយា [illegible] ទាំងឡាយថា: “ផ្ដេក, បណ្ដើរ, បញ្ឈរ, [illegible], បំ[illegible]” ជាដើមនេះ គឺគ្រប់ប្រធានរបស់កិរិយាអម្បាលនេះឯង មិនបានសម្រេចនូវទង្វើអ្វី ដោយខ្លួនឯង សុទ្ធតែប្រើគេឲ្យសម្រេចជួសខ្លួនទាំងអស់ ឯខ្លួនគ្រាន់តែជាអ្នកប្រើប៉ុណ្ណោះ គឺពាក្យកិរិយាថា “ផ្ដេក” នេះ អ្នកម្ចាស់ខ្លួនមិនបានដេកដោយខ្លួនឯងឡើយ ប្រាកដជាប្រើអ្នកដទៃណាមួយឲ្យដេកជួសខ្លួន ដូចជា: “មាតាផ្ដេកកូន” ; ពាក្យកិរិយាថា: “បំបួស” នេះ អ្នកសាមីខ្លួនក៏មិនបានបួសដោយខ្លួនឯងដែរ ជាក់ជាប្រើបុគ្គលឯទៀតឲ្យបួសជួស ឯខ្លួនគ្រាន់តែចាយ.គ្រឿងបរិក្ខារ ឬត្រៃចីវរ ទៅឲ្យបួសប៉ុណ្ណោះ ដូចជា: “មាតាបំបួសកូន”; ពាក្យកិរិយាថា: “បញ្ឈរ” នេះ ក៏អ្នកម្ចាស់ខ្លួនមិនបានឈរដោយ

www.elibraryofcambodia.org

ខ្លួនឯងដែរ គ្រាន់តែប្រើគេឲ្យឈរជួសខ្លួនប៉ុណ្ណោះ ដូចជា: "បិតាបញ្ឈរកូន"; ពាក្យថា: "បន្ស៊ី" នេះ ក៏អ្នកសាមីខ្លួនមិនបានស៊ីដោយខ្លួនឯងដែរ គឺប្រាកដជាប្រើអ្នកដទៃឲ្យស៊ីជួសខ្លួនប៉ុណ្ណោះ ដូចពាក្យថា: "ក្មេងបន្ស៊ីគោតាមភ្លឺស្រែ", ពាក្យកិរិយាថា: "បំផឹក" នេះ ក៏អ្នកម្ចាស់ខ្លួនមិនបានផឹកដោយខ្លួនឯងដែរ គ្រាន់តែបង្គាប់ ឬបង្ខំអ្នកឯទៀត ឲ្យផឹកជួសខ្លួនប៉ុណ្ណោះ ដូចពាក្យថា: "គេបំផឹកគោក្បែរអណ្តូង" ។ ឧទាហរណ៍ទាំងនេះគឺ "មាតាផ្តេកកូន, មាតាបំបួសកូន, បិតាបញ្ឈរកូន, ក្មេងបន្ស៊ីគោតាមភ្លឺស្រែ, គេបំផឹកគោក្បែរអណ្តូង" បើប្រសិនជាប្រែឲ្យឆ្ងាយស្តាប់ទៅក៏គឺ មាតាញុំាងកូនឲ្យដេក ឬដាក់កូនឲ្យដេក, មាតារៀបចំឲ្យកូនបួស ឬញុំាងកូនឲ្យបួស, បិតាញុំាងកូនឲ្យឈរ ឬលើកកូនឲ្យឈរ, ក្មេងញុំាងគោឲ្យស៊ីតាមភ្លឺស្រែ ឬកាន់គោឲ្យស៊ី, គេញុំាងគោឲ្យផឹកទឹកក្បែរអណ្តូង ឬដងទឹកឲ្យគោផឹក ។ ដោយហេតុកិរិយានេះ សុទ្ធតែញុំាងអ្នកដទៃ ឲ្យធ្វើដូច្នេះហើយ បានជាហៅថា ហេតុកត្តុកិរិយា ។ បទប្រធានរបស់កិរិយានេះ ហៅថា ហេតុកត្តា ឬហេតុកត្តុបយោគ ។

www.elibraryofcambodia.org

ពាក្យ "ហេតុកត្តុកិរិយា" នេះ ជាគូនឹងកត្តុកិរិយា គឺថ. បើពាក្យកត្តុកិរិយាមានហើយ ពាក្យហេតុកត្តុកិរិយាក៏ត្រូវមានដូចគ្នា គឺត្រូវផ្លាស់កត្តុកិរិយានោះឯងជាហេតុកត្តុកិរិយា ប៉ុន្តែ កត្តុ-កិរិយាមានជាសកម្មកិរិយា, ជាអកម្មកិរិយា នឹងជាសកម្មាកម្មកិរិយា ឯហេតុកត្តុកិរិយា មានតែជាសកម្មកិរិយាមួយយ៉ាង កត្តុកិរិយា ជាអកម្មកិរិយា វេលាផ្លាស់ម. ជាហេតុកត្តុកិរិយាហើយ ក៏ក្លាយទៅសកម្មកិរិយាវិញ ដូចឧទាហរណ៍កត្តុកិរិយាថា : "បក្សីហើរ" កាលណាម. ជាហេតុកត្តុកិរិយាក៏ទៅជា "គេបង្ហើរខ្លែង" ។

ការផ្លាស់កត្តុកិរិយាជាហេតុកត្តុកិរិយាមាន ១៤ យ៉ាងគឺ

១- ចំពោះកត្តុកិរិយាដែលជាព្យញ្ជនវគ្គ ២០ តួណាមួយ ត្រូវថែមពាក្យថា: "បំ" នៅខាងដើមនៃកត្តុកិរិយា ទាំងឡាយដែលត្រូវផ្លាស់នោះ រួចហើយត្រូវផ្លាស់និគ្គហិតរបស់ "បំ" នោះជាព្យញ្ជនវគ្គន្ត: គឺព្យញ្ជនៈចុងបំផុតវគ្គទាំង ៥ តួ បានដល់ ង, ញ, ណ, ន, ម; ហើយដាក់តម្រួតលើព្យញ្ជនៈក្នុងវគ្គរបស់ខ្លួន ១ គឺដាក់លើកត្តុកិរិយានោះឯង, ដូច :

ក) កត្តុកិរិយា ជាព្យញ្ជនៈ កវគ្គ: ត្រូវផ្លាស់និគ្គហិតជា "ង"

www.elibraryofcambodia.org

តម្រួតលើព្យញ្ជនៈកវគ្គៈនោះៗតាមសមគួរ;

ខ) កត្តកិរិយាជាព្យញ្ជនៈចវគ្គៈត្រូវផ្លាស់និគ្គហិតជា "ញ" តម្រួតលើព្យញ្ជនៈ ចវគ្គៈនោះៗ តាមសមគួរ;

គ) កត្តកិរិយាជាព្យញ្ជនៈដវគ្គៈ ត្រូវផ្លាស់និគ្គហិតជា "ណ" តម្រួតលើព្យញ្ជនៈ ដវគ្គៈនោះៗ តាមសមគួរ;

ឃ) កត្តកិរិយាជាព្យញ្ជនៈ តវគ្គៈ ត្រូវផ្លាស់និគ្គហិតជា "ន" តម្រួតលើព្យញ្ជនៈ តវគ្គៈនោះៗ តាមសមគួរ;

ង) កត្តកិរិយាជាព្យញ្ជនៈ បវគ្គៈ ត្រូវផ្លាស់និគ្គហិតជា "ម" តម្រួតលើព្យញ្ជនៈបវគ្គៈនោះៗ តាមសមគួរ;

៤. ចំពោះកត្តកិរិយាដែលជាព្យញ្ជនៈ សេសវគ្គៈ ៨ តួណាមួយ, ត្រូវថែមពាក្យថា "បំ" ទៅខាងដើមនៃកត្តកិរិយាទាំងឡាយដែលត្រូវផ្លាស់នោះ រួចហើយត្រូវផ្លាស់និគ្គហិតរបស់ "បំ" នោះជា "ង, ន, ម" តាមសមគួរដល់ការប្រកប ដូច :

ក) កត្តកិរិយាជាព្យញ្ជនៈ អវគ្គៈ "យ" ត្រូវផ្លាស់និគ្គហិតជា "ន" តម្រួតលើ "យ" នោះ ឬផ្លាស់ "បំ" ជា "ពិ" សិនហើយសឹមផ្លាស់និគ្គហិតជាខាងក្រោយ តម្រួតលើ "យ" ដូចគ្នា;

www.elibraryofcambodia.org

ខ) កត្តុកិរិយាជាព្យញ្ជនៈ អវគ្គៈ "រ" ត្រូវផ្លាស់និគ្គហិតជា "ង" តម្រួតលើ "រ" នោះ ឬផ្លាស់ "បំ" ជា "ពំ" សិនហើយ សឹមផ្លាស់និគ្គហិតជាខាងក្រោយ តម្រួតលើ "រ" ដូចគ្នា;

គ) កត្តុកិរិយាជាព្យញ្ជនៈ អវគ្គៈ "ល" ត្រូវផ្លាស់និគ្គហិតជា "ន" តម្រួតលើ "ល" នោះ ឬផ្លាស់ "បំ" ជា "ពំ" សិនហើយ សឹមផ្លាស់និគ្គហិតជាខាងក្រោយ តម្រួតលើ "ល" ដូចគ្នា;

ឃ) កត្តុកិរិយាជាព្យញ្ជនៈ អវគ្គៈ "វ" ត្រូវផ្លាស់និគ្គហិតជា "ង" តម្រួតលើ "វ" នោះ ឬផ្លាស់ "បំ" ជា "ពំ" សិនហើយ សឹមផ្លាស់និគ្គហិតជាខាងក្រោយ រួចតម្រួតលើ "វ" ដូចគ្នា;

ង) កត្តុកិរិយាជាព្យញ្ជនៈ អវគ្គៈ "ស" ត្រូវផ្លាស់និគ្គហិតជា "ន" តម្រួតលើ "ស" នោះតាមសមគួរ;

ច) កត្តុកិរិយាជាព្យញ្ជនៈ អវគ្គៈ "ហ" ត្រូវផ្លាស់និគ្គហិតជា "ង" តម្រួតលើ "ហ" នោះ ឬផ្លាស់ "បំ" ជា "ពំ" សិនហើយ សឹមផ្លាស់និគ្គហិតជាខាងក្រោយ តម្រួតលើ "ហ" ដូចគ្នា;

www.elibraryofcambodia.org

ឆ) កត្តុកិរិយាជាព្យញ្ជនៈ អក្ខរៈ "ឡ" ត្រូវផ្លាស់និគ្គហិតជា "ង" ហើយផ្លាស់ "ឡ" ជាជើង "ល" រួចសឹមត្រួត "ង" លើជើង "ល" នោះ តាមសមគួរដល់ការប្រកប;

ជ) កត្តុកិរិយាជាព្យញ្ជនៈ អក្ខរៈ "អ" ត្រូវផ្លាស់និគ្គហិតជា "ង" ត្រួតលើ "អ" នោះ តាមសមគួរដល់ការប្រកប ។

៣. ត្រូវថែមព្យញ្ជនៈ "ប" ដាក់ខាងដើមនៃកត្តុកិរិយាកន្លងកាលដែលត្រូវផ្លាស់ឲ្យទៅជាហេតុកត្តុកិរិយា ហើយត្រូវផ្លាស់តួព្យញ្ជនៈកត្តុកិរិយានោះជាជើង រួចដាក់តួ "ប" នោះត្រួតពីលើឲ្យទៅជាជើងដើម តាមគួរដល់ការប្រកប;

៤. ត្រូវថែម "ប្រ" ខាងដើមនៃកត្តុកិរិយាកន្លងកាលដែលត្រូវការផ្លាស់កត្តុកិរិយាឲ្យទៅជាហេតុកត្តុកិរិយា;

៥. ត្រូវថែមព្យញ្ជនៈ "ផ" ដាក់ខាងដើមនៃកត្តុកិរិយាកន្លងកាលដែលត្រូវផ្លាស់ឲ្យទៅជាហេតុកត្តុកិរិយា ហើយត្រូវផ្លាស់តួព្យញ្ជនៈកត្តុកិរិយានោះជាជើង រួចដាក់តួ "ផ" នោះ ត្រួតពីលើ ឲ្យទៅជាជើងដើម តាមសមគួរដល់ការប្រកប;

៦. ត្រូវថែម "ព្រ" ខាងដើមនៃកត្តុកិរិយា កន្លងកាល

www.elibraryofcambodia.org

ដែលត្រូវការផ្លាស់កត្តុកិរិយានោះ ឲ្យទៅជាហេតុកត្តុកិរិយា;

៧. ត្រូវថែមព្យញ្ជនៈ "ក" ដាក់ខាងដើមនៃកត្តុកិរិយា ក្នុងកាលដែលត្រូវផ្លាស់ឲ្យទៅជាហេតុកត្តុកិរិយា ហើយត្រូវផ្លាស់តួព្យញ្ជនៈ កត្តុកិរិយានោះ ជាជើង រួចដាក់តួ "ក" នោះតម្រួតពីលើ ឲ្យទៅជាជើងជើង តាមតួដែលការប្រកប;

៨. បើកត្តុកិរិយាជាព្យញ្ជនៈទី១ ក្នុងវគ្គៈទាំង ៥ គឺ ក, ច, ដ, ត, ប តម្រួតលើព្យញ្ជនៈឯទៀតនោះ ត្រូវថែម កំ, ចំ, ដំ, តំ, បំ ដាក់ខាងដើមព្យញ្ជនៈទាំងនោះ ហើយលុបព្យញ្ជនៈទី១ ដែលតម្រួតលើព្យញ្ជនៈឯទៀតនោះចេញ រួចផ្លាស់និគ្គហិតព្យញ្ជនៈថែមនោះជា "ម" តម្រួតលើជើងព្យញ្ជនៈឯទៀតនោះក៏បាន មិនបាច់ផ្លាស់និគ្គហិត គ្រាន់តែធើជើងព្យញ្ជនៈឯទៀតនោះឲ្យជាតួព្យញ្ជនៈឡើងក៏បាន :

ក) កត្តុកិរិយាជាព្យញ្ជនៈទី១ ក្នុងវគ្គទី១ តម្រួតលើតួឯទៀត ត្រូវថែម "កំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា ។

ខ) កត្តុកិរិយាជាព្យញ្ជនៈទី១ ក្នុងវគ្គទី២ តម្រួតលើតួឯទៀត ត្រូវថែម "ចំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

www.elibraryofcambodia.org

គ) កត្តុកិរិយាជាព្យញ្ជនៈទី១ ក្នុងវគ្គទី៣ តម្រួតលើគ្នាឯទៀត ត្រូវថែម "ជំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

ឃ) កត្តុកិរិយាជាព្យញ្ជនៈទី១ ក្នុងវគ្គទី៤ តម្រួតលើគ្នាឯទៀត ត្រូវថែម "តំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

ង) កត្តុកិរិយាជាព្យញ្ជនៈទី១ ក្នុងវគ្គទី៥ តម្រួតលើគ្នាឯទៀត ត្រូវថែម "បំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា ។

៤. បើកត្តុកិរិយាជាព្យញ្ជនៈទី២ ក្នុងវគ្គទាំង ៥ គឺ ខ, ឆ, ឋ, ថ, ផ តម្រួតលើព្យញ្ជនៈឯទៀតនោះ ត្រូវថែម កំ, ចំ, ដំ, តំ, បំ នៅខាងដើម ហើយលុបព្យញ្ជនៈទី២ នោះចេញ ទុកតែព្យញ្ជនៈតួក្រោម រួចផ្លាស់និគ្គហិតជា "ម" តម្រួតលើព្យញ្ជនៈតួក្រោមនោះ និគ្គហិតនោះ បើមិនផ្លាស់ក៏បាន គ្រាន់តែលុបព្យញ្ជនៈលើ ហើយសម្រួលជើងព្យញ្ជនៈក្រោមឲ្យស្រួលប៉ុណ្ណោះ ៖

ក) កត្តុកិរិយាជាព្យញ្ជនៈទី២ ក្នុងវគ្គទី១ តម្រួតលើគ្នាឯទៀត ត្រូវថែម "កំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

ខ) កត្តុកិរិយាជាព្យញ្ជនៈទី២ ក្នុងវគ្គទី២ តម្រួតលើគ្នាឯទៀត

www.elibraryofcambodia.org

ត្រូវថែម "ចំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

គ) កត្តុកិរិយាជាព្យញ្ជនៈទី២ ក្នុងវគ្គទី៣ តម្រួតលើគ្នាឯទៀត ត្រូវថែម "ដំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

ឃ) កត្តុកិរិយាជាព្យញ្ជនៈទី ២ក្នុងវគ្គទី៤តម្រួតលើគ្នាឯទៀត ត្រូវថែម "តំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា,

ង) កត្តុកិរិយាជាព្យញ្ជនៈទី២ ក្នុងវគ្គទី៥តម្រួតលើគ្នាឯទៀត ត្រូវថែម "បំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា ។

១០- បើកត្តុកិរិយាជាព្យញ្ជនៈទី ៣ ក្នុងវគ្គទាំង ៥ គឺ គ, ជ, ឌ, ទ, ព តម្រួតលើព្យញ្ជនៈឯទៀតនោះ ត្រូវថែម គំ, ជំ, ឌំ, ទំ, ពំ ជាក់ខាងដើមនៃព្យញ្ជនៈទី ៣ នោះ។ ហើយលុបព្យញ្ជនៈទី ៣ ដែលតម្រួតលើព្យញ្ជនៈឯទៀតនោះចេញ រួចផ្លាស់និគ្គហិត ថែមជា "ម" តម្រួតលើជើងព្យញ្ជនៈឯទៀតនោះក៏បាន, មិនបាច់ផ្លាស់និគ្គហិត គ្រាន់តែដាក់ជើងព្យញ្ជនៈឯទៀតនោះ ឲ្យជាគូព្យញ្ជនៈឡើងក៏បាន :

ក) កត្តុកិរិយាជាព្យញ្ជនៈទី ៣ ក្នុងវគ្គទី ១ គឺ "គ" តម្រួតលើគ្នាឯទៀត ត្រូវថែម "គំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជា

www.elibraryofcambodia.org

ហេតុកត្តុកិរិយា ;

ខ) កត្តុកិរិយាជាព្យញ្ជនៈទី ៣ ក្នុងវគ្គទី ២ គឺ "ជ" តម្រួតលើតួឯទៀត ត្រូវថែម "ជំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុ-កត្តុកិរិយា ;

គ) កត្តុកិរិយាជាព្យញ្ជនៈទី ៣ ក្នុងវគ្គទី ៣ គឺ "ឌ" តម្រួតលើតួឯទៀត ត្រូវថែម "ឌំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា ;

ឃ) កត្តុកិរិយាជាព្យញ្ជនៈទី ៣ ក្នុងវគ្គទី ៤ គឺ "ទ" តម្រួតលើតួឯទៀត ត្រូវថែម "ទំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា ;

ង) កត្តុកិរិយាជាព្យញ្ជនៈទី ៣ ក្នុងវគ្គទី ៥ គឺ "ព" តម្រួតលើតួឯទៀត ត្រូវថែម "ពំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា ។

១០- បើកត្តុកិរិយាជាព្យញ្ជនៈទី ៤ ក្នុងវគ្គទាំង ៥ គឺ ឃ, ឈ, ឍ, ធ, ភ តម្រួតលើព្យញ្ជនៈឯទៀតនោះ ត្រូវថែម គំ, ជំ, ឌំ, ទំ, ពំ នៅខាងដើមនៃកិរិយានោះ ។ ហើយលុបព្យញ្ជនៈទី ៤

www.elibraryofcambodia.org

នោះចេញ ទុកតែព្យញ្ជនៈតួក្រោម រួចផ្លាស់និគ្គហិតជា "ម" ត្រួតលើព្យញ្ជនៈតួក្រោមនោះ, និគ្គហិតនោះ បើមិនបានផ្លាស់ក៏បាន គ្រាន់តែលុបព្យញ្ជនៈតួលើចេញ ហើយផ្លាស់ជើងព្យញ្ជនៈក្រោមនោះ ឲ្យជាតួព្យញ្ជនៈឡើងប៉ុណ្ណោះ :

ក) កត្តុកិរិយាជាព្យញ្ជនៈវគ្គ ក្នុងវគ្គទី ១ គឺ "ឃ" ត្រួតលើតួឯទៀត ត្រូវថែម "ំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

ខ) កត្តុកិរិយាជាព្យញ្ជនៈវគ្គ ក្នុងវគ្គទី២ គឺ "ឈ" ត្រួតលើតួឯទៀត ត្រូវថែម "ំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

គ) កត្តុកិរិយាជាព្យញ្ជនៈវគ្គ ក្នុងវគ្គទី ៣ គឺ "ឍ" ត្រួតលើតួឯទៀត ត្រូវថែម "ំ" ក្នុងកាលដែត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

ឃ) កត្តុកិរិយាជាព្យញ្ជនៈវគ្គ ក្នុងវគ្គទី៤ គឺ "ធ" ត្រួតលើតួឯទៀត ត្រូវថែម "ំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា;

www.elibraryofcambodia.org

ឆ) កត្តុកិរិយាជាព្យញ្ជនៈទី៤ ក្នុងវគ្គទី៥ គឺ "ក" តម្រួតលើគ្នាឯទៀត ត្រូវថែម "ពំ" ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុ-កត្តុកិរិយា ;

១៤. បើកត្តុកិរិយាជាព្យញ្ជនៈអវគ្គៈ តម្រួតលើព្យញ្ជនៈឯទៀត នោះ ព្យញ្ជនៈអវគ្គៈជាតួអ្វី ក៏ត្រូវថែមតួនោះមាននិគ្គហិតនៅលើ ដាក់ខាងដើមនៃកត្តុកិរិយានោះ ។ ហើយលុបតួព្យញ្ជនៈអវគ្គៈដែលតម្រួតលើព្យញ្ជនៈឯទៀតនោះ ទុកតែព្យញ្ជនៈតួក្រោម រួចផ្លាប់និគ្គហិតលើព្យញ្ជនៈអវគ្គៈ ដែលថែមម ខាងដើមនោះជាតួ "ម" តម្រួតលើព្យញ្ជនៈតួក្រោមដែលនៅសល់នោះ ឲ្យអា-ស្រ័យទឹងសរៈដែលព្យញ្ជនៈមុនអាស្រ័យនោះឯង ឬនិគ្គហិតនោះ បើមិនបាច់ផ្លាប់ ទុកឲ្យនៅដូចដែលក៏បាន គ្រាន់តែលុបតួព្យញ្ជនៈអវគ្គៈដែលនៅអាស្រ័យលើគេនោះ ហើយផ្លាស់ដើមព្យញ្ជនៈនោះឲ្យជាតួព្យញ្ជនៈឡើង រួចឲ្យអាស្រ័យទឹងសរៈដែលព្យញ្ជនៈអវគ្គៈមុនបានអាស្រ័យនោះឯង :

ក) កត្តុកិរិយាជាព្យញ្ជនៈអវគ្គៈគឺ "ល" តម្រួតលើគ្នាឯទៀត ត្រូវថែម "លំ" ដាក់ខាងដើម ក្នុងកាលដែលត្រូវផ្លាស់ទៅជា

www.elibraryofcambodia.org

ហេតុកត្តុកិរិយា ;

១) កត្តុកិរិយាជាព្យញ្ជនៈអវគ្គៈ គឺ "ស" កម្រងលើគ្នងទៀត ត្រូវថែម "សំ" ដាក់ខាងដើម ក្នុងកាលដែលត្រូវផ្លាស់ទៅជាហេតុកត្តុកិរិយា ។

១៣- កត្តុកិរិយាដែលមានអក្សរ "រ" នៅខាងដើម ហើយខាងចុងមានព្យញ្ជនៈរ៉ូ ១ ថែមទៀត វេលាផ្លាស់ទៅជាហេតុកត្តុ-កិរិយាត្រូវថែម "រំ" ដាក់ខាងដើម ហើយលុប "រ" ដែលជាតួកិរិយាដើមនោះចេញ;

១៤- កត្តុកិរិយាដែលជាតួព្យញ្ជនៈ "ល" វេលាផ្លាស់ទៅជាហេតុកត្តុកិរិយា អាចនឹងថែម "រំ" ដាក់ខាងដើមក៏បានខ្លះ សម្បីកត្តុកិរិយាជាព្យញ្ជនៈដទៃក្រៅពី "ល" ក៏ដាក់ "រំ" ខាងដើមបានខ្លះដែរ តែមានតិច;

១៥- កត្តុកិរិយាដែលមាន "អ" នៅខាងដើម ហើយខាងចុងមានព្យញ្ជនៈផ្សេងទៀត វេលាផ្លាស់ទៅជាហេតុកត្តុកិរិយា ត្រូវថែម "ប" កម្រងលើ "អ" ផ្សំគ្នាស្របតែម្តង :

www.elibraryofcambodia.org

# ឥក្ខសរាបទទី ២៥

១- កិរិយាយ៉ាងណាហៅថា ហេតុកត្តុកិរិយា?

២- ហេតុកត្តុកិរិយា ផ្សេងពីកត្តុកិរិយាយ៉ាងណា?

៣- ហេតុកត្តុកិរិយា បានដល់ពាក្យកិរិយាជាម៉េច?

៤- ពាក្យកិរិយាថា: ផ្ដេក, បណ្ដើរ, បញ្ឈរ, បង្ស៊ី, បំផឹក នេះមានសេចក្ដីខុសគ្នាពីពាក្យកិរិយាថា: ដេក, ដើរ, ឈរ, ស៊ី, ផឹក ដូចម្ដេច? ចូរអធិប្បាយឲ្យសព្វគ្រប់!

៥- តួប្រធានរបស់កត្តុកិរិយា និងហេតុកត្តុកិរិយាផ្សេងគ្នាដូចម្ដេច? របស់ហេតុកត្តុកិរិយា មានឈ្មោះយ៉ាងណា?

៦- ហេតុកត្តុកិរិយា ជាគូគ្នានឹងកិរិយាអ្វី?

៧- អកម្មកិរិយានិងសកម្មាកម្មកិរិយា ក្នុងហេតុកត្តុកិរិយា មានឬទេ? ព្រោះហេតុអ្វី?

៨- បើកត្តុកិរិយាជាអកម្មកិរិយា វេលាផ្លាស់ទៅជាហេតុកត្តុ-កិរិយាក្លាយទៅជាអ្វីទៅវិញ? ដូចឧទាហរណ៍យ៉ាងណា?

៩- វិធីផ្លាស់កត្តុកិរិយាទៅជាហេតុកត្តុកិរិយាមានប៉ុន្មានយ៉ាង?

១០- កត្តុកិរិយាជាព្យញ្ជនៈអ្វី ទើបដាក់ "បំ" ម.ខាងដើមបាន?

www.elibraryofcambodia.org

១១- ព្យញ្ជនៈ វគ្គៈ គឺព្យញ្ជនៈដូចម្តេច? បានដល់ព្យញ្ជនៈណាខ្លះ ?

១២- កត្តុកិរិយាដែលដាក់ "បំ" ម.ខាងដើមហើយ, និគ្គហិតរបស់ "បំ" នោះ ត្រូវផ្លាស់ទៅជាព្យញ្ជនៈអ្វីបានខ្លះ?

១៣- ដែលមិនផ្លាស់និគ្គហិតរបស់ "បំ" ទៅជា "ង" បាននោះ តើព្រោះមានព្យញ្ជនៈអ្វី នៅខាងចុង?

១៤. និគ្គហិតរបស់ "បំ" ដែលមិនផ្លាស់ទៅជា "ញ" បាននោះ តើដោយមានអ្វីនៅខាងចុង?

១៥- ដែលអាចផ្លាស់និគ្គហិតរបស់ "បំ" ទៅជា "ណ" បាននោះ តើព្រោះមានអ្វីនៅខាងចុង ?

១៦- និគ្គហិតរបស់ "បំ" ដែលអាចផ្លាស់ជា "ន" បានតើដោយហេតុមានអ្វីនៅខាងចុង ?

១៧- មានព្យញ្ជនៈអ្វីនៅខាងចុងខ្លះ ទើបមិនអាចផ្លាស់និគ្គហិតរបស់ "បំ" ជា "ម" បាន ?

១៨- កត្តុកិរិយាជាព្យញ្ជនៈ អវគ្គៈ វេលាផ្លាស់ទៅជាហេតុកត្តុកិរិយា ត្រូវថែមអ្វីម.ខាងដើម ?

www.elibraryofcambodia.org

១៩- កត្តុកិរិយាជា "យ" ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ? ហើយផ្លាស់អ្វីជាអ្វី ?

២០- "រ" ជាតួកត្តុកិរិយា ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ? ហើយផ្លាស់អ្វីជាអ្វី ?

២១- កត្តុកិរិយាភាគក់ចង់ដោយ "ល" ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ? ហើយផ្លាស់អ្វីជាអ្វី ?

២២- តួ "វ" ជាកត្តុកិរិយា ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ? ហើយផ្លាស់អ្វីជាអ្វីបានទៀត ?

២៣- កត្តុកិរិយាជាព្យញ្ជនៈ អវគ្គៈ "ស" ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ? ហើយផ្លាស់អ្វីជាអ្វីបានទៀតឬទេ?

២៤- កត្តុកិរិយាជាតួ "ហ" ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ? ហើយផ្លាស់អ្វីជាអ្វីទៀត ?

២៥- កត្តុកិរិយាជាតួ "ឡ" ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ? ហើយផ្លាស់អ្វីជាអ្វី ?

២៦- កត្តុកិរិយាជា "អ" ត្រូវផ្លាស់និគ្គហិតរបស់ "បំ" ជាអ្វី ?

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្ចៅ យ៉ាតណៃ, ខ្ចៅ សុផល, ខ្ចៅ វិសាល, ខ្ចៅ រ៉ាមុន, ខ្ចៅ ភារាជា, ខ្ចៅ ចំរើន និង ខ្ចៅ ភារី
បានឧបត្ថមការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ពាញ និង ឧបាសិកា ឈរ យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ សាន់ ចណ្ណា
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព “រក្សាសិទ្ធ” របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ចៅ ឃុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org